ពាក្យសម្តី

ការប្រកបរបស់យើង

# ជាមួយនឹងព្រះបន្ទូល និងព្រះអម្ចាស់

11/12
2024



មជ្ឈមណ្ឌល
CDLD

មជ្ឈមណ្ឌលអភិវឌ្ឍន៍សិស្ស និង អ្នកដឹកនាំ (CDLD)
Center for Discipleship & Leadership Development

# ជាមួយនឹងព្រះបន្ទូល និងព្រះអម្ចាស់

ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំ
ហើយជាពន្លឺបំភ្លឺផ្លូវទូលបង្គំផង
ទំនុកដំកើង ១១៩ :១០៥

ជូនចំពោះ:__________

អារម្ភកថារបស់អ្នកនិពន្ធ លោកគ្រូគង្វាល គីម មង្គល

# ចូររស់នៅជាមួយគ្រួសារ សហគមន៍និងក្រុមជំនុំ



ភាពពិតនៃ Q.T

- **ហេតុអ្វីបានជាយើងត្រូវធ្វើ** Q.T ?

កុំឱ្យគម្ពីរក្រិត្យវិន័យនេះភ្លេចបាត់ពីមាត់ឯងឡើយ គឺត្រូវអោយនឹកសញ្ជឹងទាំងយប់ទាំងថ្ងៃ ដើម្បីអោយបានកាន់ហើយប្រព្រឹត្តតាមអស់ទាំងសេចក្តីដែលកត់ទុកនៅក្នុងគម្ពីរនេះឯងដ្បិតគឺយ៉ាងនោះដែលឯងនិងបានកើតការនៅគ្រប់ទាំងផ្លូវឯងហើយនិងបានចម្រើនឡើងផង ( យ៉ូស្វេ1:8 )មានពរហើយអស់អ្នកដែលរំពឹងគិតទាំងយប់ទាំងថ្ងៃ ( ទំនុកដំកើង1:2 )Q.Tមិនត្រឹមតែចូលរួមការថ្វាយបង្គំនិងបម្រើព្រះវិហារទេ។តែមានន័យថាការរស់នៅជាមួយព្រះ។ឥឡូវនេះខ្ញុំកំពុងតែរស់នៅលើផែនដី ប៉ុន្តែព្រលឹងវិញ្ញាណរបស់ខ្ញុំកំពុងតែសញ្ជឹងគិតអំពីព្រះបន្ទូលរបស់ព្រះ ដោយអរព្រះគុណ ។ វិធីដ៏ល្អបំផុតសម្រាប់ខ្ញុំដើម្បីរស់នៅតាមបំណងព្រះហឫទ័យរបស់ព្រះក្នុងលោកិយ៍គឺក្នុងការសញ្ជឹងគិតលើបទគម្ពីរដើម្បីបង្កើតការយល់ដឹងឲ្យបានច្រើនសម្រាប់សញ្ជឹងគិតព្រះបន្ទូលរបស់ព្រះ។ ពេលខ្លះខ្ញុំអានព្រះគម្ពីរប៉ុន្តែមិនយល់ ពីព្រះហឫទ័យនៃព្រះទេ ខ្ញុំបន្តការអធិស្ឋានទៅកាន់ព្រះទ្រង់ដើម្បីទទួលបាននូវព្រះវិញ្ញាណសម្រាប់ការសញ្ជឹងគិតនេះ។

- **តើអ្នកណាសញ្ជឹងគិតអំពីព្រះគម្ពីរ** ?

អស់អ្នកដែលព្រះទ្រង់តម្រូវទុកជាមុន ហើយទ្រង់ក៏ដំកើងឡើងឲ្យទទួលភាពពេញវ័យខាងឯវិញ្ញាណចូលរួមក្នុងការសញ្ជឹងគិតព្រះបន្ទូលដោយការស្តាប់បង្គាប់ និងធ្វើតាមបង្គាប់ព្រះបន្ទូលនៃព្រះ។ដើម្បីទទួលបានការគ្រប់គ្រងរបស់ព្រះ យើងត្រូវតែប្រាស្រ័យទាក់ទងជាមួយព្រះក្នុងព្រះបន្ទូលនិងការអធិស្ឋានជារៀងរាល់ថ្ងៃ។ ( ហេព្រើរ 3:13 )

និយមន័យនៃ Q.T អាចត្រូវបានដាក់បញ្ចូលគ្នាក្នុងវិធីផ្សេងគ្នា

1 ) គឺជាពេលវេលាដើម្បីជួបព្រះដោយផ្ទាល់។
2 ) គឺដល់ពេលដែលត្រូវទទួលស្គាល់និងសរសើរដំកើងព្រះ។
3 ) គឺជាពេលវេលាដើម្បីរកឃើញបំណងព្រះហឫទ័យរបស់ព្រះ។
4 ) ដើម្បីរស់នៅក្នុងជីវិតដែលធ្វើតាមព្រះហឫទ័យព្រះជារៀងរាល់ថ្ងៃ។
5 ) គឺជាពេលវេលាដើម្បីថ្វាយខ្លួនដល់ព្រះ។
6 ) ឥឡូវនេះជាពេលដែលត្រូវបញ្ជាក់អំពីភក្តីភាពនិងស្តាប់បង្គាប់។

ព្រះយេស៊ូវ ជាគំរូសម្រាប់ខ្ញុំក្នុងការស្តាប់បង្គាប់ព្រះបន្ទូលនៃព្រះ។( ម៉ាកុស 1:35, 45, 2:13, 3: 7, 6:46, 9: 2, 14:32 )នៅពេលដែលព្រះយេស៊ូវបានបម្រើនៅលើផែនដីទ្រង់បានស្រឡាញ់ព្រះហើយបានធ្វើការតាមបំណងព្រះហឫទ័យរបស់ព្រះ។ យើងក៏ត្រូវយល់បំណងរបស់ព្រះនៅលើផែនដីនេះដែរ។



# មាតិកា


00 អារម្ភកថារបស់អ្នកនិពន្ធ

02 ប្រតិទិន ខែ 11 - 12

04 ការសិក្សា និងប្រវត្តិសាស្ត្រព្រះគម្ពីរ ១យ៉ូហាន

05 ការសិក្សា និងប្រវត្តិសាស្ត្រព្រះគម្ពីរ ១ពង្សាវតារក្សត្រ

06 ការសិក្សា និងប្រវត្តិសាស្ត្រព្រះគម្ពីរ ២ពង្សាវតារក្សត្រ

07 ការសិក្សា និងប្រវត្តិសាស្ត្រព្រះគម្ពីរ ទំនុកដំកើង

08 របៀបធ្វើការសៀមស្ងាត់

10 អត្ថបទការសៀមស្ងាត់ខែ វិច្ឆិកា

70 អត្ថបទការសៀមស្ងាត់ខែ ធ្នូ

*ការអធិប្បាយថ្ងៃអាទិត្យ* 14 , 28 , 42 , 56 , 70 , 84 , 98 , 112 , 126

132 *ការសៀមស្ងាត់តាមបន្ទប់ប្រជុំ ខែ វិច្ឆិកា*

សប្តាហ៍ទី១ ជំនឿដែលរីកឡើងក្នុងគ្រាលំបាក( ពង្សាវតារក្សត្រទី១ ១៥:១-២៤ )

សប្តាហ៍ទី២ ព្រះកំពុងចិញ្ចឹមអេលីយ៉ា( ពង្សាវតារក្សត្រទី១ ១៧:១-៧ )

សប្តាហ៍ទី៣ ពួកគេបានមកដល់ភ្នំហោរេបជាភ្នំរបស់ព្រះ( ពង្សាវតារក្សត្រទី១ ១៩:១-៨ )

សប្តាហ៍ទី៤ កេរដំណែលដូនតា( ពង្សាវតារក្សត្រទី១ ២១:១-១៦ )

136 *ការសៀមស្ងាត់តាមបន្ទប់ប្រជុំ ខែ ធ្នូ*

សប្តាហ៍ទី១ ការបំពេញនិងការថែទាំ( ពង្សាវតារក្សត្រទី២ ៤:១-៧ )

សប្តាហ៍ទី២ ពូថៅអណ្តែតលើទឹក( ពង្សាវតារក្សត្រទី២ ៦:១-៧ )

សប្តាហ៍ទី៣ ដូចព្រះអម្ចាស់មានបន្ទូល( ពង្សាវតារក្សត្រទី២ ៧:១១-២០ )

សប្តាហ៍ទី៤ រសជាតិនៃបន្ទូលរបស់ព្រះជាម្ចាស់( ទំនុកដំកើង ១១៩:៩៧-១០៤ )

*ការថ្វាយបង្គំគ្រួសារ* 140 , 141 , 142 , 143 , 144 , 145 , 146 , 147

148 ការចំណាំ

151 រឿងដោយរូបភាព

152 សៀវភៅដែលCDLDបានបោះពុម្ពហើយ

153 សកម្មភាពសិក្ខាសាលាQT

154 ទីបន្ទាល់ អ៊ុច យីម

155 ទីបន្ទាល់ ហោ សុនឿន

156 ការបណ្តុះបណ្តាលសិស្សម្នាក់ទៅម្នាក់

158 សាលានិម្មិតឡូហ្គោសអន្តរជាតិ

161 គណៈកម្មការបោះពុម្ព


**NOVEMBER / DECEMBER 2024**

# 11/12

ពីព្រោះឯព្រះបន្ទូលនៃព្រះរស់នៅ ហើយ ពូកែផងក៏មុតជាងដាវណាមានមុខ២ទាំង ធ្លុះចូលទៅទាល់តែកាត់ព្រលឹងនិង វិញ្ញាណហើយសន្លាក់និងខួរឆ្អឹងដាច់ពីគ្នា ទាំងពិចារណាអស់ទាំងគំនិតដែលចិត្ត គិតហើយដែលសំរេចដែរ

( ហេព្រើរ ៤: ១២ )

11 / November 2024

| Sun | Mon | Tue | Wed | Thu | Fri | Sat |
|---|---|---|---|---|---|---|
| | | | | | 1 | 2 |
| 3 | 4 | 5 | 6 | 7 | 8 | 9 |
| 10 | 11 | 12 | 13 | 14 | 15 | 16 |
| 17 | 18 | 19 | 20 | 21 | 22 | 23 |
| 24 | 25 | 26 | 27 | 28 | 29 | 30 |

# 11

## វិច្ឆិកា / 2024

ជញ្ជីងមិនត្រឹមត្រូវ ជាទីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា តែកូនជញ្ជីងគ្រប់ទំងន់ ជាទីគាប់ដល់ព្រះហឫទ័យទ្រង់វិញ ( សុភាសិត ១១ : ១ )

| SUN | MON | TUE | WED | THU | FRI | SAT |
|---|---|---|---|---|---|---|
| | | | | | 1 | 2 |
| 3 | 4 | 5 | 6 | 7 | 8 | 9 |
| 10 | 11 | 12 | 13 | 14 | 15 | 16 |
| 17 | 18 | 19 | 20 | 21 | 22 | 23 |
| 24 | 25 | 26 | 27 | 28 | 29 | 30 |

# 12

## ធ្នូ / 2024

12 / December 2024

| Sun | Mon | Tue | Wed | Thu | Fri | Sat |
|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 |
| 8 | 9 | 10 | 11 | 12 | 13 | 14 |
| 15 | 16 | 17 | 18 | 19 | 20 | 21 |
| 21 | 22 | 23 | 24 | 25 | 26 | 27 |
| 28 | 29 | 30 | 31 | | | |



គ្រប់ទាំងព្រះបន្ទូលនៃព្រះ សុទ្ធតែបរិសុទ្ធ ទ្រង់ជាខែល ដល់អស់អ្នកដែលពឹងជ្រកក្នុងទ្រង់ ( សុភាសិត៣០ : ៥ )

| SUN | MON | TUE | WED | THU | FRI | SAT |
|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 |
| 8 | 9 | 10 | 11 | 12 | 13 | 14 |
| 15 | 16 | 17 | 18 | 19 | 20 | 21 |
| 22 | 23 | 24 | 25 | 26 | 27 | 28 |
| 29 | 30 | 31 | | | | |

# មគ្គុទេសមុនសៀមស្វាត់ព្រះគម្ពីរ ១យ៉ូហាន

## ❖ អ្នកនិពន្ធ & កាលបរិច្ឆេទ

អ្នកនិពន្ធគឺលោកយ៉ូហាន ដែលត្រូវជាកូនលោកសេបេដេជាសាវ័ក និងជាអ្នកនិពន្ធនៃព្រះគម្ពីរដំណឹងល្អយ៉ូហាន និង ព្រះគម្ពីរវិវរណៈ។ គាត់គឺជាអ្នកនេសាទម្នាក់ក្នុងចំណោមអ្នកនេសាទទាំងឡាយដែលព្រះយេស៊ូវទ្រង់បានត្រាស់ហៅធ្វើជាសាវ័ក ហើយគាត់ជាសិស្សម្នាក់ដែលព្រះយេស៊ូវស្រឡាញ់។ គាត់ប្រហែលត្រូវជាបងប្អូនជីដូនមួយរបស់ព្រះយេស៊ូវ ម្ដាយរបស់គាត់ប្រហែលជានាងសាឡូមេ ដែលអាចជាបងប្អូនស្រីរបស់នាងម៉ារា។ មានការលំបាកក្នុងការកំណត់កាលបរិច្ឆេទនៃសំបុត្រនេះអោយបានជាក់លាក់ ប៉ុន្តែមានការកំណត់យកចុងសតវត្សទី១ គឺនៅចន្លោះឆ្នាំ៨៥-៩៥នៃគ.ស។ ដែលនៅក្រោយកាលបរិច្ឆេទនៃការនិពន្ធដំណឹងល្អទី៤គឺជាការសមហេតុផល។

## ❖ អ្នកទទួល និងគោលបំណង

លោកយ៉ូហានបានសរសេរសំបុត្រនេះផ្ញើរដល់អ្នកជឿ។ ប៉ុន្តែសំបុត្រនេះមិនបានបង្ហាញថា អ្នកអានជានរណា និងនៅកន្លែងណាទេ។ ការដែលសំបុត្រនេះមិនបាននិយាយអំពីឈ្មោះអ្នកទទួលក៏បានបង្ហាញផងដែរថា សំបុត្រនេះគឺជាសំបុត្រសម្រាប់ផ្ញើរដល់ពួកជំនុំនៅកន្លែងផ្សេងៗមួយចំនួន។
អ្នកអានសំបុត្ររបស់លោកយ៉ូហានបានជួបប្រទះនឹងគ្រោះថ្នាក់ដែលបង្កឡើងដោយពួកគ្រូបង្រៀនខុសឆ្គង ដែលនាំអោយមានការប្រព្រឹត្តខុសនឹងបំណងព្រះហឫទ័យព្រះ។ លោកយ៉ូហានបានសរសេរសំបុត្រនេះដោយមានគោលបំណង២យ៉ាង ១ដើម្បីប្រាប់អោយពួកជំនុំដឹងអំពីពួកគ្រូបង្រៀនខុសឆ្គង ២ដើម្បីអោយពួកអ្នកជឿដឹងច្បាស់អំពីសេចក្ដីសង្គ្រោះ។

## ❖ គម្រោងអត្ថបទ ៖

I. សេចក្ដីផ្ដើម: សេចក្ដីពិតនៃការយាងមកយកកំណើតនៃព្រះគ្រីស្ទ (១:១-៤)
II. ការរស់នៅរបស់គ្រីស្ទបរិស័ទដោយមានការប្រកបជាមួយនឹងព្រះវរបិតា និងព្រះរាជបុត្រា (១:៥-២:២៨)
III. ការរស់នៅរបស់គ្រីស្ទបរិស័ទដូចជាកូនព្រះ (២:២៩-៤:៦)
IV. ការរស់នៅរបស់គ្រីស្ទបរិស័ទដោយស្រឡាញ់គ្នាទៅវិញទៅមក (៤:៧-៥:១២)
V. សេចក្ដីបញ្ចប់: ការដឹងជាក់ច្បាស់របស់គ្រីស្ទបរិស័ទ (៥:១៣-២១)

# មគ្គុទេសមុនសៀមស្វាត់ព្រះគម្ពីរ ១ពង្សាវតារក្សត្រ

## ❖ អ្នកនិពន្ធ & កាលបរិច្ឆេទ

កណ្ឌគម្ពីរពង្សាវតារក្សត្រទី១ មានភស្តុតាងតិចតួចណាស់ក្នុងការបញ្ជាក់ពីអ្នកនិពន្ធ។ ទោះបីប្រពៃណីវប្បធម៌ពួកយូដាទទួលស្គាល់លោកយេរេមាក៏ដោយ តែបច្ចុប្បន្ននេះមានតិចតួចណាស់ដែលទទួលស្គាល់ថា នរណាជាអ្នកនិពន្ធនោះ កណ្ឌគម្ពីរនេះត្រូវគ្នានិងកណ្ឌគម្ពីរចោទិយកថា ដែលមានហោរាអ៊ីស្រាអែលជាច្រើន។ កណ្ឌគម្ពីរនេះ បានបញ្ជាក់យ៉ាងច្បាស់ថា អ្នកនិពន្ធបានប្រើប្រភពជាច្រើនក្នុងការចងក្រងជាបញ្ជីពង្សាវតារក្សត្រនេះឡើង។ មានពួកអ្នកប្រាជ្ញ បានដាក់កាលបរិច្ឆេទនៃការនិពន្ធកណ្ឌគម្ពីរពង្សាវតារក្សត្រទី១ នៅក្នុងអំឡុងពេលដែលគេបានដោះលែងស្តេចយេហូយ៉ាគីមពីគុក(ឆ្នាំ៥៦២មុនគ.ស) នឹងមុនពេលបញ្ចប់ការនិរទេសពួកបាប៊ីឡូន ឆ្នាំ ៥៣៨មុនគ.ស។ តាមរយៈការអះអាងខាងលើនេះបញ្ជាក់ថាអ្នកនិពន្ធត្រូវតែជាមនុស្សដែលបានរស់នៅក្នុងទឹកដីយូដា នៅអំឡុងពេលមុនការនិរទេសខ្លួន គឺមិនមែនក្រោយពេលការនិរទេសខ្លួនរបស់ពួកបាប៊ីឡូននោះទេ។

## ❖ គម្រោងអត្ថបទ ៖

I. រជ្ជកាលក្នុងរាជ្យស្តេចសាឡូម៉ូន (ជំពូក ១:១-១២:២៤)
II. ពួកអ៊ីស្រាអែល និងពួកយូដា តាមរយៈស្តេចយេរ៉ូបោម១ និងរេហូបោមទៅដល់អ័ហាប់ និងអេសា (ជំពូក ១២:២៥-១៦:៣៤)
III. បេសកកម្មរបស់លោកហោរាអេលីសេ និងហោរាផ្សេងទៀតតាមរយៈស្តេចអ័ហាប់ ស្តេចអេសា រហូតដល់ស្តេចអ័ហាស៊ីយ៉ា និងស្តេចយេហូសាផាត (ជំពូក ១៧-២២)
IV. បេសកកម្មរបស់លោកហោរាអេលីយ៉ា និងហោរាអេលីសេនៅក្នុងរជ្ជកាលស្តេចអ័ហាស៊ីយ៉ា និងយ៉ូរ៉ាម (២ពវ ១:១-៨:១៥)
V. ពួកយូដា និងអ៊ីស្រាអែល ត្រូវនិរទេសខ្លួនដោយយ៉ូរ៉ាម (ជំពូក ៨:១៦-១៧:៤១)
VI. ពួកយូដាចាកចេញពីស្តេចហេសេគា ដោយសារការនិរទេសខ្លួនរបស់ពួកបាប៊ីឡូន (ជំពូក ១៨:២៥)

# មគ្គុទេសមុនសៀមស្វាត់ព្រះគម្ពីរ ២ពង្សាវតារក្សត្រ

## ❖ អ្នកនិពន្ធ & កាលបរិច្ឆេទ

កណ្ឌគម្ពីរពង្សាវតារក្សត្រទី២ មានភស្តុតាងតិចតួចណាស់ក្នុងការបញ្ជាក់ពីអ្នកនិពន្ធ។ ទោះបីប្រពៃណីវប្បធម៌ពួកយូដាទទួលស្គាល់លោកយេរេមាក៏ដោយ តែបច្ចុប្បន្ននេះមានតិចតួចណាស់ដែលទទួលស្គាល់ថា នរណាជាអ្នកនិពន្ធនោះ កណ្ឌគម្ពីរនេះត្រូវគ្នានិងកណ្ឌគម្ពីរចោទិយកថា ដែលមានហោរាអ៊ីស្រាអែលជាច្រើន។ កណ្ឌគម្ពីរនេះ បានបញ្ជាក់យ៉ាងច្បាស់ថា អ្នកនិពន្ធបានប្រើប្រភពជាច្រើនក្នុងការចងក្រងជាបញ្ជីពង្សាវតារក្សត្រនេះឡើង។ មានពួកអ្នកប្រាជ្ញ បានដាក់កាលបរិច្ឆេទនៃការនិពន្ធកណ្ឌគម្ពីរពង្សាវតារក្សត្រទី២ នៅក្នុងអំឡុងពេលដែលគេបានដោះលែងស្តេចយេហូយ៉ាគីមពីគុក(ឆ្នាំ៥៦២មុនគ.ស) នឹងមុនពេលបញ្ចប់ការនិរទេសពួកបាប៊ីឡូន ឆ្នាំ៥៣៨មុនគ.ស។ តាមរយៈការអះអាងខាងលើនេះបញ្ជាក់ថាអ្នកនិពន្ធត្រូវតែជាមនុស្សដែលបានរស់នៅក្នុងទឹកដីយូដា នៅអំឡុងពេលមុនការនិរទេសខ្លួន គឺមិនមែនក្រោយពេលការនិរទេសខ្លួនរបស់ពួកបាប៊ីឡូននោះទេ។

## ❖ គម្រោងអត្ថបទ ៖

VII. បេសកកម្មរបស់លោកហោរាអេលីយ៉ា និងហោរាអេលីសេនៅក្នុងរជ្ជកាលស្តេចអ័ហាស៊ីយ៉ា និងយ៉ូរ៉ាម (២ពវ ១:១-៨:១៥)

VIII. ពួកយូដាចាកចេញពីស្តេចហោសេគា ដោយសារការនិរទេសខ្លួនរបស់ពួកបាប៊ីឡូន (ជំពូក ១៨:២៥)

# មគ្គុទេសមុនសៀមស្វាត់ព្រះគម្ពីរ ទំនុកដំកើង

## ❖ អ្នកនិពន្ធ

ទំនាក់ទំនងនឹងកិច្ចការរបស់អ្នកនិពន្ធ ក៏មានយោបល់ផ្សេងៗពីគ្នាដែរ។ តាមការកត់ចំណាំរបស់អ្នកនិពន្ធ គឺមានភាពមិនច្បាស់លាស់ខ្លះ ខណៈពេលអ្នកនិពន្ធបានប្រើពីរបៀបសរសេរឃ្លាឃ្លោងជាភាសាហេព្រើ ដូចជាការប្រើពាក្យមានលក្ខណៈទូទៅពេកដូចពាក្យ «កម្មសិទ្ធិ» ក៏អាចមានន័យថា «ទាក់ទងនឹង» ឬក៏ «សម្រាប់ប្រើ» ឬក៏មានន័យថា «ថ្វាយចំពោះ»។

## ❖ កាលបរិច្ឆេទ

អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងបានប្រមែប្រមូលនៅការចងក្រងជាច្រើនមកទុកជាតំណាង និងជាឯកសារតម្កល់ទុក ដែលជានិច្ចកាលចុងក្រោយវាជាភាពនាំឲ្យមានវិសាលគមន៍ ជាចំណែកដែលបន្សល់ទុកជាច្រើនសតវត្សតៗមក។ ព្រះគម្ពីរទំនុកដំកើងនេះ ក៏ត្រូវបានគេរៀបចំឲ្យមានជាបែបបទត្រឹមត្រូវចុងក្រោយ ទៅតាមសម័យកាល គឺចាប់តាំងពីប្រវត្តិសាស្រ្តសម័យសាសន៍យូដា រហូតដល់សម័យកាលនិរទេស ក្នុងសម័យបាប៊ីឡូនក៏មានព្រះវិហារដែរ ហើយកិច្ចការទាំងនោះ បានចប់សព្វគ្រប់ក្នុងសតវត្សទី៣ មុនគ.ស ។


07

# ជាមួយនឹងព្រះអម្ចាស់និងព្រះបន្ទូល សូមស្វែងយល់ដោយរបៀបនេះ!

## 1 ការរៀបចំអធិដ្ឋាន

បន្ទាប់ពីអ្នករៀបចំពេលវេលាស្ងៀមស្ងាត់រួចមុននឹងអ្នកអានអត្ថបទចូរត្រៀមខ្លួនជាមុនសិន។ យើងអធិស្ឋានសុំឱ្យព្រះវិញ្ញាណបរិសុទ្ធបើកចិត្តនិងភ្នែករបស់យើង ហើយស្តាប់ព្រះបន្ទូលដែលបានប្រទានដល់យើងក្នុងថ្ងៃនេះ។

## 2 អានអត្ថបទ

អានអត្ថបទជាមុនសិន អានអោយខ្លាំងៗ ដោយប្រើការសញ្ជឹងគិតលើសំណួរ ថា តើព្រះកំពុងមានបន្ទូលអ្វី ?ហេតុអ្វី? តើអ្វីទៅ? នៅកន្លែងណាដែលទ្រង់មានបន្ទូល? សូមសញ្ជឹងគិតពីសំណួរទាំងនេះ ដោយអនុញ្ញាតិអោយព្រះវត្តមានព្រះដឹកនាំ រង់ចាំការឆ្លើយតបរបស់ព្រះមកកាន់អ្នក ឬ ប្រាប់អ្នកពីអ្វីដែលទ្រង់ចង់អោយអ្នកធ្វើនៅក្នុងថ្ងៃនេះ។

## 3 ព្រះបន្ទូលដែលប្រទាននៅថ្ងៃនេះ

គឺមានន័យថាព្រះបានបង្ហាញដល់យើងក្នុងការសញ្ជឹងគិតនិងអានការសួរនិងការស្វែងរកចម្លើយ។ ព្រះបន្ទូលនៃព្រះគឺជាពន្លឺនៃជីវិតរបស់ខ្ញុំហើយដឹកនាំខ្ញុំ។ សូមកត់ត្រាទុកនូវអ្វីដែលទ្រង់បានប្រទានដល់អ្នកនៅថ្ងៃនេះ។

## 4 ការអនុវត្តក្នុងការរស់នៅ

ការប្រែចិត្តចេញពីអំពើបាបគឺជាផ្លូវដែលល្អសម្រាប់អ្នក ការលួងលោមនិងការលើកទឹកចិត្តរបស់ព្រះត្រូវបានសរសេរឡើង។សូមកត់ត្រានូវអ្វីដែលអ្នករៀនបានដើម្បីអនុវត្តន៍ក្នុងការរស់នៅ។

## 5 ចូរអធិដ្ឋានទូលអង្វរ

គឺជាការស្រាវជ្រាវដើម្បីស្វែងយល់ប្រធានបទក្នុងព្រះបន្ទូល ។សូមអានសៀវភៅនេះយ៉ាងហ្មត់ចត់ជាមុនសិនបន្ទាប់មកចូរសញ្ជឹងគិត តាមគំនិតដែលបានស្រាវជ្រាវហើយ។

## 6 ជំនួយ

ស្គាល់ពាក្យពិបាកឬមាតិកាក្នុងអត្ថបទអាចជួយអ្នកឱ្យយល់អត្ថបទបានយ៉ាងងាយស្រួល។

## 7 ការយល់ដឹងពីអត្ថបទ

ជារៀងរាល់ថ្ងៃអ្នកចែកចាយព្រះបន្ទូល និងជួយអ្នកនៅក្នុងការអធិស្ឋាន យើងនឹងដឹកនាំអ្នកឱ្យអធិស្ឋាន។

## 8 មេរៀនថ្ងៃអាទិត្យសញ្ជឹងគិតនិងចំណាំ

នៅថ្ងៃអាទិត្យសូមកត់ត្រានូវព្រះបន្ទូលដែលអ្នកបានស្តាប់លឺនៅថ្ងៃនោះតាមរយៈសេចក្តីអធិប្បាយក្នុងអត្ថបទខ្លីនិងអនុវត្តការនោះនៅក្នុងជីវិតរបស់អ្នក។



**2024**

# 11/12

**១យ៉ូហាន ៥**
**១ពង្សាវតារក្សត្រ ១៥ - ២២**
**២ពង្សាវតារក្សត្រ ១ - ៧**
**ទំនុកដំកើង ១១៩**

*បើអ្នករាល់គ្នានៅជាប់នឹងខ្ញុំ ហើយពាក្យខ្ញុំនៅជាប់ក្នុង*
*អ្នករាល់គ្នា នោះចូរសូមអ្វីតាមតែប្រាថ្នាចុះ សេចក្ដីនោះ*
*នឹងបានសម្រេចដល់អ្នករាល់គ្នាជាមិនខាន*
*យ៉ូហាន 15 : 7*

ខែ11
ថ្ងៃសុក្រ 01

# ជំនឿលើព្រះយេស៊ូវជាប្រភពនៃសេចក្ដីស្រឡាញ់

១យ៉ូហាន 5:1-12

ការអធិស្ឋាន

អានអត្ថបទ

១ អស់អ្នកណាដែលជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ អ្នកនោះបានកើតពីព្រះមក ហើយអស់
ទាំងអ្នកណាដែលស្រឡាញ់ព្រះដ៏បង្កើតខ្លួនមក នោះក៏រមែងស្រឡាញ់ដល់អស់អ្នកឯទៀត
ដែលកើតពីទ្រង់មកដែរ ២ កាលណាយើងស្រឡាញ់ដល់ព្រះ ហើយកាន់តាមអស់ទាំងបញ្ញត្ត
របស់ទ្រង់ នោះយើងដឹងថា យើងស្រឡាញ់ដល់ពួកកូនរបស់ព្រះដែរ ៣ ដ្បិតនេះហើយជាសេចក្តី
ស្រឡាញ់ដល់ព្រះ គឺឲ្យយើងកាន់តាមអស់ទាំងបញ្ញត្តរបស់ទ្រង់ ឯបញ្ញត្តទ្រង់ នោះមិនមែនជា
បន្ទុកដ៏ធ្ងន់ទេ ៤ ពីព្រោះគ្រប់ទាំងអស់ដែលកើតពីព្រះមក នោះបានឈ្នះលោកីយ៍ហើយ ឯជ័យជំ
នះដែលឈ្នះលោកីយ៍ នោះគឺជាសេចក្តីជំនឿរបស់យើង ៥ តើអ្នកណាជាអ្នកឈ្នះលោកីយ៍ បើ
មិនមែនជាអ្នកដែលជឿថា ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ។
៦ គឺព្រះយេស៊ូវគ្រីស្ទនេះហើយ ដែលយាងមកដោយទឹក ហើយនិងឈាម មិនមែនដោយទឹកតែ
ប៉ុណ្ណោះ គឺទាំងទឹកទាំងឈាមផង គឺជាព្រះវិញ្ញាណដែលធ្វើបន្ទាល់ ដ្បិតព្រះវិញ្ញាណទ្រង់ជាសេ
ចក្តីពិត ៧ មានសាក្សី៣អង្គដែលធ្វើបន្ទាល់នៅស្ថានសួគ៌ គឺជាព្រះវរបិតា១ ព្រះបន្ទូល១ និងព្រះ
វិញ្ញាណបរិសុទ្ធ១ តែទាំង៣អង្គនេះរួមមកតែ១ទេ ៨ ហើយមាន៣មុខទៀត ដែលធ្វើបន្ទាល់នៅ
ផែនដីដែរ គឺជាព្រះវិញ្ញាណ១ ទឹក១ និងឈាម១ ទាំង៣នេះក៏ត្រូវគ្នាដែរ ៩ បើសិនជាយើងបាន
ទទួលសេចក្តីបន្ទាល់របស់មនុស្សទៅហើយ នោះសេចក្តីបន្ទាល់របស់ព្រះ ក៏ប្រសើរជាងទៅ
ទៀត ដ្បិតសេចក្តីបន្ទាល់របស់ព្រះ គឺជាសេចក្តីដែលទ្រង់ថ្លែងប្រាប់ ពីព្រះរាជបុត្រានៃ
ទ្រង់ ១០ អ្នកណាដែលជឿដល់ព្រះរាជបុត្រានៃព្រះ នោះមានសេចក្តីបន្ទាល់ នៅក្នុងខ្លួនហើយ តែ
អ្នកណាដែលមិនជឿសោះ នោះឈ្មោះថា បានធ្វើឲ្យទ្រង់ទៅជាអ្នកកុហកវិញ ពីព្រោះមិនបាន
ជឿដល់សេចក្តីបន្ទាល់ ដែលទ្រង់បានធ្វើពីដំណើរព្រះរាជបុត្រានៃទ្រង់ ១១ នេះហើយជាសេចក្តី
បន្ទាល់នោះ គឺថា ព្រះទ្រង់បានប្រទាន ជីវិតដ៏នៅអស់កល្បជានិច្ចមកយើងរាល់គ្នា ហើយជីវិត
នោះ គឺនៅក្នុងព្រះរាជបុត្រានៃទ្រង់ ១២ ឯអ្នកណាដែលមានព្រះរាជបុត្រា នោះក៏មានជីវិតដែរ តែ
អ្នកណាដែលគ្មានព្រះរាជបុត្រានៃព្រះទេ នោះគ្មានជីវិតឡើយ។

1 Everyone who believes that Jesus is the Christ is born of God, and everyone who loves the
father loves his child as well. 2 This is how we know that we love the children of God: by
loving God and carrying out his commands. 3 In fact, this is love for God: to keep his
commands. And his commands are not burdensome, 4 for everyone born of
God overcomes the world. This is the victory that has overcome the world, even our
faith. 5 Who is it that overcomes the world? Only the one who believes that Jesus is the
Son of God.
6 This is the one who came by water and blood Jesus Christ. He did not come by water only,
but by water and blood. And it is the Spirit who testifies, because the Spirit is the truth.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

### ការយល់ដឹងអំពីអត្ថបទ

***ជំនឿលើព្រះយេស៊ូវជាប្រភពនៃសេចក្ដីស្រឡាញ់***

លោកយ៉ូហានបានពោលជាថ្មីម្ដងទៀតថា មនុស្សយើងត្រូវតែជឿលើព្រះយេស៊ូវ ក្នុងនាមព្រះជារាជបុត្រានៃព្រះអម្ចាស់ ដើម្បីអោយបានសង្គ្រោះ ហើយសេចក្ដីស្រលាញ់ចំពោះព្រះត្រូវបានផ្សារភ្ជាប់និងសេចក្ដីស្រលាញ់ចំពោះរាស្ត្ររបស់ទ្រង់ដែរ។គេមិនធ្វើបែបនេះដោយសារតែច្បាប់បង្ខំនោះទេ តែធ្វើដោយមានចិត្តអំណរ និងស្ម័គ្រចិត្ត ព្រោះគេចង់ធ្វើអ្វីដែលនាំអោយព្រះជាម្ចាស់សព្វព្រះហឫទ័យ។ ពួកគេនឹងមានកម្លាំងក្នុងការស្ដាប់បង្គាប់ព្រះជាម្ចាស់ តាមរយៈជំនឿក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះ។ ព្រះយេស៊ូវបានយកជ័យជំនះលើអំពើទុច្ចរិតរបស់លោកិយ៍ ហេតុប្រជារាស្ត្ររបស់ព្រះអង្គទាំងអស់ដែលមានជំនឿដល់ទ្រង់ក៏មានជ័យជម្នះដូចគ្នាដែរ។ គ្រូបង្រៀនអំពីវិជ្ជានិយម មិនជឿថា អង្គដែលសុគតលើឈើឆ្កាង គឺជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះជាម្ចាស់នោះទេ។ ពួកគេអះអាងថា ព្រះគ្រីស្ទ(ព្រះជាម្ចាស់)បានមកសណ្ឋិតលើព្រះយេស៊ូវ(ជាមនុស្ស) ក្នុងសភាពជាសត្វព្រាប ក្រោយពេលព្រះយេស៊ូវទទួលពិធីជ្រមុជទឹក តែព្រះបានចាកចេញពីព្រះយេស៊ូវវិញមុនពេលទ្រង់សុគតលើឈើឆ្កាង។បើតាមសំដីរបស់ពួកគេ ព្រះយេស៊ូវទទួលរងទុក្ខ និងសុគត នោះគ្រាន់តែជាមនុស្សធម្មតាម្នាក់តែប៉ុណ្ណោះ ព្រះអង្គមិនមែនជាព្រះគ្រីស្ទទេ។

សេចក្ដីអធិស្ឋាន

# សក្ខីភាពអំពីព្រះយេស៊ូវគ្រីស្ទ និងអំពីជីវិតអស់កល្បជានិច្ច

១យ៉ូហាន 5:13-21

ការអធិស្ឋាន

អានអត្ថបទ

១៣ ខ្ញុំបានសរសេរសេចក្ដីទាំងនេះ ផ្ញើមកអ្នករាល់គ្នា ដែលជឿដល់ព្រះនាមព្រះរាជបុត្រានៃព្រះ
ដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ ១៤ យើងក៏មានសេច
ក្តីក្លាហាន ដល់ទ្រង់យ៉ាងដូច្នេះដែរ គឺថា បើយើងនឹងសូមអ្វី ដែលត្រូវតាមព្រះហឫទ័យទ្រង់ នោះ
ទ្រង់នឹងទទួលព្រម ១៥ បើយើងដឹងថា ទ្រង់ទទួលព្រមតាមយើង ក្នុងការអ្វីដែលយើងសូមដូច្នេះ
នោះយើងក៏ដឹងថា យើងបានអ្វីដែលយើងសូមពីទ្រង់ហើយដែរ។
១៦ បើអ្នកណាឃើញបងប្អូនកំពុងតែធ្វើបាប គឺជាបាបដែលមិនមានទោសដល់ស្លាប់ទេ នោះត្រូវ
សូមចុះ ទ្រង់នឹងប្រទានជីវិតមកដល់អស់អ្នកធ្វើបាប ដែលមិនមែនមានទោសដល់ស្លាប់នោះជា
ពិត តែមានបាបម្យ៉ាងដែលមានទោសដល់ស្លាប់វិញ ឯបាបនោះខ្ញុំមិនថា ឲ្យសូមអង្វរឲ្យ
ទេ ១៧ គ្រប់ទាំងអំពើទុច្ចរិត សុទ្ធតែជាបាបទាំងអស់ ហើយក៏មានបាបខ្លះ ដែលមិនមានទោស
ដល់ស្លាប់ដែរ ១៨ យើងដឹងថា អ្នកណាដែលកើតពីព្រះមក នោះមិនចេះធ្វើបាបទេ អ្នកនោះឯងជា
អ្នករក្សាខ្លួនវិញ ហើយមេកំណាចនឹងពាល់អ្នកនោះមិនបានឡើយ ១៩ យើងដឹងថា យើងមកពី
ព្រះពិត តែលោកីយ៍ទាំងមូលដេកនៅក្នុងឱវាទនៃមេកំណាចវិញ ២០ យើងក៏ដឹងថា ព្រះរាជបុត្រា
នៃព្រះបានយាងមកហើយ ក៏បានប្រទានឲ្យយើងរាល់គ្នាមានប្រាជ្ញា ដើម្បីឲ្យបានស្គាល់ព្រះដ៏
ពិតប្រាកដ យើងរាល់គ្នាជាអ្នកនៅក្នុងព្រះដ៏ពិតប្រាកដនោះ គឺក្នុងព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជ
បុត្រានៃទ្រង់ ព្រះអង្គនោះឯងជាព្រះពិតប្រាកដ ហើយជាជីវិតអស់កល្បជានិច្ចផង។
២១ កូនតូចៗ រាល់គ្នាអើយ ចូរឲ្យអ្នករាល់គ្នារក្សាខ្លួនឲ្យផុតពីរូបព្រះចេញ។ អាម៉ែន។:៚

13 I write these things to you who believe in the name of the Son of God so that you may
know that you have eternal life. 14 This is the confidence we have in approaching God: that
if we ask anything according to his will, he hears us. 15 And if we know that he hears us
whatever we ask we know that we have what we asked of him. 16 If you see any brother or
sister commit a sin that does not lead to death, you should pray and God will give them
life. I refer to those whose sin does not lead to death. There is a sin that leads to death. I am
not saying that you should pray about that. 17 All wrongdoing is sin, and there is sin that
does not lead to death. 18 We know that anyone born of God does not continue to sin; the
One who was born of God keeps them safe, and the evil one cannot harm them. 19 We know
that we are children of God, and that the whole world is under the control of the evil
one. 20 We know also that the Son of God has come and has given us understanding, so that
we may know him who is true. And we are in him who is true by being in his Son Jesus
Christ. He is the true God and eternal life. 21 Dear children, keep yourselves from idols.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

.................................................................................................

.................................................................................................

.................................................................................................

## ការយល់ដឹងអំពីអត្ថបទ

***សក្ខីភាពអំពីព្រះយេស៊ូវគ្រីស្ទ និងអំពីជីវិតអស់កល្បជានិច្ច***

យើងរាល់គ្នាដែលជាអ្នកជឿលើព្រះយេស៊ូវគ្រីស្ទបានដឹងច្បាស់ថា ព្រះជាម្ចាស់ទទួលយើង និងប្រទានជីវិតអស់កល្បជានិច្ចអោយយើងរាល់គ្នា នោះគេនឹងចូលមករកព្រះអង្គដោយមានការជឿជាក់ ព្រមទាំងនាំសំណូមពររបស់គេទូលដល់ព្រះអង្គផង។ លោកយ៉ូហានបានលើកទឹកចិត្តដល់យើងរាល់គ្នាក៏ដូចជាដល់ពួកគេនៅសម័យនោះដែរ ហើយលោកបានអោយយើងចេះអធិស្ឋានអោយគ្នាទៅវិញទៅមក។ក្នុងនាមយើងជាគ្រីស្ទបរិស័ទត្រូវតែហ្វឹកហ្វឺនខ្លួនអោយចេះបែងចែករវាងករណីទាំងអស់នោះ ថាតើករណីណាគេគួរអធិស្ឋាន ហើយករណីណាដែលមិនត្រូវអធិស្ឋាន។អំពើបាបមិនមែនជាលក្ខណៈរបស់ពួកអ្នកជឿលើព្រះគ្រីស្ទទេ ពីព្រោះព្រះគ្រីស្ទបានការពារពួកគេមិនអោយធ្លាក់ទៅក្រោមអំណាចរបស់ពួកអារក្សសាតាំង។ ដោយសារតែគេជារាស្ត្ររបស់ព្រះជាម្ចាស់គេត្រូវតែមានជីវិតខុសប្លែកពីមនុស្សដែលស្ថិតក្រោមអំណាចរបស់លោកិយ៍ជាទូទៅ។ លោកយ៉ូហានបាននិយាយម្តងទៀតថា ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះជាម្ចាស់ ដែលបានសុគតសម្រាប់មនុស្សមានបាប គឺជាព្រះពិត ហើយព្រះនឹងប្រទានជីវិតអស់កល្បជានិច្ចសម្រាប់មនុស្សមានបាប។

សេចក្តីអធិស្ឋាន

ខែ11
ថ្ងៃអាទិត្យ 03

# ការអធិប្បាយថ្ងៃអាទិត្យ

- ចំណងជើង :
- អត្ថបទ :
- អ្នកអធិប្បាយ :



ពាក្យសម្ដី

ការប្រកបរបស់យើងជាមួយនិងព្រះ

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ



ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

## សេចក្ដីអធិស្ឋាន

ខែ11 ថ្ងៃច័ន្ទ 04

# ស្ដេចអ័ប៊ីយ៉ាសោយរាជ្យនៅស្រុកយូដា

## ១ពង្សាវតារក្សត្រ 15:1-24

ការអធិស្ឋាន

អានអត្ថបទ

១ លុះដល់ឆ្នាំទី១៨ ក្នុងរាជ្យយេរ៉ូបោម ជាបុត្រនេបាត នោះអ័ប៊ីយ៉ាក៏ចាប់តាំងសោយរាជ្យឡើងនៅស្រុកយូដា ២ ទ្រង់
គ្រងរាជ្យបាន៣ឆ្នាំនៅក្រុងយេរូសាឡិម ឯមាតា ព្រះនាមជាម្អាកា បុត្រីអ័ប៊ីសាឡុម ៣ ទ្រង់ក៏ប្រព្រឹត្តតាមអស់ទាំងអំពើ
បាប ដែលព្រះបិតាបានប្រព្រឹត្តពីមុនមកដែរ ព្រះទ័យទ្រង់មិនបានស្មោះត្រង់ ដល់ព្រះយេហូវ៉ា ជាព្រះនៃទ្រង់ ដូចជាព្រះ
ទ័យដាវីឌ ជាឰយុកោទ្រង់ទេ ៤ ប៉ុន្តែ ដោយព្រោះយល់ដល់ដាវីឌ បានជាព្រះយេហូវ៉ា ជាព្រះនៃទ្រង់ បានប្រទានឲ្យមាន
ចង្កៀង១ភ្លឺ នៅក្រុងយេរូសាឡិម គឺបានតាំងព្រះរាជបុត្រាទ្រង់ឲ្យសោយរាជ្យឡើងជំនួសបិតា ដើម្បីនឹងប្រោសឲ្យក្រុង
យេរូសាឡិមនៅជាប់តទៅ ៥ ពីព្រោះដាវីឌបានប្រព្រឹត្តសេចក្ដីដែលទៀងត្រង់នៅព្រះនេត្រព្រះយេហូវ៉ា ដោយឥតបែរ
ចេញ ពីសេចក្ដីបង្គាប់ណាមួយរបស់ទ្រង់ ដរាបអស់ព្រះជន្ម លើកតែក្នុងរឿងពីអ៊ូរី ជាសាសន៍ហេតប៉ុណ្ណោះ ៦ ឯរេហូបោ
ម និងយេរ៉ូបោម ទ្រង់ចេះតែច្បាំងគ្នាដរាបដល់អស់ព្រះជន្ម។៧ រីឯដំណើរឯទៀតពីអ័ប៊ីយ៉ា និងការទាំងប៉ុន្មានដែលទ្រង់ធ្វើ
នោះសុទ្ធតែកត់ទុកក្នុងសៀវភៅ ជាពង្សាវតារនៃពួកស្ដេចយូដាហើយ អ័ប៊ីយ៉ា និងយេរ៉ូបោម ក៏តែងតែច្បាំងគ្នា ៨ អ័ប៊ីយ៉ា
ទ្រង់ផុំលក់ទៅជាមួយនឹងពួកឰយុកោទ្រង់ទៅ គេបញ្ចុះទ្រង់នៅក្នុងទីក្រុងរបស់ដាវីឌ រួចអេសាជាព្រះរាជបុត្រា ក៏សោយ
រាជ្យឡើងជំនួសបិតា។៩ លុះដល់ឆ្នាំទី២០ ក្នុងរាជ្យយេរ៉ូបោម ជាស្ដេចពួកអ៊ីស្រាអែល នោះអេសាចាប់តាំងសោយរាជ្យ
ឡើង នៅស្រុកយូដា ១០ ទ្រង់សោយរាជ្យនៅក្រុងយេរូសាឡិមបាន៤១ឆ្នាំ ឯមាតា ទ្រង់ ព្រះនាមជាម្អាកា បុត្រីអ័ប៊ីសាឡុ
ម ១១ អេសានេះទ្រង់បានប្រព្រឹត្តទៀងត្រង់ នៅព្រះនេត្រព្រះយេហូវ៉ា ដូចជាដាវីឌ ជាឰយុកោទ្រង់ដែរ ១២ ទ្រង់កំចាត់ពួក
កូនជឹងពីនគរចេញ ក៏បំបាត់អស់ទាំងរូបព្រះ ដែលវង្សានុវង្សទ្រង់បានធ្វើបង់។ ១៣ ទ្រង់ដកម្អាកា ជាមាតា ពីដំណែងជា
មាតាហ្លួង ដោយព្រោះព្រះនាងបានធ្វើរូប១ ដែលគួរស្អប់ខ្ពើម ទុកសំរាប់ជាព្រះ ហើយអេសាក៏កាប់រូបនោះ យកទៅដុត
នៅត្រង់ជ្រោះកេដ្រុន ១៤ តែឯទីខ្ពស់ទាំងប៉ុន្មាន នោះមិនបានបំបាត់ចេញទេ ប៉ុន្តែទ្រង់មានព្រះទ័យស្មោះត្រង់ ដល់ព្រះ
យេហូវ៉ា រហូតដល់អស់ព្រះជន្ម ១៥ ហើយគ្រឿងប្រដាប់ទាំងប៉ុន្មាន ដែលព្រះបិតាបានថ្វាយ និងរបស់ដែលអង្គទ្រង់បាន
ថ្វាយ គឺជាប្រាក់ មាស និងគ្រឿងប្រដាប់ផ្សេងៗ នោះទ្រង់ក៏យកទៅដាក់ក្នុងព្រះវិហារនៃព្រះយេហូវ៉ា។
១៦ អេសានេះ និងបាសា ជាស្ដេចស្រុកអ៊ីស្រាអែល ទ្រង់ច្បាំងគ្នា រហូតដល់អស់ព្រះជន្ម ១៧ ឯបាសា ជាស្ដេចស្រុកអ៊ីស្រា
អែល ទ្រង់ឡើងទៅទាស់នឹងពួកយូដា ក៏សង់ក្រុងរ៉ាម៉ាឡើង ដើម្បីកុំឲ្យមានអ្នកណាចេញចូលទៅខាងអេសា ជាស្ដេច
ស្រុកយូដាបានឡើយ ១៨ ដូច្នេះ អេសាទ្រង់យកអស់ទាំងប្រាក់មាស ដែលនៅសល់ក្នុងឃ្លាំងនៃព្រះវិហារព្រះយេហូវ៉ា
និងទ្រព្យសម្បត្តិទាំងប៉ុន្មានដែលនៅក្នុងដំណាក់ស្ដេច ប្រគល់ទៅក្នុងដៃនៃពួកមហាតលិកទ្រង់ ចាត់គេទៅឯបេន-ហាដា
ឌ់ ជាបុត្រថាបរីម៉ូន ដែលជាបុត្រហេសយ៉ូន ស្ដេចស្រុកស៊ីរី ដែលនៅក្រុងដាម៉ាស ដោយពាក្យថា ១៩ ទ្រង់ ហើយនឹងទូល
បង្គំមានសេចក្ដីសញ្ញានឹងគ្នាមកហើយ ព្រមទាំងព្រះបិតាទូលបង្គំ និងព្រះបិតារបស់ទ្រង់ផង នោះនែ ទូលបង្គំផ្ញើដង្វាយ
ជាប្រាក់មាសមកថ្វាយដល់ទ្រង់ សូមឲ្យទ្រង់ទៅផ្ដាច់សេចក្ដីសញ្ញា ដែលទ្រង់មានចំពោះបាសា ជាស្ដេចស្រុកអ៊ីស្រាអែ
លទៅ ដើម្បីឲ្យគេថយពីទូលបង្គំចេញ ២០ បេន-ហាដាឌ់ក៏ស្ដាប់តាមស្ដេចអេសា ទ្រង់ចាត់ពួកពលទ័ពទៅច្បាំងនឹងអស់
ទាំងទីក្រុងនៅស្រុកអ៊ីស្រាអែល គេក៏វាយក្រុងអ៊ីយ៉ូន ក្រុងដាន់ និងក្រុងអេបិល-បេត-ម្អាកា ព្រមទាំងស្រុកគីនេរ៉ែតទាំង
មូល ហើយស្រុកណែបថាលីទាំងអស់ ២១ កាលបាសាបានជ្រាប នោះទ្រង់ក៏លែងសង់ក្រុងរ៉ាម៉ា ទៅអាស្រ័យនៅឯក្រុងធើសា
វិញ ២២ គ្រានោះ ស្ដេចអេសាទ្រង់ចេញព្រះរាជឱង្ការ ប្រកាសដល់ពួកយូដាទាំងអស់គ្នា ឥតប្រោសទុកអ្នកណាមួយឡើយ ហើយគេក៏ទៅ
យកទាំងថ្ម និងឈើ ដែលបាសាបានប្រើ ដើម្បីនឹងសង់ក្រុងរ៉ាម៉ាមក រួចស្ដេចអេសាក៏យកទៅសង់ក្រុងកេបានៅខែត្របេនយ៉ាមីន ព្រម
ទាំងក្រុងមីសប៉ាវិញ។២៣ រីឯដំណើរឯទៀត ពីអេសា និងអំណាចរបស់ទ្រង់ ហើយការដែលទ្រង់ធ្វើទាំងប៉ុន្មាន ព្រមទាំងទីក្រុងទាំងអស់
ដែលទ្រង់បានសង់ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅជាពង្សាវតាររបស់ពួកស្ដេចយូដាហើយ តែកាលស្ដេចទ្រង់ព្រះជរាហើយ នោះក៏
កើតព្រះរោគឡើងត្រង់ព្រះបាទ ២៤ អេសា ទ្រង់ក៏ផុំលក់ទៅមួយនឹងពួកឰយុកោទ្រង់ទៅ គេបញ្ចុះទ្រង់ នៅមួយនឹងពួកឰយុកោទ្រង់ ក្នុងទី
ក្រុងរបស់ដាវីឌ ជាឰយុកោ រួចយ៉ូសាផាត ជាព្រះរាជបុត្រាក៏សោយរាជ្យឡើងជំនួសបិតា។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

..............................................................................................

..............................................................................................

..............................................................................................

## ការយល់ដឹងអំពីអត្ថបទ

### *ស្តេចអ័ប៊ីយ៉ាសោយរាជ្យនៅស្រុកយូដា*

ស្តេចអ័ប៊ីយ៉ា គិតថាបើស្រុកយូដានៅតែធ្វើពិធីសាសនាផ្សេងៗតាមច្បាប់ទម្លាប់ពីបុរាណដែលព្រះជាម្ចាស់បានប្រទានមកតាមរយៈលោកម៉ូសេ នោះព្រះជាម្ចាស់នឹងធានាអោយទ្រង់មានជ័យជម្នះក្នុងការធ្វើសង្គ្រាមជាមួយស្តេចយេរ៉ូបោម។ ទ្រង់ពិតជាអាចយកជ័យជម្នះលើកងទ័ពស្តេចយេរ៉ូបោមមែនប៉ុន្តែជ័យជម្នះនេះបានមកដោយសារតែកងទ័ពទ្រង់ប្រយុទ្ធដោយពឹងអាងលើព្រះជាម្ចាស់ មិនមែនព្រះជាម្ចាស់មានកាតព្វកិច្ចត្រូវជួយដល់ស្តេចអ័ប៊ីយ៉ានោះទេ។អេសាជាស្តេចថ្មីរបស់យូដា បានចំណាយពេលដប់ឆ្នាំក្នុងការលុបបំបាត់ចោលនូវការប្រព្រឹត្តតាមសាសនាពួកកាណាន និងពង្រឹងសុវត្ថិភាពជាតិ។មានហោរាម្នាក់បានចង្អុលបង្ហាញថា ពេលនេះក៏ដូចជាជំនាន់ពួកចៅហ្វាយដែរ ព្រះជាម្ចាស់ប្រទានពរដល់អ្នកដែលទុកចិត្តលើព្រះអង្គ ក្នុងពេលមានអាសន្ន។នេះជាការលើកទឹកចិត្តស្តេចអេសា អោយបន្តការកែទម្រង់របស់ទ្រង់ទៀត។បន្ទាប់មក ស្តេចអេសាបានដកតំណែងពីមាតារបស់ទ្រង់ ដែលជាអ្នកគាំទ្រសាសនាក្លែងក្លាយធំបំផុត។ទ្រង់បានបោសសម្អាតអំពើពេស្យាចារសាសនា ប៉ុន្តែទ្រង់មិនបានរុះរើសបង្គោលរបស់ព្រះបាលទេ។ក្នុងពេលដែលស្តេចស្រុកយូដាកំពុងតែជាប់ដៃជាមួយសត្រូវនៅប៉ែកខាងត្បូង ស្តេចអ៊ីស្រាអែលឈ្មោះបា្អសា បានឆ្លៀតឱកាសចូលវាយលុកក្រុងយូដា។

សេចក្តីអធិស្ឋាន

ខែ11
ថ្ងៃអង្គារ 05

# ស្តេចណាដាបសោយរាជ្យនៅស្រុកអ៊ីស្រាអែល

១ពង្សាវតារក្សត្រ 15:25-16:7

ការអធិស្ឋាន

អានអត្ថបទ

២៥ លុះដល់ឆ្នាំទី២ ក្នុងរាជ្យអេសា ជាស្តេចស្រុកយូដា នោះណាដាប ជាព្រះរាជបុត្រាយេរ៉ូបោម
ទ្រង់ចាប់តាំងសោយរាជ្យ នៅស្រុកអ៊ីស្រាអែល ទ្រង់គ្រងរាជ្យនៅស្រុកអ៊ីស្រាអែលបាន២
ឆ្នាំ ២៦ ទ្រង់ប្រព្រឹត្តអំពើដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ា ហើយប្រតិបត្តិតាមផ្លូវ និង
តាមអំពើបាបរបស់ព្រះបិតា ជាការដែលនាំឲ្យពួកអ៊ីស្រាអែលធ្វើបាបដែរ ២៧ រួចបាសា ជាកូនអ័
ហ៊ីយ៉ា ក្នុងពូជអំបូរអ៊ីសាខារ ក៏ក្បត់ទ្រង់ ហើយប្រហារសំឡាប់ទ្រង់នៅត្រង់គីបថោន ជាទីក្រុង
របស់ពួកភីលីស្ទីនទៅ ដ្បិតនៅគ្រានោះ ណាដាប និងពួកអ៊ីស្រាអែលទាំងអស់ គេកំពុងឡោម
ព័ទ្ធច្បាំងនឹងក្រុងគីបថោន ២៨ គឺនៅឆ្នាំទី៣ ក្នុងរាជ្យអេសាជាស្តេចស្រុកយូដា ដែលបាសាបានធ្វើគុត
ណាដាប រួចក៏សោយរាជ្យឡើងជំនួសទ្រង់ ២៩ លុះបានតាំងឡើងជាស្តេចហើយ នោះទ្រង់ក៏ប្រហារជីវិតនៃ
ពួកវង្សារបស់យេរ៉ូបោមទាំងអស់បង់ ឥតមានទុកឲ្យពូជពង្សយេរ៉ូបោមណាមួយ មានដង្ហើមនៅរស់ទៀត
ឡើយ រហូតដល់បានធ្វើឲ្យវិនាសអស់រលីងទៅ តាមសេចក្តីដែលព្រះយេហូវ៉ាបានមានព្រះបន្ទូល
ដោយសារអ័ហ៊ីយ៉ា ជាអ្នកបំរើទ្រង់ ដែលនៅក្រុងស៊ីឡូរ ៣០ ដោយព្រោះអំពើបាបដែលយេរ៉ូបោមបានធ្វើ
ព្រមទាំងឲ្យពួកអ៊ីស្រាអែលប្រព្រឹត្តតាមដែរ ជាអំពើដែលបណ្តាលឲ្យព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រា
អែល មានសេចក្តីក្រោធ។៣១ រីឯដំណើរឯទៀតពីណាដាប និងការទាំងប៉ុន្មានដែលទ្រង់ធ្វើ នោះសុទ្ធតែបាន
កត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចអ៊ីស្រាអែលហើយ ៣២ អេសា នឹងបាសា ជាស្តេចអ៊ីស្រាអែ
ល ក៏ច្បាំងគ្នាដរាបដល់អស់ព្រះជន្ម។៣៣ លុះដល់ឆ្នាំទី៣ ក្នុងរាជ្យអេសា ជាស្តេចយូដា នោះបាសា ជាកូនអ័
ហ៊ីយ៉ា ចាប់តាំងសោយរាជ្យលើស្រុកអ៊ីស្រាអែលទាំងមូលនៅក្រុងធើសា ទ្រង់បានសោយរាជ្យអស់២៤
ឆ្នាំ ៣៤ ទ្រង់ក៏ប្រព្រឹត្តអំពើដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ា ហើយបានប្រតិបត្តិតាមផ្លូវ និងអំពើ
បាប ដែលយេរ៉ូបោមបានធ្វើ ជាការដែលនាំឲ្យពួកអ៊ីស្រាអែលធ្វើបាបដែរ។១ នៅគ្រានោះ ព្រះបន្ទូលនៃព្រះ
យេហូវ៉ាបានមកដល់យេហ៊ូវ ជាកូនហាណានីទាស់នឹងបាសាថា ២ ដោយព្រោះអញបានលើកឯងពីធូលីដី
ឡើង តាំងឲ្យធ្វើជាស្តេចលើអ៊ីស្រាអែលជារាស្ត្រអញ តែឯងបានដើរតាមផ្លូវរបស់យេរ៉ូបោមវិញ ព្រមទាំងប
ណ្តាលឲ្យអ៊ីស្រាអែល ជារាស្ត្រអញធ្វើបាបដែរ ជាការដែលនាំឲ្យអញខឹង ដោយសារអំពើបាបរបស់
គេ ៣ នេះនែ អញនឹងបោសឯង នឹងពូជពង្សឯងចេញអស់រលីង ឲ្យបានដូចជាពូជពង្សរបស់យេរ៉ូបោម ជា
កូននេបាតដែរ ៤ អ្នកណាក្នុងវង្សបាសា ដែលស្លាប់នៅក្នុងទីក្រុង នោះឆ្កែនឹងទំពាស៊ី ហើយអ្នកណាដែល
ស្លាប់នៅទីវាល នោះសត្វហើរលើអាកាសនឹងចឹកស៊ីទៅ។៥ បាសាក៏ផ្ទំលក់ ទៅជាមួយនឹងពួកឰយុកោទ្រង់
ទៅ គេបញ្ចុះទ្រង់នៅក្រុងធើសា រួចអេឡា ជាព្រះរាជបុត្រា ក៏សោយរាជ្យឡើងជំនួសបិតា ។ ៦ បាសាក៏ផ្ទំ
លក់ ទៅជាមួយនឹងពួកឰយុកោទ្រង់ទៅ គេបញ្ចុះទ្រង់នៅក្រុងធើសា រួចអេឡា ជាព្រះរាជបុត្រា ក៏សោយ
រាជ្យឡើងជំនួសបិតា ៧ ឯព្រះបន្ទូលនៃព្រះយេហូវ៉ា នោះបានសំដែងមក ទាស់នឹងបាសា ហើយនឹងព្រះរាជវង្សទ្រង់
ដោយសារហោរាយេហ៊ូវ ជាកូនហាណានី គឺដោយព្រោះការដ៏លាមកអាក្រក់ទាំងប៉ុន្មាន ដែលទ្រង់បានប្រព្រឹត្តនៅព្រះ
នេត្រព្រះយេហូវ៉ា ជាការដែលបណ្តាលឲ្យទ្រង់ក្រោធដោយសារអំពើដែលបានធ្វើ ដោយប្រព្រឹត្តដូចជាព្រះវង្សាយេរ៉ូបោ
មនោះ ហើយដោយព្រោះទ្រង់បានប្រហារជីវិតគេថែមទៀត។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

### *ស្តេចណាដាបសោយរាជ្យនៅស្រុកអ៊ីស្រាអែល*

រាជ្យរបស់ស្តេចយេរ៉ូបោម បានត្រូវបញ្ចប់ដូចហោរាអ័ហ៊ីយ៉ាបានទាយទុកមែន។ បុត្ររបស់ទ្រង់ត្រូវលោកប្អាសា( បាសា ) ដែលជាមេទ័ពម្នាក់របស់ទ្រង់សម្លាប់ ហើយមេទ័ពនោះក៏ប្រកាសខ្លួនធ្វើជាស្តេច។ ស្តេចប្អាសាចាប់ផ្តើមកម្ទាត់ពូជពង្សរបស់ស្តេចយេរ៉ូបោមទាំងអស់ ដើម្បីការពារសាងរាជវង្សឡើងវិញ។ទោះជាយ៉ាងណាក៏ដោយ ស្តេចប្អាសាក៏មិនមែនជាស្តេចល្អជាងស្តេចយេរ៉ូបោមដែរ។ដោយទ្រង់បានធ្វើតាមនយោបាយស្តេចយេរ៉ូបោម នោះទ្រង់ក៏បានទទួលវាសនាដូចជាស្តេចយេរ៉ូបោមដែរ។នយោបាយជឿលើពួកបរទេសបានបង្ហាញថា ស្តេចអេសាមានជំនឿទន់ខ្សោយចំពោះព្រះជាម្ចាស់ និងនាំអោយទ្រង់មានទំនាស់ជាមួយហោរាណានី។ទ្រង់មិនបានរក្សាជំនឿរបស់ទ្រង់អោយមាំមួន ហើយកិច្ចការនេះបានកើតឡើងម្តងហើយម្តងទៀត ដូចជានៅពេលទ្រង់មានជំងឺ ទ្រង់បែរជារកគ្រូមន្តអាគមទៅវិញ តែមិនបានសុំព្រះជាម្ចាស់អោយជួយទ្រង់ឡើយ។

សេចក្តីអធិស្ឋាន

ខែ11
ថ្ងៃពុធ 06

# ស្តេចអេឡាសោយរាជ្យនៅស្រុកអ៊ីស្រាអែល

១ពង្សាវតារក្សត្រ 16:8-20

ការអធិស្ឋាន

អានអត្ថបទ

៨ លុះដល់ឆ្នាំទី២៦ ក្នុងរាជ្យអេសា ជាស្តេចយូដា នោះអេឡា ជាកូនបាសា ចាប់តាំងសោយរាជ្យ
ឡើង លើស្រុកអ៊ីស្រាអែលនៅក្រុងធើសា ក៏សោយរាជ្យបាន២ឆ្នាំ។
៩ រួចស៊ីមរី ជាមេទ័ពរបស់ទ្រង់ ដែលត្រួតលើរទេះចំបាំងទ្រង់ពាក់កណ្តាល លោកបានក្បត់ទ្រង់ រីឯ
កាលទ្រង់គង់នៅក្រុងធើសា កំពុងតែសោយស្រាស្រវឹង ក្នុងផ្ទះរបស់អើសា ជាឧកញ៉ាវាំងនៅ
ក្រុងធើសា ១០ នោះស៊ីមរីក៏ចូលទៅធ្វើគុតទ្រង់ ក្នុងឆ្នាំទី២៧នៃរាជ្យអេសា ជាស្តេចយូដា រួច
សោយរាជ្យឡើងជំនួសទ្រង់ ១១ លុះបានគង់លើបល្ល័ង្កសោយរាជ្យឡើងហើយ នោះក៏ប្រហារ
ជីវិតនៃវង្សានុវង្សរបស់បាសាទាំងអស់ទៅ ឥតទុកពួកប្រុសៗណាមួយខាងបាសា ទោះទាំងវង្សា
ឬជាមិត្រសំឡាញ់របស់ទ្រង់ ឲ្យនៅសល់ឡើយ ១២ គឺយ៉ាងនោះដែលស៊ីមរីបានរំលាយពួកវង្ស
របស់បាសាទាំងអស់ទៅ តាមសេចក្តីដែលព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលទាស់នឹងបាសា
ដោយសារហោរាយេហ៊ូវ ១៣ ដោយព្រោះអំពើបាបរបស់បាសា និងអំពើបាបរបស់អេឡា ជាបុត្រ
ទ្រង់ ដែលទ្រង់បានប្រព្រឹត្ត ព្រមទាំងបណ្តាលឲ្យពួកអ៊ីស្រាអែលធ្វើបាបដែរ ជាការដែលនាំឲ្យ
ព្រះយេហូវ៉ា ជាព្រះនៃពួកអ៊ីស្រាអែល មានសេចក្តីក្រោធ ដោយសាររបស់ជាអសារឥតការរបស់
គេ ១៤ រីឯដំណើរឯទៀតពីអេឡា និងការទាំងប៉ុន្មានដែលទ្រង់ធ្វើ នោះសុទ្ធតែបានកត់ទុកក្នុង
សៀវភៅ ជាពង្សាវតាររបស់ពួកស្តេចអ៊ីស្រាអែលហើយ។
១៥ លុះដល់ឆ្នាំទី២៧ ក្នុងរាជ្យអេសា ជាស្តេចយូដា នោះស៊ីមរីបានសោយរាជ្យអស់៧ថ្ងៃ នៅក្រុង
ធើសា រីឯពួកពលទ័ព គេកំពុងតែច្បាំងនឹងគីបថោន ជាទីក្រុងរបស់ពួកភីលីស្ទីន ១៦ ហើយពួក
ទាំងនោះក៏ឮថា ស៊ីមរីបានក្បត់ស្តេច ហើយធ្វើគុតទ្រង់ផង ដូច្នេះ ពួកអ៊ីស្រាអែលទាំងអស់គ្នាក៏
លើកអំរី ជាមេទ័ពធំតាំងឡើងជាស្តេចលើពួកអ៊ីស្រាអែល នៅឯទីបោះទ័ពក្នុងថ្ងៃនោះ
ឯង ១៧ ដូច្នេះអំរី និងពួកអ៊ីស្រាអែលទាំងអស់គ្នា ក៏ចេញពីក្រុងគីបថោន ឡើងទៅឡោមព័ទ្ធក្រុង
ធើសាវិញ ១៨ កាលស៊ីមរីបានឃើញថា គេចាប់បានទីក្រុងហើយ នោះក៏ចូលទៅក្នុងដំណាក់ស្តេ
ច ក្នុងរាជវាំង រួចដុតដំណាក់ ហើយខ្លួនក៏ស្លាប់ក្នុងភ្លើងនោះទៅ ១៩ ដោយព្រោះអំពើបាបដែល
បានធ្វើ ដោយប្រព្រឹត្តលាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ា ព្រមទាំងដើរតាមផ្លូវនឹងអំពើបាប
ដែលយេរ៉ូបោមបានធ្វើ ជាការដែលនាំឲ្យពួកអ៊ីស្រាអែលធ្វើបាបតាមដែរ ២០ រីឯដំណើរឯទៀតពី
ស៊ីមរី និងការដែលលោកក្បត់ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេច
អ៊ីស្រាអែលហើយ។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

...........................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

...........................................................................................

## ការយល់ដឹងអំពីអត្ថបទ

### *ស្តេចអេឡាសោយរាជ្យនៅស្រុកអ៊ីស្រាអែល*

ស្តេចបាសាបានបញ្ចប់រាជវង្សរបស់ស្តេចយេរ៉ូបោម ដោយសម្លាប់បុត្រទាំងអស់របស់ទ្រង់ និងក្រុមញាតិវង្សទាំងអស់ ឯរាជវង្សរបស់ទ្រង់ផ្ទាល់ក៏ត្រូវបញ្ចប់ ដោយមេទ័ពរបស់ទ្រង់ម្នាក់បានសម្លាប់បុត្រារបស់ទ្រង់ ឯសមាជិករាជវង្សទាំងអស់ក៏ដូចគ្នាដែរ។លោកស៊ីមរី បានធ្វើអត្តឃាតនៅពេលដែលទាហានទាំងអស់ មិនគាំទ្រលោកអោយធ្វើជាស្តេច តែបែរជាគាំទ្រលោកអ៊ំរីទៅវិញ។ប្រសិនជាយើងបានអាននិងពិនិត្យម្តងហើយម្តងទៀតនោះយើងនឹងឃើញថា ការដែលក្បត់គ្នា ការដែលសំលាប់គ្នាទៅវិញទៅមក ពីម្នាក់ទៅម្នាក់ វាសុទ្ធតែកើតចេញពីអំពើបាបរបស់ពួកគេរៀងៗខ្លួន ដែលអំពើអាក្រក់ទាំងនេះកើតចេញមក គឺសុទ្ធតែដោសារតែការស្រលាញ់អំណាច ការដែលមានគំនុំ និងភាពលោភលន់ទាំងអស់។មនុស្សដែលកាចសាហាវ មិនចេះប្រណី គ្មានការអាណិតអាសូរ ឬក្តីមេត្តាករុណាសោះ រមែងបានជួបសេចក្តីទាំងនោះវិញនៅថ្ងៃក្រោយជាមិនខានឡើយ។

សេចក្តីអធិស្ឋាន

ខែ11
ថ្ងៃព្រ.ហ 07

# ស្ដេចអំរីសោយរាជ្យនៅស្រុកអ៊ីស្រាអែល

## ១ពង្សាវតារក្សត្រ 16:21-34

ការអធិស្ឋាន

អានអត្ថបទ

២១ គ្រានោះ ប្រជាជនទាំងឡាយ ជាសាសន៍អ៊ីស្រាអែល គេបែកគ្នាជា២ពួក ពួក១កាន់ខាងធីបនី
ជាកូនគីណាត ប្រាថ្នានឹងលើកឡើងជាស្ដេច ហើយពួក១ទៀតកាន់ខាងអំរី ២២ តែបណ្ដាជន
ដែលចូលដៃខាងអំរី គេឈ្នះពួកខាងធីបនីជាកូនគីណាត ដូច្នេះធីបនីក៏ស្លាប់ទៅ ហើយអំរីសោយ
រាជ្យឡើង។
២៣ គឺនៅឆ្នាំទី៣១ ក្នុងរាជ្យអេសា ជាស្ដេចយូដា ដែលអំរីចាប់តាំងសោយរាជ្យឡើងលើស្រុកអ៊ី
ស្រាអែល ក៏សោយរាជ្យបាន១២ឆ្នាំ ទ្រង់សោយរាជ្យនៅក្រុងធើសាបាន៦ឆ្នាំ ២៤ រួចទ្រង់ទិញភ្នំ
សាម៉ារីពីសេមើរ ដំឡៃ២ហាបប្រាក់ ទ្រង់ក៏សង់ទីក្រុងនៅលើភ្នំនោះ ឲ្យឈ្មោះថា សាម៉ារី តាម
ឈ្មោះសេមើរជាម្ចាស់ភ្នំ ២៥ ឯអំរីទ្រង់ប្រព្រឹត្តដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ា ក៏ធ្វើ
អាក្រក់លើសជាងអស់អ្នកណាដែលនៅមុនទ្រង់ទៅទៀត ២៦ ដ្បិតទ្រង់បានប្រតិបត្តិតាមអស់
ទាំងផ្លូវ និងអំពើបាប របស់យេរ៉ូបោម ជាកូននេបាត ជាអ្នកដែលបណ្ដាលឲ្យពួកអ៊ីស្រាអែលធ្វើ
បាបតាមដែរ គឺជាការដែលនាំឲ្យព្រះយេហូវ៉ា ជាព្រះនៃពួកអ៊ីស្រាអែលមានសេចក្ដីក្រោធ
ដោយសាររបស់ជាអសារឥតការរបស់គេ ២៧ រីឯដំណើរឯទៀត ដែលអំរីធ្វើ និងអំណាចទ្រង់
នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្ដេចអ៊ីស្រាអែលហើយ ២៨ អំរីក៏ផ្ទំ
លក់ ទៅជាមួយនឹងពួកឰយុកោទ្រង់ទៅ ហើយគេបញ្ចុះទ្រង់នៅក្នុងក្រុងសាម៉ារី រួចអ័ហាប់ ជា
ព្រះរាជបុត្រា បានសោយរាជ្យឡើងជំនួសបិតា។
២៩ លុះដល់ឆ្នាំទី៣៨ ក្នុងរាជ្យអេសា ជាស្ដេចយូដានោះអ័ហាប់ ជាបុត្រអំរី ចាប់តាំងសោយរាជ្យឡើងលើ
ស្រុកអ៊ីស្រាអែល ទ្រង់គ្រងរាជ្យលើពួកអ៊ីស្រាអែល នៅក្រុងសាម៉ារីបាន២២ឆ្នាំ ៣០ អ័ហាប់ ជាបុត្រអំរី ទ្រង់
ប្រព្រឹត្តលាមកអាក្រក់នៅព្រះនេត្រព្រះយេហូវ៉ា លើសជាងអស់អ្នកណាដែលនៅមុនទ្រង់ទៅទៀត ៣១ ទ្រង់
ក៏យកនាងយេសិបិល ជាបុត្រីអេតបាល ស្ដេចពួកស៊ីដូន ធ្វើជាភរិយា ព្រមទាំងទៅគោរពប្រតិបត្តិថ្វាយបង្គំ
ដល់ព្រះបាលផង ទុកដូចជាការ ដែលទ្រង់ប្រព្រឹត្ត តាមអំពើបាបរបស់យេរ៉ូបោម ជាបុត្រនេបាតនោះ ជាការ
យ៉ាងស្រាលវិញ ៣២ ទ្រង់ក៏ស្អាងអាសនាមួយ ថ្វាយព្រះបាល នៅក្នុងវិហារព្រះបាលដែលទ្រង់បានស្អាង
នៅក្រុងសាម៉ារី ៣៣ អ័ហាប់ទ្រង់ធ្វើរូបព្រះ ហើយប្រព្រឹត្តអំពើអាក្រក់ លើសជាងអស់ទាំងស្ដេចដែលនៅមុន
ទ្រង់ទៅទៀត ជាការដែលបណ្ដាលឲ្យព្រះយេហូវ៉ា ជាព្រះនៃពួកអ៊ីស្រាអែលមានសេចក្ដីក្រោធ ៣៤ នៅក្នុង
រាជ្យទ្រង់ នោះហ៊ីអែល ជាអ្នកក្រុងបេត-អែល ក៏សង់ក្រុងយេរីខូរឡើងវិញ កាលគាត់ដាក់ជើងកំផែងចុះ
នោះអ័ប៊ីរ៉ាម ជាកូនច្បងក៏ស្លាប់ទៅ ហើយកាលរៀបចំទ្វារក្រុងឡើង នោះសេគូបជាកូនពៅក៏ស្លាប់ទៅ តាម
សេចក្ដីដែលព្រះយេហូវ៉ាបានមានព្រះបន្ទូល ដោយសារយ៉ូស្វេជាកូននុន។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

........................................................................................................

........................................................................................................

........................................................................................................

## ការយល់ដឹងអំពីអត្ថបទ

### *ស្តេចអំរីសោយរាជ្យនៅស្រុកអ៊ីស្រាអែល*

មានការជ្រួលច្របល់មួយកើតឡើងក្រោយពេលដែលលោកស៊ីមរីស្លាប់។ លោកអំរីបានដណ្តើមយកបល្ល័ង្កបាន តែមានលោកធីបនី ឡើងមកប្រជែងបន្តទៀត។ មានសង្គ្រាមក្នុងស្រុកបានកើតឡើងអស់រយៈពេលបួនឆ្នាំ មុនពេលស្តេចអំរីឡើងសោយរាជជាផ្លូវការ។ ពីរឆ្នាំក្រោយមកទ្រង់បានរើរាជធានីពីធើសា ទៅក្រុងសាម៉ារី ដែលស្ថិតនៅជារាជធានីរហូតដល់ទីអវសាននៃអាណាចក្រប៉ែកខាងជើង។ សាម៉ារីជាទីក្រុងមួយដែលស្ថិតនៅក្នុងយុទ្ធសាស្ត្រយ៉ាងល្អ អាចជួយអោយស្តេចជំនាន់ក្រោយ តស៊ូប្រឆាំងនឹងសត្រូវដែលខ្លាំងពូកែ។ រយៈពេលមួយឆ្នាំនៃរាជ្យស្តេចអំរីទ្រង់បានធ្វើអោយស្រុកទេសមានលំនឹងល្អ ទោះបីជាការប្រព្រឹត្តខាងសាសនារបស់ទ្រង់ អាក្រក់ជាងស្តេចមុនៗក៏ដោយ។ ហើយរាជ្យវង្សរបស់ទ្រង់បានស្ថិតនៅអស់ជាងបួនជំនាន់ មានតែរាជវង្សស្តេចយេហ៊ូវដែលមកជំនួសទ្រង់ទេដែលស្ថិតនៅយូរជាងទ្រង់។ អ័ហាប់ជាស្តេចថ្មីគ្រងរាជ្យនៅអ៊ីស្រាអែល ដែលមានប្រពន្ធឈ្មោះយេសិបិល ស្តេចនេះគោរពកោតខ្លាចព្រះបាលជាផ្លូវការ ហើយព្រះបាលនេះបាននាំចូលមកដោយប្រពន្ធស្តេច យេសិបិលដែលមានចិត្តទុច្ចរិតចំពោះសាសនានិងប្រជាជនអ៊ីស្រាអែលជាខ្លាំង។

សេចក្តីអធិស្ឋាន

ខែ11
ថ្ងៃសុក្រ 08

# ហោរាអេលីយ៉ាប្រកាសការរាំងស្ងួត

១ពង្សាវតារក្សត្រ 17:1-7

ការអធិស្ឋាន

អានអត្ថបទ

១ គ្រានោះ អេលីយ៉ា ជាអ្នកស្រុកធេសប៊ី ដែលនៅជាមួយនឹងពួកស្រុកកាឡាត លោកទូលនឹងអ័
ហាប់ថា ទូលបង្គំស្បថ ដោយនូវព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលដ៏មានព្រះជន្មរស់
ដែលទូលបង្គំឈរនៅចំពោះទ្រង់នេះថា ក្នុងប៉ុន្មានឆ្នាំទៅមុខនេះនឹងគ្មានភ្លៀង គ្មានសន្សើម
ឡើយ វៀរតែដោយសារពាក្យទូលបង្គំប៉ុណ្ណោះ ២ រួចព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកបង្គាប់លោក
ថា ៣ ចូរចេញពីទីនេះ បែរទៅខាងកើត ហើយពួនខ្លួននៅឯជ្រោះកេរីត ដែលនៅប្រទល់មុខនឹង
ទន្លេយ័រដាន់ទៅ ៤ ឯងនឹងផឹកទឹកជ្រោះនោះ ហើយអញបានបង្គាប់ឲ្យក្អែកចិញ្ចឹមឯងនៅទីនោះ
ដែរ ៥ ដូច្នេះ លោកក៏ធ្វើតាមព្រះបន្ទូលនៃព្រះយេហូវ៉ា គឺទៅអាស្រ័យនៅក្បែរជ្រោះកេរីត ដែល
នៅប្រទល់មុខទន្លេយ័រដាន់ ៦ ហើយរាល់ព្រឹករាល់ល្ងាច ក្អែកតែងពាំនំប៉័ង និងសាច់មកជូន
លោក លោកក៏ផឹកទឹកពីជ្រោះនោះ។
៧ លុះកន្លងយូរបន្តិចមក ទឹកជ្រោះក៏រីងទៅ ពីព្រោះមិនមានភ្លៀងធ្លាក់នៅស្រុកនោះសោះ។

1 Now Elijah the Tishbite, from Tishbe in Gilead, said to Ahab, “As the Lord, the God of Israel, lives, whom I serve, there will be neither dew nor rain in the next few years except at my word.”
2 Then the word of the Lord came to Elijah: 3 “Leave here, turn eastward and hide in the Kerith Ravine, east of the Jordan. 4 You will drink from the brook, and I have directed the ravens to supply you with food there.”
5 So he did what the Lord had told him. He went to the Kerith Ravine, east of the Jordan, and stayed there. 6 The ravens brought him bread and meat in the morning and bread and meat in the evening, and he drank from the brook.
7 Some time later the brook dried up because there had been no rain in the land.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

### *ហោរាអេលីយ៉ាប្រកាសការរាំងស្ងួត*

ពេលនេះសាសនារបស់អ៊ីស្រាអែលកំពុងស្ថិតនៅក្នុងភាពគ្រោះថ្នាក់ ជំរុញអោយព្រះជាម្ចាស់លូកព្រះហស្តមកធ្វើការអស្ចារ្យ និងជំនុំជម្រះលើជាតិសាសន៍នេះជាច្រើនលើកច្រើនសារ។ ដំបូងបំផុត ព្រះបានបញ្ជូនហោរាអេលីយ៉ាមកប្រកាសពីគ្រោះរាំងស្ងួតរយៈពេលបីឆ្នាំ នៅទូទាំងស្រុកអ៊ីស្រាអែល។ នេះជាការបង្ហាញពីភាពគ្មានអំណាចរបស់ព្រះបាល ដែលគួរតែជាព្រះនៃធម្មជាតិ និងជីជាតិ តែក្នុងពេលនោះដែរ គឺជាពេលដែលបង្ហាញពីអំណាចនៃព្រះយេហូវ៉ាជាព្រះអ៊ីស្រាអែលវិញ។ ប្រជារាស្ត្រមិនចូលចិត្តលោកអេលីយ៉ាទេ ដោយសារតែគ្រោះរាំងស្ងួត ហេតុនេះហើយព្រះជាម្ចាស់បាននាំគាត់ទៅលាក់ខ្លួននៅក្បែរជ្រោះមួយក្នុងភូមិឋានរបស់គាត់ជិតតំបន់កេរីត ខាងកើតទន្លេយ័រដាន់។ គ្មាននរណាម្នាក់បានដឹងថា គាត់លាក់ខ្លួននៅទីណាឡើយ ហើយលោកក៏មិនព្រួយពីការស្វែងរកចំណីអាហារដែរ ព្រោះព្រះជាម្ចាស់បានផ្គត់ផ្គង់យ៉ាងបរិបូរ។

សេចក្ដីអធិស្ឋាន

ខែ11 ថ្ងៃសៅរ៍ 09

# អេលីយ៉ាស្នាក់នៅផ្ទះស្ត្រីមេម៉ាយម្នាក់នៅក្រុងសារិបតា

១ពង្សាវតារក្សត្រ 17:8-24

ការអធិស្ឋាន

អានអត្ថបទ

៨ នោះព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកបង្គាប់លោកថា ៩ ចូរក្រោកឡើង ទៅឯសារិបតា ជាទីក្រុងរបស់ពួក
ស៊ីដូនអាស្រ័យនៅទីនោះវិញចុះ អញបានបង្គាប់ស្រីមេម៉ាយម្នាក់នៅទីនោះ ឲ្យចិញ្ចឹមឯង ១០ ដូច្នេះ លោក
ក៏ក្រោកឡើងទៅឯក្រុងសារិបតា កាលបានទៅដល់មាត់ទ្វារក្រុងហើយ នោះឃើញមានស្រីមេម៉ាយម្នាក់
កំពុងតែរើសរំកាច់ឈើ លោកក៏ហៅនាងថា សូមយកទឹកក្នុងផ្តិលមកឲ្យខ្ញុំផឹកបន្តិច ១១ កាលនាងកំពុងតែ
ទៅយកទឹក នោះលោកស្រែកផ្តាំថា សូមយកនំបុ័ងបន្តិចមកឲ្យខ្ញុំផង ១២ តែនាងឆ្លើយថា ខ្ញុំស្បថដោយនូវ
ព្រះយេហូវ៉ា ជាព្រះនៃអ្នកដ៏មានព្រះជន្មរស់នៅថា ខ្ញុំគ្មាន១ដុំឡើយ មានតែម្សៅ១ក្តាប់នៅក្នុងខាប់ និង
ប្រេងបន្តិចបន្តួចនៅដបប៉ុណ្ណោះ មើលនែ ខ្ញុំកំពុងតែរើសរំកាច់ឈើ២នេះ ដើម្បីចូលទៅចំអិនសំរាប់ខ្ញុំ និង
កូន យើងនឹងបរិភោគតែប៉ុណ្ណោះ រួចស្លាប់ទៅ ១៣ តែអេលីយ៉ាប្រាប់នាងថា កុំឲ្យខ្លាចឡើយ សូមទៅធ្វើដូច
ជាអ្នកបានថាចុះ តែសូមធ្វើនំ១យ៉ាងតូចមកឲ្យខ្ញុំជាមុនសិន រួចសឹមធ្វើសំរាប់អ្នក និងកូនអ្នកចុះ ១៤ ដ្បិត
ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានព្រះបន្ទូលដូច្នេះថា ម្សៅក្នុងខាប់នោះនឹងមិនដែលផុត
ទៅ ហើយប្រេងក្នុងដបក៏មិនដែលរលោះឡើយ ដរាបដល់ថ្ងៃដែលព្រះយេហូវ៉ានឹងបង្អុរភ្លៀងមកលើផែន
ដី ១៥ ដូច្នេះ នាងក៏ទៅធ្វើតាមបង្គាប់របស់អេលីយ៉ា រួចទាំងនាង និងលោក ព្រមទាំងកូននាង គ្រប់គ្នាបាន
បរិភោគ តមកជាយូរថ្ងៃ ១៦ ឯម្សៅក្នុងខាប់នោះ មិនដែលអស់ទៅ ហើយប្រេងក្នុងដបក៏មិនចេះរលោះឡើយ
ដូចជាសេចក្តីដែលព្រះយេហូវ៉ាបានមានព្រះបន្ទូល ដោយសារអេលីយ៉ា។
១៧ ក្រោយនោះមក មានកាល១ថ្ងៃ កូនរបស់នាងម្ចាស់ផ្ទះនោះចាប់ជំងឺឈឺ ជំងឺនោះមានទំងន់ណាស់ ដល់
ម្ល៉េះបានជាគ្មានដង្ហើមក្នុងខ្លួនឡើយ ១៨ ដូច្នេះ នាងនិយាយទៅអេលីយ៉ាថា ឱអ្នកសំណប់របស់ព្រះអើយ តើ
ខ្ញុំនឹងលោកមានការណ៍អ្វីនឹងគ្នា លោកបានមកឯណេះ ដើម្បីរំឭកពីអំពើបាបរបស់ខ្ញុំ ហើយនឹងសំឡាប់កូន
ខ្ញុំឬ ១៩ តែលោកឆ្លើយតបថា សូមឲ្យកូនអ្នកមកខ្ញុំចុះ រួចលោកក៏ទទួលកូនពីទ្រូងនាង បីឡើងចូលទៅក្នុង
បន្ទប់ដែលលោកអាស្រ័យនៅ ហើយផ្តេកនៅលើដំណេករបស់លោក ២០ រួចអំពាវនាវដល់ព្រះយេហូវ៉ាថា ឱ
ព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ តើទ្រង់បាននាំសេចក្តីអាក្រក់មកលើស្រីមេម៉ាយនេះ ដែលទូលបង្គំ
អាស្រ័យនៅជាមួយ ដោយសំឡាប់កូននាងដែរឬ ២១ លោកក៏ទ្រោបលើកូននោះ៣ដង ទាំងអំពាវនាវដល់
ព្រះយេហូវ៉ាថា ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ សូមឲ្យព្រលឹងរបស់កូននេះត្រឡប់ចូលមកក្នុងខ្លួនវា
វិញចុះ ២២ ព្រះយេហូវ៉ាទ្រង់ស្តាប់តាមអេលីយ៉ា ហើយព្រលឹងរបស់កូននោះ ក៏ត្រឡប់ចូលមកក្នុងខ្លួនវា ឲ្យ
រស់ឡើងវិញ ២៣ នោះអេលីយ៉ាក៏បីកូននោះចុះពីបន្ទប់មក ចូលទៅក្នុងផ្ទះប្រគល់ដល់ម្តាយវិញ ដោយពាក្យ
ថា មើល កូនអ្នកមានជីវិតរស់ ២៤ នាងនិយាយឡើងថា ឥឡូវនេះខ្ញុំដឹងហើយថា លោកជាអ្នកសំណប់របស់
ព្រះពិត ហើយថា ព្រះបន្ទូលនៃព្រះយេហូវ៉ាដែលនៅមាត់លោក

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

***អេលីយ៉ាស្នាក់នៅផ្ទះស្ត្រីមេម៉ាយម្នាក់នៅក្រុងសារិបតា***

នៅពេលទឹកជ្រោះដែលផ្គត់ផ្គង់លោកអេលីយ៉ាបានរីងស្ងួតអស់ ព្រះបានបញ្ជូនលោកទៅទីក្រុងសារិបតាក្នុងតំបន់ពួកស៊ីដូន។នេះជាស្រុករបស់ព្រះបាល ប៉ុន្តែគ្រោះរាំងស្ងួតនៅទីនោះក៏មានភាពធ្ងន់ធ្ងរដែរ។ ព្រះបានប្រទានចំណីអាហារសម្រាប់លោកតាមរយៈស្ត្រីមេម៉ាយក្នុងរបៀបដ៏អស្ចារ្យ ព្រះអង្គបានបង្ហាញថា អំណាចរបស់ព្រះអង្គធំធេងជាងព្រះបាល ទោះបីជានៅក្នុងស្រុកភូមិរបស់ព្រះបាលក៏ដោយ ហើយក៏ខុសអំពីព្រះបាលដែរ ពីព្រោះអំណាចរបស់ព្រះទ្រង់ជាអំណាចមិនពឹងផ្អែកលើធម្មជាតិទេ។ ក្នុងព្រឹត្តិការណ៍នេះបានបង្ហាញថា ព្រះជាម្ចាស់បានតាមវ៉ៃព្រះបាលដល់ផ្ទះតែម្តង ហើយព្រះបានមកប្រទានពរដល់ចំពោះអ្នកដែលជឿទុកចិត្តលើព្រះអង្គវិញ។ ព្រះមិនមែនប្រទានពរដល់ចំពោះតែសាសន៍ណាមួយទេ។ ការដែលកូនប្រុសស្រីស្ត្រីមេម៉ាយនោះបានជាពីជំងឺនោះបានបញ្ជាក់ពីជំនឿរបស់នាង និងធ្វើអោយលោកអេលីយ៉ាបានជឿជាក់ក្នុងចិត្តពីវត្តមាន និងអំណាចរបស់ព្រះជាម្ចាស់នៅជាមួយគាត់ ក្នុងពេលមានឧបសគ្គ និងភាពឯកោនៅអនាគតផង។

សេចក្តីអធិស្ឋាន

ខែ11 ថ្ងៃអាទិត្យ 10

# ការអធិប្បាយថ្ងៃអាទិត្យ

- ចំណងជើង :
- អត្ថបទ :
- អ្នកអធិប្បាយ :



ពាក្យសម្តី

ការប្រកបរបស់យើងជាមួយនិងព្រះ

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ



ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

## សេចក្តីអធិស្ឋាន

ខែ11
ថ្ងៃច័ន្ទ 11

# ហោរាអេលីយ៉ាជួបស្តេចអ័ហាប់

១ពង្សាវតារក្សត្រ 18:1-15

ការអធិស្ឋាន

អានអត្ថបទ

១ កាលកន្លងជាយូរហើយ គឺដល់ឆ្នាំទី៣ នោះព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់អេលីយ៉ាថា
ចូរទៅបង្ហាញខ្លួនឲ្យអ័ហាប់ឃើញ នោះអញនឹងបង្អុរឲ្យភ្លៀងធ្លាក់ចុះមកលើផែនដី ២ ដូច្នេះ អេលី
យ៉ាក៏ទៅ ដើម្បីបង្ហាញខ្លួនដល់អ័ហាប់ រីឯនៅស្រុកសាម៉ារី មានអំណត់អត់ជាខ្លាំង
ណាស់ ៣ ចំណែកអ័ហាប់ទ្រង់ហៅអូបាឌា ជាឧកញ៉ាវាំងមក (រីឯអូបាឌានេះ លោកកោតខ្លាច
ដល់ព្រះយេហូវ៉ាណាស់ ៤ ដ្បិតកាលយេសិបិលបានសំឡាប់ពួកហោរានៃព្រះយេហូវ៉ា នោះ
លោកក៏នាំយកពួកហោរានោះ១០០នាក់ ទៅបំពួននៅក្នុងរអាង ក្នុង១ពួក៥០នាក់ ហើយបាន
ចិញ្ចឹម ដោយនំបុ័ង និងទឹក)
៥ អ័ហាប់មានព្រះបន្ទូលទៅអូបាឌាថា ចូរឯងទៅអស់ទាំងរន្ធទឹក និងជ្រោះទឹកទាំងអស់ដែលនៅ
ក្នុងស្រុក ប្រហែលជាយើងនឹងរកបានស្មៅល្មមនឹងចិញ្ចឹមសេះ ហើយនឹងលាកាត់ឲ្យរស់នៅបាន
ដើម្បីកុំឲ្យហ្វូងសត្វស្លាប់ទៅទាំងអស់ឡើយ ៦ ដូច្នេះ គេក៏ចែកស្រុកគ្នា ដើម្បីនឹងដើរទៅមក គឺអ័
ហាប់បានដើរផ្លូវ១តែឯងទៅ ហើយអូបាឌាក៏ទៅតាមផ្លូវ១ទៀតតែឯងដែរ។
៧ កាលអូបាឌាកំពុងតែដើរទៅ នោះអេលីយ៉ាមកប្រទះ ហើយលោកក៏ស្គាល់អេលីយ៉ា រួចក្រាប
ផ្កាប់មុខចុះសួរថា នេះគឺលោកអេលីយ៉ា ជាម្ចាស់ខ្ញុំឬអី ៨ លោកឆ្លើយតបថា គឺខ្ញុំនេះហើយ សូម
ទៅទូលចៅហ្វាយអ្នកថា មើល អេលីយ៉ាមកហើយ ៩ តែអូបាឌាប្រកែកថា តើខ្ញុំបានធ្វើបាបអ្វី
បានជាលោកចង់ប្រគល់ខ្ញុំប្របាទ ទៅក្នុងកណ្តាប់ដៃនៃអ័ហាប់ ឲ្យសំឡាប់ខ្ញុំដូច្នេះ ១០ ខ្ញុំស្បថ
ដោយនូវព្រះយេហូវ៉ា ជាព្រះនៃលោកដ៏មានព្រះជន្មរស់នៅថា គ្មានសាសន៍ណា ឬនគរណាមួយ ដែល
ចៅហ្វាយខ្ញុំមិនបានចាត់គេឲ្យទៅរកលោកនោះឡើយ ហើយកាលណាគេថា លោកមិននៅទីនេះទេ នោះ
ទ្រង់ក៏ឲ្យពួកសាសន៍នោះ ឬនគរនោះស្បថថា គេមិនបានឃើញលោកមែន ១១ ឥឡូវនេះ លោកមាន
ប្រសាសន៍ថា សូមទៅទូលចៅហ្វាយរបស់អ្នកថា មើល អេលីយ៉ាមកហើយ ១២ រួចកាលណាខ្ញុំចេញពី
លោកទៅ នោះព្រះវិញ្ញាណនៃព្រះយេហូវ៉ានឹងយកលោកទៅកន្លែងណាក៏មិនដឹង ដូច្នេះ កាលខ្ញុំទៅទូល
ដល់អ័ហាប់ ហើយទ្រង់រកលោកមិនឃើញ នោះទ្រង់នឹងសំឡាប់ខ្ញុំចោល ប៉ុន្តែខ្ញុំប្របាទនេះបានកោតខ្លាច
ដល់ព្រះយេហូវ៉ា តាំងតែពីក្មេងមក ១៣ តើគេមិនបានជំរាបដល់លោក ជាម្ចាស់ខ្ញុំទេឬអី ពីការដែលខ្ញុំបានធ្វើ
ក្នុងកាលដែលយេសិបិលសំឡាប់ពួកហោរានៃព្រះយេហូវ៉ា ថាខ្ញុំបានបំពួនពួកហោរានៃព្រះយេហូវ៉ា ចំនួន
១០០នាក់នៅក្នុងរអាងភ្នំ ក្នុង១ពួកៗ៥០នាក់ ព្រមទាំងចិញ្ចឹមគេ ដោយនំបុ័ងហើយទឹកផង ១៤ ឥឡូវនេះ
លោកមានប្រសាសន៍ឲ្យខ្ញុំទៅទូលចៅហ្វាយថា មើលអេលីយ៉ាមកហើយ ដូច្នេះ ទ្រង់នឹងសំឡាប់ខ្ញុំជាមិន
ខាន ១៥ តែអេលីយ៉ាតបថា ខ្ញុំស្បថដោយនូវព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារដ៏មានព្រះជន្មរស់នៅ ដែល
ខ្ញុំឈរនៅចំពោះទ្រង់ដែរ ថា នៅថ្ងៃនេះ ខ្ញុំនឹងបង្ហាញខ្លួន ឲ្យស្តេចឃើញជាពិតប្រាកដ។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

### *ហោរាអេលីយ៉ាជួបស្តេចអ័ហាប់*

ក្រោយពេលរាំងស្ងួតរយៈពេលបីឆ្នាំមក ព្រះជាម្ចាស់បានប្រាប់លោកអេលីយ៉ាថា នេះជាពេលដែលស្តេចអ័ហាប់ និងរាស្ត្ររបស់ទ្រង់ត្រូវសម្រេចចិត្តថា តើពួកគេនឹងដើរតាមព្រះជាម្ចាស់ ឬដើរតាមព្រះបាល។ស្តេចអ័ហាប់បានបារម្ភចំពោះគ្រោះរាំងស្ងួតដែលមានឥទ្ធិពលលើជំនួញ និងសុវត្ថិភាពរបស់អ៊ីស្រាអែល ប៉ុន្តែមិនបារម្ភចំពោះលក្ខខណ្ឌសាសនារបស់អ៊ីស្រាអែលទេ។ ស្តេចនៅតែព្យាយាមបម្រើព្រះជាម្ចាស់ផង និងព្រះបាលផង។ ពេលដែលមហេសីទ្រង់ធ្វើបាបហោរារបស់ព្រះមានមេការនៅក្នុងរាជវាំងម្នាក់បានជួយការពារពួកគេទាំងនោះ។នៅពេលដែលលោកហោរាអេលីយ៉ាបានវិលត្រឡប់មកពីស្រុកអ៊ីស្រាអែលវិញ លោកក៏សុំជួបនឹងស្តេចអ័ហាប់។

សេចក្តីអធិស្ឋាន

ខែ11 ថ្ងៃអង្គារ 12

# ហោរាអេលីយ៉ា និងពួកហោរារបស់ព្រះបាល ប្រជែងគ្នានៅលើភ្នំកើមែល

## ១ពង្សាវតារក្សត្រ 18:16-29

ការអធិស្ឋាន

អានអត្ថបទ

១៦ ដូច្នេះ អូបាឌាក៏ទៅជួបនឹងអ័ហាប់ ទូលឲ្យទ្រង់ជ្រាប រួចអ័ហាប់ទ្រង់យាងទៅជួបនឹងអេលី
យ៉ា ១៧ កាលអ័ហាប់ឃើញអេលីយ៉ាហើយ នោះទ្រង់មានព្រះបន្ទូលសួរថា ឱអ្នកដែលធ្វើឲ្យមានសេចក្តី
វេទនា ដល់ពួកអ៊ីស្រាអែលអើយ តើឯងឬអី ១៨ តែលោកឆ្លើយថា ទូលបង្គំមិនបានធ្វើឲ្យពួកអ៊ីស្រាអែល
មានសេចក្តីវេទនាទេ គឺទ្រង់ និងវង្សានុវង្សនៃព្រះបិតាទ្រង់វិញទេតើ ពីព្រោះទ្រង់បានបោះបង់ចោល
អស់ទាំងបញ្ញត្តនៃព្រះយេហូវ៉ា ព្រមទាំងប្រតិបត្តិតាមព្រះបាលវិញ ១៩ ដូច្នេះ ឥឡូវនេះ សូមចាត់គេទៅ
ប្រមូលពួកអ៊ីស្រាអែលទាំងអស់គ្នាមកឯទូលបង្គំ នៅត្រង់ភ្នំកើមែល ព្រមទាំងពួកហោរានៃព្រះបាល
ទាំង៤៥០នាក់ និងពួកហោរានៃរូបព្រះទាំង៤០០នាក់ ដែលបរិភោគនៅតុរបស់ព្រះនាងយេសិបិលមក
ផង។

២០ អ័ហាប់ក៏ចាត់គេ ឲ្យទៅឯពួកកូនចៅអ៊ីស្រាអែលទាំងអស់ បានប្រមូលទាំងពួកហោរាមកឯភ្នំកើមែល
ដែរ ២១ រួចអេលីយ៉ាក៏ចូលទៅជិតពួកជនសួរថា តើអ្នករាល់គ្នានៅតែស្ទាក់ស្ទើរនាកណ្តាលផ្លូវទាំង២នេះ
ដល់កាលណាទៀត បើព្រះយេហូវ៉ាទ្រង់ជាព្រះ នោះចូរដើរតាមទ្រង់ទៅ តែបើព្រះបាលជាព្រះវិញ នោះ
ចូរប្រតិបត្តិតាមចុះ តែពួកបណ្តាជនមិនបានឆ្លើយ សូម្បី១ម៉ាត់ឡើយ ២២ នោះអេលីយ៉ាមានប្រសាសន៍
ទៅបណ្តាជនថា ក្នុងពួកហោរានៃព្រះយេហូវ៉ា នោះសល់នៅតែខ្ញុំម្នាក់ឯងទេ ឯហោរារបស់ព្រះបាលវិញ
មានចំនួន៤៥០នាក់ ២៣ ដូច្នេះ សូមយកគោឈ្មោល២មកឲ្យយើង ឲ្យគេរើសយក១សំរាប់ពួកគេ
ហើយកាប់ជាដុំៗដាក់លើឧសទៅ តែកុំឲ្យដាក់ភ្លើងឡើយ រួចខ្ញុំនឹងរៀបគោ១ទៀតដាក់លើឧស ឥតដាក់
ភ្លើងដែរ ២៤ ហើយចូរឲ្យអ្នករាល់គ្នាអំពាវនាវដល់ព្រះនាមព្រះរបស់អ្នករាល់គ្នាចុះ ឯក៏ខ្ញុំនឹងអំពាវនាវ
ដល់ព្រះនាមព្រះយេហូវ៉ាវិញ បើព្រះណាឆ្លើយមកដោយសារភ្លើង នោះចូរឲ្យរាប់ព្រះនោះទុកជាព្រះពិត
ចុះ ពួកបណ្តាជនទាំងឡាយក៏ឆ្លើយឡើងថា ស្រួលហើយ។

២៥ ដូច្នេះ អេលីយ៉ាក៏ប្រាប់ដល់ពួកហោរារបស់ព្រះបាលថា ចូររើសគោ១សំរាប់អ្នករាល់គ្នាចុះ ហើយ
រៀបដាក់ជាមុនទៅ ដ្បិតខាងអ្នករាល់គ្នាមានគ្នាច្រើន រួចចូរអំពាវនាវដល់ព្រះនាមនៃព្រះរបស់អ្នករាល់
គ្នាចុះ តែកុំឲ្យដាក់ភ្លើងឡើយ ២៦ គេក៏ទទួលយកគោ១ ដែលបានឲ្យដល់គេ រួចគេរៀបចំ ហើយអំពាវ
នាវដល់ព្រះនាមនៃព្រះបាល ចាប់តាំងពីព្រឹករហូតដល់ថ្ងៃត្រង់ថា ឱព្រះបាលអើយ សូមឆ្លើយមកយើង
ខ្ញុំរាល់គ្នាផង ប៉ុន្តែគ្មានឮសំឡេង ឬចំឡើយណាឆ្លើយមកសោះ គេក៏លោតព័ទ្ធជុំវិញអាសនា ដែលគេ
បានធ្វើនោះ ២៧ គ្រាដល់ពេលថ្ងៃត្រង់ហើយ នោះអេលីយ៉ាពោលចំអកថា ចូរស្រែកឲ្យខ្លាំងឡើង ដ្បិត
លោកជាព្រះ ប្រហែលជាកំពុងរំពឹងគិតឬបានថយចេញ១ភ្លែត ឬធ្វើដំណើរ ឬប្រហែលជាដេកលក់ទេ
ដឹង ត្រូវដាស់លោកឡើង ២៨ គេក៏ស្រែកខ្លាំងឡើង ព្រមទាំងយកកាំបិតឆូតសាច់តាមទំលាប់របស់គេ
ទាល់តែឈាមហូរប្រឡាក់កាយ ២៩ លុះកាលហួសថ្ងៃត្រង់ហើយ នោះគេក៏ថ្វាយបង្គំ រហូតដល់ពេល
ថ្វាយដង្វាយល្ងាច តែគ្មានឮសំឡេង ឬចំឡើយណាឆ្លើយសោះ ក៏គ្មានអ្នកណាស្តាប់ផង។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

***ហោរាអេលីយ៉ា និងពួកហោរារបស់ព្រះបាល***
***ប្រជែងគ្នានៅលើភ្នំកើមែល***

គាត់បានមកប្រាប់ស្តេចអ័ហាប់យ៉ាងច្បាស់ថា ការដែលទ្រង់បានបែងចែកភាពស្មោះត្រង់មានន័យថា មិនស្មោះត្រង់ចំពោះព្រះជាម្ចាស់ នេះជាអំពើបាបរបស់ទ្រង់ និងជាមូលហេតុចម្បងដែលជាអ៊ីស្រាអែលមានគ្រោះថ្នាក់។ ព្រះនាងយេសិបិលមានបំណងយ៉ាងមុតមាំ ក្នុងការផ្សព្វផ្សាយពីព្រះបាលនៅអ៊ីស្រាអែល រហូតទាល់តែមានពួកហោរាព្រះបាលជាច្រើននាក់ធ្វើការសម្រាប់ព្រះនាង។ លោកអេលីយ៉ាបានពន្យុះស្តេចអ័ហាប់ អោយនាំហោរាទាំងនោះទៅឯភ្នំកើមែល (គេជឿថា នេះជាកន្លែងស័ក្តិសិទ្ធិរបស់ព្រះបាល) ដើម្បីធ្វើការប្រកួតប្រជែងជាសាធារណៈអោយដឹងថា តើព្រះមួយណាជាព្រះពិត។ ព្រះបាលគួរតែជាព្រះនៃធម្មជាតិ ប៉ុន្តែព្រះបាលនេះបានបង្ហាញថា គេគ្មានអំណាចអ្វីទាល់តែសោះ។

សេចក្តីអធិស្ឋាន

ខែ11
ថ្ងៃពុធ 13

# ហោរាអេលីយ៉ា និងពួកហោរារបស់ព្រះបាល ប្រជែងគ្នានៅលើភ្នំកើមែល

## ១ពង្សាវតារក្សត្រ 18:30-40

ការអធិស្ឋាន

អានអត្ថបទ

៣០ បន្ទាប់នោះ អេលីយ៉ាមានប្រសាសន៍ទៅបណ្ដាជនថា សូមចូលមកជិតខ្ញុំវិញ ជនទាំងឡាយក៏
អែបចូលមកជិតលោក រួចលោកជួសជុលអាសនានៃព្រះយេហូវ៉ាដែលបានរំលំហើយ ៣១ អេលី
យ៉ាលោកយកថ្ម១២តាមចំនួនពូជអំបូរពួកកូនចៅយ៉ាកុប ដែលព្រះបន្ទូលនៃព្រះយេហូវ៉ាបាន
មកដល់លោកនោះថា ឈ្មោះឯងត្រូវហៅថា អ៊ីស្រាអែលវិញ ៣២ លោកក៏យកថ្មទាំងនោះ ស្អាង
អាសនា១ថ្វាយព្រះនាមព្រះយេហូវ៉ា ក៏ជីកប្រឡាយព័ទ្ធជុំវិញ មានទំហំល្មមដាក់ពូជស្រូវ២រ
ង្វាល់ ៣៣ រួចលោកដាក់ឱសជាលំដាប់ ក៏កាប់គោនោះជាដុំៗ ដាក់ពីលើ ហើយប្រាប់ថា ចូរដង
ទឹកពេញ៤ក្អម យកមកចាក់លើដង្វាយ និងឧសនេះ ៣៤ រួចលោកប្រាប់ថា ចូរចាក់ម្តងទៀត នោះ
គេក៏ចាក់ម្តងទៀត រួចលោកប្រាប់ថា ចូរចាក់ម្តងទៀត គេក៏ចាក់ម្តងទៀត គេក៏ចាក់ជាគំរប់៣
ដង ៣៥ ទឹកនោះបានហូរព័ទ្ធជុំវិញអាសនា គេក៏ចាក់ទឹករហូតដល់ពេញប្រឡាយដែរ ៣៦ លុះដល់
ពេលថ្វាយដង្វាយល្ងាច នោះហោរាអេលីយ៉ាក៏ចូលមកជិតទូលថា ឱព្រះយេហូវ៉ា ជាព្រះនៃអ័ប្រា
ហាំ នៃអ៊ីសាក ហើយនៃអ៊ីស្រាអែល សូមឲ្យមនុស្សបានដឹងនៅថ្ងៃនេះថា ទ្រង់ជាព្រះនៃពួកអ៊ី
ស្រាអែល ហើយថា ទូលបង្គំជាអ្នកបំរើទ្រង់ ព្រមទាំងថា ទូលបង្គំបានធ្វើការទាំងនេះ ដោយស្តា
ប់តាមព្រះបន្ទូលទ្រង់ផង ៣៧ សូមស្តាប់ទូលបង្គំ ឱព្រះយេហូវ៉ាអើយ សូមស្តាប់ទូលបង្គំ ដើម្បីឲ្យ
ប្រជាជននេះបានដឹងថា គឺទ្រង់ឱព្រះយេហូវ៉ាអើយ ដែលជាព្រះ ហើយថា គឺទ្រង់ដែលនាំចិត្តគេ
ត្រឡប់មកវិញ ៣៨ ខណៈនោះ ភ្លើងនៃព្រះយេហូវ៉ាក៏ធ្លាក់ចុះមកបញ្ឆេះដង្វាយ ព្រមទាំងឧស ថ្ម
និងធូលីដី ហើយក៏លិទ្ធទឹកដែលនៅក្នុងប្រឡាយអស់ទៅដែរ ៣៩ កាលពួកជនទាំងឡាយបាន
ឃើញ នោះគេក៏ក្រាបផ្កាប់មុខពោលថា ព្រះយេហូវ៉ាទ្រង់ជាព្រះ ព្រះយេហូវ៉ាទ្រង់ជាព្រះពិត
ហើយ ៤០ រួចអេលីយ៉ាប្រាប់គេថា ចូរចាប់ពួកហោរារបស់ព្រះបាលទៅ កុំឲ្យអ្នកណាមួយរួច
ឡើយ គេក៏ចាប់ ហើយអេលីយ៉ាលោកនាំចុះទៅឯជ្រោះគីសុនសំឡាប់ចោលទាំងអស់នៅទីនោះ
ទៅ។

30 Then Elijah said to all the people, “Come here to me.” They came to him, and he
repaired the altar of the Lord, which had been torn down. 31 Elijah took twelve
stones, one for each of the tribes descended from Jacob, to whom the word of
the Lord had come, saying, “Your name shall be Israel.” 32 With the stones he built
an altar in the name of the Lord, and he dug a trench around it large enough to hold
two seahs of seed. 33 He arranged the wood, cut the bull into pieces and laid it on
the wood. Then he said to them, “Fill four large jars with water and pour it on the
offering and on the wood.”

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

.................................................................................

.................................................................................

.................................................................................

.................................................................................

.................................................................................

.................................................................................

.................................................................................

.................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

.................................................................................

.................................................................................

.................................................................................

## ការយល់ដឹងអំពីអត្ថបទ

***ហោរាអេលីយ៉ា និងពួកហោរារបស់ព្រះបាល***
***ប្រជែងគ្នានៅលើភ្នំកើមែល***

ព្រះយេហូវ៉ាបានបង្ហាញថា ព្រះអង្គមានអំណាចពេញលេញលើធម្មជាតិ ដោយទ្រង់បានធ្វើអោយព្រះបាលចុះចាញ់ ព្រោះទ្រង់បានបញ្ជាអោយមានរន្ទះ ភ្លើង ខ្យល់ និងទឹកទៀតផង។នៅក្នុងពេលប្រជារាស្ត្រទាំងអស់កំពុងគាំទ្រព្រះយេហូវ៉ា លោកអេលីយ៉ាយកឱកាសនេះកម្ទេចពួកហោរាព្រះបាលចោល។

នៅពេលនេះជាពេលដែលព្រះចេស្តារបស់ព្រះជាម្ចាស់បានបង្ហាញអោយពួកប្រជាជាតិអ៊ីស្រាអែលបានឃើញថា ព្រះយេហ៊ូវ៉ាជាព្រះពិតតែមួយ។តែអ្វីដែលយើងគួរដឹងនោះគឺថា សូមយើងកុំជឿលើព្រះជាម្ចាស់ដោយព្រោះតែត្រឹមបានឃើញនៅការអស្ចារ្យរបស់ទ្រង់តែប៉ុណ្ណោះ។តែត្រូវជឿលើទ្រង់ដោយព្រោះទ្រង់គឺជាព្រះនៃសេចក្តីសង្គ្រោះ ជាព្រះនៃក្តីស្រលាញ់ មេត្តាករុណា និងសណ្តោសប្រណី។

សេចក្តីអធិស្ឋាន

ខែ11 ថ្ងៃព្រ.ហ 14

# ភ្លៀងបង្អុរចុះមកសាជាថ្មី

១ពង្សាវតារក្សត្រ 18:41-46

ការអធិស្ឋាន

អានអត្ថបទ

៤១ រួចមកអេលីយ៉ាទូលដល់អ័ហាប់ថា សូមស្ដេចឡើងទៅសោយព្រះស្ងោយចុះ ដ្បិតមានសូរ
សន្ធឹកភ្លៀងជាធំមកហើយ ៤២ ដូច្នេះ អ័ហាប់ក៏ឡើងទៅសោយ ឯអេលីយ៉ា លោកឡើងទៅលើ
កំពូលភ្នំកើមែលវិញ ក៏ក្រាបខ្លួនចុះដល់ដី ដាក់មុខនៅកណ្ដាលក្បាលជង្គង់ ៤៣ រួចប្រាប់អ្នកបំរើថា
ចូរឡើងទៅមើលខាងសមុទ្រឥឡូវ អ្នកបំរើក៏ឡើងទៅមើល រួចជំរាបថា គ្មានអ្វីឡើយ លោកប្រាប់
ថា ចូរទៅឲ្យអស់វារៈ៧ដងទៀត ៤៤ លុះដល់គំរប់៧ដង នោះក៏ជំរាបថា ឃើញមានពពកតូចប៉ុន
បាតដៃមនុស្សឡើងពីសមុទ្រមក នោះលោកបង្គាប់ថា ចូរឡើងទៅទូលអ័ហាប់ថា សូមទឹមរទេះ
ហើយចុះទៅចុះ ដើម្បីកុំឲ្យអាក់ដំណើរដោយសារភ្លៀង ៤៥ បន្ទាប់នោះបន្តិចមក មេឃត្រឡប់ជា
ខ្មៅ ដោយពពក និងខ្យល់ ក៏ធ្លាក់ភ្លៀងជាខ្លាំង ឯអ័ហាប់ទ្រង់ជិះរទេះទៅឯយេសរាល ៤៦ ហើយ
ព្រះហស្តនៃព្រះយេហូវ៉ាបានសណ្ឋិតនៅលើអេលីយ៉ា លោកក៏ក្រវាត់ចង្កេះ រត់ទៅខាងមុខអ័ហាប់
ទៅ រហូតដល់មាត់ទ្វារក្រុងយេសរាល។

41 And Elijah said to Ahab, “Go, eat and drink, for there is the sound of a heavy rain.” 42 So
Ahab went off to eat and drink, but Elijah climbed to the top of Carmel, bent down to the
ground and put his face between his knees.
43 “Go and look toward the sea,” he told his servant. And he went up and looked.
“There is nothing there,” he said.
Seven times Elijah said, “Go back.”
44 The seventh time the servant reported, “A cloud as small as a man’s hand is rising from the
sea.”
So, Elijah said, “Go and tell Ahab, ‘Hitch up your chariot and go down before the rain stops
you.’”
45 Meanwhile, the sky grew black with clouds, the wind rose, a heavy rain started falling and
Ahab rode off to Jezreel. 46 The power of the Lord came on Elijah and, tucking his cloak into
his belt, he ran ahead of Ahab all the way to Jezreel.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

*ភ្លៀងបង្អុរចុះមកសាជាថ្មី*

លោកអេលីយ៉ាបានផ្តល់នូវភស្តុតាងចុងក្រោយថា គឺព្រះជាម្ចាស់ជាអ្នកគ្រប់គ្រងលើធម្មជាតិ មិនមែនព្រះបាលនោះទេ គាត់បានប្រកាសថា គ្រោះរាំងស្ងួតនឹងត្រូវបញ្ចប់។ពេលស្តេចអ័ហាប់បំផាយរទេះសេះរបស់ទ្រង់ ដើម្បីគេចពីខ្យល់ព្យុះ នោះលោកអេលីយ៉ាបានរត់ទៅមុនរទេះសេះរបស់ទ្រង់ទៅទៀតដោយសារតែអំណាចចេស្តារបស់ព្រះជាម្ចាស់។

ពួកព្រះបាលបរិស័ទ ពួកគេបានគិតថា ព្រះបាលរបស់ពួកគេគឺជាព្រះនៃធម្មជាតិ ផលដំណាំផ្សេងៗ តែមិនមែនទេ ព្រះនៃធម្មជាតិពិតប្រាកដនោះគឺជាព្រះយេហ៊ូវ៉ា ជាព្រះនៃពួកអ៊ីស្រាអែល និងមនុស្សគ្រប់ជាត់សាសន៍។ ព្រះអង្គចង់បង្ហាញអោយពួកកូនចៅអ៊ីស្រាអែលដឹងថា ទ្រង់ជាព្រះពិត ហើយត្រូវជឿទុកចិត្តលើទ្រង់ កុំងាកបែទៅស្តាំ ឬឆ្វេងឡើយ។ព្រះជាម្ចាស់អាចបញ្ជាទៅភ្លៀងឬខ្យល់បាន ទ្រង់បានធ្វើអោយកើតរាំងស្ងួត ទ្រង់ក៏អាចធ្វើអោយមានភ្លៀងវិញបានដែរ។

សេចក្តីអធិស្ឋាន

ខែ11 ថ្ងៃសុក្រ 15

# ហោរាអេលីយ៉ានៅលើភ្នំហោរែប

១ពង្សាវតារក្សត្រ 19:1-8

ការអធិស្ឋាន

អានអត្ថបទ

[១] អ័ហាប់ទ្រង់ប្រាប់ដល់យេសិបិល ពីគ្រប់ទាំងការ ដែលអេលីយ៉ាបានធ្វើ ហើយពីការ
ដែលលោកបានសំឡាប់ហោរាទាំងប៉ុន្មានដោយដាវ [២] ដូច្នេះ យេសិបិល ព្រះនាងចាត់
គេឲ្យនាំពាក្យទៅប្រាប់អេលីយ៉ាថា ដល់ស្អែកនេះ ពេលថ្មើរនេះ បើយើងមិនបានធ្វើឲ្យ
ជីវិតឯងបានដូចជាជីវិតនៃអ្នកទាំងនោះទេ នោះសូមឲ្យអស់ទាំងព្រះធ្វើដល់យើង
ដូច្នោះវិញ ហើយលើសទៅទៀតផង [៣] កាលលោកបានជ្រាបដូច្នោះហើយ នោះក៏
ក្រោកឡើងរត់ទៅឲ្យរួចជីវិត បានដល់ទៅបៀរ-សេបា ជាស្រុករបស់ពួកយូដា លោកក៏
ទុកអ្នកបំរើនៅទីនោះ [៤] តែខ្លួនលោកដើរពេញ១ថ្ងៃ ចូលក្នុងទីរហោស្ថាន ទៅអង្គុយនៅ
ក្រោមដើមដង្កោ រួចទូលសូមឲ្យខ្លួនស្លាប់ទៅ ដោយពាក្យថា ល្មមហើយ ឱព្រះយេហូវ៉ា
អើយ សូមយកព្រលឹងទូលបង្គំទៅឥឡូវចុះ ដ្បិតទូលបង្គំមិនវិសេសជាងពួកឰយុកោ
ទូលបង្គំទេ [៥] លោកក៏ប្រះខ្លួនដេកលក់ នៅក្រោមដើមដង្កោនោះទៅ នោះមានទេវតា
មកដាស់លោកប្រាប់ថា ចូរក្រោកឡើងបរិភោគសិន [៦] លោកក្រឡេកមើលទៅឃើញ
នៅក្បាលដំណេក មាននំដុតឆ្អិនទៅលើថ្យូងភ្លើង ហើយមានទឹក១ក្អមផង នោះលោកក៏
បរិភោគនំ និងទឹកនោះ រួចដេកទៅវិញ [៧] ទេវតានៃព្រះយេហូវ៉ាក៏មកដាស់ម្តងទៀតប្រាប់
ថា ចូរក្រោកឡើងបរិភោគទៅ ដ្បិតផ្លូវដែលត្រូវដើរ នោះហួសកំឡាំងឯង
ណាស់ [៨] លោកក៏ក្រោកឡើងបរិភោគទៅ ហើយដោយសារកំឡាំង ដែលបានពីអាហារ
នោះ លោកក៏ដើរទៅអស់៤០ថ្ងៃ៤០យប់ បានដល់ទៅភ្នំហោរែប ជាភ្នំនៃព្រះ។

[1] Now Ahab told Jezebel everything Elijah had done and how he had killed all the
prophets with the sword. [2] So Jezebel sent a messenger to Elijah to say, “May the
gods deal with me, be it ever so severely, if by this time tomorrow I do not make
your life like that of one of them.”
[3] Elijah was afraid and ran for his life. When he came to Beersheba in Judah, he
left his servant there, [4] while he himself went a day’s journey into the wilderness.
He came to a broom bush, sat down under it and prayed that he might die. “I have
had enough, Lord,” he said. “Take my life; I am no better than my
ancestors.” [5] Then he lay down under the bush and fell asleep.
All at once an angel touched him and said, “Get up and eat.” [6] He looked around,
and there by his head was some bread baked over hot coals, and a jar of water. He
ate and drank and then lay down again.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

.................................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

.................................................................................................

.................................................................................................

.................................................................................................

## ការយល់ដឹងអំពីអត្ថបទ

***ហោរាអេលីយ៉ានៅលើភ្នំហោរែប***

យេសិបិលបានឮថា លោកអេលីយ៉ាសម្លាប់ពួកហោរាព្រះបាលអស់ នោះព្រះនាងគំរាមថានឹងសម្លាប់ហោរារបស់ព្រះជាម្ចាស់វិញ។នាងនៅតែមានអំណាចខ្លាំងលើប្រជានុរាស្ត្រ ដែលក្រោយមកបានងាកទៅថ្វាយបង្គំរូបព្រះវិញទោះបើពួកគេបានឃើញជ័យជម្នះរបស់លោកអេលីយ៉ា នៅលើភ្នំកើមែលក៏ដោយ។លោកអេលីយ៉ាបានរត់ទៅលាក់ខ្លួននៅទិសខាងត្បូង តាមតំបន់រហោស្ថាននៃស្រុកយូដា នៅទីនោះលោកអេលីយ៉ាចង់ស្លាប់មែនទែន ដោយសារតែការរងទុក្ខវេទនាពេកទៅ។តែបន្ទាប់មកព្រះបានចម្រើនកំលាំងដល់គាត់ ជួយគាត់អាចបន្តដំណើរឆ្ពោះទៅទិសខាងត្បូង សំដៅទៅភ្នំស៊ីណាយជាកន្លែងព្រះបានធ្វើសម្ព័ន្ធមេត្រីភាពជាមួយអ៊ីស្រាអែល។

សេចក្តីអធិស្ឋាន

ខែ11
ថ្ងៃសៅរ៍ 16

# ព្រះអម្ចាស់ប្រទានឲ្យហោរាអេលីយ៉ាមានសេចក្ដីក្លាហានឡើងវិញ

១ពង្សាវតារក្សត្រ 19:9-21

ការអធិស្ឋាន

អានអត្ថបទ

៩ កាលលោកបានទៅដល់ហើយ នោះក៏ចូលទៅអាស្រ័យក្នុងរអាង១នៅទីនោះ គ្រានោះ ឮព្រះបន្ទូលនៃ
ព្រះយេហូវ៉ាមកសួរថា អេលីយ៉ាអើយ តើធ្វើអីនៅទីនេះ ១០ លោកទូលថា ទូលបង្គំបានមានចិត្តឈឺឆ្អាលនឹង
ព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារជាខ្លាំង ដ្បិតពួកកូនចៅអ៊ីស្រាអែលគេបានបោះបង់ចោលសេចក្ដីសញ្ញា
ទ្រង់ គេបានរំលំអស់ទាំងអាសនារបស់ទ្រង់ ហើយបានសំឡាប់ពួកហោរាទ្រង់ដោយដាវផង នៅសល់តែ
ទូលបង្គំម្នាក់ឯងប៉ុណ្ណោះ ហើយគេរកជីវិតទូលបង្គំថែមទៀត ១១ ទ្រង់មានព្រះបន្ទូលទៅថា ចូរឯងចេញទៅ
ឈរលើភ្នំនៅចំពោះព្រះយេហូវ៉ាចុះ នោះមើល ព្រះយេហូវ៉ាទ្រង់យាងទៅតាមទីនោះ ហើយកើតមានខ្យល់
ព្យុះគំហុកជាខ្លាំង បក់មកប៉ះបំបាក់ភ្នំបំបែកថ្មខ្ទេចខ្ទីនៅចំពោះព្រះយេហូវ៉ា តែព្រះយេហូវ៉ាទ្រង់មិនមែនគង់
នៅក្នុងខ្យល់នោះទេ ក្រោយខ្យល់នោះមក ក៏មានកក្រើកដី តែព្រះយេហូវ៉ាទ្រង់មិនមែនគង់នៅក្នុងការ
កក្រើកដីនោះទេ ១២ បន្ទាប់ពីការកក្រើកដីនោះមក នោះមានភ្លើងឆេះ តែព្រះយេហូវ៉ាទ្រង់មិនមែនគង់នៅ
ក្នុងភ្លើងនោះទេ ក្រោយពីភ្លើងនោះមក មានឮសំឡេងតូចរហៀងៗ ១៣ កាលអេលីយ៉ាបានឮហើយ នោះ
លោកក៏យកក្រមាគ្រលុំមុខ ចេញមកឈរនៅមាត់រអាង នោះមានឮសំឡេងមកដល់លោកថា អេលីយ៉ា
អើយ តើឯងធ្វើអ្វីនៅទីនេះ ១៤ លោកទូលឆ្លើយថា ទូលបង្គំបានមានចិត្តឈឺឆ្អាលនឹងព្រះយេហូវ៉ា ជាព្រះនៃ
ពួកពលបរិវារជាខ្លាំង ដ្បិតពួកកូនចៅអ៊ីស្រាអែល គេបានបោះបង់ចោលសេចក្ដីសញ្ញាទ្រង់ គេបានរំលំអស់
ទាំងអាសនាទ្រង់ ហើយបានសំឡាប់ពួកហោរាទ្រង់ ដោយដាវផង នៅសល់តែទូលបង្គំម្នាក់ឯងប៉ុណ្ណោះ
ហើយគេស្វែងរកជីវិតទូលបង្គំថែមទៀត។
១៥ ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលទៅលោកថា ចូរឯងត្រឡប់ទៅតាមផ្លូវ ដែលកាត់ទីរហោស្ថាន ទៅឯក្រុង
ដាម៉ាសទៅ កាលណាបានដល់ហើយ នោះចូរចាក់ប្រេងតាំងហាសែលឡើង ឲ្យធ្វើជាស្តេចស្រុកស៊ីរី
ចុះ ១៦ ហើយត្រូវចាក់ប្រេង តាំងយេហ៊ូវ ជាកូននីមស៊ីឡើង ឲ្យធ្វើជាស្តេច សោយរាជ្យលើស្រុកអ៊ីស្រាអែល
ដែរ ឯអេលីសេ ជាកូនសាផាត ដែលនៅអេបិល-មហូឡា នោះត្រូវចាក់ប្រេងតាំងឲ្យធ្វើជាហោរាជំនួស
ឯង ១៧ ដូច្នេះ អ្នកណាដែលរួចពីដាវរបស់ហាសែល នោះយេហ៊ូវនឹងសំឡាប់គេវិញ ហើយអ្នកណាដែលរួច
ពីដាវរបស់យេហ៊ូវ នោះអេលីសេនឹងសំឡាប់បង់ ១៨ ប៉ុន្តែ អញនឹងទុកឲ្យមានមនុស្ស៧ពាន់នាក់សល់នៅ
ក្នុងពួកអ៊ីស្រាអែល ជាពួកអ្នកដែលមិនបានលុតជង្គង់ក្រាប នៅចំពោះព្រះបាល ឬថើបវាឡើយ។
លោកអេលីយ៉ាតែងតាំងលោកអេលីសេ ជាព្យាការី
១៩ ដូច្នេះ លោកក៏ចេញពីទីនោះ ទៅរកអេលីសេ ជាកូនសាផាត ឃើញកំពុងតែភ្ជួរ មានគោ១២នឹមភ្ជួរនៅ
ខាងមុខគាត់ គឺគាត់ដែលភ្ជួរដោយនឹមក្រោយបង្អស់ នៅខណៈនោះ អេលីយ៉ាក៏ដើរដំរង់ទៅឯគាត់ ហើយ
បោះក្រមាខ្លួនទៅលើ ២០ គាត់ក៏លះបង់គោចោល រត់ទៅតាមអេលីយ៉ា ដោយពាក្យថា សូមអនុញ្ញាតឲ្យខ្ញុំ
ទៅថើបលាឪពុកម្ដាយខ្ញុំសិន នោះខ្ញុំនឹងមកតាមលោក តែអេលីយ៉ាឆ្លើយតបថា ចូរទៅវិញទៅ តើអញបាន
ធ្វើអ្វីដល់ឯង ២១ ដូច្នេះ គាត់ក៏ត្រឡប់ទៅវិញ យកគោ១នឹមសំឡាប់ទៅ ហើយស្ងោរដោយគ្រឿងប្រដាប់ទឹម
គោ រួចចែកគ្នាបរិភោគទៅ រួចហើយគាត់ក្រោកឡើងទៅតាមអេលីយ៉ា ដើម្បីបំរើលោក។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

....................................................................................................

....................................................................................................

....................................................................................................

## ការយល់ដឹងអំពីអត្ថបទ

### *ព្រះអម្ចាស់ប្រទានឲ្យហោរាអេលីយ៉ាមានសេចក្តីក្លាហានឡើងវិញ*

ប្រជារាស្ត្រអ៊ីស្រាអែលទូទៅបានធ្វើការទាស់នឹងបញ្ញត្តព្រះជាម្ចាស់ ទោះបីជាមានគ្រោះរាំងស្ងួត ព្រមទាំងការអស្ចារ្យដែលព្រះបានធ្វើក្នុងការលុបបំបាត់គ្រោះរាំងស្ងួតនោះក៏ដោយ តែពួកគេនៅតែមិនប្រែចិត្តដដែល។ ព្រះជាម្ចាស់បានសំដែងអោយលោកអេលីយ៉ាឃើញថា ទោះបីជាការដាក់ទណ្ឌកម្ម និងព្រឹត្តិការណ៍ដ៏អស្ចារ្យអាចមានប្រយោជន៍ ប៉ុន្តែគេអាចទទួលបានប្រយោជន៍លុះត្រាតែពេលគេបានឮបន្ទូលព្រះអង្គ ហើយគេឆ្លើយតបតាមព្រះបន្ទូលនោះ។តាមរយៈអំពើអាក្រក់របស់ស្តេចហាសែល ជាសត្រូវនឹងយេហ៊ូវ( យេហ៊ូ ) ជាស្តេចនៃអ៊ីស្រាអែល និងហោរាអេលីសេ គ្រោះរាំងស្ងួត និងការអស្ចារ្យដែលកើតមាននោះ ប្រៀបបាននឹងទណ្ឌកម្មលើអ៊ីស្រាអែល ហើយការនេះនឹងធ្វើអោយមនុស្សមួយចំនួនយកចិត្តទុកដាក់នឹងព្រះបន្ទូល និងនៅស្មោះត្រង់ចំពោះព្រះអង្គ។ ពេលនេះអេលីយ៉ាបានបានត្រឡប់ទៅអ៊ីស្រាអែលវិញដោយការមានទំនុកចិត្តថ្មី។លោកបានបង្ហាញពីបំណងរបស់គាត់ ក្នុងការជំនួសតំណែងលោកអេលីយ៉ា ដោយសម្លាប់សត្វគោបារបស់គាត់ (ដែលជាប្រភពចំណូលរបស់គាត់ )ទៅធ្វើម្ហូបសម្រាប់គ្រួសារ និងមិត្តភក្តិក្នុងពិធីលាគ្នា។

សេចក្តីអធិស្ឋាន

ខែ11
ថ្ងៃអាទិត្យ 17

# ការអធិប្បាយថ្ងៃអាទិត្យ

- ចំណងជើង : ______
- អត្ថបទ : ______
- អ្នកអធិប្បាយ : ______



ពាក្យសម្ដី

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការប្រកបរបស់យើងជាមួយនិងព្រះ



ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

## សេចក្ដីអធិស្ឋាន

ខែ11 ថ្ងៃច័ន្ទ 18

# ស្តេចស្រុកស៊ីរីឡោមព័ទ្ធក្រុងសាម៉ារី

១ពង្សាវតារក្សត្រ 20:1-12

ការអធិស្ឋាន

អានអត្ថបទ

១ គ្រានោះ បេន-ហាដាឌ់ ជាស្តេចស្រុកស៊ីរី ទ្រង់ប្រជុំពួកពលទ័ពរបស់ទ្រង់មក មានស្តេចរង៣២អង្គនៅ
ជាមួយនឹងទ្រង់ ព្រមទាំងសេះ និងរទេះចំបាំងផង ទ្រង់ឡើងទៅឡោមព័ទ្ធច្បាំងនឹងក្រុងសាម៉ារី ២ ក៏
ចាត់រាជទូតទៅក្នុងទីក្រុង ទូលដល់អ័ហាប់ ជាស្តេចអ៊ីស្រាអែលថា បេន-ហាដាឌ់ទ្រង់មានព្រះបន្ទូល
ដូច្នេះថា ៣ មាសប្រាក់របស់ឯងជារបស់ផងអញវិញ ហើយប្រពន្ធកូនទាំងប៉ុន្មានរបស់ឯង ដែលមានរូប
ល្អបំផុត នោះសុទ្ធតែរបស់ផងអញដែរ ៤ ស្តេចអ៊ីស្រាអែលក៏តបទៅថា បពិត្រស្តេចជាម្ចាស់អើយ តាម
ព្រះបន្ទូលទ្រង់ នោះខ្លួនទូលបង្គំ ព្រមទាំងសព្វសារពើដែលទូលបង្គំមាន ក៏ជារបស់ផងទ្រង់ដែរ ៥ រួច
ពួករាជទូតក៏មកម្តងទៀត ទូលថា បេន-ហាដាឌ់ទ្រង់មានព្រះបន្ទូលម្តងហើយថា អញបានចាត់ទូតឲ្យ
មកឯងប្រាប់ថា ត្រូវឲ្យឯងប្រគល់មាស ប្រាក់ និងប្រពន្ធកូនឯងមកអញ ៦ តែដល់ថ្ងៃស្អែកពេលថ្មើរនេះ
នោះអញនឹងចាត់ពួកអញឲ្យមកឯឯង គេនឹងឆែកមើលក្នុងដំណាក់ឯង ហើយក្នុងផ្ទះពួកបំរើឯង ឯរបស់
ណាដែលជាទីគាប់ភ្នែកឯង នោះគេនឹងចាប់កាន់នៅដៃយកទៅ។
៧ ដូច្នេះ ស្តេចអ៊ីស្រាអែលក៏ហៅពួកចាស់ទុំក្នុងស្រុកមក មានព្រះបន្ទូលថា សូមអ្នករាល់គ្នាពិចារណា
មើល ដែលមនុស្សនេះរករឿងហេតុនឹងយើងជាយ៉ាងណា ដ្បិតវាបានចាត់ទូត ឲ្យមកទារយកប្រពន្ធកូន
និងមាសប្រាក់របស់យើងទៅ យើងក៏ឥតមានប្រកែកឡើយ ៨ នោះពួកចាស់ទុំ និងប្រជាជនទាំងឡាយ
ទូលឆ្លើយឡើងថា សូមទ្រង់កុំស្តាប់ ឬព្រមតាមគេឡើយ ៩ ហេតុដូច្នេះទ្រង់ឆ្លើយប្រាប់ទៅពួករាជទូត
របស់បេន-ហាដាឌ់ថា ចូរទៅទូលស្តេចជាម្ចាស់យើងថា គ្រប់ទាំងសេចក្តី ដែលទ្រង់បានចាត់មកបង្គាប់
ឲ្យខ្ញុំធ្វើជាន់មុន នោះខ្ញុំសុខចិត្តធ្វើហើយ តែសេចក្តីក្រោយនេះខ្ញុំមិនអាចនឹងធ្វើបានទេ ពួករាជទូតក៏នាំ
ពាក្យនោះទៅទូលដល់បេន-ហាដាឌ់វិញ ១០ ដូច្នេះ ទ្រង់ចាត់គេឲ្យមកទូលថា បើមានធូលីក្នុងក្រុងសា
ម៉ារីល្មម១កំបង់ដៃ ដល់ពួកអ្នកដែលតាមអញមកគ្រប់គ្នា នោះសូមឲ្យអស់ទាំងព្រះធ្វើដល់អញយ៉ាង
ដូច្នេះ ហើយលើសទៅទៀតផង ១១ រួចស្តេចអ៊ីស្រាអែលមានព្រះបន្ទូលឆ្លើយថា ចូរទៅប្រាប់បេន-ហា
ដាឌ់វិញថា កុំបីឲ្យអ្នកដែលកំពុងតែពាក់គ្រឿងក្រោះអួតអាងខ្លួន ដូចជាអ្នកដែលដោះគ្រឿងចេញនោះ
ឡើយ ១២ បេន-ហាដាឌ់បានឮពាក្យនោះ ក្នុងវេលាកំពុងដែលសោយស្រានៅក្នុងពន្លា ជាមួយនឹងពួក
ស្តេចរង នោះទ្រង់ប្រាប់ដល់ពួកពលទ័ពទ្រង់ថា ចូររៀបចំឡើង គេក៏ដំរៀបគ្នារៀបច្បាំងនឹងទីក្រុង។

1 Now Ben-Hadad king of Aram mustered his entire army. Accompanied by thirty-two
kings with their horses and chariots, he went up and besieged Samaria and attacked
it. 2 He sent messengers into the city to Ahab king of Israel, saying, “This is what Ben-
Hadad says: 3 ‘Your silver and gold are mine, and the best of your wives and children
are mine.’” 4 The king of Israel answered, “Just as you say, my lord the king. I and all I
have are yours.” 5 The messengers came again and said, “This is what Ben-Hadad says:
‘I sent to demand your silver and gold, your wives and your children. 6 But about this
time tomorrow I am going to send my officials to search your palace and the houses of
your officials. They will seize everything you value and carry it away.’” 7 The king of
Israel summoned all the elders of the land and said to them, “See how this man is
looking for trouble! When he sent for my wives and my children, my silver and my
gold, I did not refuse him.”

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

.....................................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

.....................................................................................................

## ការយល់ដឹងអំពីអត្ថបទ

***ស្ដេចស្រុកស៊ីរីឡោមព័ទ្ធក្រុងសាម៉ារី***

ពេលនេះអ័ហាប់ស្ថិតនៅក្នុងភាពគ្រោះថ្នាក់ នៅពេលក្រុមសម្ព័ន្ធមិត្តរបស់ប្រទេសស៊ីរីវាយយកទីក្រុងសាម៉ារី ហើយទាមទារអោយទ្រង់បង់ប្រាក់ជាច្រើន។ ពីដំបូងស្ដេចអ័ហាប់ព្រមចុះចូល ប៉ុន្តែពេលដែលពួកប្រទេសទាំងនោះទាមទារឡើងថ្លៃទៀតនោះ ទ្រង់ប្ដូរចិត្ត ហើយប្រយុទ្ធតបវិញ។តាមការពិតទៅស្ដេចអ័ហាប់គ្មានភាពជាម្ចាស់ការលើខ្លួនឯងឡើយទ្រង់ក៏មានភាពកំសោយក្នុងការសម្រេចចិត្តចុះចូលជាមួយសត្រូវ ឬយ៉ាងណានោះទេ។ទ្រង់បានសុំយោបល់ពីពួកចាស់ទុំនៅក្នុងរាជ្យនគរ ប៉ុន្តែទ្រង់ភ្លេចសួរនាំពីព្រះជាម្ចាស់។តាមពិតទៅស្ដេចអ័ហាប់នេះមានជំនឿលាយឡំ (ជឿលើព្រះជាម្ចាស់ផង និងជឿលើព្រះបាលផង ដែលជាព្រះដែលយេសេបិលមហេសីទ្រង់បាននាំយកមក។

សេចក្ដីអធិស្ឋាន

ខែ11
ថ្ងៃអង្គារ 19

# ស្ដេចអ័ហាប់ទទួលជ័យជំនះ

១ពង្សាវតារក្សត្រ 20:13-21

ការអធិស្ឋាន

អានអត្ថបទ

[១៣] ខណៈនោះ មានហោរាម្នាក់ចូលទៅគាល់អ័ហាប់ ជាស្ដេចអ៊ីស្រាអែល ទូលថា ព្រះយេហូវ៉ា
ទ្រង់មានព្រះបន្ទូលដូច្នេះថា តើឃើញហ្វូងទ័ពធំនេះឬទេ មើល នៅថ្ងៃនេះ អញនឹងប្រគល់គេមក
ក្នុងកណ្ដាប់ដៃឯងហើយ នោះឯងនឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត [១៤] អ័ហាប់មានព្រះ
បន្ទូលសួរថា តើដោយសារអ្នកណា រួចគាត់ទូលឆ្លើយថា ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលដូច្នេះ គឺ
ដោយសារពួកទ័ពរបស់ចៅហ្វាយខែត្រទាំងប៉ុន្មាន ស្ដេចក៏សួរទៀតថា តើអ្នកណាត្រូវនាំទៅបះ
នឹងគេជាមុន គាត់ទូលឆ្លើយថា គឺជាទ្រង់ព្រះករុណា [១៥] ដូច្នេះ ស្ដេចក៏ចេញទៅ ត្រួតមើលពួកទ័ព
របស់ចៅហ្វាយខែត្រទាំងប៉ុន្មាន ឃើញមានគ្នា២៣២នាក់ បន្ទាប់មក ស្ដេចក៏ត្រួតមើលបណ្ដាជន
ជាពួកកូនចៅអ៊ីស្រាអែលទាំងអស់ ឃើញមាន៧ពាន់នាក់។
[១៦] គេក៏ចេញទៅនៅពេលថ្ងៃត្រង់ ឯបេន-ហាដាឌ់ និងពួកស្ដេចរងទាំង៣២អង្គ ដែលមកជួយទ្រង់
គេកំពុងតែសោយស្រាស្រវឹង នៅក្នុងពន្លា [១៧] ហើយពួកពលទ័ពរបស់ចៅហ្វាយខែត្រទាំងប៉ុន្មាន
ក៏នាំមុខចេញទៅ បេន-ហាដាឌ់ក៏ចាត់ម្នាក់ឲ្យទៅក្រៅមើល អ្នកនោះមកទូលដល់ទ្រង់វិញថា មាន
ពួកមនុស្សចេញពីក្រុងសាម៉ារីមកហើយ [១៨] នោះទ្រង់បង្គាប់ថា ទោះបើគេចេញមកដោយមេត្រី ឬ
ដោយចង់ធ្វើសង្គ្រាមក៏ដោយ គង់តែត្រូវចាប់គេមកទាំងរស់ដែរ [១៩] យ៉ាងនោះពួកទ័ពរបស់
ចៅហ្វាយខែត្រទាំងប៉ុន្មាន និងកងទ័ពដែលទៅតាមក្រោយក៏ចេញពីទីក្រុងទៅ [២០] គ្រប់គ្នាក៏សំ
ឡាប់ខ្មាំងសត្រូវដែលតនឹងខ្លួន ដូច្នេះ ពួកស៊ីរីគេបែកខ្ញែករត់ទៅ ហើយពួកអ៊ីស្រាអែលក៏ដេញ
តាមឯបេន-ហាដាឌ់ ជាស្ដេចស្រុកស៊ីរី ទ្រង់ជិះសេះរត់រួចជាមួយនឹងពួកទ័ពសេះ [២១] នេះគឺស្ដេចអ៊ី
ស្រាអែល ទ្រង់ចេញទៅវាយទាំងពួកទ័ពសេះ និងរទេះចំបាំង ប្រហារជីវិតពួកស៊ីរីយ៉ាងសន្ធឹក។
[២២] រួចមក ហោរានោះក៏ចូលទៅឯស្ដេចអ៊ីស្រាអែលទូលថា សូមទ្រង់ទៅចំរើនកំឡាំងឡើង ហើយ
ខំប្រឹងមើលការដែលទ្រង់ធ្វើ ដ្បិតដល់ចូលឆ្នាំថ្មី ស្ដេចស៊ីរីនឹងឡើងមកច្បាំងនឹងទ្រង់ទៀត។

[13] Meanwhile a prophet came to Ahab king of Israel and announced, “This is what
the Lord says: ‘Do you see this vast army? I will give it into your hand today, and then you
will know that I am the Lord.’”[14] “But who will do this?” asked Ahab.The prophet replied,
“This is what the Lord says: ‘The junior officers under the provincial commanders will do
it.’” “And who will start the battle?” he asked. The prophet answered, “You will.”

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

***ស្ដេចអ័ហាប់ទទួលជ័យជំនះ***

មានហោរាម្នាក់បានអះអាងនឹងអ័ហាប់ថា ព្រះជាម្ចាស់នឹងប្រទានជ័យជម្នះអោយអ៊ីស្រាអែល។ស្ដេចអ័ហាប់បានរៀបចំគម្រោងការមួយ ដោយយោងទៅតាមការទស្សន៍ទាយរបស់ហោរានោះគឺទ្រង់អោយពួកទាហានក្មេងៗមួយក្រុមទៅល្បួងពួកស៊ីរី បន្ទាប់មកកងទ័ពរបស់ទ្រង់នឹងវាយប្រហារពួកស៊ីរីមិនអោយតដៃទាន់។ ស្ដេចអ័ហាប់បានទទួលជោគជ័យយ៉ាងត្រចេះត្រចង់ តែទ្រង់ត្រូវបានព្រមានថានឹងមានការវាយប្រហារថ្មី នៅនិទាឃរដូវខាងមុខនេះ។

សេចក្ដីអធិស្ឋាន

ខែ11 ថ្ងៃពុធ 20

# ស្តេចអ័ហាប់ទុកជីវិតអោយស្តេចស៊ីរី

១ពង្សាវតារក្សត្រ 20:22-33

ការអធិស្ឋាន

អានអត្ថបទ

[២២] រួចមក ហោរានោះក៏ចូលទៅឯស្តេចអ៊ីស្រាអែលទូលថា សូមទ្រង់ទៅចំរើនកំឡាំងឡើង ហើយ
ខំប្រឹងមើលការដែលទ្រង់ធ្វើ ដ្បិតដល់ចូលឆ្នាំថ្មី ស្តេចស៊ីរីនឹងឡើងមកច្បាំងនឹងទ្រង់ទៀត។[២៣] ឯ
ពួកជំនិតខាងស្តេចស៊ីរីគេទូលស្តេចរបស់ខ្លួនថា ព្រះរបស់គេជាព្រះនៃភ្នំ បានជាម្តងនេះគេពូកែ
ជាងយើងរាល់គ្នា ដូច្នេះ សូមយើងរាល់គ្នាតនឹងគេនៅស្រុកវាលចុះ នោះប្រាកដជាយើងនឹងបាន
ពូកែជាងគេវិញ [២៤] ហើយត្រូវធ្វើដូច្នេះ គឺត្រូវដកពួកស្តេចទាំងប៉ុន្មានពីចំណែករបស់ទ្រង់ចេញ
ហើយតាំងឲ្យមានមេទ័ពឡើងជំនួសវិញ [២៥] រួចសូមលើកពលទ័ព ឲ្យស្មើនឹងពលទ័ពដែលទើប
នឹងបាត់នោះ គឺចំនួនសេះស្មើគ្នា និងចំនួនរទេះក៏ស្មើគ្នា នោះយើងរាល់គ្នានឹងច្បាំងនឹងគេនៅ
ស្រុកវាល ប្រាកដជាយើងនឹងមានកំឡាំងជាងគេទ្រង់ក៏យល់ព្រមតាមពាក្យគេ ហើយបានធ្វើ
ដូច្នោះ។[២៦] លុះដល់ចូលឆ្នាំថ្មី បេន-ហាដាឌ់ក៏ត្រួតមើលពួកទ័ពស៊ីរី ហើយឡើងទៅដល់ក្រុងអា
ផែក ដើម្បីច្បាំងនឹងពួកអ៊ីស្រាអែល [២៧] ពួកកូនចៅអ៊ីស្រាអែលក៏មានគេត្រួតត្រាមើល ហើយចែក
ស្បៀងអាហារឲ្យដែរ រួចគេចេញទៅទាស់នឹងពួកស៊ីរី ឯពួកកូនចៅអ៊ីស្រាអែល គេបោះទ័ពទល់
មុខនឹងពួកស៊ីរី ដូចជាកូនពពែ២ហ្វូងយ៉ាងតូច តែពួកស៊ីរី គេនៅពេញពាស ក្នុងស្រុកនោះ [២៨] គ្រា
នោះ មានអ្នកសំណប់របស់ព្រះម្នាក់ បានចូលមកទូលដល់ស្តេចអ៊ីស្រាអែលថា ព្រះយេហូវ៉ាទ្រង់
មានព្រះបន្ទូលដូច្នេះ ដោយព្រោះពួកស៊ីរីបាននិយាយថា ព្រះយេហូវ៉ាទ្រង់ជាព្រះនៃភ្នំ មិនមែនជា
ព្រះនៃស្រុកវាលទេ បានជាអញនឹងប្រគល់ហ្វូងទ័ពធំទាំងនេះ មកក្នុងកណ្តាប់ដៃឯង ហើយឯង
នឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត [២៩] គេក៏បោះទ័ពប្រទល់មុខគ្នាអស់៧ថ្ងៃ ដល់ថ្ងៃទី៧ នោះ
គេចូលតយុទ្ធគ្នា ក្នុង១ថ្ងៃនោះឯង ពួកកូនចៅអ៊ីស្រាអែលក៏សំឡាប់ពួកពលថ្មើរជើងរបស់
សាសន៍ស៊ីរីអស់១សែននាក់ [៣០] ឯសំណល់ដែលសល់នៅ គេបានរត់ចូលទៅក្នុងក្រុងអាផែក
ហើយកំផែងក្រុងនោះក៏រលំមក សង្កត់ស្លាប់អស់២មុឺន៧ពាន់នាក់ទៀត ឯបេន-ហាឌាឌ់ទ្រង់រត់
ចូលទៅក្នុងទីក្រុង ពួននៅក្នុងបន្ទប់ខាងក្នុង។[៣១] ពួកជំនិតទ្រង់ទូលថា យើងខ្ញុំបានឮថា អស់ទាំង
ស្តេចនៃពួកអ៊ីស្រាអែល សុទ្ធតែជាស្តេចមានសេចក្តីមេត្តាករុណា ដូច្នេះ សូមយើងរាល់គ្នាស្លៀក
សំពត់ធ្មៃ ហើយដាក់ខ្សែរូតនៅក ចេញទៅគាល់ស្តេចអ៊ីស្រាអែលប្រហែលទ្រង់នឹងទុកជីវិតដល់
ព្រះករុណាទេដឹង [៣២] ដូច្នេះ គេក៏ស្លៀកសំពត់ធ្មៃ ព្រមទាំងដាក់ខ្សែរូតនៅក ចេញទៅគាល់ស្តេចអ៊ីស្រាអែ
លទូលថា បេន-ហាឌាឌ់ជាអ្នកបំរើទ្រង់ទូលថា សូមទុកជីវិតឲ្យទូលបង្គំនៅរស់ផង ស្តេចអ៊ីស្រាអែលទ្រង់សួរ
ថា ដូច្នេះតើលោកនៅរស់នៅឡើយឬ លោកជាបងប្អូននឹងយើងដែរ [៣៣] អ្នកទាំងនោះបានយកពាក្យនោះទុក
ជាផ្ទួលល្អ ក៏ទូលតបភ្លាមថា ហ្នឹងហើយបងប្អូនទ្រង់ រួចទ្រង់ប្រាប់គេថា ចូរទៅនាំលោកមក ដូច្នេះបេន-ហា
ឌាឌ់ក៏ចេញមកគាល់ទ្រង់ ហើយទ្រង់ឲ្យឡើងជិះលើរាជរថជាមួយនឹងទ្រង់។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

***ស្ដេចអ័ហាប់ទុកជីវិតអោយស្ដេចស៊ីរី***

ពួកស៊ីរីបានផ្លាស់ប្ដូរមេបញ្ជាការកងទ័ពខ្លួន ដើម្បីពង្រឹងកម្លាំងទ័ពជាថ្មី។ ពួកគេសង្ឃឹមថានឹងឈ្នះដោយការប្ដូរទិសដៅប្រយុទ្ធ ទៅតំបន់ដែលព្រះរបស់គេមានកម្លាំងមាំមួនជាង។ ប៉ុន្តែអ៊ីស្រាអែលបានទទួលជ័យជម្នះជាថ្មីទៀត ជាការបញ្ជាក់អោយពួកស៊ីរី ដឹងថា ពួកគេយល់ច្រឡំដោយគិតថា អំណាចរបស់ព្រះមានព្រំដែនកំណត់តែនៅតំបន់មួយចំនួនប៉ុណ្ណោះ។ស្ដេចអ័ហាប់ចាប់បានស្ដេចបេនហាដាឌ ជាចំណាប់ខ្មាំង ប៉ុន្តែទ្រង់បានដោះលែងទៅវិញ ដោយព្រោះស្ដេចបេនហាដាឌ សន្យាថា នឹងប្រគល់ទឹកដីដែលទ្រង់ចាប់យកបាននោះមកអោយអ៊ីស្រាអែលវិញ។

សេចក្ដីអធិស្ឋាន

ខែ១១ ថ្ងៃព្រ.ហ 21

# ព្រះយេហូវ៉ាដាក់ទោសស្តេចអ័ហាប់

១ពង្សាវតារក្សត្រ 20:34-43

ការអធិស្ឋាន

អានអត្ថបទ

៣៤ នោះបេន-ហាដាឌ់ទូលទ្រង់ថា  អស់ទាំងទីក្រុងដែលព្រះបិតាទូលបង្គំបានរឹបយកពីព្រះបិតា
ទ្រង់  នោះទូលបង្គំនឹងប្រគល់ថ្វាយទាំងអស់វិញ  ហើយទ្រង់នឹងធ្វើផ្សារសំរាប់ទ្រង់នៅក្រុងដា
ម៉ាសបាន ដូចជាព្រះបិតាទូលបង្គំបានធ្វើនៅក្រុងសាម៉ារីដែរ អ័ហាប់មានព្រះបន្ទូលឆ្លើយថា ឯ
ខ្ញុំៗនឹងឲ្យលោកទៅវិញ ដោយសេចក្តីសញ្ញានេះ ដូច្នេះ ទ្រង់ក៏តាំងសេចក្តីសញ្ញានឹងគ្នារួចលែង
ឲ្យទៅវិញ។ ៣៥ បន្ទាប់មក មានម្នាក់ជាសិស្សពួកហោរា គាត់និយាយទៅគូកន ដោយព្រះបន្ទូល
ព្រះយេហូវ៉ាថា សូមឲ្យវាយខ្ញុំចុះ តែអ្នកនោះមិនព្រមវាយទេ ៣៦ គាត់ក៏ប្រាប់ថា ដោយព្រោះអ្នក
មិនបានស្តាប់តាមព្រះបន្ទូលនៃព្រះយេហូវ៉ានោះមើល  កាលណាអ្នកចេញពីខ្ញុំទៅ  នឹងមានសិង្ហ
មកសំឡាប់អ្នក ដូច្នេះ កាលអ្នកនោះបានចេញពីគាត់ទៅ ក៏មានសិង្ហ១មកប្រទះ ហើយសំឡាប់
ទៅ ៣៧ រួចគាត់ជួបនឹងម្នាក់ទៀត  ប្រាប់ថា  សូមឲ្យអ្នកវាយខ្ញុំចុះ  អ្នកនោះក៏វាយគាត់ឲ្យមាន
របួស ៣៨ នោះហោរាក៏ក្លែងខ្លួន ដោយយកសំពត់ឈ្នួតមកបិទភ្នែក រួចទៅនៅចាំស្តេចយាងមក
តាមផ្លូវ ៣៩ កាលស្តេចទ្រង់យាងមកតាមផ្លូវ នោះគាត់ស្រែកឡើងទូលថា ទូលបង្គំបានចេញទៅ
ឯកណ្តាលទីចំបាំងហើយមើល មានម្នាក់ទៀតបែរមក នាំមនុស្សម្នាក់មកឯទូលបង្គំ ដោយបង្គាប់
ថា ចូររក្សាមនុស្សនេះទុក បើវាបាត់ទៅដោយហេតុណា នោះត្រូវយកជីវិតឯងជំនួសវាវិញ ឬត្រូវ
ឲ្យឯងសងអញជាប្រាក់១ហាប ៤០ តែកាលទូលបង្គំកំពុងតែរវល់នេះផងនោះផង អ្នកនោះក៏បាត់
ទៅ ឯស្តេចអ៊ីស្រាអែល មានព្រះបន្ទូលតបថា ទោសឯងត្រូវដូច្នោះហើយ គឺខ្លួនឯងបានកាត់សេ
ចក្តីនោះស្រាប់ ៤១ គាត់ក៏ប្រញាប់នឹងបកសំពត់ពីភ្នែកចេញ  រួចស្តេចអ៊ីស្រាអែលទ្រង់ស្គាល់ថា
ជាពួកហោរា ៤២ គាត់ក៏ទូលដល់ស្តេចថា ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលដូច្នេះហើយ ថា ដោយ
ព្រោះឯងបានលែងមនុស្ស ឲ្យរួចពីដៃឯង ដែលអញបានកាត់ទោសថា ត្រូវវិនាស នោះត្រូវយក
ជីវិតឯងជំនួសវាវិញ ហើយរាស្ត្រឯងជំនួសរាស្ត្រវា ៤៣ ដូច្នេះ ស្តេចអ៊ីស្រាអែលក៏យាងត្រឡប់ទៅ
ឯដំណាក់នៅក្រុងសាម៉ារីវិញ ដោយអន់អាក់ថ្នាំងថ្នាក់ព្រះទ័យ។

34 "I will return the cities my father took from your father," Ben-Hadad offered. "You may
set up your own market areas in Damascus, as my father did in Samaria."
Ahab said, "On the basis of a treaty I will set you free." So, he made a treaty with him, and
let him go. 35 By the word of the Lord one of the companies of the prophets said to his
companion, "Strike me with your weapon," but he refused.
36 So the prophet said, "Because you have not obeyed the Lord, as soon as you leave me a
lion will kill you." And after the man went away, a lion found him and killed him.
37 The prophet found another man and said, "Strike me, please." So, the man struck him
and wounded him. 38 Then the prophet went and stood by the road waiting for the king. He
disguised himself with his headband down over his eyes.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

.......................................................................................................

.......................................................................................................

.......................................................................................................

## ការយល់ដឹងអំពីអត្ថបទ

***ព្រះយេហូវ៉ាដាក់ទោសស្ដេចអ័ហាប់***

ស្ដេចទាំងពីរក៏បានធ្វើកិច្ចព្រមព្រៀងខាងជំនួញមួយ ដែលខាងអ៊ីស្រាអែលមានប្រៀបខ្លាំងជាង។ ស្ដេចអ័ហាប់មានបំណងពង្រឹងសុវត្ថិភាពអ៊ីស្រាអែលពីការឈ្លានពានរបស់ពួកស៊ីរី នៅក្នុងការធ្វើកិច្ចសហប្រតិបត្តិការនេះ ប៉ុន្តែបើស្ដេចអ័ហាប់ជឿទុកចិត្តលើព្រះយេហូវ៉ា នោះទ្រង់មិនចាំបាច់ធ្វើដូច្នោះទេ ទ្រង់គួរតែរៀនពីបទពិសោធន៍មុនៗ។ មានហោរាក្មេងម្នាក់បានធ្វើប្រស្នាមួយប្រាប់ស្ដេចអ័ហាប់ថា ដោយព្រោះទ្រង់មិនបានកម្ទេចសត្រូវរបស់ទ្រង់ ក្នុងពេលកំពុងមានឱកាសនោះពួកគេនឹងធ្វើអោយអ៊ីស្រាអែលរងទុក្ខជាច្រើននៅពេលក្រោយវិញ។

សេចក្ដីអធិស្ឋាន

ខែ11 ថ្ងៃសុក្រ 22

# ចំការទំពាំងបាយជូររបស់លោកណាបោត

## ១ពង្សាវតារក្សត្រ 21:1-16

ការអធិស្ឋាន

អានអត្ថបទ

១ រីឯណាបោត ជាអ្នកស្រុកយេសរាល គាត់មានចំការទំពាំងបាយជូរ នៅស្រុកយេសរាល ជិតបង្អើយនឹង
ដំណាក់អ័ហាប់ ជាស្តេចនៃក្រុងសាម៉ារី ២ ហើយក្រោយការទាំងនោះមក អ័ហាប់ក៏មានព្រះបន្ទូលនឹងណាបោ
តថា ចូរឲ្យចំការទំពាំងបាយជូររបស់ឯងមកយើងចុះ ដើម្បីឲ្យយើងបានធ្វើច្បារបន្លែ ដ្បិតនៅជិតដំណាក់របស់
យើង យើងនឹងឲ្យចំការ១ល្អជាងដល់ឯង ឬបើឯងចូលចិត្តនឹងប្រាក់ នោះយើងនឹងឲ្យតាមដំឡៃចំការនោះ
វិញ ៣ តែណាបោតទូលតបថា សូមព្រះយេហូវ៉ាទ្រង់ឃាត់ កុំឲ្យទូលបង្គំថ្វាយមរដករបស់ពួកឰយុកោទូលបង្គំ
ដល់ព្រះករុណាឡើយ ៤ អ័ហាប់ក៏ត្រឡប់ទៅឯដំណាក់ទ្រង់វិញ មានព្រះទ័យអន់អាក់ ថ្នាំងថ្នាក់ ដោយព្រោះ
ពាក្យដែលណាបោត ជាអ្នកស្រុកយេសរាល បានទូលដល់ទ្រង់ថា ទូលបង្គំមិនថ្វាយមរដករបស់ពួកឰយុកោ
ទូលបង្គំ ដល់ព្រះករុណាទេ ហើយទ្រង់ក៏ប្រះផ្ទំលើព្រះទែនបន្ទំ បែរព្រះភក្ត្រចេញ មិនព្រមសោយព្រះស្ងោយ
ឡើយ។ ៥ ឯយេសិបិល ជាភរិយាទ្រង់ ក៏មកទូលសួរថា ហេតុអ្វីបានជាព្រួយព្រះទ័យ មិនសោយព្រះស្ងោយ
ដូច្នេះ ៦ ទ្រង់មានព្រះបន្ទូលតបថា គឺពីព្រោះអញបាននិយាយនឹងណាបោត ជាអ្នកស្រុកយេសរាលថា ចូរ
លក់ចំការទំពាំងបាយជូរឯងមកឲ្យយើង ឬបើឯងចូលចិត្ត នោះយើងនឹងឲ្យចំការ១ផ្សេងទៀតប្តូរនឹងចំការនេះ
តែវាឆ្លើយមកថា ទូលបង្គំមិនថ្វាយចំការទូលបង្គំដល់ទ្រង់ទេ ៧ នោះយេសិបិល ជាភរិយា ក៏ទូលថា ឥឡូវនេះ
ទ្រង់សោយរាជ្យនៅនគរអ៊ីស្រាអែលមិនមែនឬ សូមតើនឡើង សោយព្រះស្ងោយទៅ ឲ្យព្រះទ័យបានរីករាយ
សប្បាយចុះ ខ្ញុំម្ចាស់នឹងថ្វាយចំការទំពាំងបាយជូររបស់ណាបោត ជាអ្នកស្រុកយេសរាលដល់ទ្រង់ ៨ នោះព្រះ
នាងក៏ធ្វើសំបុត្រដោយនូវព្រះនាមអ័ហាប់ ហើយប្រថាប់ត្រាផែនដី រួចផ្ញើទៅពួកចាស់ទុំ នឹងពួកអ្នកមាន
ត្រកូលខ្ពស់ ដែលនៅក្នុងទីក្រុង ជាមួយនឹងណាបោត ៩ ក្នុងសំបុត្រនោះ ព្រះនាងបង្គាប់ថា ចូរប្រកាសប្រាប់
ឲ្យមានបុណ្យត្រណម ហើយតាំងណាបោត ឲ្យអង្គុយនៅលើទីដ៏ប្រសើរកណ្តាលពួកជន ១០ រួចនាំមនុស្សខូច
អាក្រក់២នាក់មក ឲ្យឈរនៅមុខវា ដើម្បីធ្វើបន្ទាល់ទាស់នឹងវាថា វាបានប្រមាថដល់ព្រះ ហើយដល់ស្តេចផង
ស្រេចហើយ ចូរនាំវាចេញទៅក្រៅ ចោលនឹងថ្មសំឡាប់ទៅ។ ១១ ពួកមនុស្សនៅក្រុងរបស់គាត់ គឺជាពួកចាស់ទុំ
និងពួកអ្នកមានត្រកូលខ្ពស់ ដែលនៅទីក្រុងជាមួយនឹងគាត់ គេក៏ធ្វើតាមសេចក្តីដែលយេសិបិលបានបង្គាប់
ដូចជាសេចក្តីដែលព្រះនាងបានសរសេរចុះក្នុងសំបុត្រ ផ្ញើទៅគេ ១២ គេក៏ប្រកាសប្រាប់ឲ្យមានបុណ្យត្រណម
ហើយដាក់ណាបោត ឲ្យអង្គុយនៅទីដ៏ប្រសើរកណ្តាលពួកជន ១៣ រួចមានមនុស្សខូចអាក្រក់២នាក់ ចូលមកអង្គុយ
ខាងមុខណាបោត ធ្វើបន្ទាល់ទាស់នឹងគាត់នៅមុខបណ្តាជនថា ណាបោតនេះបានប្រមាថដល់ព្រះ ហើយដល់ស្តេចផង
ដូច្នេះ គេនាំយកគាត់ចេញទៅឯក្រៅទីក្រុង ហើយចោលសំឡាប់នឹងថ្មទៅ ១៤ រួចហើយគេចាត់មនុស្សឲ្យទៅទូលយេសិបិ
ល ឲ្យជ្រាបថា បានចោលសំឡាប់ណាបោតនឹងថ្មហើយ ១៥ កាលយេសិបិលបានឮថា គេបានចោលសំឡាប់ណាបោតនឹង
ថ្មហើយដូច្នោះ នោះព្រះនាងក៏ទូលអ័ហាប់ថា សូមតើនឡើងទៅទទួលយកចំការរបស់ណាបោត ជាអ្នកស្រុកយេសរាល
ដែលវាមិនព្រមលក់ថ្វាយនោះ មកទុកជារបស់ផងទ្រង់វិញចុះ ពីព្រោះណាបោតមិននៅរស់ទៀតទេ គឺវាស្លាប់ហើយ

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

.....................................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

.....................................................................................................

## ការយល់ដឹងអំពីអត្ថបទ

### *ចំការទំពាំងបាយជូររបស់លោកណាបោត*

ព្រឹត្តិការណ៍ដែលកើតឡើងជាបន្តបន្ទាប់នេះបានបង្ហាញថា នយោបាយខាងសាសនា សេដ្ឋកិច្ច និងយោធារបស់ស្ដេចអ័ហាប់ សុទ្ធតែទាស់នឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ការដែលទ្រង់រឹបអូសយកចម្ការទំពាំងបាយជូររបស់លោកណាបោត ក៏បានបង្ហាញដែរថា ទ្រង់ជាស្ដេចដែលមិនប្រកាន់យុត្តិធម៌ទេ។ដំបូងស្ដេចបានសុំទិញដីពីលោកណាបោតដោយត្រង់ៗ។ ប៉ុន្តែលោកណាបោតប្រកែក ពីព្រោះដីនោះជាកេរដូនតា ជាវត្ថុមានតម្លៃបំផុតសម្រាប់ជនជាតិអ៊ីស្រាអែល។ ព្រះនាងយេសិបិលបានរៀបចំគម្រោងការចោទប្រកាន់លោកណាបោត ហើយសម្លាប់គាត់ទៅ។ ពួកប្រជារាស្ដ្រ និងមន្ត្រីនាំគ្នាប្រព្រឹត្តអំពើពុករលួយ គ្មាននរណាម្នាក់ចេញមុខការពារយុត្តិធម៌អោយពលរដ្ឋសាមញ្ញឡើយ។

សេចក្ដីអធិស្ឋាន

ខែ11
ថ្ងៃសៅរ៍ 23

# ព្រះអម្ចាស់ដាក់ទោសស្តេចអ័ហាប់ និងម្ចាស់ក្សត្រីយេសិបិល

១ពង្សាវតារក្សត្រ 21:17-29

ការអធិស្ឋាន

អានអត្ថបទ

១៧ ខណៈនោះ ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់អេលីយ៉ា ជាអ្នកស្រុកធេសប៊ីថា ១៨ ចូរក្រោក
ឡើងចុះទៅជួបនឹងអ័ហាប់ ជាស្តេចអ៊ីស្រាអែល ដែលគង់នៅក្រុងសាម៉ារីទៅ មើល ទ្រង់នៅក្នុងចំ
ការរបស់ណាបោតទ្រង់បានចុះទៅទទួលយកចំការនោះ ទុកជារបស់ផងទ្រង់ ១៩ ដូច្នេះ ឯងត្រូវ
ទូលថា ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលដូច្នេះ តើឯងបានសំឡាប់ ហើយបានទាំងរឹបជាន់យក
របស់ទ្រព្យផងមែនឬ ក៏ត្រូវទូលដូច្នេះទៀតថា ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលដូច្នេះថា នៅកន្លែង
ដែលឆ្កែបានលិទ្ធឈាមរបស់ណាបោត នោះនឹងលិទ្ធឈាមរបស់ឯងដែរ ២០ អ័ហាប់មានព្រះ
បន្ទូលតបថា ឱខ្មាំងសត្រូវយើងអើយ តើឯងមកតាមយើងទាន់ហើយឬ លោកទូលឆ្លើយថា ទាន់
ហើយ ពីព្រោះព្រះករុណាបានលក់ព្រះអង្គទ្រង់ ឲ្យធ្វើអំពើដ៏លាមកអាក្រក់នៅព្រះនេត្រព្រះយេ
ហូវ៉ា ២១ មើល អញនឹងនាំសេចក្តីវេទនាមកលើឯង អញនឹងបោសឯងចេញអស់រលីង ហើយនឹង
កាត់អស់ទាំងកូនប្រុសៗពីអ័ហាប់ចេញ ព្រមទាំងអ្នកបិទបាំងទុក និងអ្នកដែលឥតមានចំណង ក្នុង
ពួកអ៊ីស្រាអែលផង ២២ អញនឹងធ្វើឲ្យជំនួរវង្សរបស់ឯងបានដូចជាជំនួរវង្សរបស់យេរ៉ូបោម ជាកូន
នេបាត ហើយដូចជាជំនួរវង្សរបស់បាសា ជាកូនអ័ហ៊ីយ៉ា ដោយព្រោះការប្រទាំង ដែលឯងបានធ្វើ
ឲ្យអញបានក្តាញ់ក្នុងព្រះទ័យ ហើយបានបណ្តាលឲ្យពួកអ៊ីស្រាអែលធ្វើបាបដែរ ២៣ ព្រះយេហូវ៉ា
ក៏មានព្រះបន្ទូលពីដំណើរយេសិបិលដែរថា ឆ្កែនឹងទំពាស៊ីយេសិបិល នៅជិតកំផែងក្រុងយេ
សរាល ២៤ អ្នកណាក្នុងពូជពង្សអ័ហាប់ ដែលស្លាប់នៅក្នុងទីក្រុង នោះឆ្កែនឹងទំពាស៊ី ហើយអ្នក
ណាដែលស្លាប់នៅទីវាល នោះសត្វហើរលើអាកាសនឹងចឹកស៊ីវិញ ២៥ រីឯអ័ហាប់ គ្មានអ្នកណាមួយឲ្យ
ដូចទ្រង់ ដែលបានលក់ខ្លួនឲ្យធ្វើអំពើដ៏លាមកអាក្រក់នៅព្រះនេត្រព្រះយេហូវ៉ា ដែលយេសិបិល ជាភរិយា
បានញុះញង់នោះទេ ២៦ ទ្រង់បានប្រព្រឹត្តបែបគួរស្អប់ខ្ពើមណាស់ ដោយគោរពប្រតិបត្តិតាមអស់ទាំងរូបព្រះ
តាមគ្រប់ទាំងទំនៀមរបស់សាសន៍អាម៉ូរី ដែលព្រះយេហូវ៉ាទ្រង់បានបណ្តេញ ពីមុខពួកកូនចៅអ៊ីស្រាអែលចេ
ញ។ ២៧ កាលអ័ហាប់បានឮពាក្យទាំងនោះហើយ នោះទ្រង់ក៏ហែកព្រះពស្ត្រទ្រង់ រួចស្លៀកសំពត់ធ្មៃវិញ
ហើយតមព្រះស្ងោយ ទ្រង់ផ្ទំទាំងសំពត់ធ្មៃនោះ ហើយក៏យាងមួយៗ ២៨ នោះព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មក
ដល់អេលីយ៉ា ជាអ្នកស្រុកធេសប៊ីថា ២៩ ឯងបានឃើញឬទេ អ័ហាប់បន្ទាបខ្លួននៅមុខអញហើយ ដូច្នេះ
ដោយព្រោះបានបន្ទាបខ្លួននៅមុខអញ នោះអញមិននាំសេចក្តីវេទនានោះ មកក្នុងគ្រាព្រះជន្មទ្រង់ទេ គឺអញ
នឹងនាំសេចក្តីវេទនានោះ មកលើជំនួរវង្សទ្រង់គ្រានៃបុត្រទ្រង់វិញ។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

### ការយល់ដឹងអំពីអត្ថបទ

***ព្រះអម្ចាស់ដាក់ទោសស្តេចអ័ហាប់ និងម្ចាស់ក្សត្រីយេសិបិល***

អ័ហាប់បានរឹបអូសយកចម្ការទំពាំងបាយជូរ នោះហោរាអេលីយ៉ាបានជួបជាមួយនឹងទ្រង់។ ហោរាអេលីយ៉ាបានប្រកាសពីការជំនុំជម្រះលើរូបទ្រង់ ជាពិសេសលើមហេសីរបស់ទ្រង់ដែលជាឃាតករសម្លាប់ណាបោត។ ស្តេចអ័ហាប់ និងមហេសីទ្រង់ បានធ្វើអោយអ៊ីស្រាអែលវិនាសជារៀងរហូត។ បុត្រាពីរអង្គរបស់ទ្រង់នឹងឡើងសោយរាជ្យ ប៉ុន្តែរាជវង្សរបស់ស្តេចអំរីនឹងត្រូវបញ្ចប់។

សេចក្តីអធិស្ឋាន

ខែ11
ថ្ងៃអាទិត្យ 24

# ការអធិប្បាយថ្ងៃអាទិត្យ

- ចំណងជើង : ____________________
- អត្ថបទ : ____________________
- អ្នកអធិប្បាយ : ____________________



ពាក្យសម្ដី

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការប្រកបរបស់យើងជាមួយនិងព្រះ



ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

## សេចក្ដីអធិស្ឋាន

ខែ11 ថ្ងៃច័ន្ទ 25

# ស្ដេចអ័ហាប់ និងស្ដេចយ៉ូសាផាត លើកទ័ពចេញទៅច្បាំងជាមួយស្រុកស៊ីរី

## ១ពង្សាវតារក្សត្រ 22:1-12

ការអធិស្ឋាន

អានអត្ថបទ

[១] ក្នុងរវាង៣ឆ្នាំនោះ សាសន៍ស៊ីរី និងសាសន៍អ៊ីស្រាអែល ឥតមានចំបាំងនឹងគ្នាឡើយ [២] តែដល់
ឆ្នាំទី៣នោះយ៉ូសាផាត ជាស្ដេចយូដា ទ្រង់យាងចុះមកគាល់ស្ដេចអ៊ីស្រាអែល [៣] ហើយស្ដេចអ៊ី
ស្រាអែលទ្រង់មានព្រះបន្ទូលនឹងពួកជំនិតទ្រង់ថា អ្នករាល់គ្នាដឹងហើយថា ក្រុងរ៉ាម៉ូត-កាឡាតជា
របស់ផងយើង ចុះហេតុអ្វីបានជាយើងនៅតែស្ងៀម ឥតទៅចាប់យកពីកណ្ដាប់ដៃស្ដេចស៊ីរីមក
វិញដូច្នេះ [៤] រួចទ្រង់ទូលសួរយ៉ូសាផាតថា តើទ្រង់នឹងទៅច្បាំងនឹងក្រុងរ៉ាម៉ូត-កាឡាត ជាមួយនឹង
ទូលបង្គំឬទេ យ៉ូសាផាតទូលឆ្លើយថា ទូលបង្គំក៏ដូចជាទ្រង់ រាស្ត្ររបស់ទូលបង្គំក៏ដូចជារាស្ត្រ
របស់ទ្រង់ ហើយសេះរបស់ទូលបង្គំទាំងប៉ុន្មាន ក៏ដូចជាសេះរបស់ទ្រង់ដែរ។
[៥] តែយ៉ូសាផាតទូលដល់ស្ដេចអ៊ីស្រាអែលថា សូមទ្រង់ទូលសួរព្រះបន្ទូលនៃព្រះយេហូវ៉ាជាមុន
សិន [៦] ដូច្នេះ ស្ដេចអ៊ីស្រាអែលក៏ប្រមូលពួកហោរាប្រហែលជា៤០០នាក់មកសួរថា តើត្រូវឲ្យ
យើងចេញទៅ ច្បាំងនឹងរ៉ាម៉ូត-កាឡាត ឬឈប់ខាន គេទូលឆ្លើយថា សូមយាងឡើងទៅចុះ ដ្បិត
ព្រះអម្ចាស់ទ្រង់នឹងប្រគល់គេ មកក្នុងកណ្ដាប់ព្រះហស្តនៃព្រះករុណាហើយ [៧] តែយ៉ូសាផាតសួរ
ថា នៅទីនេះ តើគ្មានហោរាណាម្នាក់របស់ព្រះយេហូវ៉ា ល្មមឲ្យយើងសួរគាត់ដែរទេឬ [៨] ស្ដេចអ៊ី
ស្រាអែលទូលឆ្លើយថា មានម្នាក់ទៀត ដែលល្មមឲ្យយើងទូលសួរដល់ព្រះយេហូវ៉ាបាន គឺឈ្មោះ
មីកាយ៉ា ជាកូនយីមឡា តែទូលបង្គំស្អប់វា ដ្បិតវាមិនដែលទាយល្អពីទូលបង្គំសោះ គឺចេះតែទាយ
អាក្រក់វិញ យ៉ូសាផាតទូលថា សូមទ្រង់កុំមានព្រះបន្ទូលដូច្នេះឡើយ។
[៩] នោះស្ដេចអ៊ីស្រាអែល ទ្រង់ហៅមហាតលិកម្នាក់បង្គាប់ថា ចូរទៅនាំមីកាយ៉ា ជាកូនយីមឡា មក
នេះជាឆាប់ៗ [១០] ឯស្ដេចអ៊ីស្រាអែល និងយ៉ូសាផាត ជាស្ដេចស្រុកយូដា ទ្រង់ព្រះពស្ត្រាជ្យគង់
លើបល្ល័ង្ករៀងអង្គ ត្រង់ទីធ្លា នៅទ្វារក្រុងសាម៉ារី ហើយពួកហោរាក៏ឈរទាយ នៅចំពោះ
ទ្រង់ [១១] ឯសេដេគា ជាកូនក្នាណា គាត់បានធ្វើស្នែងដែក ហើយក៏ទូលថា ព្រះយេហូវ៉ាទ្រង់មាន
ព្រះបន្ទូលដូច្នេះ ព្រះករុណានឹងជល់ពួកស៊ីរីដោយស្នែងនេះ ដរាបដល់វិនាសសូន្យទៅ [១២] ហើយ
ពួកហោរាទាំងអស់ក៏ទាយដូច្នោះដែរថា សូមយាងឡើងទៅឯរ៉ាម៉ូត-កាឡាត ហើយមានជ័យជំនះ
ចុះ ដ្បិតព្រះយេហូវ៉ាទ្រង់នឹងប្រគល់ក្រុងនោះ មកក្នុងកណ្ដាប់ព្រះហស្តនៃព្រះករុណាហើយ។

[1]For three years there was no war between Aram and Israel. [2] But in the third year
Jehoshaphat king of Judah went down to see the king of Israel. [3] The king of Israel had said
to his officials, “Don’t you know that Ramoth Gilead belongs to us and yet we are doing
nothing to retake it from the king of Aram?”
[4] So he asked Jehoshaphat, “Will you go with me to fight against Ramoth Gilead?”

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

***ស្ដេចអ័ហាប់ និងស្ដេចយ៉ូសាផាតលើកទ័ពចេញទៅច្បាំងជាមួយស្រុកស៊ីរី***

អ័ហាប់បានកាត់ផ្ដាច់កិច្ចព្រមព្រៀងសន្តិភាព ជាមួយស្ដេចបេន-ហាដាឌ នៃប្រទេសស៊ីរី ក្រោយពីចុះកិច្ចព្រមព្រៀងបានបីឆ្នាំមក។ ទ្រង់សម្លឹងឃើញឱកាសដែលអាចយកទីក្រុងមួយនៅទល់ដែនឈ្មោះរ៉ាម៉ូត-កាឡាត ហើយបញ្ចុះបញ្ចូលអោយស្ដេចយ៉ូសាផាតជួយទ្រង់ក្នុងរឿងនេះ។ (ស្ដេចយ៉ូសាផាតធ្វើសម្ព័ន្ធមិត្តជាមួយនឹងស្ដេចអ័ហាប់ ដោយអោយរាជបុត្ររបស់ទ្រង់នាមយ៉ូរ៉ាម អភិសេកនឹងបុត្រីស្ដេចអ័ហាប់នាមនាងអ័ថាលា។ពួកហោរាក្នុងរាជវាំងបានព្យាយាមធ្វើអោយស្ដេចអ័ហាប់សប្បាយចិត្ត ជាជាងប្រាប់ទ្រង់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ស្ដេចយ៉ូសាផាតមិនសព្វព្រះទ័យនឹងពួកគេទេ រួចសុំអោយស្ដេចអ័ហាប់បញ្ជូនហោរាថ្មីម្នាក់ទៀតឈ្មោះមីកាយ៉ា(មីកា)។

សេចក្ដីអធិស្ឋាន

ខែ11
ថ្ងៃអង្គារ 26

# ហោរាមីកាយ៉ាប្រកាសប្រាប់ពីបរាជ័យ

១ពង្សាវតារក្សត្រ 22:13-23

ការអធិស្ឋាន

អានអត្ថបទ

១៣ រីឯអ្នកដែលទៅហៅមីកាយ៉ាមក ក៏ប្រាប់គាត់ថា មើល ពួកហោរាទាំងអស់ សុទ្ធតែទាយល្អដល់
ស្តេចព្រមគ្នា ដូច្នេះ សូមឲ្យពាក្យលោកបានដូចជាពាក្យរបស់ហោរាទាំងនោះដែរ ដោយពោលតែ
សេចក្តីល្អចុះ ១៤ តែមីកាយ៉ាឆ្លើយថា ខ្ញុំស្បថដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់ថា សេចក្តី
ណាដែលព្រះយេហូវ៉ាមានព្រះបន្ទូលមកខ្ញុំ នោះខ្ញុំនឹងបញ្ចេញតាមសេចក្តីនោះ ១៥ រួចកាលបាន
ចូលទៅគាល់ស្តេចហើយ នោះទ្រង់មានព្រះបន្ទូលសួរថា មីកាយ៉ាអើយ តើត្រូវឲ្យយើងទៅច្បាំង
នឹងរ៉ាម៉ូត-កាឡាត ឬឈប់ខាន គាត់ទូលឡកថា សូមយាងទៅ ហើយមានជ័យជំនះចុះ ដ្បិតព្រះ
យេហូវ៉ាទ្រង់នឹងប្រគល់គេមកក្នុងកណ្តាប់ព្រះហស្តនៃព្រះករុណាហើយ ១៦ ដូច្នេះ ស្តេចទ្រង់មាន
ព្រះបន្ទូលថា អញបានស្តីឯងប៉ុន្មានដងហើយ ឲ្យនិយាយតែសេចក្តីពិតប៉ុណ្ណោះ ដោយនូវព្រះ
នាមព្រះយេហូវ៉ា ១៧ គាត់ទូលឆ្លើយថា ទូលបង្គំបានឃើញពួកអ៊ីស្រាអែលត្រូវខ្ចាត់ខ្ចាយនៅលើភ្នំ
ប្រៀបដូចជាហ្វូងចៀមដែលគ្មានអ្នកគង្វាល ហើយព្រះយេហូវ៉ាបានមានព្រះបន្ទូលថា ពួកទាំង
នេះគ្មានចៅហ្វាយទេ ចូរឲ្យគេត្រឡប់ទៅផ្ទះរៀងខ្លួនវិញ ដោយសេចក្តីសុខចុះ ១៨ ដូច្នេះ ស្តេចអ៊ី
ស្រាអែលទ្រង់ទូលទៅយ៉ូសាផាតថា តើទូលបង្គំមិនបានទូលទ្រង់ទេឬអី ថាវាមិនដែលទាយល្អពី
ទូលបង្គំទេ គឺទាយតែអាក្រក់ប៉ុណ្ណោះ ១៩ នោះមីកាយ៉ាទូលថា ដូច្នេះ សូមស្តាប់ព្រះបន្ទូលនៃព្រះ
យេហូវ៉ាសិន ទូលបង្គំបានឃើញព្រះយេហូវ៉ា ទ្រង់គង់លើបល្ល័ង្ក មានទាំងពួកពលបរិវារនៃស្ថាន
សួគ៌ទាំងអស់ ឈរអមអង្គ ទាំងខាងស្តាំ និងខាងឆ្វេង ២០ ហើយព្រះយេហូវ៉ា ទ្រង់មានព្រះបន្ទូល
ថា តើអ្នកណានឹងទៅបបួលអ័ហាប់ ឲ្យឡើងទៅច្បាំង ហើយដួលស្លាប់នៅត្រង់រ៉ាម៉ូត-កាឡាត
ម្នាក់ក៏ថាយ៉ាងនេះ ម្នាក់ក៏ថាយ៉ាងនោះ ២១ រួចមានវិញ្ញាណ១ចេញមកឈរនៅចំពោះព្រះយេហូវ៉ាទូល
ថា ទូលបង្គំចង់ទៅ ២២ ដូច្នេះ ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលសួរថា នឹងធ្វើយ៉ាងណាទៅ វិញ្ញាណនោះទូល
ថា ទូលបង្គំនឹងចេញទៅធ្វើជាវិញ្ញាណភូតកុហក នៅក្នុងមាត់នៃពួកហោរាទាំងប៉ុន្មានរបស់ស្តេច ព្រះយេហូ
វ៉ាទ្រង់មានព្រះបន្ទូលថា ចូរចេញទៅធ្វើដូច្នោះចុះ ឯងនឹងបបួលវាឲ្យសំរេចបាន ២៣ ដូច្នេះមើល ឥឡូវនេះ
ព្រះយេហូវ៉ាទ្រង់ដាក់វិញ្ញាណភូតកុហកនៅក្នុងមាត់នៃពួកហោរារបស់ព្រះករុណាទាំងនេះ ហើយព្រះយេហូ
វ៉ាបានមានព្រះបន្ទូលពីសេចក្តីអន្តរាយ ដែលនឹងកើតដល់ព្រះករុណាវិញ។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

*ហោរាមីកាយ៉ាប្រកាសប្រាប់ពីបរាជ័យ*

អ្នកនាំដំណឹងបានព្រមានដល់លោកមីកាយ៉ាថា ត្រូវយល់ស្របជាមួយនឹងពួកហោរាទាំងអស់ ហេតុដូច្នេះ លោកមីកា ក៏និយាយតាមអ្វីដែលពួកគេបានប្រាប់។ហើយស្តេចអ័ហាប់ក៏បានដឹងថា លោកមីកា និយាយមិនពិតដែរ។ បន្ទាប់មក មីកាក៏បានប្រកាសការពិតយ៉ាងចំហរថា ពួកហោរាទាំងនេះបាននិយាយពាក្យកុហក ហើយគាត់ប្រាប់ទៀតថា អ៊ីស្រាអែលនឹងបរាជ័យ។

សេចក្តីអធិស្ឋាន

ខែ11 ថ្ងៃពុធ 27

# ហោរាមីកាយ៉ាប្រកាសប្រាប់ពីបរាជ័យ

១ពង្សាវតារក្សត្រ 22:24-40

ការអធិស្ឋាន

អានអត្ថបទ

២៤ លំដាប់នោះសេដេគាជាកូនក្នាណា ក៏ចូលទៅទះកំផ្លៀងមីកាយ៉ាសួរថា ព្រះវិញ្ញាណនៃព្រះយេហូវ៉ាបាន
ចេញពីអញ ទៅមានព្រះបន្ទូលនឹងឯងតាមណា ២៥ មីកាយ៉ាឆ្លើយថា ចាំមើល នៅថ្ងៃនោះឯងនឹងបានឃើញ
ក្នុងកាលដែលឯងរត់ទៅពួននៅក្នុងបន្ទប់ខាងក្នុង ២៦ ស្តេចអ៊ីស្រាអែលទ្រង់បង្គាប់ថា ចូរនាំយកមីកាយ៉ាត្រ
ឡប់ទៅឯអាំម៉ូន ជាចៅហ្វាយទីក្រុង និងយ៉ូអាស ជាព្រះរាជបុត្រទៅ ២៧ ហើយបង្គាប់ថា ស្តេចទ្រង់មានព្រះ
បន្ទូលដូច្នេះ គឺឲ្យដាក់មនុស្សនេះក្នុងគុក ចិញ្ចឹមដោយនំបុ័ងនឹងទឹកដ៏វេទនា ដរាបដល់អញមកវិញដោយសុខ
សាន្ត ២៨ នោះមីកាយ៉ាទូលថា បើសិនជាទ្រង់ដែលយាងមកវិញ ដោយសុខសាន្ត នោះគឺព្រះយេហូវ៉ាមិនបាន
មានព្រះបន្ទូល ដោយសារទូលបង្គំទេ រួចគាត់ថែមពាក្យនេះថា ឱជនទាំងឡាយអើយ ចូរស្តាប់ចុះ។
២៩ ដូច្នេះ ស្តេចអ៊ីស្រាអែល និងយ៉ូសាផាត ជាស្តេចយូដា ក៏ឡើងទៅឯក្រុងរ៉ាម៉ូត-កាឡាត ៣០ ស្តេចអ៊ីស្រាអែ
លទ្រង់ទូលទៅយ៉ូសាផាតថា ទូលបង្គំនឹងក្លែងខ្លួនចូលទៅច្បាំង តែព្រះអង្គ សូមឲ្យទ្រង់គ្រឿងព្រះពស្ត្ររាជ្យ
របស់ទ្រង់វិញ ស្តេចអ៊ីស្រាអែលក៏ក្លែងខ្លួនចូលទៅច្បាំងនឹងគេ ៣១ រីឯខាងស្តេចស៊ីរី បានបង្គាប់ដល់ពួកមេទ័ព
រទេះចំបាំងទ្រង់ទាំង៣២នាក់ថា កុំឲ្យតនឹងអ្នកណា ទោះតូចឬធំក្តី ចូរតតែនឹងស្តេចអ៊ីស្រាអែល១
ប៉ុណ្ណោះ ៣២ ដូច្នេះ កាលពួកមេទ័ពទាំងនោះបានឃើញយ៉ូសាផាត គេក៏បែរទៅបំរុងតនឹងទ្រង់ ដោយស្មានថា
នេះប្រាកដជាស្តេចអ៊ីស្រាអែលហើយ តែយ៉ូសាផាតទ្រង់ស្រែកឡើង ៣៣ កាលពួកមេទ័ពឃើញថា មិនមែន
ជាស្តេចអ៊ីស្រាអែលទេ នោះក៏លែងតាមតទៅ ៣៤ តែមានមនុស្សម្នាក់យឹតធ្នូ បាញ់ព្រាវទៅ ត្រូវស្តេចអ៊ីស្រាអែ
ល ត្រង់ប្រឡោះអាវក្រោះទ្រង់ ដូច្នេះ ទ្រង់មានព្រះបន្ទូលបង្គាប់ ដល់អ្នកបរព្រះរាជរថទ្រង់ថា ចូរញាក់បង្វៀរ
ត្រឡប់រថ នាំយើងចេញពីពលទ័ពទៅ ដ្បិតយើងមានរបួសជាទំងន់ ៣៥ នៅថ្ងៃនោះ ចំបាំងក៏កាន់តែខ្លាំងឡើង
តែគេគ្រាហ៍គាំស្តេចនៅក្នុងព្រះរាជរថ ដើម្បីតស៊ូនឹងពួកស៊ីរី លុះដល់ពេលល្ងាច ទ្រង់សុគតទៅ ហើយឈាម
ពីរបួសនោះក៏ហូរទៅក្នុងបាតព្រះរាជរថ ៣៦ រួចដល់ពេលថ្ងៃលិច នោះក៏មានឮសំរែក នៅពេញក្នុងពួកទ័ពថា
ចូរគ្រប់គ្នាត្រឡប់ទៅឯទីក្រុង និងស្រុករបស់ខ្លួនវិញទៅ។
៣៧ គឺយ៉ាងនោះដែលស្តេចទ្រង់សុគត ហើយគេក៏នាំសពទ្រង់មកវិញ បញ្ចុះនៅក្នុងក្រុងសាម៉ារី ៣៨ គេលាង
ព្រះរាជរថនៅត្រង់ស្រះទឹកនៃក្រុងសាម៉ារី ហើយមានឆ្កែលិទ្ធឈាម (រីឯនៅទីនោះពួកស្រីសំផឹងតែងងូត
ទឹក) តាមសេចក្តីដែលព្រះយេហូវ៉ាបានមានព្រះបន្ទូលទុក ៣៩ ឯដំណើររឿងទៀតពីអ័ហាប់ និងការទាំងប៉ុន្មាន
ដែលទ្រង់ធ្វើ ព្រមទាំងដំណាក់ភ្លុកដែលទ្រង់បានធ្វើ និងអស់ទាំងទីក្រុងដែលទ្រង់បានសង់ នោះសុទ្ធតែបាន
កត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចអ៊ីស្រាអែលហើយ ៤០ គឺយ៉ាងនោះ ដែលអ័ហាប់បានផ្ទំលក់
ទៅ ជាមួយនឹងពួកឰយុកោទ្រង់ រួចអ័ហាស៊ីយ៉ា ជាព្រះរាជបុត្រា ក៏ឡើងសោយរាជ្យជំនួសបិតា។

24 Then Zedekiah son of Kenaanah went up and slapped Micaiah in the face. “Which way
did the spirit from the Lord go when he went from me to speak to you?” he asked.
25 Micaiah replied, “You will find out on the day you go to hide in an inner room.”
26 The king of Israel then ordered, “Take Micaiah and send him back to Amon the ruler of
the city and to Joash the king’s son 27 and say, ‘This is what the king says: Put this fellow in
prison and give him nothing but bread and water until I return safely.’”

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

### *ហោរាមីកាយ៉ាប្រកាសប្រាប់ពីបរាជ័យ*

នៅពេលមានហោរាម្នាក់ប្រឆាំងនឹងអ្វីដែលលោកមីកាបានទស្សន៍ទាយនោះ លោកប្រាប់ហោរានោះថា លោកគួរតែចំណាយពេលស្វែងរកបំណងព្រះហឫទ័យរបស់ព្រះជាជាងការខំព្យាយាមធ្វើអោយស្តេចសប្បាយចិត្ត។ ពាក្យសំដីនេះបានធ្វើអោយស្តេចចាប់លោកមីកាយ៉ាយកទៅដាក់គុក។ ស្តេចអ័ហាប់មិនបានស្តាប់ពាក្យសំដីរបស់លោកមីកាទេ ហើយកចេញទៅច្បាំងជាមួយពួកស៊ីរីដោយល្ងិតល្ងង់។ ស្តេចបានខំប្រឹងរត់គេចចេញពីសេចក្តីស្លាប់ក្នុងសមរភូមិ ដោយក្លែងខ្លួនធ្វើជាកូនទាហានម្នាក់ ប៉ុន្តែវាគ្មានប្រយោជន៍អ្វីសោះ។

សេចក្តីអធិស្ឋាន

ខែ11
ថ្ងៃព្រ.ហ 28

# ស្ដេចយ៉ូសាផាតសោយរាជ្យនៅស្រុកយូដា

១ពង្សាវតារក្សត្រ 22:41-53

ការអធិស្ឋាន

អានអត្ថបទ

៤១ រីឯនៅឆ្នាំទី៤ ក្នុងរាជ្យអ័ហាប់ ស្ដេចអ៊ីស្រាអែល នោះយ៉ូសាផាត ជាកូនអេសា ក៏ចាប់តាំង
សោយរាជ្យឡើងលើស្រុកយូដា ៤២ កាលយ៉ូសាផាតចាប់តាំងសោយរាជ្យ នោះទ្រង់មានព្រះជន្ម
៣៥ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុងយេរូសាឡិមបាន២៥ឆ្នាំ ព្រះមាតាទ្រង់ព្រះនាមជាអ័ស៊ូបា
បុត្រីស៊ីលហ៊ី ៤៣ ទ្រង់ក៏ដើរតាមគ្រប់ទាំងផ្លូវរបស់អេសា ជាព្រះបិតាទ្រង់ ឥតងាកបែរចេញឡើយ
គឺបានប្រព្រឹត្តសេចក្ដីដែលត្រឹមត្រូវនៅព្រះនេត្រព្រះយេហូវ៉ា ប៉ុន្តែមិនបានបំបាត់អស់ទាំងទីខ្ពស់
ចេញទេ ពួកបណ្តាជនគេនៅតែថ្វាយយញ្ញបូជា ហើយដុតកំញានៅលើទីខ្ពស់ទាំងនោះនៅ
ឡើយ ៤៤ យ៉ូសាផាតទ្រង់ក៏បានចងស្ពានមេត្រីនឹងស្ដេចអ៊ីស្រាអែលដែរ។
៤៥ រីឯដំណើរឯទៀតពីយ៉ូសាផាត និងអំណាចដែលទ្រង់បានសំដែង ហើយពីការសង្គ្រាមរបស់
ទ្រង់ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្ដេចយូដាហើយ ៤៦ ឯសំណល់
ពួកកូនជឹង ដែលនៅសល់ ពីក្នុងរាជ្យអេសា ជាព្រះបិតា នោះទ្រង់ក៏បណ្តេញគេចេញពីស្រុក
ទៅ ៤៧ គ្រានោះ នៅស្រុកអេដំមគ្មានស្ដេចទេ មានតែអ្នកតំណាងរាជការ ដែលកាន់កាប់ត្រួតត្រា
ប៉ុណ្ណោះ ៤៨ យ៉ូសាផាតក៏បានធ្វើក្រុមនាវាតើស៊ីស ដើម្បីនឹងទៅយកមាសពីស្រុកអូភារមក តែ
នាវាទាំងនោះមិនបានចេញទៅទេ ពីព្រោះត្រូវបាក់បែកទាំងអស់ នៅត្រង់ក្រុងអេស៊ាន-គេប៊េរ
វិញ ៤៩ គ្រានោះ អ័ហាស៊ីយ៉ា ជាបុត្រអ័ហាប់ ក៏ទូលដល់យ៉ូសាផាតថា សូមឲ្យពួកបំរើទូលបង្គំ
បានចុះនាវាទៅជាមួយនឹងពួកបំរើទ្រង់ផង តែយ៉ូសាផាតទ្រង់មិនព្រមទេ ៥០ រួចមកយ៉ូសាផាតក៏ផ្ទំ
លក់ទៅជាមួយនឹងពួកឰយុកោទ្រង់ទៅ គេបញ្ចុះទ្រង់នៅជាមួយនឹងពួកឰយុកោទ្រង់ ក្នុងក្រុង
របស់ដាវីឌ ជាឰយុកោ រួចយ៉ូរ៉ាម ជាព្រះរាជបុត្រា ក៏ឡើងសោយរាជ្យជំនួសបិតា។

ស្ដេចអ័ហាស៊ីយ៉ាសោយរាជ្យនៅស្រុកអ៊ីស្រាអែល

៥១ ឯអ័ហាស៊ីយ៉ា ជាបុត្រអ័ហាប់ ទ្រង់ចាប់តាំងសោយរាជ្យនៅក្រុងសាម៉ារី លើពួកអ៊ីស្រាអែល
ក្នុងឆ្នាំទី១៧នៃរាជ្យយ៉ូសាផាត ជាស្ដេចយូដា ក៏សោយរាជ្យលើពួកអ៊ីស្រាអែលបាន២ឆ្នាំ ៥២ ទ្រង់
បានប្រព្រឹត្តអំពើដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ា ក៏ដើរតាមផ្លូវរបស់ព្រះបិតា និងព្រះ
មាតាទ្រង់ ហើយតាមផ្លូវរបស់យេរ៉ូបោម ជាកូននេបាត ដែលបានបណ្តាលឲ្យពួកអ៊ីស្រាអែលធ្វើ
បាបនោះដែរ ៥៣ ទ្រង់បានគោរពប្រតិបត្តិ ហើយថ្វាយបង្គំដល់ព្រះបាល ជាការដែលនាំឲ្យព្រះយេ
ហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល មានសេចក្ដីក្រោធ ដូចជាព្រះបិតាបានធ្វើដែរ។៚

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

..................................................................................................................

..................................................................................................................

..................................................................................................................

## ការយល់ដឹងអំពីអត្ថបទ

### *ស្តេចយ៉ូសាផាតសោយរាជ្យនៅស្រុកយូដា*

ចាប់តាំងពីដំបូងស្តេចបានមានរបួសក្នុងចម្បាំងរួចទៅហើយ ប៉ុន្តែទ្រង់នៅមានសេចក្តីក្លាហាន ដើម្បីនឹងបញ្ជាទ័ពរបស់ទ្រង់ ហើយទ្រង់ក៏សុគតនាពេលយប់នោះទៅ។ យើងមើលឃើញថា ការទស្សន៍ទាយរបស់លោកអេលីយ៉ា បានក្លាយទៅជាការពិតហើយ។
ស្តេចយ៉ូសាផាតបានធ្វើអោយរាជ្យរបស់ទ្រង់ល្អក់កករ ដោយសារតែទ្រង់បានទៅចូលរួមជាមួយនឹងស្តេចអ័ហាប់ វាយយកប្រទេសស៊ីរី។ យោងទៅតាមកិច្ចសហប្រតិបត្តិការរបស់ទ្រង់ ជាមួយនឹងពួកស្តេចអ៊ីស្រាអែល ទ្រង់បានសម្រេចចិត្តរកស៊ីរួមគ្នាជាមួយនឹងបុត្រារបស់ស្តេចអ័ហាប់ ឈ្មោះអ័ហាស៊ីយ៉ា។ នៅពេលដែលសំពៅជំនួញទាំងអស់នោះបានលិច ទើបទ្រង់ដឹងថា ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យជាមួយនឹងទំនាក់ទំនងជិតស្និតរបស់ទ្រង់ ជាមួយនឹងមនុស្សអាក្រក់ដូចជាស្តេចអ័ហាស៊ីយ៉ាទេ។

សេចក្តីអធិស្ឋាន

ខែ11 ថ្ងៃសុក្រ 29

# ព្រះដាក់ទោសស្ដេចអ័ហាស៊ីយ៉ា

២ពង្សាវតារក្សត្រ 1:1-8

ការអធិស្ឋាន

អានអត្ថបទ

១ ក្រោយដែលអ័ហាប់សុគតហើយ នោះសាសន៍ម៉ូអាប់ គេបះបោរនឹងពួកអ៊ីស្រាអែល ២ នៅខ
ណៈនោះ អ័ហាស៊ីយ៉ាទ្រង់ធ្លាក់ ពីភ្នាក់ដៃរានជាន់លើ នៃដំណាក់នៅក្រុងសាម៉ារី ហើយក៏ទ្រង់
ប្រឈួន នោះទ្រង់ប្រើគេឲ្យទៅ ដោយបង្គាប់ថា ចូរទៅសួរដល់ព្រះបាល-សេប៊ូប ជាព្រះនៃពួកអេ
ក្រុន តើអញនឹងបានជាពីការឈឺនេះឬទេ ៣ តែទេវតានៃព្រះយេហូវ៉ា ក៏មកប្រាប់អេលីយ៉ា ជាអ្នក
ស្រុកធេសប៊ីថា ចូរក្រោកឡើងទៅជួបនឹងពួកអ្នក ដែលស្ដេចក្រុងសាម៉ារីចាត់ប្រើទៅនោះ សួរគេ
ថា តើដោយហេតុតែគ្មានព្រះនៅស្រុកអ៊ីស្រាអែលឬអី បានជាឯងរាល់គ្នាទៅសួរដល់ព្រះបាល-
សេប៊ូប ជាព្រះនៃពួកអេក្រុនវិញ ៤ ហេតុនោះ ឥឡូវនេះ ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលដូច្នេះថា
ឯងនឹងមិនចុះពីដំណេក ដែលឯងបានឡើងទៅនោះបានឡើយ គឺនឹងត្រូវស្លាប់ជាពិត រួចអេលី
យ៉ាក៏ចេញបាត់ទៅ។

៥ ឯពួកអ្នកដែលស្ដេចចាត់ប្រើនោះ គេក៏វិលត្រឡប់មកឯទ្រង់វិញ ហើយទ្រង់មានព្រះបន្ទូលសួរ
ថា ហេតុអ្វីបានជាឯងរាល់គ្នាវិលមកវិញដូច្នេះ ៦ គេក៏ទូលឆ្លើយថា មានមនុស្សម្នាក់ឡើងមកជួប
នឹងយើងខ្ញុំប្រាប់ថា ចូរវិលទៅឯស្ដេច ដែលចាត់ប្រើឯងរាល់គ្នាមក ហើយទូលទ្រង់ថា ព្រះយេហូ
វ៉ាទ្រង់មានព្រះបន្ទូលដូច្នេះ តើដោយហេតុតែគ្មានព្រះនៅស្រុកអ៊ីស្រាអែលឬអី បានជាព្រះ
ករុណាចាត់គេឲ្យទៅសួរដល់ព្រះបាល-សេប៊ូប ជាព្រះនៃពួកអេក្រុនវិញ ហេតុនេះទ្រង់នឹងមិនចុះ
ពីដំណេក ដែលបានឡើងទៅនោះបានឡើយ គឺត្រូវសុគតជាពិតវិញ ៧ ទ្រង់មានព្រះបន្ទូលសួរគេ
ថា មនុស្សដែលឡើងមកជួបនឹងឯងរាល់គ្នា ពោលសេចក្ដីទាំងនេះ តើបែបយ៉ាងណា ៨ គេទូល
តបថា មនុស្សនោះពាក់អាវធ្វើពីរោម ហើយមានខ្សែក្រវាត់ស្បែកនៅចង្កេះ ទ្រង់មានព្រះបន្ទូលថា
នោះគឺជាអេលីយ៉ា ជាអ្នកស្រុកធេសប៊ីហើយ។

1 After Ahab’s death, Moab rebelled against Israel. 2 Now Ahaziah had fallen through the
lattice of his upper room in Samaria and injured himself. So, he sent messengers, saying to
them, “Go and consult Baal-Zebub, the god of Ekron, to see if I will recover from this
injury.”

3 But the angel of the Lord said to Elijah the Tishbite, “Go up and meet the messengers of
the king of Samaria and ask them, ‘Is it because there is no God in Israel that you are going
off to consult Baal-Zebub, the god of Ekron?’ 4 Therefore this is what the Lord says: ‘You
will not leave the bed you are lying on. You will certainly die!’” So, Elijah went.

5 When the messengers returned to the king, he asked them, “Why have you come back?”

6 “A man came to meet us,” they replied. “And he said to us, ‘Go back to the king who sent
you and tell him, “This is what the Lord says: Is it because there is no God in Israel that you
are sending messengers to consult Baal-Zebub, the god of Ekron? Therefore, you will not
leave the bed you are lying on. You will certainly die!”’”

7 The king asked them, “What kind of man was it who came to meet you and told you this?”

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

### *ព្រះដាក់ទោសស្តេចអ័ហាស៊ីយ៉ា*

អ័ហាស៊ីយ៉ាជាបុត្រារបស់ស្តេចអ័ហាប់ ហើយក៏បានឡើងសោយរាជ្យសម្បត្តិជំនួសបិតារបស់ទ្រង់បានតែ២ឆ្នាំប៉ុណ្ណោះស្រាប់តែទ្រង់បានរបួសគ្រោះថ្នាក់។ ពេលនោះទ្រង់បានបញ្ជូនអ្នកនាំសារអោយទៅសួរព្រះរបស់ពួកបរទេសថា តើទ្រង់អាចជាឡើងវិញឬទេ នោះលោកអេលីយ៉ាបានឡើងទៅជួបពួកគេនៅពាក់កណ្តាលផ្លូវ។គាត់បានប្រាប់អោយពួកគេត្រឡប់ទៅវិញ ដោយផ្តាំផ្ញើពាក្យសំដីទៅសួរស្តេចថា ទ្រង់នឹងសុគត់ ពីព្រោះទ្រង់បានបំភ្លេចព្រះពិត ហើយទៅរើសយកព្រះបរទេសវិញ។ ការស្វែងរកជំនួយពីព្រះខុស នោះនឹងនាំអោយយើងរាល់គ្នាជួបនឹងមហន្តរាយដល់ទ្រព្យសម្បត្តិ រួមទាំងអាយុជីវិតដូចជាស្តេចអ័ហាស៊ីយ៉ាងអញ្ចឹងដែរ។មានគ្រីស្ទបរិស័ទមួយចំនួនក៏មិនខុសពីស្តេចអង្គនេះដែរ ពេលដែលជួបបញ្ហាគ្រោះថ្នាក់មកដល់ពួកគេមិនបានស្វែងរកព្រះជាមុននោះទេ តែបែរជាស្វែងរកជួយពីអបិយជំនឿលើដូនតា គ្រូមន្តអាគម ឬគ្រូជាមុនដំបូងទៅវិញ។

សេចក្តីអធិស្ឋាន

# ស្ដេចអ័ហាស៊ីយ៉ារកចាប់ហោរាអេលីយ៉ា

២ពង្សាវតារក្សត្រ 1:9-18

ការអធិស្ឋាន

អានអត្ថបទ

៩ នោះទ្រង់ចាត់មេទ័ពម្នាក់ និងពួកទាហាន៥០នាក់របស់គាត់ ឲ្យទៅរកអេលីយ៉ា គេក៏ឡើងទៅឯ
លោកដែលកំពុងអង្គុយនៅលើកំពូលភ្នំ មេទ័ពនោះនិយាយនឹងលោកថា ឱអ្នកសំណប់របស់ព្រះ
អើយ ស្ដេចទ្រង់បង្គាប់ឲ្យអ្នកចុះមក ១០ អេលីយ៉ាឆ្លើយទៅមេទ័ពនោះថា បើខ្ញុំជាអ្នកសំណប់របស់
ព្រះពិត នោះសូមឲ្យភ្លើងធ្លាក់ពីលើមេឃមកបញ្ឆេះឯង និងពួក៥០នាក់របស់ឯងទៅ នោះក៏មាន
ភ្លើងធ្លាក់ពីលើមេឃ មកបញ្ឆេះទ័ពនោះ នឹងពួក៥០នាក់របស់គាត់មែន ១១ ទ្រង់ក៏ចាត់មេទ័ពម្នាក់
និងពួក៥០នាក់របស់គាត់ ឲ្យទៅរកលោកទៀត មេទ័ពនោះនិយាយនឹងលោកថា ឱអ្នកសំណប់
របស់ព្រះអើយ ស្ដេចទ្រង់មានព្រះបន្ទូលដូច្នេះថា ចូរចុះមកជាឆាប់ ១២ អេលីយ៉ាក៏ឆ្លើយទៅគេថា
បើខ្ញុំជាអ្នកសំណប់របស់ព្រះពិត នោះសូមឲ្យភ្លើងធ្លាក់ពីលើមេឃមកបញ្ឆេះឯង និងពួក៥០នាក់
របស់ឯងទៅ នោះក៏មានភ្លើងនៃព្រះធ្លាក់ពីលើមេឃឯង នឹងពួក៥០នាក់របស់ទៅ នោះក៏មានភ្លើង
នៃព្រះធ្លាក់ពីលើមេឃ មកបញ្ឆេះមេទ័ពនោះ និងពួក៥០នាក់របស់គាត់ដែរ ១៣ រួចទ្រង់ក៏ចាត់មេ
ទ័ពទី៣ នឹងពួក៥០នាក់របស់គាត់ ឲ្យទៅថែមទៀត មេទ័ពទី៣នោះក៏ឡើងទៅលុតជង្គង់ក្រាបនៅ
មុខអេលីយ៉ាអង្វរថា ឱអ្នកសំណប់របស់ព្រះអើយ សូមអាណិតមេត្តាឲ្យជីវិតរបស់ខ្ញុំប្របាទ និង
ជីវិតរបស់៥០នាក់នេះ បានមានដំឡៃនៅភ្នែកលោកចុះ ១៤ មើល មានភ្លើងធ្លាក់ចុះពីលើមេឃមក
បញ្ឆេះមេទ័ពទាំង២នាក់ នឹងពួក៥០នាក់របស់គេ ដែលមកមុននោះទៅហើយ តែឥឡូវនេះ សូមឲ្យ
ជីវិតខ្ញុំប្របាទ មានដំឡៃនៅភ្នែកលោកវិញ ១៥ នោះទេវតានៃព្រះយេហូវ៉ា ក៏ប្រាប់អេលីយ៉ាថា ចូរ
ចុះទៅជាមួយនឹងគេចុះ កុំឲ្យខ្លាចឡើយ ដូច្នេះ លោកក៏ក្រោកឡើងចុះទៅជាមួយនឹងគេ ចូលទៅ
គាល់ស្ដេច ១៦ លោកទូលស្ដេចថា ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលដូច្នេះ ឯងចាត់ប្រើគេឲ្យទៅសួរ
ដល់ព្រះបាល-សេប៊ូប ជាព្រះនៃពួកអេក្រុន នោះតើមិនមែនដោយព្រោះគ្មានព្រះនៅស្រុកអ៊ីស្រា
អែល ដែលល្មមសួរព្រះបន្ទូលទ្រង់បានឬអី ហេតុនេះឯងនឹងមិនបានចុះពីដំណេក ដែលបានឡើង
ទៅនោះឡើយ គឺនឹងត្រូវស្លាប់វិញជាពិត។
១៧ ទ្រង់ក៏សុគតទៅ តាមព្រះបន្ទូលនៃព្រះយេហូវ៉ាដែលអេលីយ៉ាបានពោលហើយ រួចយ៉ូរ៉ាមក៏
ឡើងសោយរាជ្យជំនួសទ្រង់ គឺក្នុងឆ្នាំទី២នៃរាជ្យយ៉ូរ៉ាម ជាបុត្រនៃយ៉ូសាផាត ស្ដេចយូដា ដ្បិតអ័
ហាស៊ីយ៉ាគ្មានព្រះរាជបុត្រាទេ ១៨ រីឯដំណើរឯទៀត ពីអ័ហាស៊ីយ៉ា ដែលទ្រង់បានធ្វើ នោះសុទ្ធតែ
បានកត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្ដេចអ៊ីស្រាអែលហើយ។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

.......................................................................................................

.......................................................................................................

.......................................................................................................

## ការយល់ដឹងអំពីអត្ថបទ

### *ស្តេចអ័ហាស៊ីយ៉ារកចាប់ហោរាអេលីយ៉ា*

ស្តេចអ័ហាស៊ីយ៉ាបានបញ្ជូនទាហានទៅចាប់លោកអេលីយ៉ា ហើយមានបំណងសម្លាប់គាត់ ព្រោះតែពាក្យសំដីត្រង់ៗរបស់គាត់។ ទាហាន១០០នាក់បានស្លាប់ ដោយសារស្តេចដែលមិនគោរពថ្វាយបង្គំព្រះជាម្ចាស់មុនពេលទ្រង់ដឹងថា មិនអាចបំបិតមាត់ ឬសម្លាប់មនុស្សដែលព្រះជាម្ចាស់បញ្ជូនមកដើម្បីបន្ទោសទ្រង់នោះទេ។ដោយសារតែភាពរឹងចចេសរបស់អ័ហាស៊ីយ៉ា បានធ្វើអោយមនុស្សដទៃរងគ្រោះដោយសារទ្រង់ផងដែរ។ ការប្រព្រឹត្តអំពើបាបដដែលៗដោយមិនបានដឹងពីទោសកំហុសរបស់ខ្លួន អ្នកនោះមិនអាចស្រោចស្រង់អោយរួចអាយុជីវិតបានឡើយ ហើយសេចក្តីអត់ទោសបាបក៏មកមិនដល់អ្នកនោះដែរ។

សេចក្តីអធិស្ឋាន

ខែ12
ថ្ងៃអាទិត្យ 01

# ការអធិប្បាយថ្ងៃអាទិត្យ

- ចំណងជើង :
- អត្ថបទ :
- អ្នកអធិប្បាយ :



ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ពាក្យសម្ដី

ការប្រកបរបស់យើងជាមួយនិងព្រះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

## សេចក្ដីអធិស្ឋាន

ខែ12
ថ្ងៃច័ន្ទ
02

# ព្រះអម្ចាស់លើកហោរាអេលីយ៉ាទៅស្ថានសួគ៌

## ២ពង្សាវតារក្សត្រ 2:1-11

ការអធិស្ឋាន

អានអត្ថបទ

១ ក្រោយមក ក្នុងគ្រាដែលព្រះយេហូវ៉ា ទ្រង់សព្វព្រះហឫទ័យនឹងលើកអេលីយ៉ា ឡើងទៅស្ថានសួគ៌
ដោយខ្យល់កួច នោះអេលីយ៉ា និងអេលីសេ ក៏ចេញពីក្រុងគីលកាលទៅជាមួយគ្នា ២ ឯអេលីយ៉ា លោក
ប្រាប់ដល់អេលីសេថា ចូរឯងរង់ចាំនៅទីនេះសិន ដ្បិតព្រះយេហូវ៉ាទ្រង់បានចាត់អញ ឲ្យទៅឯក្រុងបេត-
អែល តែអេលីសេប្រកែកថា ខ្ញុំស្បថដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅ ហើយដោយព្រលឹង
លោកដ៏រស់នៅដែរថា ខ្ញុំមិនព្រមឃ្លាតពីលោកទេ ដូច្នេះ អ្នកទាំង២ក៏ចុះទៅឯបេត-អែល ៣ រីឯពួកសិស្ស
របស់ពួកហោរា ដែលនៅក្រុងបេត-អែល គេចេញមកសួរអេលីសេថា តើលោកជ្រាបថានៅថ្ងៃនេះ ព្រះ
យេហូវ៉ានឹងលើកគ្រូលោក ពីមុខលោកចេញឬទេ គាត់ឆ្លើយថា អើ ខ្ញុំដឹងហើយ ចូរអ្នករាល់គ្នានៅស្ងៀម
ទៅ ៤ អេលីយ៉ាក៏ប្រាប់គាត់ថា អេលីសេអើយ សូមរង់ចាំនៅទីនេះសិន ដ្បិតព្រះយេហូវ៉ាបានចាត់ខ្ញុំឲ្យ
ទៅឯក្រុងយេរីខូរ តែគាត់ប្រកែកថា ខ្ញុំស្បថដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់នៅ ហើយដោយ
ព្រលឹងលោកដ៏នៅរស់ដែរថា ខ្ញុំមិនព្រមឃ្លាតពីលោកទេ ដូច្នេះ អ្នកទាំង២ក៏ទៅដល់យេរីខូរ ៥ រីឯពួក
សិស្សរបស់ពួកហោរា ដែលនៅក្រុងយេរីខូរ គេមកសួរអេលីសេថា តើលោកជ្រាបថា នៅថ្ងៃនេះ ព្រះយេ
ហូវ៉ានឹងលើកគ្រូលោកពីមុខលោកទៅឬទេ គាត់ឆ្លើយថា អើ ខ្ញុំដឹងហើយ ចូរអ្នករាល់គ្នានៅស្ងៀម
ទៅ ៦ រួចអេលីយ៉ាប្រាប់គាត់ថា សូមឲ្យឯងរង់ចាំនៅទីនេះសិន ដ្បិតព្រះយេហូវ៉ាបានចាត់ខ្ញុំឲ្យទៅឯទន្លេ
យ័រដាន់ តែគាត់ប្រកែកថា ខ្ញុំស្បថដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់នៅ ហើយដោយព្រលឹង
លោកដ៏នៅរស់ដែរថា ខ្ញុំមិនព្រមឃ្លាតពីលោកទេ ដូច្នេះ អ្នកទាំង២ក៏ដើរតទៅ ៧ មានពួកសិស្ស៥០នាក់
នៃពួកហោរា ក៏តាមទៅឈរមើលពីចំងាយ តែអ្នកទាំង២ក៏ឈរនៅមាត់ទន្លេយ័រដាន់ ៨ ឯអេលីយ៉ា
លោកយកក្រមារបស់លោកបត់វាយទឹក នោះទឹកក៏ញែកចេញពីគ្នា ឲ្យលោកទាំង២បានដើរឆ្លងទៅនៅ
ដីគោក ៩ កាលបានឆ្លងទៅផុតហើយ នោះអេលីយ៉ាប្រាប់អេលីសេថា ចូរឲ្យឯងសូមអ្វីៗដែលចង់ឲ្យ
អញធ្វើសំរាប់ឯង ក្នុងពេលមុនដែលព្រះបានលើកអញឡើងពីឯងទៅ អេលីសេឆ្លើយថា សូមឲ្យវិញ្ញាណ
របស់លោកបានសណ្ឋិតលើខ្ញុំ ដល់ទៅ២ភាគផង ១០ លោកមានប្រសាសន៍ថា ឯងបានសូមសេចក្តី
យ៉ាងពិបាក ប៉ុន្តែបើឯងឃើញអញ ក្នុងកាលដែលព្រះលើកអញឡើងពីឯងទៅ នោះនឹងបានដូចប្រាថ្នា
បើមិនបានឃើញវិញ នោះមិនបានទេ ១១ រួចកំពុងដែលអ្នកទាំង២ដើរទៅ ហើយនិយាយគ្នាទៀត នោះ
ស្រាប់តែឃើញរថជាភ្លើង នឹងសេះជាភ្លើង មកញែកលោកចេញពីគ្នា ហើយអេលីយ៉ាក៏ឡើងទៅឯស្ថាន
សួគ៌ ដោយខ្យល់កួច

1 When the Lord was about to take Elijah up to heaven in a whirlwind, Elijah and Elisha were on
their way from Gilgal. 2 Elijah said to Elisha, “Stay here; the Lord has sent me to Bethel.”
But Elisha said, “As surely as the Lord lives and as you live, I will not leave you.” So, they went
down to Bethel. 3 The company of the prophets at Bethel came out to Elisha and asked, “Do you
know that the Lord is going to take your master from you today?” “Yes, I know,” Elisha replied,
“so be quiet.” 4 Then Elijah said to him, “Stay here, Elisha; the Lord has sent me to Jericho.”
And he replied, “As surely as the Lord lives and as you live, I will not leave you.” So, they went
to Jericho.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

***ព្រះអម្ចាស់លើកហោរាអេលីយ៉ាទៅស្ថានសួគ៌***

លោកអេលីយ៉ាបានទុកចិត្តលើការការពារពីព្រះជាម្ចាស់ ហើយដឹងថា គាត់ត្រូវផ្ទេរកិច្ចការដែលគាត់កំពុងតែធ្វើនេះទៅអោយអេលីសេ បន្ទាប់មកព្យាការីទាំងពីរនាក់បានធ្វើដំណើរទៅមើលកន្លែងដែលមានពួកហោរាក្មេងៗ និងអ្នកដែលស្មោះត្រង់ចំពោះព្រះជាម្ចាស់រស់នៅ( សាលាបង្រៀនសម្រាប់ហោរា )។ សាលានេះបានបង្កើតតាំងពីជំនាន់ហោរាសាំយ៉ូអែល។ នេះជាការសាកល្បងសម្រាប់លោកអេលីសេ ដែលអាចនឹងធ្លាក់ទៅក្នុងសេចក្តីល្បួងអោយរស់នៅក្នុងសាលាណាមួយ ដោយមិនបន្តដំណើរទៅជាមួយនឹងលោកអេលីយ៉ាទៀត។ លោកអេលីសេបានឆ្លងផុតការសាកល្បងនេះ គាត់ដឹងថា ដោយសារតែគាត់ជាអ្នកបន្តការងារខាងព្រលឹងវិញ្ញាណជំនួសលោកអេលីយ៉ា គាត់ត្រូវតែនៅជាមួយនឹងលោកអេលីយ៉ារហូតដល់ទីបញ្ចប់ដើម្បីនឹងទទួលអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ក្នុងការបន្តការងាររបស់លោកអេលីយ៉ាទៅមុខទៀត។ គាត់បានទទួលមរតកពីចំណែកពីឪពុករបស់គាត់ ដែលជាសញ្ញាថាគាត់គឺជាអ្នកបន្តតំណែងពីលោកអេលីយ៉ា។

សេចក្តីអធិស្ឋាន

ខែ12
ថ្ងៃអង្គារ 03

# សង្គ្រាមរវាងយូដា និងអ៊ីស្រាអែល នៅគីបៀន

## ២ពង្សាវតារក្សត្រ 2:12-18

ការអធិស្ឋាន

អានអត្ថបទ

១២ អេលីសេក៏បានឃើញ ហើយស្រែកឡើងថា ឱលោកឪពុក លោកឪពុកខ្ញុំអើយ នុ៎ះន៏ ព្រះរាជ
រថ និងទ័ពសេះរបស់ពួកអ៊ីស្រាអែលហើយ រួចលោកមិនបានឃើញអេលីយ៉ាទៀតឡើយ នោះ
លោកចាប់អាវខ្លួនហែកចេញជា២ផ្នែក ១៣ ក៏រើសយកក្រមារបស់អេលីយ៉ា ដែលជ្រុះចុះមក វិល
ត្រឡប់ទៅវិញ ឈរនៅមាត់ទន្លេយ័រដាន់ ១៤ ហើយក៏យកក្រមារបស់អេលីយ៉ា ដែលជ្រុះមកពី
លោកនោះ ទៅវាយទឹក ដោយពាក្យថា តើព្រះយេហូវ៉ា ជាព្រះនៃអេលីយ៉ា ទ្រង់គង់នៅឯណា
កាលបានវាយទឹកហើយ នោះទឹកក៏ញែកចេញពីគ្នា ហើយអេលីសេឆ្លងផុតទៅ។
១៥ លុះកាលពួកសិស្សរបស់ពួកហោរា ពីក្រុងយេរីខូរ ដែលឈរមើលពីត្រើយម្ខាង បានឃើញ
ហើយ នោះក៏ថា វិញ្ញាណរបស់អេលីយ៉ា បានសណ្ឋិតលើអេលីសេហើយ រួចគេមកទទួលលោក
ក៏ក្រាបចុះដល់ដីនៅចំពោះលោក ១៦ គេជំរាបលោកថា មើល មានមនុស្សខ្លាំងពូកែ៥០នាក់ នៅ
ជាមួយនឹងយើងខ្ញុំប្របាទនេះ ដូច្នេះ សូមឲ្យគេទៅរកគ្រូរបស់លោកចុះ ក្រែងព្រះវិញ្ញាណនៃព្រះ
យេហូវ៉ាបានលើកលោកឡើង ទៅបោះចោលលើភ្នំណា ឬក្នុងច្រកណា១ តែលោកប្រកែកថា កុំ
ឲ្យប្រើគេទៅឡើយ ១៧ តែដោយគេចេះតែទទូចសូម ទាល់តែលោកបានខ្មាស បានជាលោក
បណ្តោយទៅថា ចូរឲ្យគេទៅចុះ ដូច្នេះ គេក៏ប្រើ៥០នាក់នោះឲ្យទៅ ហើយគេរកលោកអស់៣ថ្ងៃ
ឥតឃើញសោះ ១៨ រួចគេវិលត្រឡប់មកឯអេលីសេវិញ ដែលលោករង់ចាំនៅក្រុងយេរីខូរ ហើយ
លោកមានប្រសាសន៍ថា តើខ្ញុំមិនបានប្រាប់ថា កុំឲ្យទៅឡើយទេឬអី។

12 Elisha saw this and cried out, “My father! My father! The chariots and horsemen of
Israel!” And Elisha saw him no more. Then he took hold of his garment and tore it in two.
13 Elisha then picked up Elijah’s cloak that had fallen from him and went back and stood on
the bank of the Jordan. 14 He took the cloak that had fallen from Elijah and struck the water
with it. “Where now is the Lord, the God of Elijah?” he asked. When he struck the water, it
divided to the right and to the left, and he crossed over.
15 The company of the prophets from Jericho, who were watching, said, “The spirit of Elijah
is resting on Elisha.” And they went to meet him and bowed to the ground before
him. 16 “Look,” they said, “we your servants have fifty able men. Let them go and look for
your master. Perhaps the Spirit of the Lord has picked him up and set him down on some
mountain or in some valley.” “No,” Elisha replied, “do not send them.”
17 But they persisted until he was too embarrassed to refuse. So, he said, “Send them.” And
they sent fifty men, who searched for three days but did not find him. 18 When they returned
to Elisha, who was staying in Jericho, he said to them, “Didn’t I tell you not to go?”

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

### *សង្គ្រាមរវាងយូដា និងអ៊ីស្រាអែល នៅតែបៀន*

ព្រះជាម្ចាស់បានលើកលោកអេលីយ៉ាទៅឋានសួគ៌ ដោយអំណាចដ៏អស្ចារ្យ ហើយក្នុងពេលភ្លាមៗនោះ លោកអេលីសេបានដឹងថា អ៊ីស្រាអែលបានបាត់បង់កម្លាំងការពារមួយ ដែលស្មើនឹងកងទ័ពសេះ និងមនុស្សទាំងអស់។ ប៉ុន្តែមិនយូរប៉ុន្មានគាត់ក៏បានដឹងថា ព្រះជាម្ចាស់បានផ្ទេរអំណាចពិសេសរបស់ព្រះអង្គ ពីលោកអេលីយ៉ាមកអោយគាត់វិញ។ហោរាទាំងអស់ដែលនៅយេរីខូមិនជឿថា លោកអេលីយ៉ាឡើងទៅឋានសួគ៌ តាមរយៈហេតុការណ៍ដ៏អស្ចារ្យទេ គេដើររុករកគាត់អស់បីថ្ងៃ តែមិនឃើញសោះ។

ក្នុងនាមជាអ្នកដឹកនាំសម័យថ្មីត្រូវយល់ដឹង និងចែករំលែក បង្ហាត់បង្រៀនមនុស្សជំនាន់ក្រោយអោយបន្តវេនយើងរាល់គ្នា សូមកុំអោយមានគំនិតអាត្មានិយមអោយសោះ វាមិនធ្វើអោយយើង និងពួកជំនុំនៃព្រះបានរីកចម្រើនឡើងឡើយ។តែវាគឺជាបញ្ហាអោយមានការរាំងស្ទះដំណឹងល្អនៃព្រះវិញ។

សេចក្តីអធិស្ឋាន

ខែ12 ថ្ងៃពុធ 04

# ហោរាអេលីសេធ្វើឲ្យប្រភពទឹកនៅក្រុងយេរីខូរល្អឡើងវិញ

## ២ពង្សាវតារក្សត្រ 2:19-25

ការអធិស្ឋាន

អានអត្ថបទ

[១៩] រួចមក ពួកមនុស្សនៅទីក្រុងនោះ ក៏និយាយនឹងអេលីសេថា សូមទានលោកមើល កន្លែងសង់ទីក្រុងនេះ
សប្បាយ ដូចជាលោកម្ចាស់ឃើញហើយ ប៉ុន្តែទឹកមិនល្អទេ ហើយដីក៏មិនកើតផលផង [២០] ដូច្នេះ លោក
ប្រាប់ថា ចូរយកក្អមថ្មី១មកឲ្យខ្ញុំ ហើយដាក់អំបិលផង គេក៏យកមក [២១] រួចលោកចេញទៅចាក់អំបិលនោះ
ទៅក្នុងរន្ធទឹកដោយពាក្យថា ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលដូច្នេះ អញបានកែទឹកនេះ ឲ្យបានល្អឡើងវិញ
ហើយ ពីនេះទៅមុខនឹងគ្មានអ្វីស្លាប់ឬឥតផល ដោយព្រោះទឹកនេះទៀតឡើយ [២២] ដូច្នេះ ទឹកនោះក៏បានប្រែ
ជាល្អ ដរាបដល់សព្វថ្ងៃនេះ ដូចជាពាក្យដែលអេលីសេបានពោល។

ព្រះអម្ចាស់ដាក់ទោសដល់ក្មេងៗដែលប្រមាថហោរាអេលីសេ

[២៣] លោកក៏ចេញពីទីនោះឡើងទៅឯក្រុងបេត-អែល កាលលោកកំពុងតែឡើងតាមផ្លូវទៅ នោះមានពួកក្មេង
ជំទង់ប្រុសៗ ចេញពីទីក្រុងមក ពោលមើលងាយដល់លោកថា អាទំពែកអើយ ចូរឡើងទៅចុះ អាទំពែក
អើយ ចូរឡើងទៅចុះ [២៤] លោកក៏បែរមើលមកក្រោយឃើញ ហើយដាក់បណ្តាសាដល់វា ដោយនូវព្រះនាម
ព្រះយេហូវ៉ាស្រាប់តែមានខ្លាឃ្មុំញី២ ចេញពីព្រៃមក ហែកក្មេងទាំងនោះ អស់៤២នាក់ទៅ [២៥] លោកក៏ចេញ
ពីទីនោះ ទៅឯភ្នំកើមែល ហើយពីនោះ លោកវិលត្រឡប់ទៅឯក្រុងសាម៉ារីវិញ។

[19] The people of the city said to Elisha, “Look, our lord, this town is well situated, as you can see, but the water is bad and the land is unproductive.”
[20] “Bring me a new bowl,” he said, “and put salt in it.” So, they brought it to him.
[21] Then he went out to the spring and threw the salt into it, saying, “This is what the Lord says: ‘I have healed this water. Never again will it cause death or make the land
unproductive.’” [22] And the water has remained pure to this day, according to the word Elisha
had spoken.[23] From there Elisha went up to Bethel. As he was walking along the road, some boys came out of the town and jeered at him. “Get out of here, baldy!” they said. “Get out
of here, baldy!” [24] He turned around, looked at them and called down a curse on them in the name of the Lord. Then two bears came out of the woods and mauled forty-two of the
boys. [25] And he went on to Mount Carmel and from there returned to Samaria.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

***ហោរាអេលីសេធ្វើឲ្យប្រភពទឹកនៅក្រុងយេរីខូរល្អឡើងវិញ***

មានការអស្ចារ្យពីរយ៉ាងដែលលោកអេលីសេបានធ្វើ គឺជាសញ្ញាបញ្ជាក់ពីព្រះពរ និងបណ្តាសារជាលក្ខណៈទាំងពីរនៃបេសកកម្មរបស់គាត់ក្នុងពេលអនាគត។ នៅឯក្រុងយេរីខូ ជាកន្លែងដែលប្រជារាស្ត្រកំពុងកើតទុក្ខ ដោយមិនមានទឹកស្អាតប្រើប្រាស់ គាត់ជួយធ្វើអោយទឹកនោះអាចផឹកបាន។ នៅឯបេតអែល ជាកន្លែងពួកមេដឹកនាំសាសនាក្លែងក្លាយរស់នៅ គាត់បាននាំបណ្តាសារបស់ព្រះជាម្ចាស់មកដាក់លើពួកអ្នកបដិសេធដំណឹងល្អរបស់គាត់។

សេចក្តីអធិស្ឋាន

ខែ12
ថ្ងៃព្រ.ហ 05

# ស្ដេចយ៉ូរ៉ាមសោយរាជ្យនៅស្រុកអ៊ីស្រាអែល សង្គ្រាមរវាងអ៊ីស្រាអែល និងម៉ូអាប់

២ពង្សាវតារក្សត្រ 3:1-12

ការអធិស្ឋាន

អានអត្ថបទ

[១]រីឯយ៉ូរ៉ាម ជាបុត្រអ័ហាប់ ទ្រង់ចាប់តាំងសោយរាជ្យលើពួកអ៊ីស្រាអែលនៅក្រុងសាម៉ារី ក្នុងឆ្នាំទី១២នៃ
រាជ្យយ៉ូសាផាត ជាស្ដេចយូដា ក៏សោយរាជ្យបាន១២ឆ្នាំ [២] ទ្រង់ប្រព្រឹត្តដ៏លាមកអាក្រក់នៅព្រះនេត្រព្រះយេ
ហូវ៉ា តែមិនដល់ព្រះបិតា និងព្រះមាតាទ្រង់ទេ ដ្បិតទ្រង់បានបំបាត់រូបព្រះបាល ដែលព្រះបិតាទ្រង់បានធ្វើ
ចេញ [៣] ប៉ុន្តែទ្រង់នៅតែកាន់តាមអំពើបាបរបស់យេរ៉ូបោម ជាកូននេបាតដែលបាននាំឲ្យពួកអ៊ីស្រាអែលធ្វើ
តាមផងនៅឡើយ ទ្រង់មិនបានលះបង់អំពើបាបនោះទេ។
[៤]រីឯមេសា ជាស្ដេចសាសន៍ម៉ូអាប់ ទ្រង់ជាអ្នកមានហ្វូងចៀមច្រើន ហើយទ្រង់ក៏ឡើងសួយ ជារោមរបស់កូន
ចៀម១សែន និងរោមរបស់ចៀមឈ្មោល១សែន មកថ្វាយស្ដេចអ៊ីស្រាអែល [៥] តែកាលអ័ហាប់ទ្រង់សុគត
ទៅ នោះស្ដេចម៉ូអាប់បានបះបោរនឹងស្ដេចអ៊ីស្រាអែល [៦] គ្រានោះ ស្ដេចយ៉ូរ៉ាមក៏ចេញពីក្រុងសាម៉ារី ទៅត្រួត
មើលពួកអ៊ីស្រាអែលទាំងអស់ ហើយយាងនាំមុខគេទៅ [៧] ទ្រង់ក៏ចាត់សារទៅឯយ៉ូសាផាត ជាស្ដេចយូដាថា
ស្ដេចម៉ូអាប់បានបះបោរនឹងទូលបង្គំហើយ តើទ្រង់សព្វព្រះទ័យចង់ទៅច្បាំងនឹងសាសន៍ម៉ូអាប់ជាមួយនឹង
ទូលបង្គំឬទេ ទ្រង់មានព្រះបន្ទូលឆ្លើយថា ទូលបង្គំចង់ទៅដែរ ទូលបង្គំក៏ដូចជាទ្រង់ រាស្ត្រទូលបង្គំក៏ដូចជារា
ស្ត្ររបស់ទ្រង់ ហើយសេះទូលបង្គំក៏ដូចជាសេះរបស់ទ្រង់ដែរ [៨] ទ្រង់ក៏សួរថា តើត្រូវឲ្យយើងឡើងទៅតាមផ្លូវ
ណា ស្ដេចអ៊ីស្រាអែលឆ្លើយថា តាមផ្លូវកាត់ទីរហោស្ថានស្រុកអេដំម [៩] ដូច្នេះ ស្ដេចអ៊ីស្រាអែល ព្រមទាំងស្ដេ
ចយូដា និងស្ដេចអេដំមក៏នាំគ្នាចេញទៅ គេដើរផ្លូវវាងអស់៧ថ្ងៃ ឥតមានទឹកសំរាប់ពលទ័ព និងហ្វូងសត្វ
ដែលតាមគេទៅនោះសោះ [១០] ដូច្នេះ ស្ដេចអ៊ីស្រាអែលទ្រង់មានព្រះបន្ទូលថា ស្ដាយណាស់ ព្រះយេហូវ៉ា
ទ្រង់បានហៅយើងខ្ញុំ ជាស្ដេចទាំង៣អង្គនេះមក ដើម្បីនឹងប្រគល់ទៅក្នុងកណ្ដាប់ដៃនៃសាសន៍ម៉ូអាប់
ហើយ [១១] តែយ៉ូសាផាតមានព្រះបន្ទូលសួរថា នៅទីនេះ តើគ្មានហោរាម្នាក់របស់ព្រះយេហូវ៉ា ឲ្យយើងបាន
សួរដល់ព្រះអង្គដោយសារអ្នកនោះទេឬអី នោះអ្នកជំនិតម្នាក់របស់ស្ដេចអ៊ីស្រាអែលក៏ទូលឆ្លើយឡើងថា អេ
លីសេ ជាកូនសាផាត ដែលបានចាក់ទឹកលាងដៃអេលីយ៉ា លោកនៅទីនេះដែរ [១២] យ៉ូសាផាតក៏មានព្រះ
បន្ទូលថា ព្រះបន្ទូលនៃព្រះយេហូវ៉ាក៏សណ្ឋិតនៅនឹងលោក ដូច្នេះ ស្ដេចអ៊ីស្រាអែល និងយ៉ូសាផាត ហើយ
ស្ដេចអេដំម ទាំង៣អង្គ ក៏យាងចុះទៅឯលោក។

[1]Joram son of Ahab became king of Israel in Samaria in the eighteenth year of Jehoshaphat
king of Judah, and he reigned twelve years. [2] He did evil in the eyes of the Lord, but not as
his father and mother had done. He got rid of the sacred stone of Baal that his father had
made. [3] Nevertheless he clung to the sins of Jeroboam son of Nebat, which he had caused
Israel to commit; he did not turn away from them.
[4] Now Mesha king of Moab raised sheep, and he had to pay the king of Israel a tribute of a
hundred thousand lambs and the wool of a hundred thousand rams. [5] But after Ahab died,
the king of Moab rebelled against the king of Israel. [6] So at that time King Joram set out
from Samaria and mobilized all Israel. [7] He also sent this message to Jehoshaphat king of
Judah: “The king of Moab has rebelled against me. Will you go with me to fight against
Moab?” “I will go with you,” he replied. “I am as you are, my people as your people, my
horses as your horses.”

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

***ស្ដេចយ៉ូរ៉ាមសោយរាជ្យនៅស្រុកអ៊ីស្រាអែល សង្គ្រាមរវាងអ៊ីស្រាអែល និងម៉ូអាប់***

យ៉ូរ៉ាមបានឡើងសោយរាជ្យជំនួសព្រះរៀមរបស់ទ្រង់នាមអ័ហាស៊ីយ៉ា។ ស្ដេចថ្មីនេះមិនមានចិត្តអាក្រក់ដូចបិតា និងបងប្រុសឡើយ ហើយយ៉ាងហោចណាស់ ទ្រង់ក៏បានបង្ហាញការមិនពេញចិត្តចំពោះព្រះបាលដែរ ដោយបានរុះរើកន្លែងថ្វាយបង្គំរបស់ព្រះបាល ដែលបិតារបស់ទ្រង់បានសាងសង់ចេញ។ក្រោយពីស្ដេចអ័ហាប់បានសុគតទៅ ពួកសាសន៍ម៉ូអាប់បានក្រោយឡើងទាស់នឹងជនជាតិអ៊ីស្រាអែល ដោយពួកគេលែងថ្វាយសួយសារអាករទៀតហើយ ប៉ុន្តែក្នុងពេលនោះ អ័ហាស៊ីយ៉ាមិនបានចាត់ការអ្វីដល់ពួកគេទេ។ ស្ដេចយ៉ូរ៉ាមបានព្យាយាមស្រោចស្រង់ប្រភពចំណូលឡើងវិញ ទ្រង់បានប្រើកម្លាំងទ័ព ព្រមទាំងមានការជួយឧបត្ថម្ភពីស្រុកយូដា និងអេដំមផង ព្រោះប្រជាជាតិទាំងនោះនឹងបានផលចំណេញ បើពួកម៉ូអាប់ចុះទន់ខ្សោយ។ ឯពួកកងទ័ពបានមកជួបជុំគ្នានៅចុងសមុទ្រស្លាប់ ហើយចូលទៅវាយម៉ូអាប់តាមវាលរហោស្ថាននៃស្រុកអេដុំម។ ប្រយុទ្ធគ្នាក្រោយបានមួយសប្ដាហ៍មកពួកទាហានគ្មានទឹកផឹក ស្ដេចយ៉ូរ៉ាមក៏បន្ទោសព្រះជាម្ចាស់។ ស្ដេចយ៉ូសាផាតស្គាល់ព្រះជាម្ចាស់ច្បាស់ជាងយ៉ូរ៉ាម ទ្រង់បានសួរព្រះជាម្ចាស់តាមហោរាអេលីសេថា តើទ្រង់គួរធ្វើយ៉ាងដូចម្ដេច ?

សេចក្ដីអធិស្ឋាន

ខែ12
ថ្ងៃសុក្រ 06

# ស្តេចយ៉ូរ៉ាមសោយរាជ្យនៅស្រុកអ៊ីស្រាអែល សង្គ្រាមរវាងអ៊ីស្រាអែល និងម៉ូអាប់

២ពង្សាវតារក្សត្រ 3:13-20

ការអធិស្ឋាន

អានអត្ថបទ

[១៣] ឯអេលីសេ ក៏ទូលដល់ស្តេចអ៊ីស្រាអែលថា តើទ្រង់នឹងទូលបង្គំត្រូវការអ្វីនឹងគ្នា ចូរទៅឯពួក
ហោរារបស់ព្រះបិតា និងព្រះមាតាទ្រង់ចុះ តែស្តេចអ៊ីស្រាអែលមានព្រះបន្ទូលតបថា ទេ ដ្បិតព្រះ
យេហូវ៉ាបានហៅស្តេចទាំង៣អង្គនេះមក ដើម្បីនឹងប្រគល់ទៅក្នុងកណ្តាប់ដៃ នៃពួកម៉ូអាប់
ហើយ [១៤] រួចអេលីសេទូលថា ទូលបង្គំស្បថដោយនូវព្រះយេហូវ៉ា នៃពួកពលបរិវារ ដ៏មានព្រះជន្ម
រស់នៅ ដែលទូលបង្គំឈរនៅចំពោះទ្រង់នេះថា បើទូលបង្គំមិនបានយល់ដល់យ៉ូសាផាត ជាស្តេច
យូដា នោះប្រាកដជាទូលបង្គំមិនព្រមទាំងក្រឡេកមើលទៅទ្រង់ ឬឃើញទ្រង់ទេ [១៥] តែឥឡូវនេះ
សូមនាំអ្នកភ្លេងម្នាក់មកឯទូលបង្គំ រួចកាលអ្នកនោះកំពុងតែលេងភ្លេង នោះព្រះហស្តនៃព្រះយេហូ
វ៉ា ក៏មកលើអេលីសេ [១៦] ហើយលោកទាយថា ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលដូច្នេះ ចូរជីក
ប្រឡាយឲ្យពេញក្នុងច្រកភ្នំនេះទៅ [១៧] ដ្បិតព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា ឯងរាល់គ្នានឹងមិន
ឃើញខ្យល់បក់ ឬភ្លៀងធ្លាក់ឡើយ តែច្រកភ្នំនេះនឹងមានទឹកពេញ នោះឯងរាល់គ្នានឹងបានទឹកផឹក
ព្រមទាំងហ្វូងសត្វ និងសត្វជំនិះរបស់ឯងរាល់គ្នាផង [១៨] ឯការនេះក៏ជាការយ៉ាងតូច នៅព្រះនេត្រ
ព្រះយេហូវ៉ាទេ គឺព្រះទ្រង់នឹងប្រគល់សាសន៍ម៉ូអាប់មកក្នុងកណ្តាប់ព្រះហស្តនៃទ្រង់ទៀត [១៩] ត្រូវ
ឲ្យវាយអស់ទាំងទីក្រុងមានកំផែង និងគ្រប់ទាំងទីក្រុងយ៉ាងវិសេស ព្រមទាំងកាប់អស់ទាំងឈើល្អ
និងខ្ទប់អស់ទាំងរន្ធទឹក ហើយយកដុំថ្មទៅ វាយបង្ខូចអស់ទាំងស្រែចំការល្អៗ [២០] លុះព្រឹកឡើង
នៅពេលថ្វាយដង្វាយ ក៏មានទឹកហូរមកពីខាងស្រុកអេដំម នោះច្រកភ្នំក៏មានទឹកពេញ។

[13] Elisha said to the king of Israel, “Why do you want to involve me? Go to the prophets of your father and the prophets of your mother.”
“No,” the king of Israel answered, “because it was the Lord who called us three kings together to deliver us into the hands of Moab.”
[14] Elisha said, “As surely as the Lord Almighty lives, whom I serve, if I did not have respect for the presence of Jehoshaphat king of Judah, I would not pay any attention to you. [15] But
now bring me a harpist.”
While the harpist was playing, the hand of the Lord came on Elisha [16] and he said, “This is
what the Lord says: I will fill this valley with pools of water. [17] For this is what the Lord says:
You will see neither wind nor rain, yet this valley will be filled with water, and you, your cattle and your other animals will drink. [18] This is an easy thing in the eyes of the Lord; he
will also deliver Moab into your hands. [19] You will overthrow every fortified city and every major town. You will cut down every good tree, stop up all the springs, and ruin every good field with stones.”
[20] The next morning, about the time for offering the sacrifice, there it was water flowing from the direction of Edom! And the land was filled with water.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

*ស្ដេចយ៉ូរ៉ាមសោយរាជ្យនៅស្រុកអ៊ីស្រាអែល សង្គ្រាមរវាងអ៊ីស្រាអែល និងម៉ូអាប់*

លោកអេលីសេមិនចង់ជួយស្ដេចយ៉ូរ៉ាមទេ តែដោយសារយ៉ូសាផាត គាត់បានប្រកាសថា ព្រះជាម្ចាស់នឹងប្រទានទឹកអោយយើងគ្រប់គ្រាន់។ ពួកគេត្រូវតែវាយប្រហារនិងកម្ទេចពួកម៉ូអាប់ចោលបង់។ នៅនាយប់នោះស្រាប់តែមានទឹកហូរកាត់អូរដែលស្ងួតហួតហែងចុះមកក្បែរកន្លែងពួកទាហានបោះជំរុំ ប្រហែលជាមកពីមានព្យុះនៅជើងភ្នំស្រុកអេដុំមហើយមើលទៅ។

សេចក្ដីអធិស្ឋាន

ខែ12
ថ្ងៃសៅរ៍ 07

# ស្តេចយ៉ូរ៉ាមសោយរាជ្យនៅស្រុកអ៊ីស្រាអែល សង្គ្រាមរវាងអ៊ីស្រាអែល និងម៉ូអាប់

២ពង្សាវតារក្សត្រ 3:21-27

ការអធិស្ឋាន

អានអត្ថបទ

[២១] រីឯពួកសាសន៍ម៉ូអាប់ កាលគេបានឮថា ស្តេចទាំងនោះបានឡើងមក ដើម្បីច្បាំងនឹង
ខ្លួន នោះក៏ប្រមូលគ្នា គឺអស់អ្នកណាដែលមានអាយុល្មម នឹងកាន់គ្រឿងសស្ត្រាវុធបាន
រហូតឡើងទៅលើ រួចទៅដំរៀបគ្នានៅត្រង់ព្រំប្រទល់ [២២] ព្រឹកព្រហាមថ្ងៃនោះ ពួកម៉ូអាប់
ក្រោកឡើងឃើញពន្លឺថ្ងៃចាំងមកពីលើទឹក ដែលនៅមុខគេនោះ មើលទៅក្រហមដូចជា
ឈាម [២៣] គេក៏និយាយគ្នាថា នោះគឺជាឈាមហើយ ពួកស្តេចនោះបានប្រហារជីវិតគ្នា
ប្រាកដជាបានសំឡាប់គ្នានឹងគ្នា វិនាសអស់ហើយ ដូច្នេះ ឱពួកម៉ូអាប់អើយ ចូរយើងទៅ
រឹបជាន់ចាប់យករបឹបរបស់គេចុះ [២៤] ដូច្នេះ ក៏នាំគ្នាទៅដល់ទីបោះទ័ពនៃពួកអ៊ីស្រាអែល
តែពួកអ៊ីស្រាអែលក្រោកឡើង ប្រហារពួកម៉ូអាប់ឲ្យគេរត់ទៅនៅមុខខ្លួន ពួកអ៊ីស្រាអែលក៏
ចេះតែដេញតាម វាយពួកម៉ូអាប់ទៅ រហូតដល់ក្នុងស្រុកគេ [២៥] ក៏វាយរំលំអស់ទាំងទីក្រុង
ហើយយកថ្មគ្រប់ៗគ្នា បោះទៅពេញក្នុងអស់ទាំងស្រែចំការល្អ ក៏ខ្ទប់រន្ធទឹកទាំងប៉ុន្មាន
ហើយកាប់អស់ទាំងដើមឈើដែលល្អដែរ មានតែក្រុងគារ-ហារ៉ាសែត ប៉ុណ្ណោះទេ ដែល
គេបានទុកថ្មឲ្យនៅវិញ ប៉ុន្តែពួកបាញ់ក្រួស គេបានឡោមព័ទ្ធវាយទីក្រុងនោះ [២៦] កាល
ស្តេចម៉ូអាប់ឃើញថា ចំបាំងជាខ្លាំងទប់មិនបាន នោះទ្រង់រើសយកទាហាន៧០០នាក់
ដែលកាន់ដាវនាំទៅដោយប្រាថ្នានឹងទំលាយចូលទៅដល់ស្តេចអេដំម តែធ្វើមិនកើត
ទេ [២៧] រួចមកទ្រង់យកបុត្រាច្បង ដែលត្រូវសោយរាជ្យជំនួសទ្រង់ ទៅថ្វាយជាដង្វាយដុត
នៅលើកំផែងក្រុង នោះក៏កើតមានសេចក្តីក្រេវក្រោធចំពោះពួកអ៊ីស្រាអែលជាខ្លាំង
ហើយគ្រប់គ្នាថយចេញត្រឡប់ទៅស្រុកគេរៀងខ្លួនវិញ។

[21] Now all the Moabites had heard that the kings had come to fight against them; so, every
man, young and old, who could bear arms was called up and stationed on the border. [22] When
they got up early in the morning, the sun was shining on the water. To the Moabites across
the way, the water looked red like blood. [23] “That’s blood!” they said. “Those kings must
have fought and slaughtered each other. Now to the plunder, Moab!”
[24] But when the Moabites came to the camp of Israel, the Israelites rose up and fought them
until they fled. And the Israelites invaded the land and slaughtered the Moabites. [25] They
destroyed the towns, and each man threw a stone on every good field until it was covered.
They stopped up all the springs and cut down every good tree. Only Kir Hareseth was left
with its stones in place, but men armed with slings surrounded it and attacked it.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

..........................................................................................

..........................................................................................

..........................................................................................

## ការយល់ដឹងអំពីអត្ថបទ

### *ស្ដេចយ៉ូរ៉ាមសោយរាជ្យនៅស្រុកអ៊ីស្រាអែល សង្គ្រាមរវាងអ៊ីស្រាអែល និងម៉ូអាប់*

នៅពេលព្រឹកឡើង ពួកសម្ព័ន្ធមិត្តដែលមានកម្លាំងខ្លាំងក្លា បានវាយលុកចូលទឹកដីម៉ូអាប់ ហើយកម្ទេចទីក្រុង ដីស្រែ និងព្រៃឈើរបស់ពួកគេអស់រលីង។ ពួកគេហាក់ដូចជាមានសុទិដ្ឋិនិយម ចំពោះជ័យជម្នះជាខ្លាំង តែរំពេចនោះពេលគេវាយចូលជិតដល់ទីបញ្ជាការធំ ស្រាប់តែឃើញស្ដេចម៉ូអាប់ថ្វាយបុត្ររបស់ទ្រង់ជាតង្វាយយញ្ញបូជា។ហេតុការណ៍នេះ ប្រហែលជាពញ្ញាក់អារម្មណ៍ពួកម៉ូអាប់ជាខ្លាំង និងធ្វើអោយពួកអ៊ីស្រាអែលភ័យតក់ស្លុត ហើយក៏ដកទ័ពទៅក្រោយវិញ។ក្រោយបានរួចផុតពីការវាយប្រហារនេះ ពួកម៉ូអាប់ឆក់ឱកាសពង្រឹងស្រុករបស់ខ្លួនភ្លាម ហើយបានចូលរួមនឹងពួកទ័ពព្រៃប្រឆាំងនឹងអ៊ីស្រាអែលវិញ។

សេចក្ដីអធិស្ឋាន

ខែ12
ថ្ងៃអាទិត្យ 08

# ការអធិប្បាយថ្ងៃអាទិត្យ

- ចំណងជើង :
- អត្ថបទ :
- អ្នកអធិប្បាយ :



ពាក្យសម្ដី

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការប្រកបរបស់យើងជាមួយនិងព្រះ



ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

## សេចក្ដីអធិស្ឋាន

ខែ12 ថ្ងៃច័ន្ទ 09

# ហោរាអេលីសេជួយស្ត្រីមេម៉ាយម្នាក់

២ពង្សាវតារក្សត្រ 4:1-7

ការអធិស្ឋាន

អានអត្ថបទ

[១] រីឯមានស្ត្រីម្នាក់ ជាប្រពន្ធនៃពួកសិស្ស របស់ពួកហោរាម្នាក់ នាងបានស្រែកដល់អេលីសេថា ប្ដី
ខ្ញុំ ជាអ្នកបំរើលោក បានស្លាប់ហើយ លោកក៏ជ្រាបថា អ្នកបំរើរបស់លោកបានកោតខ្លាចដល់ព្រះ
យេហូវ៉ាដែរ ឥឡូវនេះ ម្ចាស់បំណុលបានមក ចង់យកកូនខ្ញុំទាំង២ទៅធ្វើជាបាវបំរើ [២] អេលីសេសួរ
នាងថា តើចង់ឲ្យខ្ញុំធ្វើអ្វីឲ្យអ្នក សូមប្រាប់ខ្ញុំចុះ តើអ្នកមានអ្វីនៅផ្ទះ នាងឆ្លើយតបថា នាងខ្ញុំគ្មានអ្វី
នៅផ្ទះទេ មានតែដបប្រេង១ប៉ុណ្ណោះ [៣] ដូច្នេះ លោកប្រាប់ថា ចូរអ្នកចេញទៅខ្ចីភាជនៈ ពីពួកអ្នក
ជិតខាងទាំងប៉ុន្មាន គឺជាភាជនៈ ដែលនៅទទេ ហើយកុំឲ្យខ្ចីតិចឡើយ [៤] រួចឲ្យអ្នកនាំកូនចូលទៅ
ក្នុងផ្ទះ បិទទ្វារទៅ ហើយចាក់ប្រេងទៅក្នុងភាជនៈទាំងនោះ កាលណាមាន១ណាពេញ នោះចូរ
ដាក់ទុកទៅខាងម្ខាង [៥] ដូច្នេះ នាងក៏ចេញពីលោកទៅ នាំកូនចូលទៅក្នុងផ្ទះបិទទ្វារ កូនទាំង២ក៏
ហុចភាជនៈមកឲ្យម្តាយ ហើយម្តាយក៏ចាក់ប្រេងដាក់ [៦] លុះភាជនៈទាំងនោះបានពេញហើយ
នោះនាងបង្គាប់កូនថា ចូរហុច១ទៀតមកឲ្យអញ តែកូនឆ្លើយតបថា មានតែប៉ុណ្ណឹងទេ នោះប្រេង
ក៏ឈប់ហូរទៅ [៧] នាងក៏ទៅជំរាបដល់អ្នកសំណប់របស់ព្រះ ហើយលោកប្រាប់ថា ចូរយកប្រេង
នោះទៅលក់ សងបំណុលគេទៅ ឯចំណែកដែលសល់នៅ នោះចូរទុកចិញ្ចឹមខ្លួន និងកូនចុះ។

[1]The wife of a man from the company of the prophets cried out to Elisha, "Your servant my husband is dead, and you know that he revered the Lord. But now his creditor is coming to take my two boys as his slaves."

[2] Elisha replied to her, "How can I help you? Tell me, what do you have in your house?"

"Your servant has nothing there at all," she said, "except a small jar of olive oil."

[3] Elisha said, "Go around and ask all your neighbors for empty jars. Don't ask for
just a few. [4] Then go inside and shut the door behind you and your sons. Pour oil into all the jars, and as each is filled, put it to one side."

[5] She left him and shut the door behind her and her sons. They brought the jars to
her and she kept pouring. [6] When all the jars were full, she said to her son, "Bring me another one."

But he replied, "There is not a jar left." Then the oil stopped flowing.

[7] She went and told the man of God, and he said, "Go, sell the oil and pay your debts. You and your sons can live on what is left."

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

### *ហោរាអេលីសេជួយស្ត្រីមេម៉ាយម្នាក់*

ត្រង់កន្លែងនេះអ្នកនិពន្ធបានស្លេះពីរឿងរបស់ញាតិវង្ស ហើយបែរមកនិយាយអំពីកិច្ចការរបស់លោកអេលីសេវិញម្តង។ លោកអេលីសេមាននាទីសំខាន់ក្នុងការជំនុំជម្រះរបស់ព្រះជាម្ចាស់ចំពោះរាស្ត្ររបស់ទ្រង់នៅតំបន់ខាងជើង គឺដោយសារតែពួកគេមិនស្មោះត្រង់ជាមួយទ្រង់ក្នុងរជ្ជកាលរបស់ស្តេចអ័រី។អេលីសេមានតួនាទីពង្រឹង និងលើកទឹកចិត្តដល់អស់អ្នកជឿដែលស្មោះត្រង់នឹងព្រះជាម្ចាស់។ មានរឿងហេតុចំនួនប្រាំមួយបានបង្ហាញពីការប្រើប្រាស់អំណាចពិសេសរបស់លោកអេលីសេ ដើម្បីថែរក្សាពួកអ្នកជឿលើព្រះជាម្ចាស់មិនអោយផុតរលត់។ហើយមានរឿងមួយចំនួនទៀតគឺទាក់ទងនឹងការជំនុំជម្រះពួកអ៊ីស្រាអែល។ អស់អ្នកដែលជឿព្រះជាម្ចាស់នៅសេសសល់ ទទួលបានការការពារយ៉ាងអស្ចារ្យ មានស្ត្រីមេម៉ាយដែលជាប្រពន្ធរបស់ហោរាម្នាក់មានបញ្ហាយ៉ាងធ្ងន់ធ្ងរ។។ គាត់គ្មានម្ហូបអាហារនៅសេសសល់ទេហើយហៀបនឹងបាត់បង់ជីវិតកូនប្រុសដែលជាកម្លាំងធ្វើការតែមួយគត់របស់គាត់ទៀត។ លោកអេលីសេបានធ្វើការអស្ចារ្យដោយធ្វើអោយស្ត្រីនោះមានប្រេងយ៉ាងច្រើន យកទៅសងបំណុលគេ។

សេចក្ដីអធិស្ឋាន

ខែ12 ថ្ងៃអង្គារ 10

# ហោរាអេលីសេនៅភូមិស៊ូណែម

## ២ពង្សាវតារក្សត្រ 4:8-17

ការអធិស្ឋាន

អានអត្ថបទ

៨ មានកាល១ថ្ងៃទៀត អេលីសេបានដើរទៅឯក្រុងស៊ូណែម រីឯនៅទីនោះមានស្ត្រីអ្នកធំម្នាក់ នាង
បានឃាត់លោកឲ្យនៅពិសាបាយ រួចមកវេលាណាដែលលោកទៅតាមទីនោះ លោកតែងតែចូល
ទៅពិសាបាយនៅផ្ទះនាង ៩ នាងក៏និយាយនឹងប្ដីថា មើល ខ្ញុំយល់ឃើញថា មនុស្សដែលតែងធ្លាប់
មកផ្ទះយើង ជាញយៗនេះ លោកជាអ្នកបរិសុទ្ធរបស់ព្រះ ១០ សូមឲ្យយើងធ្វើបន្ទប់១តូច នៅលើ
ជញ្ជាំង ព្រមទាំងដាក់គ្រែ តុ កៅអី និងជើងទៀន សំរាប់លោកផង ដូច្នេះ កាលណាលោកមកផ្ទះ
យើង នោះនឹងនៅក្នុងបន្ទប់នោះ ១១ ក្រោយមក មានកាល១ថ្ងៃលោកក៏មកដល់ ហើយចូលទៅសំ
រាន្តក្នុងបន្ទប់នោះ ១២ លោកប្រាប់កេហាស៊ី ជាអ្នកបំរើលោកថា ចូរហៅស្ត្រីដែលនៅក្រុងស៊ូណែម
នេះមក កាលបានហៅស្ត្រីមកដល់ហើយ នោះនាងឈរនៅចំពោះលោក ១៣ រួចលោកប្រាប់អ្នកបំ
រើថា ចូរនិយាយនឹងនាងថា មើល នាងបានចាត់ចែងគោរពដល់យើងជាច្រើនដល់ម៉្លេះ ឥឡូវនេះ
តើត្រូវឲ្យយើងសងគុណដល់នាងយ៉ាងណាខ្លះ តើចង់ឲ្យខ្ញុំទូលដល់ស្តេច ឬជំរាបមេទ័ពធំឲ្យនាង
ឬទេ តែនាងឆ្លើយតបថា នាងខ្ញុំចូលចិត្តនៅតែកណ្តាលពួកសាសន៍នាងខ្ញុំនេះទេ ១៤ លោកសួរ
ទៀតថា បើដូច្នេះ តើត្រូវសងគុណដល់នាងយ៉ាងណា កេហាស៊ីឆ្លើយឡើងថា មើលគាត់គ្មានកូន
ទេ ហើយប្ដីក៏ចាស់ផង ១៥ លោកប្រាប់ថា ចូរហៅនាងមកនេះ កាលបានហៅមកដល់ហើយ នោះ
នាងឈរនៅត្រង់មាត់ទ្វារ ១៦ ហើយលោកប្រាប់ថា ដល់កំណត់ ឆ្នាំក្រោយ នោះនាងនឹងបានបីកូន
ប្រុស១ តែនាងឆ្លើយថា ទេ លោកម្ចាស់ ជាអ្នកសំណប់របស់ព្រះអើយ សូមកុំកុហកដល់នាងខ្ញុំឡើ
យ។ ១៧ ស្ត្រីនោះក៏មានទំងន់ ហើយដល់កំណត់ឆ្នាំក្រោយ នាងសំរាលបានកូនប្រុស១ ដូចពាក្យ
ដែលអេលីសេបានប្រាប់

8 One day Elisha went to Shunem. And a well-to-do woman was there, who urged him to
stay for a meal. So, whenever he came by, he stopped there to eat. 9 She said to her husband,
“I know that this man who often comes our way is a holy man of God. 10 Let’s make a small
room on the roof and put in it a bed and a table, a chair and a lamp for him. Then he can
stay there whenever he comes to us.” 11 One day when Elisha came, he went up to his room
and lay down there. 12 He said to his servant Gehazi, “Call the Shunammite.” So, he called
her, and she stood before him. 13 Elisha said to him, “Tell her, ‘You have gone to all this
trouble for us. Now what can be done for you? Can we speak on your behalf to the king or
the commander of the army?’” She replied, “I have a home among my own people.”
14 “What can be done for her?” Elisha asked. Gehazi said, “She has no son, and her husband
is old.” 15 Then Elisha said, “Call her.” So, he called her, and she stood in the
doorway. 16 “About this time next year,” Elisha said, “you will hold a son in your arms.”
“No, my lord!” she objected. “Please, man of God, don’t mislead your servant!”
17 But the woman became pregnant, and the next year about that same time she gave birth to
a son, just as Elisha had told her.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

..............................................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

..............................................................................................................

## ការយល់ដឹងអំពីអត្ថបទ

### *ហោរាអេលីសេនៅភូមិស៊ូណែម*

មានស្ត្រីដែលស្មោះត្រង់នឹងព្រះជាម្ចាស់ម្នាក់ទៀត ជាភរិយារបស់អ្នកមានម្នាក់ នាងតែងតែទទួលលោកអេលីយ៉ា យ៉ាងរាក់ទាក់ និងផ្គត់ផ្គង់លោកគ្រប់ពេលដែលលោកត្រូវការព្រោះនាងដឹងថា លោកអេលីសេគឺជាអ្នកតំណាងរបស់ព្រះជាម្ចាស់។ដូចជាក្នុងករណីស្ត្រីមេម៉ាយក្រីក្រ លោកអេលីសេបានជួយស្ត្រីនោះដោយសន្យាថា នាងនឹងមានកូនប្រុសមួយនៅថ្ងៃអនាគត។

ការជួយទំនុកបម្រុងដល់អ្នកដឹកនាំ គ្រូផ្សាយដំណឹងល្អ ឬជាគ្រូគង្វាល នោះជារឿងដ៏ប្រសើរប្រពៃ ហើយជាគំរូដ៏សែនល្អសម្រាប់ក្រុមជំនុំ។អ្នកដឹកនាំ ឬគ្រូគង្វាលគាត់ចង់បានការជួយជ្រោមជ្រែងពីពួកជំនុំរបស់គាត់ខ្លាំងណាស់ ពីព្រោះគាត់ជាគ្រូគង្វាលក៏បានជួយព័ន្ធកិច្ចរបស់ព្រះទៅមុខជាលំដាប់ ដូច្នេះគាត់ត្រូវការយើងរាល់ដើម្បីរួមគ្នាកសាងអាណាចក្ររបស់ព្រះជាម្ចាស់ដោយការជួយផ្គត់ផ្គង់ផ្នែកសេដ្ឋកិច្ចជាចាំបាច់សម្រាប់ដំណើរការរបស់ពួកជំនុំរបស់ខ្លួន។

សេចក្ដីអធិស្ឋាន

ខែ12
ថ្ងៃពុធ
11

# ហោរាអេលីសេនៅភូមិស៊ូណែម

## ២ពង្សាវតារក្សត្រ 4:18-31

ការអធិស្ឋាន

អានអត្ថបទ

១៨ កាលកូននោះបានធំឡើងហើយ នោះមានកាល១ថ្ងៃវាចេញទៅឯឪពុក ដែលនៅជាមួយនឹង
ពួកអ្នកច្រូត ១៩ នោះវាត្អូញប្រាប់ឪពុកថា ខ្ញុំឈឺក្បាល ខ្ញុំឈឺក្បាលណាស់ ឪពុកបង្គាប់ទៅអ្នកបំរើ
ថា ចូរបីវាយកទៅឲ្យម្តាយវាទៅ ២០ អ្នកនោះក៏បីយកទៅឲ្យម្តាយ ហើយវាអង្គុយលើភ្លៅម្តាយ
រហូតដល់ថ្ងៃត្រង់ រួចស្លាប់ទៅ ២១ ម្តាយក៏ឡើងទៅ ដាក់វាផ្តេកនៅលើដំណេកនៃអ្នកសំណប់
របស់ព្រះ ហើយបិទទ្វារចេញទៅ ២២ រួចនាងស្រែកទៅប្តីថា សូមចាត់បំរើម្នាក់ និងលា១មកសិន
ដើម្បីឲ្យខ្ញុំរត់ទៅឯអ្នកសំណប់របស់ព្រះ រួចវិលមកវិញ ២៣ ប្តីតបថា ឯងចង់ទៅរកលោកនៅថ្ងៃ
នេះធ្វើអី នេះមិនមែនជាថ្ងៃចូលខែ ឬថ្ងៃឈប់សំរាកទេ តែនាងឆ្លើយថា មិនអីទេ ២៤ នាងក៏ចង
កែបលា រួចបង្គាប់អ្នកបំរើថា ចូរវាយជំរត់វាទៅ កុំបង្អង់ឡើយ លើកតែអញបង្គាប់ គឺយ៉ាងនោះ
ដែលនាងធ្វើដំណើរទៅឯអ្នកសំណប់របស់ព្រះ នៅត្រង់ភ្នំកើមែល។
២៥ កាលអ្នកសំណប់របស់ព្រះ បានឃើញនាងមកពីចំងាយ នោះលោកបង្គាប់ទៅកេហាស៊ី ជាអ្នក
បំរើថា នុ៎ះន៏ស្ត្រីស្រុកស៊ូណែម ២៦ ចូររត់ទៅទទួល ហើយសួរថា តើអ្នកសុខសប្បាយជាទេឬ តើប្តី
របស់អ្នកជាទេឬ ហើយកូនរបស់អ្នកជាឬទេ តែនាងឆ្លើយថា ជាទេ ២៧ កាលបានមកដល់អ្នក
សំណប់របស់ព្រះ នៅលើភ្នំហើយ នោះនាងក៏ចាប់ជើងលោក កេហាស៊ីក៏ចូលទៅ ដើម្បីច្រាននាង
ចេញ តែអ្នកសំណប់របស់ព្រះឃាត់ថា បណ្តោយតាមនាងចុះ ពីព្រោះនាងមានសេចក្តីជូរចត់ក្នុង
ចិត្ត ហើយព្រះយេហូវ៉ាទ្រង់បានលាក់នឹងអញ ឥតសំដែងឲ្យអញដឹងសោះ ២៨ នោះនាងនិយាយ
ឡើងថា តើនាងខ្ញុំបានសូមកូនពីលោកម្ចាស់ឬទេ តើនាងខ្ញុំមិនបានសូមថា កុំបញ្ឆោតនាងខ្ញុំទេឬ
អី ២៩ នោះលោកបង្គាប់កេហាស៊ីថា ចូរក្រវាត់ចង្កេះកាន់ដំបងរបស់អញចេញទៅ បើជួបនឹងអ្នក
ណាតាមផ្លូវ កុំឲ្យគំនាប់គេឡើយ បើអ្នកណាគំនាប់ដល់ឯង ក៏កុំឲ្យគំនាប់តបវិញដែរ ចូរទៅដាក់
ដំបងអញនៅលើមុខកូននោះទៅ ៣០ តែម្តាយរបស់កូននោះនិយាយថា នាងខ្ញុំស្បថ ដោយនូវព្រះ
យេហូវ៉ាដ៏មានព្រះជន្មរស់នៅ ហើយដោយនូវព្រលឹងលោកដ៏នៅរស់ដែរថា នាងខ្ញុំមិនព្រមឃ្លាត
ចេញពីលោកទេ ដូច្នេះ លោកក៏ក្រោកឡើងទៅតាមនាងទៅ ៣១ ឯកេហាស៊ីគាត់ក៏ទៅមុន ហើយ
ដាក់ដំបងនៅលើមុខកូន តែគ្មានឮសំឡេង កូនក៏គ្មានស្តាប់អ្វីដែរ ដូច្នេះ គាត់វិលទៅជួបនឹងអេលី
សេវិញ ជំរាបថា កូនមិនបានភ្ញាក់ទេ។

18 The child grew, and one day he went out to his father, who was with the reapers. 19 He
said to his father, "My head! My head!"
His father told a servant, "Carry him to his mother." 20 After the servant had lifted him up
and carried him to his mother, the boy sat on her lap until noon, and then he died. 21 She
went up and laid him on the bed of the man of God, then shut the door and went out.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

***ហោរាអេលីសេនៅភូមិស៊ូណែម***

ប៉ុន្មានឆ្នាំក្រោយកូនប្រុសនោះបានឈឺហើយស្លាប់ទៅ ប៉ុន្តែស្ត្រីនោះនៅតែមានជំនឿយ៉ាងមាំថា ដោយលោកអេលីសេបានសន្យាហើយថា នាងនឹងមានកូនប្រុសមួយ នោះលោកត្រូវទទួលខុសត្រូវចំពោះសន្យារបស់លោក និងកែតម្រូវភាពមិនប្រក្រតី(ព្រោះអេលីសេបានសន្យាថានឹងអោយកូនមួយដោយនាងមិនបានសុំ)។លោកអេលីសេជាអ្នកតំណាងព្រះជាម្ចាស់ ដូច្នេះនាងមិនគួរស្តាប់នរណាផ្សេងឡើយ។ ភាពស្មោះត្រង់ជាកត្តាចំបាច់សម្រាប់អ្នកបម្រើព្រះយេស៊ូគ្រីស្ទ។ ហើយព្រះជាម្ចាស់ក៏បានស្អប់អំពើបាបនៃការកុហក់ ឬលោភលន់មិនស្មោះត្រង់នេះដែរ។ដូច្នេះទង្វើរបស់កេហាស៊ីនាំមកនៅការដាក់ទណ្ឌកម្មដល់គាត់ជាដាក់ច្បាស់នៅថ្ងៃខាងមុខជាមិនខាន់ឡើយ។

សេចក្តីអធិស្ឋាន

# ហោរាអេលីសេនៅភូមិស៊ូណែម

២ពង្សាវតារក្សត្រ 4:32-37

ការអធិស្ឋាន

អានអត្ថបទ

[៣២] កាលអេលីសេបានចូលទៅក្នុងផ្ទះ ក៏ឃើញកូននោះស្លាប់នៅលើដំណេករបស់លោក [៣៣] ដូច្នេះ
លោកចូលទៅបិទទ្វារ មានតែគ្នា២នាក់ ហើយក៏អធិស្ឋានដល់ព្រះយេហូវ៉ា [៣៤] រួចលោកឡើងទៅ
ពោបលើកូននោះ ដាក់មាត់លោកទល់នឹងមាត់វា ភ្នែកទល់នឹងភ្នែក ហើយដៃនៅលើដៃដែរ ក៏
សន្ធឹងខ្លួនលើវា រួចសាច់កូននោះក៏ក្តៅឧណ្ហឡើង [៣៥] នោះលោកក្រោកចេញទៅ ដើរចុះឡើងនៅ
ក្នុងផ្ទះ រួចឡើងទៅសន្ធឹងខ្លួនលើវាទៀត ហើយវាកណ្តាស់៧ដង រួចបើកភ្នែកឡើង [៣៦] ដូច្នេះ
លោកហៅកេហាស៊ីមកបង្គាប់ថា ចូរទៅហៅស្ត្រីដែលនៅក្រុងស៊ូណែមនេះមក គាត់ក៏ហៅ កាល
នាងបានចូលមកដល់ហើយ នោះលោកប្រាប់ថា ចូរលើកបីកូននាងឡើង [៣៧] នាងក៏ចូលទៅផ្តួល
ខ្លួន ក្រាបចុះដល់ដី នៅទៀបជើងលោក រួចលើកកូនបីចេញទៅ។

[32] When Elisha reached the house, there was the boy lying dead on his couch. [33] He went in,
shut the door on the two of them and prayed to the Lord. [34] Then he got on the bed and lay
on the boy, mouth to mouth, eyes to eyes, hands to hands. As he stretched himself out on
him, the boy's body grew warm. [35] Elisha turned away and walked back and forth in the room
and then got on the bed and stretched out on him once more. The boy sneezed seven times and
opened his eyes.
[36] Elisha summoned Gehazi and said, "Call the Shunammite." And he did. When she came,
he said, "Take your son." [37] She came in, fell at his feet and bowed to the ground. Then she
took her son and went out.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

..................................................................................................

..................................................................................................

..................................................................................................

## ការយល់ដឹងអំពីអត្ថបទ

***ហោរាអេលីសេនៅភូមិស៊ូណែម***

ស្ត្រីនោះបានទាមទារអោយលោកអេលីសេតែម្នាក់ ទៅផ្ទះរបស់នាង។ នាងបានទទួលរង្វាន់ពីជំនឿដ៏រឹងមាំ ដោយលោកអេលីសេបានធ្វើអោយកូនប្រុសនាងរស់ឡើងវិញ។ការទទួលអំណាចចេស្តាពីព្រះជាម្ចាស់ដើម្បីអធិស្ឋានប្រោសលោះ វាជាកត្តាសំខាន់សម្រាប់ជាទីបន្ទាល់ក្នុងដំណឹងល្អរបស់ព្រះជាម្ចាស់ ហើយការអធិស្ឋានដែលពូកែនិងអស្ចារ្យនោះគឺជាការអធិស្ឋានដោយជំនឿជឿដោយឥតសង្ស័យ និងមានទំនុកចិត្តលើព្រះជាម្ចាស់ក្នុងការប្រោសលោះមនុស្សផ្សេងៗបាន។ការសំដែងនូវការអស្ចារ្យរបស់ព្រះជាម្ចាស់វាមិនមែនជាការងាយស្រួលនោះទេ គឺវាបានតម្រូវអោយអ្នកដឹកនាំ គ្រូគង្វាលនោះ គ្រូផ្សាយដំណឹងល្អនោះ បានស្អាតបរិសុទ្ធ និងសុចរិតនៅចំពោះព្រះជាម្ចាស់។ ព្រះបានបំពេញយើងរាល់គ្នាដែលជាអ្នកប្រកាស់ដំណឹងល្អនៃព្រះបានពេញជាព្រះវិញ្ញាណបរិសុទ្ធក្នុងគោលបំណងនៃព្រះគឺចង់អោយសង្ឃរបស់ទ្រង់បាននាំមនុស្សមកថ្វាយទ្រង់ជារៀងរាល់ថ្ងៃដើម្បីអោយនគរព្រះបានរីកចម្រើនឡើង។

សេចក្តីអធិស្ឋាន

ខែ12 ថ្ងៃសុក្រ 13

# បបរមានជាតិពុល

## ២ពង្សាវតារក្សត្រ 4:38-44

ការអធិស្ឋាន

អានអត្ថបទ

[៣៨] ឯអេលីសេ លោកត្រឡប់ទៅឯក្រុងគីលកាលវិញទៀត ហើយមានអំណត់នៅក្នុងស្រុកនោះ ឯ
ពួកសិស្សរបស់ពួកហោរា គេអង្គុយចំពោះមុខលោក ហើយលោកបង្គាប់អ្នកបំរើថា ចូរដាក់ថ្លាងធ្វើ
បបរ ឲ្យពួកសិស្សហោរាទាំងនេះទៅ
[៣៩] មានម្នាក់ចេញទៅរកបន្លែឯទីវាល ក៏ឃើញវល្លិព្រៃ ហើយ
បេះផ្លែពេញថ្នក់អាវ វិលមកកាប់ជាកង់ៗ ដាក់ចុះទៅក្នុងថ្លាង ដ្បិតគេមិនបានស្គាល់ផ្លែនោះ
ទេ
[៤០] រួចគេដួសបបរនោះឲ្យគ្រប់គ្នាបរិភោគ តែកាលគេកំពុងតែបរិភោគ នោះក៏ស្រែកឡើងថា ឱ
អ្នកសំណប់របស់ព្រះអើយ បបរនេះពុលទេ ហើយគេបរិភោគពុំបាន
[៤១] តែលោកប្រាប់ថា ដូច្នេះ
ចូរយកម្សៅមកចុះ រួចលោកក៏ចាក់ទៅក្នុងថ្លាង ហើយប្រាប់ថា ចូរដួសចែកឲ្យគេបរិភោគទៅ នោះ
ក៏គ្មានជាតិពុលនៅក្នុងបបរទៀតឡើយ។
[៤២] នៅគ្រានោះ មានមនុស្សម្នាក់ មកពីស្រុកបាល-សាលីសា គាត់យកនំបុ័ងម្សៅឱក២០ដុំធ្វើពី
ផលដំបូង និងគួរស្រូវស្រស់ មកជូនដល់អ្នកសំណប់របស់ព្រះ នោះលោកប្រាប់ថា ចូរចែកឲ្យប
ណ្ដាជនបរិភោគទៅ
[៤៣] អ្នកបំរើលោកសួរថា តើធ្វើដូចម្ដេចឲ្យខ្ញុំដាក់តែប៉ុណ្ណេះ ឲ្យមនុស្ស១០០
នាក់បរិភោគបាន តែលោកបង្គាប់ថា ចូរចែកឲ្យគេបរិភោគទៅ ដ្បិតព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូល
ដូច្នេះថា គេនឹងបរិភោគឆ្អែត ហើយនឹងនៅមានសល់ផង
[៤៤] ដូច្នេះ គាត់ក៏ដាក់ឲ្យគេបរិភោគ ហើយ
គេបានឆ្អែត រួចនៅមានសល់ ដូចជាព្រះយេហូវ៉ាបានមានព្រះបន្ទូលហើយ។

[38] Elisha returned to Gilgal and there was a famine in that region. While the company of the
prophets was meeting with him, he said to his servant, “Put on the large pot and cook some
stew for these prophets.”
[39] One of them went out into the fields to gather herbs and found a
wild vine and picked as many of its gourds as his garment could hold. When he returned, he
cut them up into the pot of stew, though no one knew what they were.
[40] The stew was poured
out for the men, but as they began to eat it, they cried out, “Man of God, there is death in the
pot!” And they could not eat it.
[41] Elisha said, “Get some flour.” He put it into the pot and
said, “Serve it to the people to eat.” And there was nothing harmful in the pot.
[42] A man came
from Baal Shalishah, bringing the man of God twenty loaves of barley bread baked from the
first ripe grain, along with some heads of new grain. “Give it to the people to eat,” Elisha
said.
[43] “How can I set this before a hundred men?” his servant asked. But Elisha answered,
“Give it to the people to eat. For this is what the Lord says: ‘They will eat and have some left
over.’”
[44] Then he set it before them, and they ate and had some left over, according to the
word of the Lord.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

***បបរមានជាតិពុល***

អេលីសេបានធ្វើដំណើរទៅកាន់សាលារបស់ពួកហោរាក្មេងៗដើម្បីជួយបង្រៀន និងលើកទឹកចិត្តគេអោយមានជំនឿមាំមួន។ នៅសាលារៀនមួយនោះមានគ្រោះទុរភិក្សកើតឡើងមនុស្សទាំងអស់ត្រូវហូបបន្លែដុះនៅតាមព្រៃ។ ក្នុងកាលៈទេសៈនោះពួកគេបានជួបប្រទះនឹងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ពេលដែលមានគ្នារបស់ពួកគេម្នាក់ច្រឡំបេះបន្លែពុលយកមកស្ល។ តាមរយៈលោកអេលីសេព្រះជាម្ចាស់បានជួយសង្គ្រោះពួកគេដោយសេចក្ដីស្រលាញ់។ ព្រះជាម្ចាស់បានបង្ហាញនៅសេចក្ដីស្រលាញ់ និងការឃុំគ្រងរបស់ព្រះអង្គម្ដងទៀត គឺក្នុងពេលកសិករម្នាក់យកអាហារមកអោយពួកគេ ដែលអាចផ្គត់ផ្គង់លោកអេលីសេ និងពួកសិស្សចំនួនមួយរយនាក់ទៀតបាន។

សេចក្ដីអធិស្ឋាន

ខែ12 ថ្ងៃសៅរ៍ 14

# លោកមេទ័ពណាម៉ាន់បានជាពីរោគឃ្លង់

## ២ពង្សាវតារក្សត្រ 5:1-14

ការអធិស្ឋាន

អានអត្ថបទ

១ រីឯណាម៉ាន់ជាមេទ័ពរបស់ស្តេចស៊ីរី លោកជាអ្នកធំនៅចំពោះចៅហ្វាយខ្លួន ក៏មានយសខ្ពស់ ដោយព្រោះ
ព្រះយេហូវ៉ាបានប្រោស ឲ្យពួកស៊ីរីមានជ័យជំនះ ដោយសារលោក លោកក៏ជាមនុស្សខ្លាំងពូកែដែរ តែកើត
រោគឃ្លង់ ២ គ្រានោះ ពួកទ័ពស៊ីរីបានចេញ ទៅដោយកងៗ គេចាប់ក្មេងស្រីម្នាក់ នាំមកពីស្រុកអ៊ីស្រាអែល
នាងនោះក៏បំរើប្រពន្ធណាម៉ាន់ ៣ នាងនិយាយនឹងចៅហ្វាយស្រីរបស់ខ្លួនថា ឱបើជាលោកប្រុស ជាចៅហ្វាយ
នាងខ្ញុំ បាននៅជាមួយនឹងហោរាដែលនៅក្រុងសាម៉ារីទៅអេះ នោះលោកនឹងមើលរោគឃ្លង់នេះឲ្យជា
ទៅ ៤ នោះមានម្នាក់ចូលទៅជំរាបចៅហ្វាយខ្លួនថា ក្មេងស្រីដែលមកពីស្រុកអ៊ីស្រាអែល វានិយាយយ៉ាងនេះ
មួយៗ ៥ ដូច្នេះ ស្តេចស៊ីរីមានព្រះបន្ទូលថា ចូរទៅចុះ អញនឹងធ្វើសំបុត្រ១ផ្ញើទៅស្តេចអ៊ីស្រាអែលដែរ នោះ
លោកក៏ចេញទៅ នាំយកទាំងប្រាក់១០ហាប និងមាស៦ពាន់ ហើយសំលៀកបំពាក់១០បន្លាស់ ៦ លោកក៏នាំ
យកសំបុត្រនោះទៅថ្វាយស្តេចអ៊ីស្រាអែល មានសេចក្តីថា កាលណាទ្រង់ទទួលសំបុត្រនេះ នោះមើលទូល
បង្គំបានចាត់ណាម៉ាន់ ជាអ្នកជំនិតរបស់ទូលបង្គំមកហើយ ដើម្បីឲ្យទ្រង់បានប្រោសឲ្យគាត់រួចពីរោគ
ឃ្លង់ ៧ កាលស្តេចអ៊ីស្រាអែលទ្រង់បានទតសំបុត្រនោះរួចហើយ នោះក៏ហែកព្រះពស្ត្រទ្រង់ ដោយព្រះបន្ទូល
ថា តើយើងជាព្រះដែលអាចនឹងធ្វើឲ្យស្លាប់ ឬឲ្យរស់បានឬ បានជាគេចាត់ឲ្យមនុស្សឃ្លង់នេះមក ចង់ឲ្យយើង
មើលរោគឲ្យជាដូច្នេះ ចូរពិចារណាមើល ជាយ៉ាងណា ដែលគេរករឿងនឹងយើងនេះ។
៨ កាលអេលីសេ ជាអ្នកសំណប់របស់ព្រះ បានឮថា ស្តេចអ៊ីស្រាអែលបានហែកព្រះពស្ត្រទ្រង់ដូច្នោះ នោះក៏
ចាត់គេឲ្យទៅទូលសួរស្តេចថា ហេតុអ្វីបានជាទ្រង់ហែកព្រះពស្ត្រដូច្នេះ សូមឲ្យលោកនោះមកឯទូលបង្គំសិន
ចុះ នោះលោកនឹងបានជ្រាបថា មានហោរា១នៅពួកអ៊ីស្រាអែលមែន ៩ ដូច្នេះ ណាម៉ាន់ក៏មកឈរនៅមាត់ទ្វារ
ផ្ទះរបស់អេលីសេ មានទាំងសេះ និងរទេះផង ១០ ឯអេលីសេ លោកចាត់អ្នកបំរើម្នាក់ ឲ្យទៅជំរាបថា សូមឲ្យ
លោកទៅមុជទឹកក្នុងទន្លេយ័រដាន់៧ដងទៅ នោះសាច់របស់លោកនឹងបានជា ហើយលោកនឹងបានស្អាត
ឡើងវិញ ១១ តែណាម៉ាន់មានសេចក្តីកំហឹង ហើយក៏ចេញទៅ ដោយពោលថា មើល អញស្មានថាប្រាកដជា
លោកនឹងចេញមកឯអញ ឈរអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា ជាព្រះនៃលោក ហើយរាដៃពីលើដំបៅឲ្យ
រោគឃ្លង់បានជា ១២ ឯទន្លេអាបាណា និងទន្លេផើផើរ ជាទន្លេស្រុកដាម៉ាស តើមិនល្អជាងទឹកទាំងឡាយ នៅ
ស្រុកអ៊ីស្រាអែលទេឬអី បើអញមុជទឹកទន្លេនោះ តើមិនបានស្អាតទេឬអី ដូច្នេះ លោកក៏ត្រឡប់ចេញពីទីនោះ
ទៅ ដោយសេចក្តីឃោរឃៅជាខ្លាំង ១៣ តែពួកអ្នកបំរើលោកក៏អែបចូលជិត ជំរាបថា លោកឪពុកអើយ បើសិន
ជាហោរានោះបានប្រាប់ឲ្យលោកធ្វើការអ្វីយ៉ាងធំ នោះតើលោកមិនធ្វើតាមទេឬអី ចំណង់បើលោកគ្រាន់តែឲ្យ
ទៅមុជទឹកប៉ុណ្ណោះ ដើម្បីឲ្យបានស្អាត តើនឹងគួរធ្វើតាមជាជាងអំបាលម៉ានទៅទៀត ១៤ ដូច្នេះ លោកក៏ចុះទៅ
មុជទឹកក្នុងទន្លេយ័រដាន់អស់៧ដង តាមពាក្យនៃអ្នកសំណប់របស់ព្រះ នោះសាច់របស់លោកក៏ដុះឡើងជាថ្មី
ដូចជាសាច់របស់ក្មេង ហើយលោកបានជាស្អាត។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

.............................................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

.............................................................................................................

## ការយល់ដឹងអំពីអត្ថបទ

### *លោកមេទ័ពណាម៉ាន់បានជាពីរោគឃ្លង់*

ស្រុកស៊ីរីគឺជាប្រទេសមួយស្ថិតនៅជិតខាងអ៊ីស្រាអែល ដែលមានអំណាចខ្លាំងជាងគេក្នុងជំនាន់លោកអេលីសេ ហើយតែងតែបង្កជម្លោះនៅតាមព្រំដែនជាញឹកញាប់។ នៅពេលមេទ័ពធំម្នាក់របស់ប្រទេសស៊ីរី ឈ្មោះណាម៉ាន់ បានមកស្រុកអ៊ីស្រាអែលដើម្បីសុំអោយជួយព្យាបាលជំងឺឃ្លង់ នោះស្តេចអ៊ីស្រាអែលចាត់ទុកថា នេះគឺជាកលល្បិចបង្កសង្គ្រាមទេ។ប៉ុន្តែចំពោះលោកអេលីសេវិញគាត់យល់ឃើញថា នេះជាឱកាសសម្រាប់បង្ហាញពីអំណាចចេស្តារបស់ព្រះជាម្ចាស់ចំពោះមេទ័ពស៊ីរីនោះវិញ។ ហើយមេទ័ពនេះគឺជាអ្នកដែលព្រះរក្សាទុកសម្រាប់ដឹកនាំមកប្រឆាំងនឹងអ៊ីស្រាអែល។លោកណាម៉ាន់មិនស្គាល់ព្រះជាម្ចាស់ច្បាស់ទេ តែវាក៏ប្រសើរជាងពួកកូនចៅអ៊ីស្រាអែលជាច្រើននាក់ខ្លះទៀតដែរ។

សេចក្តីអធិស្ឋាន

ខែ12
ថ្ងៃអាទិត្យ 15

# ការអធិប្បាយថ្ងៃអាទិត្យ

- ចំណងជើង :
- អត្ថបទ :
- អ្នកអធិប្បាយ :



ការប្រកបរបស់យើងជាមួយនិងព្រះ

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ



ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

## សេចក្ដីអធិស្ឋាន

ខែ12 ថ្ងៃច័ន្ទ 16

# កំហុសរបស់កេហាស៊ី

## ២ពង្សាវតារក្សត្រ 5:15-27

ការអធិស្ឋាន

អានអត្ថបទ

១៥ រួចលោក ព្រមទាំងពួកលោក ក៏វិលទៅឯអ្នកសំណប់របស់ព្រះវិញ ឈរនៅចំពោះមុខជំរាបថា មើលឥឡូវ
នេះខ្ញុំដឹងថា នៅផែនដីទាំងមូល គ្មានព្រះឯណាសោះ វៀរតែព្រះនៃសាសន៍អ៊ីស្រាអែល១ប៉ុណ្ណោះ ដូច្នេះ សូម
លោកទទួលរង្វាន់ពីខ្ញុំប្របាទចុះ ១៦ តែលោកឆ្លើយតបថា ខ្ញុំស្បថ ដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់នៅ
ដែលខ្ញុំឈរនៅចំពោះទ្រង់ថា ខ្ញុំមិនទទួលយកអ្វីសោះឡើយ ណាម៉ាន់ក៏អង្វរឲ្យទទួល តែលោកប្រកែកមិន
ព្រមទេ ១៧ ណាម៉ាន់និយាយថា បើដូច្នេះ សូមតែឲ្យដីល្មមផ្ទុកលើលាកាត់២មកខ្ញុំប្របាទចុះ ដ្បិតពីនេះទៅមុខ
ខ្ញុំប្របាទនឹងមិនថ្វាយដង្វាយដុត ឬយញ្ញបូជាដល់ព្រះឯណាទៀត ក្រៅពីព្រះយេហូវ៉ាឡើយ ១៨ តែក្នុងការនេះ
សូមព្រះយេហូវ៉ាអត់ទោសដល់ខ្ញុំប្របាទផង គឺកាលចៅហ្វាយខ្ញុំប្របាទព្រយុងខ្លួនមកលើដៃខ្ញុំ ចូលទៅថ្វាយ
បង្គំក្នុងវិហារព្រះរីម៉ូនវេលាណា ហើយខ្ញុំប្របាទក៏ឱនខ្លួននៅក្នុងវិហារព្រះរីម៉ូន នោះសូមព្រះយេហូវ៉ាអត់
ទោសដល់ខ្ញុំប្របាទ ពីការដែលឱនខ្លួននៅក្នុងវិហារព្រះរីម៉ូននោះផង ១៩ អេលីសេក៏និយាយថា អញ្ជើញទៅ
ដោយសុខសាន្តចុះ ដូច្នេះ ណាម៉ាន់ក៏ចេញពីលោកទៅតាមផ្លូវបន្តិច។

២០ ឯកេហាស៊ី ជាអ្នកបំរើរបស់អេលីសេ ជាអ្នកសំណប់របស់ព្រះ គាត់នឹកថា មើល ចៅហ្វាយអញបានយល់
ដល់ណាម៉ាន់ជាសាសន៍ស៊ីរីនោះ ដោយមិនបានទទួលរបស់ស្នងពីដៃលោក ដែលនាំមកជូននោះសោះ អញ
ស្បថ ដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់នៅថា អញនឹងរត់ទៅតាម ហើយទទួលយករបស់ខ្លះពីលោក
វិញ ២១ ដូច្នោះ កេហាស៊ីក៏ទៅតាមណាម៉ាន់ កាលណាម៉ាន់ឃើញម្នាក់កំពុងរត់មកតាម នោះលោកក៏ចុះពីរទេះ
ទៅទទួល ហើយសួរថា សុខសប្បាយទាំងអស់គ្នាទេឬ ២២ គាត់ឆ្លើយថា សុខសប្បាយជាទេ តែចៅហ្វាយខ្ញុំ
បានចាត់ខ្ញុំឲ្យមកជំរាបលោកថា មើល មានមនុស្សកំឡោះ២នាក់ជាសិស្សនៃពួកហោរា ទើបនឹងមកដល់ ពី
ស្រុកភ្នំអេប្រាអិម ដូច្នេះ សូមលោកមេត្តាឲ្យប្រាក់១ហាប និងសំលៀកបំពាក់ ២បន្លាស់មកសំរាប់គេ ២៣ ណា
ម៉ាន់ឆ្លើយតបថា សូមឲ្យអ្នកបានសុខចិត្តយកដល់ទៅ២ហាបចុះ លោកក៏បង្ខំ រួចដាក់ប្រាក់២ហាបចុះក្នុង
ការុង២ ព្រមទាំងឲ្យអាវ២បន្លាស់ ដាក់ឲ្យអ្នកបំរើរបស់លោក២នាក់បានលីទៅខាងមុខកេហាស៊ី ២៤ លុះដល់
ទៅភ្នំហើយ នោះគាត់យកដៃគេទៅដាក់ទុកក្នុងផ្ទះ រួចឲ្យគេទៅវិញ គេក៏ចេញទៅ ២៥ លំដាប់នោះគាត់ចូល
ទៅឈរនៅមុខអេលីសេជាចៅហ្វាយខ្លួន ហើយលោកសួរថា កេហាស៊ីអើយ ឯងមកពីណា គាត់ឆ្លើយថា ខ្ញុំ
ប្របាទមិនបានទៅឯណាទេ ២៦ តែលោកមានប្រសាសន៍ថា តើវិញ្ញាណអញមិនបានទៅតាមឯង ក្នុងកាល
ដែលលោកនោះចុះពីរទេះមកទទួលឯងទេឬអី នេះតើជាឱកាសគួរនឹងទទួលប្រាក់ និងសំលៀកបំពាក់ ព្រម
ទាំងចំការអូលីវ ចំការទំពាំងបាយជូរ និងចៀម គោ ហើយបាវប្រុសបាវស្រីឬអី ២៧ ហេតុនេះរោគឃ្លង់របស់
ណាម៉ាន់នឹងនៅជាប់នឹងឯងវិញ ព្រមទាំងកូនចៅឯងជារៀងរាបដរាបទៅ ដូច្នេះគាត់ក៏ចេញពីមុខលោកទៅ
កើតមានរោគឃ្លង់សដូចហិមៈតែម្តង។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

..........................................................................................

..........................................................................................

..........................................................................................

## ការយល់ដឹងអំពីអត្ថបទ

***កំហុសរបស់កេហាស៊ី***

លោកអេលីសេមិនព្រមយកប្រាក់ឈ្នួលព្យាបាលទេ ពីព្រោះលោកជាអ្នកបម្រើព្រះជាម្ចាស់ មិនមែនជាអ្នកធ្វើការដើម្បីប្រាក់នោះទេ។ ប៉ុន្តែហោរាភាគច្រើនរស់នៅក្នុងភាពក្រខ្សត់ ហើយកេហាស៊ីមិនអាចគេចពីសេចក្តីល្បួងក្នុងការស្វែងរកលាភសក្ការៈពីហេតុការណ៍អស្ចារ្យបាន។គាត់ត្រូវទទួលទណ្ឌកម្មដោយកើតរោគឃ្លង់ ជំនួសលោកណាម៉ាន់វិញ។ដំណឹងល្អនៃព្រះមិនមែនតម្រូវតែជាតិសាសន៍របស់យើងតែប៉ុណ្ណោះទេ តែយើងក៏ត្រូវផ្តល់ចែកចាយសេចក្តីស្រលាញ់នៃព្រះតាមរយៈការផ្សព្វផ្សាយព្រះបន្ទូលនឹងការអស្ចារ្យរបស់ទ្រង់ទៅកាន់មនុស្សគ្រប់ជាតិសាសន៍ទាំងអស់ ដោយមិនរើសអើង ឬប្រកាន់ជាតិសាសន៍ឡើយ។

សេចក្តីអធិស្ឋាន

ខែ12
ថ្ងៃអង្គារ៍ 17

# ផ្លែពូថៅអណ្តែត

## ២ពង្សាវតារក្សត្រ 6:1-7

ការអធិស្ឋាន

អានអត្ថបទ

១ គ្រានោះ ពួកសិស្សរបស់ពួកហោរា គេជំរាបដល់អេលីសេថា សូមមើល ទីកន្លែងដែលយើងខ្ញុំនៅជាមួយនឹង
លោកនេះ ចង្អៀតដល់យើងខ្ញុំពេកណាស់ ២ សូមបើកឲ្យយើងខ្ញុំទៅឯទន្លេយ័រដាន់ កាប់យកឈើមួយដើម
ម្នាក់ ធ្វើជាទីអាស្រ័យនៅទីនោះ លោកឆ្លើយថា ចូរទៅចុះ ៣ មានម្នាក់និយាយថា សូមលោកអញ្ជើញទៅជា
មួយនឹងយើងខ្ញុំប្របាទផង លោកតបថា អញនឹងទៅដែរ ៤ ដូច្នេះ លោកក៏ទៅជាមួយ លុះគេបានទៅដល់ទន្លេ
យ័រដាន់ហើយ នោះក៏កាប់ឈើ ៥ តែកាលម្នាក់កំពុងតែកាប់ នោះផ្លែពូថៅបានរបូតធ្លាក់ទៅក្នុងទឹក រួចអ្នក
នោះស្រែកឡើងថា វរហើយ លោកម្ចាស់ខ្ញុំអើយ ដ្បិតពូថៅនេះខ្ញុំបានខ្ចីមកពីគេ ៦ អ្នកសំណប់របស់ព្រះសួរ
ថា តើធ្លាក់ត្រង់ណា អ្នកនោះក៏បង្ហាញកន្លែង រួចលោកកាប់មែកឈើ១កំណាត់ បោះទៅក្នុងទឹក ហើយផ្លែ
ពូថៅក៏អណ្តែតឡើងមក ៧ នោះលោកបង្គាប់ថា ចូរចាប់យកចុះ អ្នកនោះក៏លូកដៃទៅចាប់យកមក។

1 The company of the prophets said to Elisha, "Look, the place where we meet with you is
too small for us. 2 Let us go to the Jordan, where each of us can get a pole; and let us build a
place there for us to meet." And he said, "Go." 3 Then one of them said, "Won't you please
come with your servants?" "I will," Elisha replied. 4 And he went with them.
They went to the Jordan and began to cut down trees. 5 As one of them was cutting down a
tree, the iron axhead fell into the water. "Oh no, my lord!" he cried out. "It was borrowed!"
6 The man of God asked, "Where did it fall?" When he showed him the place, Elisha cut a
stick and threw it there, and made the iron float. 7 "Lift it out," he said. Then the man reached
out his hand and took it.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

### *ផ្លែពូថៅអណ្តែត*

មានសាលាហោរាមួយកន្លែងត្រូវជួសជុល ប៉ុន្តែក្នុងពេលកំពុងជួសជុលនោះ គេធ្វើអោយជ្រុះបាត់ផ្លែពូថៅដែលខ្ចីគេមក។សម្រាប់អ្នកក្រីក្រ នោះការបាត់ផ្លែពូថៅមួយ មិនមែនជារឿងតូចតាចទេ ហើយលើកនេះដែរ ព្រះជាម្ចាស់បានផ្គត់ផ្គង់តម្រូវការរបស់ពួកគេ បង្ហាញអោយឃើញថាគេអាចពឹងអាងលើព្រះអង្គជានិច្ច។ រឿងរ៉ាវផ្សេងៗទៀតរបស់លោកអេលីសេផ្តោតទៅលើកិច្ចការដែលគាត់ដោះស្រាយជាមួយនឹងពួកមេដឹកនាំអ៊ីស្រាអែល និងពួកស៊ីរី។ ព្រះជាម្ចាស់នឹងប្រើពួកស៊ីរីដើម្បីដាក់ទណ្ឌកម្មអ៊ីស្រាអែលដែលបានធ្វើអំពើបាបក្នុងកំឡុងរាជ្យរបស់ស្តេចអ៊ុំរី ប៉ុន្តែមុនដំបូងព្រះជាម្ចាស់មានមេរៀនពីរសម្រាប់បង្រៀនប្រជាជាតិទាំងពីរនេះ។

សេចក្តីអធិស្ឋាន

ខែ12
ថ្ងៃពុធ 18

# ហោរាអេលីសេចាប់ទាហានស៊ីរីមកជាឈ្លើយ

## ២ពង្សាវតារក្សត្រ 6:8-23

ការអធិស្ឋាន

អានអត្ថបទ

៨ រីឯស្តេចស្រុកស៊ីរី ទ្រង់កំពុងតែច្បាំងនឹងសាសន៍អ៊ីស្រាអែល ក៏ហៅពួកអ្នកជំនិតទ្រង់មកពិគ្រោះគ្នា រួច
បង្គាប់ថា យើងនឹងបោះទ័ពនៅទីណាមួយនោះ ៩ ដូច្នេះ អ្នកសំណប់របស់ព្រះ លោកចាត់គេឲ្យទៅទូលដល់
ស្តេច អ៊ីស្រាអែលថា សូមទ្រង់ប្រយ័ត្ន កុំយាងទៅតាមទី១នោះឡើយ ដ្បិតពួកស៊ីរីគេចុះមកតាមផ្លូវនោះ
ហើយ ១០ ស្តេចអ៊ីស្រាអែលក៏ចាត់គេ ឲ្យទៅឯកន្លែងណាដែលអ្នកសំណប់របស់ព្រះបានប្រាប់ឲ្យប្រយ័ត្ន
នោះ ទ្រង់ក៏បានរួចពីសេចក្តីអន្តរាយនៅទីទាំងនោះ មិនមែនតែម្តង ឬពីរដងប៉ុណ្ណោះទេ ១១ ឯស្តេចស្រុកស៊ីរី
ទ្រង់មានព្រះទ័យវល់អំពីដំណើរនោះ ក៏ហៅពួកអ្នកជំនិតមកសួរថា តើអ្នករាល់គ្នាមិនព្រមប្រាប់ឲ្យយើងដឹង
ជាអ្នកណាក្នុងពួកយើង ដែលកាន់ខាងស្តេចអ៊ីស្រាអែលទេឬ ១២ នោះអ្នកជំនិតទ្រង់ម្នាក់ទូលតបថា បពិត្រ
ព្រះករុណា ជាព្រះអម្ចាស់នៃទូលបង្គំអើយ ឥតមានអ្នកណាឡើយ គឺជាអេលីសេ ជាហោរា ដែលនៅស្រុកអ៊ី
ស្រាអែលវិញ គាត់នាំយកអស់ទាំងព្រះបន្ទូល ដែលទ្រង់មានព្រះបន្ទូល នៅក្នុងក្រឡាព្រះបន្ទំរបស់ទ្រង់ ទៅ
ប្រាប់ដល់ស្តេចអ៊ីស្រាអែល ១៣ រួចទ្រង់បង្គាប់ថា ចូរទៅសង្កេតមើលកន្លែងណាដែលវានៅ ដើម្បីឲ្យអញបាន
ចាត់គេឲ្យទៅចាប់នាំមក នោះមានគេទូលទ្រង់ថា មើល គាត់នៅឯក្រុងដូថាន់។ ១៤ ដូច្នេះ ទ្រង់ក៏ចាត់ពល
សេះ រទេះចំបាំង និងពួកទ័ពសន្ធឹកឲ្យចេញទៅ គេក៏ទៅឡោមព័ទ្ធទីក្រុងនោះទាំងយប់ ១៥ ឯអ្នកបំរើនៃអ្នក
សំណប់របស់ព្រះ កាលបានក្រោកពីព្រលឹមចេញទៅក្រៅ នោះឃើញមានពលទ័ពដែលមានទាំងសេះ និងរទេះចំបាំង នៅ
ព័ទ្ធជុំវិញទីក្រុង រួចអ្នកបំរើជំរាបលោកថា វរហើយ ចៅហ្វាយខ្ញុំអើយ តើយើងនឹងធ្វើដូចម្តេច ១៦ លោកឆ្លើយតបថា កុំខ្លាច
អ្វីឡើយ ដ្បិតពួកដែលនៅខាងយើង មានគ្នាច្រើនជាងពួកដែលនៅខាងគេទៅទៀត ១៧ នោះអេលីសេក៏អធិស្ឋានថា ឱ
ព្រះយេហូវ៉ាអើយ សូមទ្រង់ប្រោសឲ្យភ្នែកវាបានមើលឃើញ ព្រះយេហូវ៉ាទ្រង់ក៏ប្រោសភ្នែកអ្នកបំរើនោះ ហើយវាក៏មើល
ទៅឃើញភ្នំនោះ មានពេញដោយពលសេះ និងរទេះចំបាំង ដែលសុទ្ធតែជាភ្លើង នៅព័ទ្ធជុំវិញអេលីសេ ១៨ កាលបានចុះ
មកដល់អេលីសេហើយ នោះលោកអធិស្ឋានដល់ព្រះយេហូវ៉ាថា សូមព្រះអង្គវាយពួកស៊ីរីនេះ ឲ្យភ្នែកគេត្រូវថ្កើនទៅ ដូច្នេះ
ទ្រង់ក៏ធ្វើឲ្យភ្នែកគេ ត្រូវថ្កើនតាមពាក្យអេលីសេ ១៩ ហើយអេលីសេប្រាប់គេថា មិនមែនផ្លូវនេះ ហើយមិនមែនទីក្រុងនេះដែរ
សូមមកតាមខ្ញុំចុះ ខ្ញុំនឹងនាំអ្នករាល់គ្នាទៅឯមនុស្ស ដែលត្រូវរកនោះ តែលោកនាំគេទៅឯក្រុងសាម៉ារីវិញ។
២០ លុះគេបានចូលទៅក្នុងក្រុងសាម៉ារីហើយ នោះអេលីសេអធិស្ឋានថា ឱព្រះយេហូវ៉ាអើយ សូមទ្រង់ធ្វើឲ្យភ្នែកមនុស្ស
ទាំងនេះបានភ្លឺឡើង ដើម្បីឲ្យមើលឃើញវិញ ព្រះយេហូវ៉ាទ្រង់ក៏ប្រោសប្រទានឲ្យភ្នែកគេបានភ្លឺឡើងវិញ ឲ្យគេបានមើល
ឃើញ នោះក៏ឃើញថា គេនៅកណ្តាលក្រុងសាម៉ារីហើយ ២១ កាលស្តេចអ៊ីស្រាអែលបានឃើញគេ នោះទ្រង់មានព្រះ
បន្ទូលសួរអេលីសេថា លោកឪពុកអើយ តើត្រូវឲ្យប្រហារជីវិតគេ តើត្រូវសំឡាប់គេឬអី ២២ លោកទូលឆ្លើយថា មិនត្រូវ
ប្រហារគេទេ តើនឹងវាយសំឡាប់ពួកឈ្លើយ ដែលចាប់ក្នុងការសង្គ្រាមឬអី សូមដាក់នំបុ័ង និងទឹកមក នៅមុខគេឲ្យ
បរិភោគវិញ រួចឲ្យត្រឡប់ទៅឯចៅហ្វាយគេទៅ ២៣ ដូច្នេះ ស្តេចក៏ចាត់ចែងភោជនាហារយ៉ាងច្រើនឲ្យគេ កាលគេបាន
បរិភោគរួចហើយ នោះទ្រង់លែងឲ្យទៅវិញ ហើយគេវិលត្រឡប់ទៅឯចៅហ្វាយខ្លួនទៅ ឯសាសន៍ស៊ីរីក៏លែងទន្ទ្រានចូល
ក្នុងស្រុកអ៊ីស្រាអែលដោយពួកៗទៀត។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

.......................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

.......................................................................

## ការយល់ដឹងអំពីអត្ថបទ

### *ហោរាអេលីសេចាប់ទាហានស៊ីរីមកជាឈ្លើយ*

មានគ្រាមួយនោះពេលទ័ពអ៊ីស្រាអែលនិងទ័ពស៊ីរីកំពុងប្រយុទ្ធគ្នា លោកអេលីសេបានប្រាប់ស្តេចអ៊ីស្រាអែលម្តងហើយម្តងទៀត អោយប្រយ័ត្នចំពោះកន្លែងលាក់ខ្លួនរបស់ពួកស៊ីរី។ស្តេចស៊ីរីខ្វាល់ជាខ្លាំង នៅពេលដែលកន្លែងលាក់ខ្លួនរបស់កងទ័ពទ្រង់ត្រូវខូចខ្វាយ ដូច្នេះទ្រង់ចាត់មនុស្សអោយទៅចាប់លោកអេលីសេ ប៉ុន្តែផ្ទុយទៅវិញ លោកអេលីសេចាប់ពួកកងទ័ពទាំងនោះវិញ ហើយបញ្ជូនពួកគេទៅរាជធានីសាម៉ារី។ស្តេចអ៊ីស្រាអែលគិតថា នេះគឺជាឱកាសល្អដើម្បីសម្លាប់សត្រូវ ប៉ុន្តែអេលីសេបានណែនាំទ្រង់អោយផ្តត់ផ្គង់ចំណីអាហារអោយគេ ហើយដោះលែងគេទៅវិញ។ តាមរយៈកិច្ចការនេះ ប្រទេសអ៊ីស្រាអែល និងប្រទេសស៊ីរី បានរស់នៅដោយសុខសាន្តសន្តិភាពមួយរយៈ។ រឿងនេះបានបង្ហាញប្រជាជាតិទាំងពីរថា ព្រះជាម្ចាស់ទ្រង់គ្រប់គ្រងស្ថានភាពទាំងអស់។

សេចក្តីអធិស្ឋាន

ខែ12
ថ្ងៃព្រ.ហ 19

# ទុរភិក្សនៅក្រុងសាម៉ារី

២ពង្សាវតារក្សត្រ 6:24-7:2

ការអធិស្ឋាន

អានអត្ថបទ

២៤ ក្រោយនោះមក បេន-ហាដាឌ់ ជាស្តេចស្រុកស៊ីរីទ្រង់ក៏ប្រមូលកងទ័ពទាំងអស់ លើកឡើងទៅ
ឡោមព័ទ្ធច្បាំងនឹងក្រុងសាម៉ារី ២៥ ដូច្នេះ នៅក្រុងសាម៉ារីមានអំណត់អត់ជាខ្លាំង ពួកស៊ីរីឡោម
ព័ទ្ធច្បាំងនឹងទីក្រុងនោះទាល់តែក្បាលលា១លក់ថ្លៃ៨០រៀល ហើយអាចម៍ព្រាប១កំប៉ុងលក់ថ្លៃ៥
រៀល ២៦ គ្រានោះ កាលស្តេចអ៊ីស្រាអែលទ្រង់កំពុងតែយាងនៅលើកំផែងក្រុង នោះមានស្ត្រីម្នាក់
ស្រែកទូលទ្រង់ថា បពិត្រព្រះករុណា ជាព្រះអម្ចាស់អើយ សូមជួយខ្ញុំម្ចាស់ផង ២៧ តែទ្រង់មាន
ព្រះបន្ទូលតបថា បើព្រះយេហូវ៉ាមិនជួយអ្នកទេ នោះធ្វើដូចម្តេចឲ្យយើងជួយបាន តើនឹងជួយ
ដោយស្រូវពីទីលាន ឬដោយស្រាទំពាំងបាយជូរពីធុងឃ្នាបឬអី ២៨ ស្តេចក៏សួរស្ត្រីនោះថា តើអ្នក
កើតមានអ្វី ស្ត្រីនោះទូលឆ្លើយថា នាងនេះបាននិយាយមកខ្ញុំម្ចាស់ថា ចូរឲ្យកូនឯងមកឲ្យយើង
បរិភោគនៅថ្ងៃនេះ ហើយថ្ងៃស្អែកឡើង នោះយើងនឹងបរិភោគកូនអញវិញ ២៩ ដូច្នេះ ខ្ញុំម្ចាស់បាន
ស្ងោរកូនខ្ញុំម្ចាស់ រួចយើងខ្ញុំបានបរិភោគទៅ លុះដល់ថ្ងៃក្រោយ ខ្ញុំម្ចាស់បាននិយាយទៅនាងថា
ចូរយកកូនឯងមកឲ្យយើងបរិភោគទៀត តែគេបានយកកូនទៅលាក់ទុកវិញ ៣០ កាលស្តេចបានឮ
ពាក្យ របស់ស្ត្រីនោះហើយ នោះទ្រង់ហែកព្រះពស្ត្រទ្រង់ ហើយកំពុងដែលទ្រង់យាងនៅលើ
កំផែងហួសទៅ នោះពួករាស្ត្រគេក្រឡេកមើលទៅឃើញថា ទ្រង់ស្លៀកសំពត់ធ្មៃខាងក្នុងជាប់នឹង
អង្គទ្រង់ ៣១ នោះទ្រង់មានព្រះបន្ទូលស្បថថា បើក្បាលអេលីសេ កូនសាផាត នៅជាប់លើខ្លួនវា
នៅថ្ងៃនេះ នោះសូមឲ្យព្រះទ្រង់ប្រព្រឹត្តនឹងយើងយ៉ាងនោះវិញ ហើយលើសទៅទៀតផង។
៣២ ឯអេលីសេ លោកកំពុងតែអង្គុយនៅក្នុងផ្ទះ មានពួកចាស់ទុំនៅជាមួយ ហើយស្តេចទ្រង់ចាត់
មនុស្សម្នាក់ពីចំពោះទ្រង់ ឲ្យទៅរកលោក តែមុនដែលអ្នកនោះមកដល់ នោះលោកមាន
ប្រសាសន៍ទៅពួកចាស់ទុំថា សូមមើលបែបយ៉ាងណា ដែលកូនរបស់អ្នកសំឡាប់គេនេះ បានចាត់
មនុស្សមកយកក្បាលខ្ញុំទៅ សូមចាំមើល កាលណាអ្នកនោះមកដល់ ឲ្យបិទទ្វារឲ្យជាប់ កុំឲ្យគេ
ចូលឡើយ តើមិនឮសូរជើងរបស់ចៅហ្វាយគេ មកតាមក្រោយទេឬ ៣៣ កាលលោកកំពុងមាន
ប្រសាសន៍ នឹងអ្នកទាំងនោះនៅឡើយ អ្នកនោះក៏ចុះមកដល់ និយាយថា មើល សេចក្តីវេទនានេះ
មកពីព្រះយេហូវ៉ា តើត្រូវឲ្យយើងនៅចាំព្រះយេហូវ៉ាធ្វើអីទៀត។ ១ តែអេលីសេ លោកមាន
ប្រសាសន៍ថា សូមស្តាប់ព្រះបន្ទូលនៃព្រះយេហូវ៉ាសិន ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលដូច្នេះថា
ដល់ថ្ងៃស្អែកវេលាថ្មើរណេះ នោះម្សៅយ៉ាងម៉ដ្ឋ១រង្វាល់នឹងលក់ថ្លៃតែ១រៀល និងម្សៅឱក២រ
ង្វាល់ថ្លៃតែ១រៀលទេ នៅត្រង់មាត់ទ្វារក្រុងសាម៉ារី ២ ដូច្នេះ មេទ័ពដែលស្តេចទ្រង់ព្រយុងអង្គលើដៃ
លោក ក៏ឆ្លើយទៅអ្នកសំណប់របស់ព្រះថា បើទោះជាព្រះយេហូវ៉ាទ្រង់ធ្វើទាំងទ្វារនៅលើមេឃផង នោះតើ
ការយ៉ាងនោះនឹងកើតមកដូចម្តេចបាន អេលីសេឆ្លើយតបថា ចាំមើល ភ្នែកលោកនឹងឃើញច្បាស់ តែមិន
បានបរិភោគទេ។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

.............................................................................................

.............................................................................................

.............................................................................................

.............................................................................................

.............................................................................................

.............................................................................................

.............................................................................................

.............................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

.............................................................................................

.............................................................................................

.............................................................................................

## ការយល់ដឹងអំពីអត្ថបទ

### *ទុរភិក្សនៅក្រុងសាម៉ារី*

ក្រោយមកទៀតបានមួយរយៈពេល ពួកស៊ីរីបានចូលមកឡោមព័ទ្ធក្រុងសាម៉ារី។ពេលពួកបណ្ដាជនជួបនឹងគ្រោះអត់ឃ្លាន នោះស្ដេចអ៊ីស្រាអែលបានទម្លាក់កំហុសទៅលើលោកអេលីសេ ហើយប្រុងសម្លាប់គាត់តែលោកអេលីសេបានធានាថា នៅនាថ្ងៃស្អែកនេះពួកគេនិងមានអាហារសម្រាប់បរិភោគយ៉ាងបរិបូរហើយ។ មានមនុស្សភាគច្រើនណាស់នៅពេលជួបបញ្ហា ឬទុក្ខលំបាកខ្លាំងក្រៃកន្លងទៅ ពួកគេមិនបានស្វែងរកដំណោះស្រាយឬប្រភពរបស់វាមកពីណាទេ តែបែរជាចោលកំហុសទាំងនោះទៅលើព្រះជាម្ចាស់ទៅវិញ។ យ៉ាងនេះគឺជាអំពើបាបជាន់លើអំពើបាបហើយ។ តាមពិតទៅប្រភពនៃបញ្ហាគឺច្រើនតែកើតចេញពីខ្លួនយើងជាអ្នកប្រព្រឹត្តវាឡើងមក ហើយក្រោយៗមកវាក៏ប្រសូត្រចេញជាសេចក្ដីអាក្រក់ផ្សេងមកកាន់ជីវិតប្រចាំថ្ងៃរបស់យើងដោយមិនដឹងខ្លួន។

សេចក្ដីអធិស្ឋាន

ខែ12 ថ្ងៃសុក្រ 20

# ចុងបញ្ចប់នៃទុរភិក្ស

២ពង្សាវតារក្សត្រ 7:3-10

ការអធិស្ឋាន

អានអត្ថបទ

៣រីឯនៅមាត់ទ្វារទីក្រុង នោះមានមនុស្សឃ្លង់៤នាក់ គេនិយាយគ្នាទៅវិញទៅមកថា យើងអង្គុយ
នៅទីនេះទាល់តែស្លាប់ធ្វើអី ៤បើសិនជាយើងសំរេចថា នឹងចូលទៅក្នុងទីក្រុង នោះទីក្រុងក៏មាន
អំណត់ ហើយយើងនឹងស្លាប់នៅទីនោះ បើយើងអង្គុយស្ងៀមនៅទីនេះវិញ នោះគង់តែនឹងស្លាប់
ដូចគ្នា ដូច្នេះ ចូរយើងចូលទៅខាងឯពួកទ័ពស៊ីរីវិញ បើគេទុកជីវិតដល់យើង នោះយើងនឹងបាន
រស់នៅ តែបើគេសំឡាប់ នោះយើងនឹងគ្រាន់តែស្លាប់ទៅដូចគ្នា ៥ដូច្នេះ គេក៏ក្រោកឡើងនៅពេល
ព្រលប់ទៅឯទីបោះទ័ពរបស់ពួកស៊ីរី តែកាលគេទៅដល់ជើងទីបោះទ័ពហើយ នោះមិនឃើញមាន
អ្នកណាសោះ ៦ពីព្រោះព្រះអម្ចាស់ ទ្រង់បានធ្វើឲ្យពួកទ័ពស៊ីរីបានឮសូរសន្ធឹករទេះចំបាំង និង
សន្ធឹកពលសេះ គឺជាសូរសព្ទនៃកងទ័ពយ៉ាងធំនៅក្នុងទីបោះទ័ពរបស់គេ ក៏និយាយគ្នាថា មើល
ស្តេចអ៊ីស្រាអែលបានជួលពួកស្តេចនៃសាសន៍ហេត នឹងស្តេចអេស៊ីព្ទឲ្យមកច្បាំងនឹងយើង
ហើយ ៧ហេតុនោះគេក៏ក្រោកឡើង រត់ទៅនៅពេលព្រលប់នោះ លះចោលទាំងត្រសាល និង
សេះ ហើយលារបស់គេ ទុកទីបោះទ័ពឲ្យនៅដូចដែល ក៏រត់យកតែជីវិតឲ្យរួចទៅប៉ុណ្ណោះ ៨ដូច្នេះ
កាលពួកគំលង់នោះបានទៅដល់ជើងទីបោះទ័ព នោះក៏ចូលទៅក្នុងត្រសាលមួយ នាំគ្នាស៊ីផឹកទៅ
រួចគេយកមាសប្រាក់ សំពត់អាវ ទៅលាក់ទុក ក៏ត្រឡប់ទៅចូលក្នុងត្រសាល១ទៀត យករបស់ពី
នោះទៅលាក់ទុកដែរ។៩នោះគេនិយាយគ្នាថា យើងប្រព្រឹត្តដូច្នេះមិនល្អទេ ដ្បិតថ្ងៃនេះជាថ្ងៃមាន
ដំណឹងល្អ តែយើងនៅស្ងៀមវិញ បើយើងនៅចាំរហូតដល់ព្រឹកឡើង នោះមុខជានឹងមានទោស
មកទាន់ជាមិនខាន ដូច្នេះ ចូរយើងទៅប្រាប់ដល់ពួកដំណាក់ស្តេចឥឡូវចុះ ១០គេក៏ទៅហៅអ្នកឆ្មាំ
ទ្វារទីក្រុងប្រាប់ថា ពួកយើងខ្ញុំបានទៅដល់ទីបោះទ័ពរបស់ពួកស៊ីរី តែមើល គ្មានអ្នកណាមួយ
សោះ ក៏គ្មានឮសំឡេងមនុស្សណាឡើយ មានតែសេះ និងលាដែលគេបានចងទុក ហើយទាំងត្រ
សាលគេក៏នៅដូចដែល

3 Now there were four men with leprosy at the entrance of the city gate. They said to each
other, “Why stay here until we die? 4 If we say, ‘We’ll go into the city’ the famine is there,
and we will die. And if we stay here, we will die. So, let’s go over to the camp of the
Arameans and surrender. If they spare us, we live; if they kill us, then we die.”
5 At dusk they got up and went to the camp of the Arameans. When they reached the edge of
the camp, no one was there, 6 for the Lord had caused the Arameans to hear the sound of
chariots and horses and a great army, so that they said to one another, “Look, the king of
Israel has hired the Hittite and Egyptian kings to attack us!” 7 So they got up and fled in the
dusk and abandoned their tents and their horses and donkeys. They left the camp as it was
and ran for their lives.
8 The men who had leprosy reached the edge of the camp, entered one of the tents and ate
and drank. Then they took silver, gold and clothes, and went off and hid them. They returned
and entered another tent and took some things from it and hid them also.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

...........................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

...........................................................................................

## ការយល់ដឹងអំពីអត្ថបទ

### *ចុងបញ្ចប់នៃទុរភិក្ស*

នៅពេលឮដំណឹងនេះពីអ្នករាយការណ៍សេចក្ដីរបស់លោកអេលីសេនិយាយភ្លាម ស្ដេចមិនចង់ជឿសោះថា តើមានអាហារច្រើនយ៉ាងនេះមកពីណា។ព្រះពរ ទ្រព្យសម្បត្តិ លុយកាក់ ឬសេចក្ដីសុខសាន្តខ្លះដែលយើងបានពីព្រះជាម្ចាស់ដោយមិនដឹងខ្លួន។ យើងមិនបានលើកសរសើរដល់ព្រះដែលបានបង្កើតយើងមកនោះទេ តែយើងបែរជាទៅអរគុណ ឬសរសើរដល់មនុស្សទៅវិញ។ ព្រះមិនបានចាកចេញចោលយើងទេ នៅពេលយើងអត់ឃ្លានទ្រង់ក៏គង់ជាមួយយើង នៅពេលយើងកើតទុក្ខទ្រង់ក៏នៅតែគង់ជាមួយយើង តែពេលដែលយើងបានសុខសាន្តនោះយើងបានចាកចេញពីទ្រង់ទៅវិញ។សួរថា តើព្រះហឫទ័យទ្រង់ទៅជាយ៉ាងណា? ពិតណាស់គឺព្រះទ័យទ្រង់មិនប្រួលប្រែ ដូចចិត្តរបស់យើងរាល់គ្នានោះទេ។

សេចក្ដីអធិស្ឋាន

ខែ12
ថ្ងៃសៅរ៍ 21

# ចុងបញ្ចប់នៃទុរភិក្ស

## ២ពង្សាវតារក្សត្រ 7:11-20

ការអធិស្ឋាន

អានអត្ថបទ

.[១១] អ្នកឆ្មាំទ្វារក៏ហៅពួកអ្នកយាម ឲ្យគេបន្តដំណឹងនោះដល់ទៅខាងក្នុងព្រះរាជវាំង [១២] ឯស្តេច
ទ្រង់តើនឡើងទាំងយប់ មានព្រះបន្ទូលនឹងពួកជំនិតទ្រង់ថា យើងនឹងសំដែងឲ្យអ្នករាល់គ្នាដឹងពី
ឧបាយរបស់ពួកស៊ីរី ដែលគេគិតធ្វើដល់យើង គឺគេដឹងថា យើងរាល់គ្នាអត់ឃ្លាន បានជាគេថយ
ចេញពីទីបោះទ័ព ទៅពួននៅឯទីវាល ដោយនឹកថា កាលណាយើងចេញពីក្រុងនេះទៅ នោះគេ
នឹងចាប់យើងទាំងរស់ ហើយនឹងចូលមកក្នុងទីក្រុងបាន [១៣] តែពួកជំនិតម្នាក់ទូលថា សូមឲ្យគេ
យកសេះ៥ដែលនៅសល់ ដែលបានទុកក្នុងទីក្រុង (មើល សេះទាំងនោះក៏ដូចជាសាសន៍អ៊ីស្រា
អែលទាំងប៉ុន្មាន ដែលនៅក្នុងទីក្រុងនៅឡើយ គឺដូចជាពួកអ៊ីស្រាអែល ដែលកំពុងតែរោយរៀវទៅ
ហើយនេះ) សូមចាត់គេទៅមើលចុះ [១៤] ដូច្នេះ គេក៏យករទេះចំបាំង២ទឹមដោយសេះ ហើយស្តេច
ទ្រង់ចាត់គេឲ្យទៅតាមពលទ័ពស៊ីរី ដោយព្រះបន្ទូលថា ចូរទៅមើលចុះ [១៥] អ្នកទាំងនោះក៏ទៅតាម
រហូតដល់ទន្លេយ័រដាន់ ឃើញមានសុទ្ធតែអាវ និងភាជនៈផ្សេងៗ ដែលពួកស៊ីរីបានបោះចោល
រាយរហូតតាមផ្លូវទៅ ដោយខំរត់ជាប្រញាប់ រួចពួកអ្នកដែលស្តេចចាត់ឲ្យទៅ ក៏វិលមកទូលទ្រង់វិ
ញ។[១៦] ឯពួកប្រជាជនទាំងឡាយ ក៏ចេញទៅចាប់យករបឹបនៅទីបោះទ័ពនៃពួកស៊ីរី ដូច្នេះម្សៅ
យ៉ាងម៉ដ្ត១រង្វាល់ក៏បានលក់ថ្លៃ១រៀល និងម្សៅឱក២រង្វាល់ក៏បានលក់ថ្លៃ១រៀលដែរ តាមព្រះ
បន្ទូលនៃព្រះយេហូវ៉ា [១៧] ហើយស្តេចទ្រង់តម្រូវមេទ័ពម្នាក់ ដែលទ្រង់បានព្រយុងលើដៃលោក ឲ្យ
ចេញទៅត្រួតត្រាមើលការនៅត្រង់មាត់ទ្វារក្រុង តែបណ្តាជន គេជាន់លោកស្លាប់ នៅត្រង់ទ្វារទី
ក្រុងទៅ ដូចជាអ្នកសំណប់របស់ព្រះបានទាយទុក ក្នុងកាលដែលស្តេចយាងចុះទៅឯលោក
នោះ [១៨] ហើយក៏កើតមាន ដូចជាអ្នកសំណប់របស់ព្រះ បានទូលដល់ស្តេចថា លុះថ្ងៃស្អែកពេល
ថ្មើរនេះ នោះម្សៅឱក២រង្វាល់នឹងលក់ថ្លៃ១រៀល ហើយម្សៅយ៉ាងម៉ដ្ត១រង្វាល់នឹងលក់ថ្លៃ១រៀល
ដែរ នៅត្រង់ទ្វារក្រុងសាម៉ារី [១៩] ឯមេទ័ពដែលបានឆ្លើយតបនឹងអ្នកសំណប់របស់ព្រះថា បើទោះ
ជាព្រះយេហូវ៉ាទ្រង់ធ្វើទាំងទ្វារនៅលើមេឃផង នោះតើការយ៉ាងនោះនឹងកើតមកដូចម្តេចបាន
ហើយអេលីសេបានឆ្លើយថា មើល ភ្នែកលោកនឹងឃើញច្បាស់ តែមិនបានបរិភោគទេ [២០] នោះក៏
កើតដល់មេទ័ពនោះដូច្នោះមែន ដ្បិតបណ្តាជនទាំងឡាយ គេបានជាន់លោកស្លាប់ នៅត្រង់ទ្វារទី
ក្រុងទៅ។

[11] The gatekeepers shouted the news, and it was reported within the palace.

[12] The king got up in the night and said to his officers, “I will tell you what the Arameans have done to us. They know we are starving; so they have left the camp to hide in the countryside, thinking, ‘They will surely come out, and then we will take them alive and get into the city.’”

[13] One of his officers answered, “Have some men take five of the horses that are left in the city. Their plight will be like that of all the Israelites left here yes, they will only be like all these Israelites who are doomed. So let us send them to find out what happened.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

..........

ការអនុវត្តន៍ក្នុងការរស់នៅ

..........

## ការយល់ដឹងអំពីអត្ថបទ

### *ចុងបញ្ចប់នៃទុរភិក្ស*

តែនេះជាការពិតមែន ហើយក៏មានមនុស្សយ៉ាងហោចណាស់ម្នាក់ បានស្លាប់ដោយសារតែពួកគេបានជាន់គ្នាក្នុងពេលដែលគ្រប់ៗគ្នាប្រញាប់រត់ទៅទិញអាហារ។ នេះជាបទទំនាយដែលលោកអេលីសេបានថ្លែងទាស់នឹងស្តេចអ៊ីស្រាអែល ស្តេចមិនបានជឿលើអ្វីដែលកើតមានឡើងដែលទ្រង់បានមើលឃើញនឹងភ្នែកនោះទេ រាល់អ្វីៗដែលបានកើតមានឡើង ស្តេចនៅតែមិនជឿងដែល។ ដូចគ្នាដែរមនុស្សដែលដួងចិត្តរុំព័ទ្ធទៅដោយអំពើអាក្រក់ ភ្នែករបស់គេមើលមិនឃើញពីព្រះគុណ និងសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ឡើយ។ តែទោះជាយ៉ាងណាក៏ព្រះនៅតែផ្តល់ពន្លឺថ្ងៃ ខ្យល់ដកដង្ហើម និងទឹកភ្លៀងដល់ទាំងពួកមនុស្សអាក្រក់ និងពួកមនុស្សល្អដូចគ្នាដែរ។

សេចក្តីអធិស្ឋាន

ខែ12
ថ្ងៃអាទិត្យ 22

# ការអធិប្បាយថ្ងៃអាទិត្យ

- ចំណងជើង : 
- អត្ថបទ : 
- អ្នកអធិប្បាយ : 



ការប្រកបរបស់យើងជាមួយនិងព្រះ

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ



ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

## សេចក្ដីអធិស្ឋាន

ខែ12
ថ្ងៃច័ន្ទ 23

# ក្រឹត្យវិន័យរបស់ព្រះ

## ទំនុកដំកើង 119:1-24

ការអធិស្ឋាន

អានអត្ថបទ

១ មានពរហើយ អស់អ្នកដែលផ្លូវប្រព្រឹត្តរបស់ខ្លួនបានគ្រប់លក្ខណ៍គឺជាអ្នកដែលដើរតាមក្រឹត្យវិ
ន័យរបស់ព្រះយេហូវ៉ា២ មានពរហើយ អស់អ្នកដែលរក្សាទុកនូវសេចក្តីបន្ទាល់របស់ទ្រង់ជាអ្នក
ដែលស្វែងរកទ្រង់ឲ្យអស់ពីចិត្ត៣ អើ ពួកនោះមិនដែលប្រព្រឹត្តអំពើទុច្ចរិតឡើយគឺគេដើរតាមផ្លូវ
របស់ទ្រង់វិញ ៤ ទ្រង់បានប្រកាសសេចក្តីបញ្ញត្តរបស់ទ្រង់មកដើម្បីឲ្យយើងខ្ញុំបានកាន់តាមដោយ
ម៉ត់ចត់ ៥ ឱបើសិនណាជាផ្លូវទាំងប៉ុន្មានរបស់ទូលបង្គំបានរៀបចំទៅអេះដើម្បីឲ្យបានកាន់តាម
ច្បាប់ទ្រង់ ៦ កាលណាទូលបង្គំរាប់អានអស់ទាំងសេចក្តីបង្គាប់របស់ទ្រង់នោះទូលបង្គំនឹងមិនត្រូវ
ខ្មាសឡើយ ៧ កាលណាទូលបង្គំបានរៀនអស់ទាំងខច្បាប់ដ៏សុចរិតរបស់ទ្រង់នោះទូលបង្គំនឹងអរ
ព្រះគុណដល់ទ្រង់ដោយចិត្តទៀងត្រង់ ៨ ទូលបង្គំនឹងកាន់តាមច្បាប់របស់ទ្រង់ឱសូមកុំលះចោល
ទូលបង្គំឲ្យអស់រលីងឡើយ។៩ មនុស្សកំឡោះនឹងសំអាតផ្លូវដែលខ្លួនប្រព្រឹត្តដោយសារអ្វីគឺដោយ
ប្រយ័ត្ននឹងប្រព្រឹត្តតាមព្រះបន្ទូលនៃទ្រង់ ១០ ទូលបង្គំបានស្វែងរកទ្រង់អស់ពីចិត្តឱសូមកុំឲ្យទូល
បង្គំវង្វេងចេញពីសេចក្តីបង្គាប់របស់ទ្រង់ឡើយ ១១ ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅ
ក្នុងចិត្តប្រយោជន៍កុំឲ្យទូលបង្គំធ្វើបាបនឹងទ្រង់ឡើយ ១២ ឱព្រះយេហូវ៉ាអើយ ទ្រង់មានពរហើយ
សូមបង្រៀនអស់ទាំងបញ្ញត្តរបស់ទ្រង់ដល់ទូលបង្គំ ១៣ បបូរមាត់ទូលបង្គំបានសំដែងពីគ្រប់ទាំង
ច្បាប់ដែលចេញពីព្រះឱស្ឋទ្រង់មក១៤ ទូលបង្គំបានត្រេកអរក្នុងផ្លូវប្រព្រឹត្តតាមសេចក្តីបន្ទាល់របស់
ទ្រង់ឲ្យស្មើនឹងសេចក្តីអំណរចំពោះទ្រព្យសម្បត្តិគ្រប់យ៉ាង ១៥ ទូលបង្គំនឹងរំពឹងគិតពីសេចក្តីបញ្ញត្ត
របស់ទ្រង់ហើយនឹងស្រឡាញ់រាប់អានអស់ទាំងផ្លូវរបស់ទ្រង់១៦ ទូលបង្គំនឹងមានចិត្តរីករាយចំពោះ
បញ្ញត្តទ្រង់ទាំងប៉ុន្មានឥតភ្លេចព្រះបន្ទូលទ្រង់ឡើយ។ ១៧ សូមប្រោសអ្នកបំរើរបស់ទ្រង់ ដោយ
គុណដ៏ប្រសើរប្រយោជន៍ឲ្យទូលបង្គំបានរស់នៅហើយកាន់តាមព្រះបន្ទូលទ្រង់ ១៨ សូមបំភ្លឺភ្នែក
ទូលបង្គំ ឲ្យបានឃើញសេចក្តីអស្ចារ្យនៅក្នុងក្រឹត្យវិន័យរបស់ទ្រង់១៩ ទូលបង្គំជាមនុស្សគ្រាន់តែ
ស្នាក់នៅផែនដីតែប៉ុណ្ណោះសូមកុំលាក់សេចក្តីបង្គាប់របស់ទ្រង់នឹងទូលបង្គំឡើយ ២០ ព្រលឹងទូល
បង្គំសង្រេងដោយនឹករឭកដល់ច្បាប់ទ្រង់គ្រប់ពេលវេលា២១ ទ្រង់បានបន្ទោសមនុស្សឆ្មើងឆ្មៃដែល
ត្រូវបណ្តាសាហើយជាពួកអ្នកដែលវង្វេងចេញពីសេចក្តីបង្គាប់របស់ទ្រង់២២ សូមដកយកការដំនៀ
លនិងការមើលងាយពីទូលបង្គំចេញដ្បិតទូលបង្គំបានរក្សាសេចក្តីបន្ទាល់របស់ទ្រង់ទុក ២៣ មាន
ទាំងពួកអ្នកធំបានអង្គុយប្រឹក្សាគ្នាទាស់នឹងទូលបង្គំដែរអ្នកបំរើរបស់ទ្រង់បាននឹករំពឹងតែពីសេចក្តី
បញ្ញត្តរបស់ទ្រង់វិញ២៤ ទូលបង្គំយកសេចក្តីបន្ទាល់ទ្រង់ទុកជាសេចក្តីអំណររបស់ខ្លួនហើយជាសេ
ចក្តីដំបូន្មានផង។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

### *ក្រឹត្យវិន័យរបស់ព្រះ*

ទំនុកដំកើង១១៩ មានលក្ខណៈជាកំណាព្យ នឹងចែកចេញជា២២វគ្គ ដែលទាក់ទងនឹងព្យញ្ជនៈទាំង២២របស់សាសន៍ហេព្រើ។ក្នុងមួយវគ្គៗមាន៨ខ ហើយក្នុងខនីមួយៗចាប់ផ្ដើមដោយតួរអក្សរដូចគ្នា។

អ្នកនិពន្ធបានសំដែងពីទំនុកចិត្ត និងភាពសប្បាយរីករាយរបស់មនុស្សដែលបានរស់នៅតាមបញ្ញតិរបស់ព្រះជាម្ចាស់។បន្ទាប់មកបានបង្ហាញពីការអធិស្ឋានទៅកាន់ព្រះជាម្ចាស់ថា គាត់នឹងស្ដាប់តាមព្រះបន្ទូល ហើយស្ដាប់បង្គាប់ព្រះអង្គ ដោយធ្វើតាមព្រះបន្ទូលរបស់ព្រះអង្គ។ការស្ដាប់តាមព្រះបន្ទូលច្បាស់នឹងធ្វើអោយមនុស្សអាចជៀសផុតពីអំពើបាប។ ពួកគេអាចទទួលបានការយល់ដឹងនេះដោយការទូលសុំពីព្រះក្នុងការបង្ហាញផ្លូវ។ ការគិតគូរយ៉ាងហ្មត់ចត់ពីសេចក្ដីបង្រៀនទាំងនេះគឺអាចប្រកាស់ប្រាប់មនុស្សដទៃផងដែរ។ សំខាន់បំផុតមនុស្សយើងត្រូវស្វែងរកអំណាចរបស់ព្រះបន្ទូលនៃព្រះដោយមានចិត្តចង់ដឹងនិងចង់អនុវត្តតាមព្រះបន្ទូលផងដែរ។ អ្នកនិពន្ធបានដឹងច្បាស់ថា បើគាត់ចង់អោយព្រះបន្ទូលដឹកនាំគាត់ នោះជីវិតរបស់គាត់នឹងពោរពេញដោយភាពស្កប់ស្កល់ និងមានន័យបំផុត។

សេចក្ដីអធិស្ឋាន

# ក្រឹត្យវិន័យរបស់ព្រះ

ទំនុកដំកើង 119:25-48

ការអធិស្ឋាន

អានអត្ថបទ

២៥ ព្រលឹងទូលបង្គំឈ្លក់នៅនឹងធូលីដីសូមប្រោសទូលបង្គំឲ្យភ្ញារឡើង តាមព្រះបន្ទូលទ្រង់
២៦ ទូលបង្គំបានទូលសំដែងពីផ្លូវប្រព្រឹត្តរបស់ទូលបង្គំហើយទ្រង់បានឆ្លើយមកសូមបង្រៀនអស់
ទាំងបញ្ញត្តទ្រង់មកទូលបង្គំផង ២៧ សូមឲ្យទូលបង្គំបានយល់ក្នុងផ្លូវឱវាទរបស់ទ្រង់យ៉ាងនោះទូល
បង្គំនឹងនឹករំពឹងពីការអស្ចារ្យរបស់ទ្រង់២៨ ព្រលឹងទូលបង្គំរលាយទៅ ដោយសេចក្តីធ្ងន់ចិត្តសូមចំ
រើនកំឡាំងដល់ទូលបង្គំ តាមព្រះបន្ទូលនៃទ្រង់២៩ សូមដកការប្រព្រឹត្តដោយភូតភរពីទូលបង្គំចេញ
ហើយអនុញ្ញាតប្រទានក្រឹត្យវិន័យរបស់ទ្រង់មកទូលបង្គំដោយព្រះគុណ៣០ ទូលបង្គំបានរើសយក
ផ្លូវស្មោះត្រង់ហើយទូលបង្គំបានតាំងច្បាប់របស់ទ្រង់នៅចំពោះភ្នែកដែរ ៣១ ទូលបង្គំកាន់ខ្ជាប់តាម
សេចក្តីបន្ទាល់របស់ទ្រង់ឱព្រះយេហូវ៉ាអើយ សូមកុំឲ្យទូលបង្គំត្រូវខ្មាសឡើយ៣២ ទូលបង្គំនឹងរត់
ទៅតាមផ្លូវនៃសេចក្តីបង្គាប់ទ្រង់ដ្បិតទ្រង់បានពង្រីកចិត្តទូលបង្គំឡើងហើយ។ ៣៣ ឱព្រះយេហូវ៉ា
អើយ សូមបង្រៀនផ្លូវនៃអស់ទាំងបញ្ញត្តទ្រង់មកទូលបង្គំនោះទូលបង្គំនឹងកាន់តាមដរាបដល់ចុង
បំផុត៣៤ សូមប្រទានឲ្យទូលបង្គំមានយោបល់ នោះទូលបង្គំនឹងកាន់តាមក្រឹត្យវិន័យទ្រង់អើ ទូល
បង្គំនឹងរក្សាទុកឲ្យអស់ពីចិត្តផង ៣៥ សូមបណ្តាលឲ្យទូលបង្គំដើរទៅតាមផ្លូវច្រកនៃសេចក្តីបង្គាប់
របស់ទ្រង់ដ្បិតទូលបង្គំមានសេចក្តីរីករាយក្នុងផ្លូវនោះ៣៦ សូមធ្វើឲ្យចិត្តទូលបង្គំល្អៀងទៅខាងសេ
ចក្តីបន្ទាល់របស់ទ្រង់កុំឲ្យល្អៀងទៅខាងសេចក្តីលោភឡើយ ៣៧ សូមបង្វែរភ្នែកទូលបង្គំមិនឲ្យ
មើលការឥតប្រយោជន៍ហើយប្រោសឲ្យទូលបង្គំមានកំឡាំងឡើងក្នុងផ្លូវទ្រង់ ៣៨ សូមសំរេចដល់
អ្នកបំរើទ្រង់តាមព្រះបន្ទូលជាសេចក្តីដែលទុកសំរាប់ពួកអ្នកកោតខ្លាចដល់ទ្រង់៣៩ សូមបង្វែរសេច
ក្តីដំនៀលដែលទូលបង្គំខ្លាចនោះចេញពីទូលបង្គំទៅ ដ្បិតច្បាប់នៃទ្រង់សុទ្ធតែល្អ៤០ មើល ទូលបង្គំ
បាននឹកអាល័យដល់បញ្ញត្តទាំងប៉ុន្មានរបស់ទ្រង់សូមប្រោសឲ្យទូលបង្គំមានកំឡាំងឡើងដោយ
សេចក្តីសុចរិតរបស់ទ្រង់។ ៤១ ឱព្រះយេហូវ៉ាអើយសូមឲ្យសេចក្តីសប្បុរសទ្រង់ផ្សាយមកដល់ខ្លួន
ទូលបង្គំគឺជាសេចក្តីសង្គ្រោះរបស់ទ្រង់ តាមព្រះបន្ទូលទ្រង់៤២ យ៉ាងនោះ ទូលបង្គំនឹងមានពាក្យចំ
ឡើយដល់អ្នកណាដែលត្មះតិះដៀលទូលបង្គំដ្បិតទូលបង្គំទុកចិត្តនឹងព្រះបន្ទូលទ្រង់៤៣ សូមកុំដក
ព្រះបន្ទូលដ៏ពិតចេញពីមាត់ទូលបង្គំអស់រលីងឡើយដ្បិតទូលបង្គំបានសង្ឃឹមដល់ច្បាប់នៃទ្រង់
៤៤ យ៉ាងនោះ ទូលបង្គំនឹងកាន់តាមក្រឹត្យវិន័យទ្រង់ជានិច្ចនៅអស់កល្បជានិច្ចរៀងតទៅ៤៥ ទូល
បង្គំនឹងដើរទៅដោយសេរីភាពដ្បិតទូលបង្គំបានស្វែងរកអស់ទាំងបញ្ញត្តនៃទ្រង់ ៤៦ ទូលបង្គំនឹង
ពោលពីសេចក្តីបន្ទាល់របស់ទ្រង់នៅចំពោះពួកស្តេច ឥតដែលត្រូវខ្មាសឡើយ៤៧ទូលបង្គំនឹងមាន
ចិត្តរីករាយ ដោយសារសេចក្តីបង្គាប់របស់ទ្រង់ជាសេចក្តីដែលទូលបង្គំបានស្រឡាញ់៤៨ ទូលបង្គំ
នឹងលើកដៃប្រណម្យចំពោះសេចក្តីបង្គាប់របស់ទ្រង់ ដែលទូលបង្គំបានស្រឡាញ់ហើយនឹងរំពឹង
គិតពីបញ្ញត្តទ្រង់។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

................................................................................

................................................................................

................................................................................

................................................................................

................................................................................

................................................................................

................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

................................................................................

................................................................................

................................................................................

## ការយល់ដឹងអំពីអត្ថបទ

### *ក្រឹត្យវិន័យរបស់ព្រះ*

ក្នុងរឿងនេះបានធ្វើអោយអ្នកនិពន្ធមានជំនឿលើព្រះជាម្ចាស់យ៉ាងមាំ នៅពេលគាត់កំពុងកើតទុក្ខ។ព្រះបន្ទូលព្រះបានចម្រើនកម្លាំងគាត់ ដូច្នេះហើយគាត់បានអធិស្ឋានសុំអោយព្រះបន្ថែមការយល់ដឹង និងកម្លាំងចិត្តដែលអាចអោយគាត់ឈ្នះលើអំពើអាក្រក់ ហើយដើរតាមអំពើល្អ។
ជីវិតអាចចម្រើនឡើងបានដោយសារការស្តាប់និងធ្វើតាមព្រះបន្ទូល។ ព្រះបន្ទូលមិនចង់អោយយើងដើរចេញពីគោលដៅរបស់ព្រះ ដោយបានស្វែងរកទ្រព្យសម្បត្តិ ឬកិត្តិយសនោះទេ។អ្វីដែលអ្នកនិពន្ធបានស្អប់បំផុតនោះគឺ ធ្វើអោយព្រះមិនសព្វព្រះហឫទ័យ។គាត់បានទទឹងរងចាំជីវិតដែលមាន ព្រះអម្ចាស់ជាអ្នកដឹកនាំ តាមរយៈព្រះបន្ទូល។ ព្រះបន្ទូលបានធានាថា ការសង្គ្រោះគឺជាចម្លើយសម្រាប់មនុស្សដែលសើចចំអកអោយគាត់ ផ្តល់នូវសេរីភាពដែលព្រះជាម្ចាស់បានប្រទានអោយគាត់ និងសេចក្តីក្លាហាន ដើម្បីនឹងនិយាយពីព្រះជាម្ចាស់ អោយអ្នកដឹកនាំជាតិបានឮ។

សេចក្តីអធិស្ឋាន

ខែ12
ថ្ងៃពុធ 25

# ក្រឹត្យវិន័យរបស់ព្រះ

## ទំនុកដំកើង 119:49-72

ការអធិស្ឋាន

អានអត្ថបទ

៤៩ សូមទ្រង់នឹកចាំពីសេចក្ដីដែលទ្រង់មានព្រះបន្ទូលដល់អ្នកបំរើទ្រង់ជាសេចក្ដីដែលនាំឲ្យទូល
បង្គំមានសេចក្ដីសង្ឃឹម ៥០ នេះហើយជាសេចក្ដីកំសាន្តចិត្តដល់ទូលបង្គំក្នុងវេលាដែលទូលបង្គំកើត
ទុក្ខព្រួយគឺព្រះបន្ទូលទ្រង់បានប្រោស ឲ្យទូលបង្គំមានកំឡាំងឡើង ៥១ ពួកអ្នកឆ្មើងឆ្មៃបាន
មើលងាយទូលបង្គំពន់ពេកប៉ុន្តែទូលបង្គំមិនបានបែរចេញពីក្រឹត្យវិន័យទ្រង់ឡើយ ៥២ ឱព្រះយេហូ
វ៉ាអើយ ទូលបង្គំបាននឹកចាំពីបញ្ញត្តទ្រង់ដ៏មានពីបុរាណមក ជាការនាំឲ្យទូលបង្គំបានក្សាន្តចិត្ត
៥៣ ទូលបង្គំមានសេចក្ដីគ្នាន់ក្នាញ់មកគ្របសង្កត់ចិត្តដោយព្រោះមនុស្សអាក្រក់ ដែលបោះបង់
ចោលក្រឹត្យវិន័យរបស់ទ្រង់ ៥៤ អស់ទាំងបញ្ញត្តទ្រង់ជាបទចំរៀងរបស់ទូលបង្គំនៅក្នុងផ្ទះដែលទូល
បង្គំអាស្រ័យនៅ ៥៥ ឱព្រះយេហូវ៉ាអើយ ទូលបង្គំបាននឹកចាំពីព្រះនាមទ្រង់នៅវេលាយប់ហើយ
បានកាន់តាមក្រឹត្យវិន័យទ្រង់ ៥៦ សេចក្ដីនេះបានកើតដល់ទូលបង្គំដោយព្រោះបានរក្សាទុកនូវ
បញ្ញត្តរបស់ទ្រង់។ ៥៧ ឯចំណែកនៃទូលបង្គំ ឱព្រះយេហូវ៉ាអើយទូលបង្គំបានពោលថា ត្រូវឲ្យទូល
បង្គំរក្សាអស់ទាំងព្រះបន្ទូលនៃទ្រង់ ៥៨ ទូលបង្គំបានទូលអង្វរដល់ទ្រង់អស់ពីចិត្តសូមទ្រង់មេត្តា
ប្រោសដល់ទូលបង្គំ តាមព្រះបន្ទូលទ្រង់ ៥៩ ទូលបង្គំបាននឹកពីផ្លូវប្រព្រឹត្តរបស់ខ្លួននោះបានបំបែរ
ជើងទៅតាមសេចក្ដីបន្ទាល់របស់ទ្រង់វិញ ៦០ ទូលបង្គំមិនបានបង្អែបង្អង់ឡើយគឺបានប្រញាប់នឹង
រក្សាអស់ទាំងសេចក្ដីបង្គាប់របស់ទ្រង់ ៦១ ចំណងរបស់មនុស្សអាក្រក់បានរុំព័ទ្ធទូលបង្គំជុំវិញតែ
ទូលបង្គំមិនបានភ្លេចក្រឹត្យវិន័យរបស់ទ្រង់ឡើយ ៦២ នៅកណ្ដាលអធ្រាត្រ ទូលបង្គំនឹងក្រោកឡើង
ដើម្បីអរព្រះគុណដល់ទ្រង់ដោយព្រោះអស់ទាំងច្បាប់ដ៏សុចរិតរបស់ទ្រង់ ៦៣ ទូលបង្គំជាមិត្តភក្តិ
នឹងអស់អ្នកដែលកោតខ្លាចដល់ទ្រង់ហើយនឹងអស់អ្នកដែលរក្សាបញ្ញត្តទ្រង់ដែរ ៦៤ ឱព្រះយេហូវ៉ា
អើយ ផែនដីមានពេញដោយសេចក្ដីសប្បុរសរបស់ទ្រង់សូមបង្រៀនសេចក្ដីបញ្ញត្តទ្រង់ដល់ទូល
បង្គំផង។ ៦៥ ឱព្រះយេហូវ៉ាអើយ ទ្រង់បានប្រោសអ្នកបំរើទ្រង់ដោយល្អតាមព្រះបន្ទូលនៃទ្រង់
៦៦ សូមបង្រៀនឲ្យទូលបង្គំមានប្រាជ្ញាឆ្លុះយល់ហើយចេះដឹងយ៉ាងល្អដ្បិតទូលបង្គំបានជឿចំពោះ
សេចក្ដីបង្គាប់នៃទ្រង់ហើយ ៦៧ កាលមុនដែលទូលបង្គំកើតទុក្ខព្រួយនោះទូលបង្គំបានវង្វេងទៅតែ
ឥឡូវនេះ ទូលបង្គំកាន់តាមព្រះបន្ទូលទ្រង់វិញ ៦៨ ទ្រង់ល្អប្រសើរ ហើយក៏ធ្វើការល្អដែរសូម
បង្រៀនបញ្ញត្តទ្រង់ ដល់ទូលបង្គំ ៦៩ ពួកមនុស្សឆ្មើងឆ្មៃបានបង្កើតសេចក្ដីភូតភរទាស់នឹងទូលបង្គំ
តែទូលបង្គំនឹងរក្សាទុកនូវបញ្ញត្តទ្រង់យ៉ាងអស់ពីចិត្ត ៧០ ចិត្តគេស្ពឹកដូចជាមនុស្សមានខ្លាញ់ខន់
តែទូលបង្គំមានចិត្តអំណរចំពោះក្រឹត្យវិន័យទ្រង់វិញ ៧១ ការដែលទូលបង្គំកើតមានទុក្ខព្រួយនោះគឺ
ជាប្រយោជន៍ដល់ទូលបង្គំហើយដើម្បីឲ្យទូលបង្គំបានរៀនយកបញ្ញត្តរបស់ទ្រង់ ៧២ ក្រឹត្យវិន័យ
ដែលចេញពីព្រះឱស្ឋទ្រង់មកនោះវិសេសដល់ទូលបង្គំ ជាជាងមាសប្រាក់ទាំងពាន់ផង។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

### *ក្រឹត្យវិន័យរបស់ព្រះ*

ព្រះបន្ទូលបានកំសាន្តចិត្តអ្នកដែលមានជំនឿលើព្រះអង្គ ដែលកំពុងតែកើតទុក្ខ ប៉ុន្តែក៏បានធ្វើអោយមានកំហឹងប្រឆាំងនឹងមនុស្សដែលធ្វើមិនដឹងធ្វើមិនឮចំពោះបញ្ញត្តិរបស់ទ្រង់ដែរ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកនិពន្ធមិនព្រមអោយភាពអស់សង្ឃឹម មកគ្របបាំងលើចិត្តគំនិតរបស់គាត់ឡើយ គាត់បានទទួលកម្លាំងថ្មីតាមរយៈការសញ្ជឹងគិតពីព្រះជាម្ចាស់។នៅពេលយើងស្រលាញ់ព្រះបន្ទូល យើងក៏អាចស្រលាញ់ព្រះជាម្ចាស់ដែរ។ ការស្រលាញ់នេះបានបង្កើតនៅជីវិតដែលពោរពេញដោយការស្តាប់បង្គាប់ និងអធិស្ឋាន។មនុស្សអាក្រក់គេបានស្អប់ខ្ពើម តែអ្នកដែលមានជំនឿ នឹងបានសប្បាយរីករាយ ហើយចែកចាយស្រលាញ់របស់ខ្លួនដើម្បីព្រះ។នៅក្នុងពិភពលោកសព្វថ្ងៃនេះពោរពេញដោយអំពើបាប។ ការស្វែងយល់អំពីព្រះបន្ទូលមានសារៈសំខាន់ណាស់ក្នុងការដឹកនាំមនុស្សអោយដើរតាមផ្លូវត្រឹមត្រូវ។ ពេលដែលមានអ្នកដើរខុសអំពីផ្លូវរបស់ព្រះជាម្ចាស់ ព្រះប្រហែលនឹងធ្វើអោយពួកគេរងទុក្ខវេទនា ដើម្បីអោយពួកគេបានត្រឡប់មករកព្រះអង្គវិញ។ទុក្ខវេទនារបស់អ្នកនិពន្ធក្នុងពេលនោះ ប្រហែលជាពាក្យភូតភរដែលពួកមនុស្សទុច្ចរិតចោទប្រកាន់មកលើគាត់។

សេចក្តីអធិស្ឋាន

# ក្រឹត្យវិន័យរបស់ព្រះ

## ទំនុកដំកើង 119:73-88

ការអធិស្ឋាន

អានអត្ថបទ

៧៣ ព្រះហស្តនៃទ្រង់បានបង្កើត ហើយតាំងទូលបង្គំឡើងសូមប្រោសឲ្យទូលបង្គំមានយោបល់
ដើម្បីនឹងរៀនឲ្យបានស្គាល់សេចក្តីបង្គាប់របស់ទ្រង់ ៧៤ ពួកអ្នកដែលកោតខ្លាចដល់ទ្រង់ គេនឹង
ឃើញទូលបង្គំហើយមានសេចក្តីអំណរ ដោយព្រោះទូលបង្គំបានសង្ឃឹមដល់ព្រះបន្ទូលនៃទ្រង់
៧៥ ឱព្រះយេហូវ៉ាអើយ ទូលបង្គំដឹងហើយថាអស់ទាំងខច្បាប់របស់ទ្រង់សុទ្ធតែសុចរិតហើយថា
ទ្រង់បានធ្វើឲ្យទូលបង្គំកើតមានទុក្ខដោយសេចក្តីស្មោះត្រង់របស់ទ្រង់ទេ ៧៦ ទូលបង្គំទូលអង្វរ
ដល់ទ្រង់ សូមឲ្យសេចក្តីសប្បុរសរបស់ទ្រង់ផ្សាយមកជួយដោះទុក្ខទូលបង្គំតាមសេចក្តីដែលទ្រង់
មានព្រះបន្ទូលដល់អ្នកបំរើទ្រង់ហើយ ៧៧ សូមប្រទានសេចក្តីមេត្តាករុណារបស់ទ្រង់មកទូលបង្គំ
ដើម្បីទូលបង្គំមានជីវិតស្ថិតស្ថេរនៅដ្បិតទូលបង្គំយកក្រឹត្យវិន័យទ្រង់ជាសេចក្តីអំណរដល់ខ្លួន
៧៨ សូមឲ្យពួកមនុស្សឆ្មើងឆ្មៃត្រូវមានសេចក្តីខ្មាសវិញដ្បិតគេបានប្រព្រឹត្តក្រវិចក្រវៀននឹងទូលបង្គំ
ដោយឥតហេតុតែទូលបង្គំនឹងរំពឹងគិតពីបញ្ញត្តទ្រង់ ៧៩ សូមឲ្យអស់អ្នកដែលកោតខ្លាចដល់ទ្រង់
បានបែរមកឯទូលបង្គំនោះគេនឹងស្គាល់សេចក្តីបន្ទាល់របស់ទ្រង់ផង ៨០ សូមឲ្យចិត្តទូលបង្គំបាន
ជាប់ស៊ប់នឹងបញ្ញត្តទ្រង់ដើម្បីកុំឲ្យទូលបង្គំត្រូវខ្មាសឡើយ។៨១ព្រលឹងនៃទូលបង្គំភ្លឹកទៅ ដោយ
ប្រាថ្នាចង់បានសេចក្តីសង្គ្រោះរបស់ទ្រង់ទូលបង្គំក៏សង្ឃឹមដល់ព្រះបន្ទូលទ្រង់ ៨២ ភ្នែកទូលបង្គំ
ស្រវាំងទៅដោយចង់បានព្រះបន្ទូលនៃទ្រង់ហើយទូលបង្គំនិយាយថា តើកាលណាបានទ្រង់ដោះ
ទុក្ខទូលបង្គំទៅ ៨៣ ដ្បិតទូលបង្គំបានត្រឡប់ដូចជាថង់ស្បែកដែលត្រូវផ្សែងតែទូលបង្គំមិនភ្លេច
បញ្ញត្តទ្រង់ឡើយ ៨៤ តើថ្ងៃអាយុនៃអ្នកបំរើទ្រង់បានប៉ុន្មានទៅតើដល់កាលណាបានទ្រង់សំរេច
ទោសដល់ពួកអ្នកដែលបៀតបៀនទូលបង្គំ ៨៥ ពួកមនុស្សឆ្មើងឆ្មៃបានជីករណ្តៅសំរាប់ចាប់ទូល
បង្គំជាការប្រព្រឹត្តល្មើសចំពោះក្រឹត្យវិន័យទ្រង់ ៨៦ អស់ទាំងសេចក្តីបង្គាប់របស់ទ្រង់សុទ្ធតែស្មោះ
ត្រង់ឯគេបៀតបៀនទូលបង្គំដោយឥតហេតុសូមជួយទូលបង្គំផង ៨៧ គេបានធ្វើឲ្យទូលបង្គំហៀប
តែនឹងសូន្យបាត់ពីផែនដីទៅប៉ុន្តែទូលបង្គំមិនបានបោះបង់ចោលបញ្ញត្តទ្រង់ទេ ៨៨ សូមចំរើនកំ
ឡាំងនៃទូលបង្គំ តាមសេចក្តីសប្បុរសរបស់ទ្រង់យ៉ាងនោះទូលបង្គំនឹងបានរក្សាសេចក្តីបន្ទាល់
ដែលចេញពីព្រះឱស្ឋទ្រង់មក។

73 Your hands made me and formed me;give me understanding to learn your commands.
74 May those who fear you rejoice when they see me,for I have put my hope in your word.
75 I know, Lord, that your laws are righteous,and that in faithfulness you have afflicted me.
76 May your unfailing love be my comfort,according to your promise to your servant.
77 Let your compassion come to me that I may live,for your law is my delight.
May the arrogant be put to shame for wronging me without cause;
78 but I will meditate on your precepts.
79 May those who fear you turn to me,
those who understand your statutes.
80 May I wholeheartedly follow your decrees, that I may not be put to shame.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

### *ក្រឹត្យវិន័យរបស់ព្រះ*

ព្រះជាម្ចាស់ដែលបានបង្កើតគាត់មក បានចម្រើនលក្ខណៈសម្បត្តិរបស់គាត់តាមរយៈទុក្ខវេទនានេះ ដោយសារគាត់បានឆ្លងកាត់ការលំបាកទាំងអស់នេះ នាំអោយគាត់មានជំនឿមាំមួនជាងមុន ហើយអាចលើកទឹកចិត្តដល់មនុស្សដទៃទៀតបាន។គាត់អធិស្ឋានថា បើសត្រូវវាយប្រហារម្តងទៀត សូមព្រះជាម្ចាស់ធ្វើអោយពួកគេបរាជ័យ ហើយលទ្ធផលនេះនឹងធ្វើអោយក្លាយជាការលើកទឹកចិត្តដល់ពួកអ្នកជឿថែមទៀតផង។ក្នុងពេលនេះអ្នកនិពន្ធកំពុងរងទុក្ខវេទនា ហើយមានអារម្មណ៍ថា ហេតុអ្វីបានជាព្រះពន្យាពេលក្នុងការសង្គ្រោះដល់គាត់តាមព្រះបន្ទូលសន្យា។ គាត់មានអារម្មណ៍ថា គ្មានប្រយោជន៍ និងគ្មានជីវិតសោះ ដូចជាថង់ស្រាដែលរីងស្ងួត។ទោះបីយ៉ាងណាគាត់មិនបានបោះបង់ចោលសេចក្តីសង្ឃឹមទេ។គាត់នៅតែជឿលើការស្រលាញ់ដែលមិនចេះប្រែប្រួលរបស់ព្រះជាម្ចាស់ជានិច្ច ព្រះនឹងអាចដោះគាត់អោយរួចចេញពីល្បិចកលរបស់ជនដែលបានធ្វើបាបគាត់។

សេចក្តីអធិស្ឋាន

ខែ12
ថ្ងៃព្រ.ហ 27

# ក្រឹត្យវិន័យរបស់ព្រះ

## ទំនុកដំកើង 119:89-112

ការអធិស្ឋាន

អានអត្ថបទ

៨៩ ឱព្រះយេហូវ៉ាអើយព្រះបន្ទូលទ្រង់បានតាំងនៅស្ថានសួគ៌ដរាបដល់អស់កល្បជានិច្ច ៩០ សេចក្តី
ស្មោះត្រង់របស់ទ្រង់ ក៏ស្ថិតស្ថេរនៅគ្រប់ទាំងដំណមនុស្សតទៅទ្រង់បានប្រតិស្ឋានផែនដី ហើយ
ផែនដីក៏តាំងនៅជាប់ ៩១ ទាំងអស់ស្ថិតស្ថេរនៅ ដរាបដល់សព្វថ្ងៃនេះតាមច្បាប់ទ្រង់ដ្បិតទាំងអស់
សំរាប់បំរើទ្រង់ ៩២ បើទូលបង្គំមិនបានរីករាយក្នុងក្រឹត្យវិន័យរបស់ទ្រង់នោះទូលបង្គំនឹងបានវិនាស
ទៅក្នុងសេចក្តីទុក្ខព្រួយរបស់ទូលបង្គំហើយ ៩៣ ទូលបង្គំនឹងមិនដែលភ្លេចបញ្ញត្តទ្រង់ឡើយដ្បិត
ទ្រង់បានប្រោសឲ្យទូលបង្គំមានកំឡាំងឡើងដោយសារបញ្ញត្តទាំងនោះឯង ៩៤ ទូលបង្គំជារបស់
ផងទ្រង់ហើយសូមជួយសង្គ្រោះទូលបង្គំផងដ្បិតទូលបង្គំបានស្វែងរកបញ្ញត្តទ្រង់ ៩៥ ពួកមនុស្ស
អាក្រក់បានរង់ចាំនឹងធ្វើឲ្យទូលបង្គំវិនាសតែទូលបង្គំនឹងពិចារណាសេចក្តីបន្ទាល់របស់ទ្រង់
៩៦ ទូលបង្គំបានឃើញចុងនៃសេចក្តីគ្រប់លក្ខណ៍ហើយតែសេចក្តីបង្គាប់របស់ទ្រង់ធំទូលាយ
លើសទៅទៀត។ ៩៧ ឱទូលបង្គំស្រឡាញ់ក្រឹត្យវិន័យរបស់ទ្រង់ណាស់ហ្ន៎ទូលបង្គំរំពឹងគិតពីក្រឹត្យវិ
ន័យនោះជាដរាបរាល់ថ្ងៃ ៩៨ សេចក្តីបង្គាប់របស់ទ្រង់ ក៏ធ្វើឲ្យទូលបង្គំមានប្រាជ្ញាលើសជាងខ្មាំង
សត្រូវដ្បិតបាននៅជាប់ជាមួយនឹងទូលបង្គំជាដរាប ៩៩ ទូលបង្គំមានយោបល់ជាងអស់ទាំងគ្រូ
របស់ទូលបង្គំទៅទៀតដ្បិតសេចក្តីបន្ទាល់ទ្រង់ជាទីនឹករំពឹងរបស់ទូលបង្គំ ១០០ ទូលបង្គំយល់បាន
ច្រើនជាងពួកចាស់ៗពីព្រោះទូលបង្គំបានរក្សាអស់ទាំងបញ្ញត្តរបស់ទ្រង់ ១០១ ទូលបង្គំបានបង្ខាំង
ជើងឲ្យវៀរចាកពីផ្លូវអាក្រក់ដើម្បីឲ្យទូលបង្គំបានកាន់តាមព្រះបន្ទូលនៃទ្រង់ ១០២ ទូលបង្គំមិនបាន
បែរចេញពីច្បាប់ទ្រង់ឡើយដ្បិតទ្រង់បានបង្រៀនទូលបង្គំ

89 Your word, Lord, is eternal;it stands firm in the heavens.
90 Your faithfulness continues through all generations;
you established the earth, and it endures.
91 Your laws endure to this day,for all things serve you.
92 If your law had not been my delight,
I would have perished in my affliction.
93 I will never forget your precepts,
for by them you have preserved my life.
94 Save me, for I am yours;
I have sought out your precepts.
95 The wicked are waiting to destroy me,
but I will ponder your statutes.
96 To all perfection I see a limit,but your commands are boundless.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

### *ក្រឹត្យវិន័យរបស់ព្រះ*

ព្រះជាម្ចាស់នឹងព្រះបន្ទូលរបស់ទ្រង់បានស្ថិតស្ថេរ ហើយមិនប្រែប្រួលជារៀងរហូត។ព្រះបន្ទូលសន្យារបស់ព្រះអង្គគឺជាព្រះបន្ទូលដ៏ពិតតែមួយគត់។ក្នុងរឿងនេះបានលើកទឹកចិត្តដល់គាត់ក៏ដូចជាយើងរាល់គ្នាអោយជឿថា ព្រះជាម្ចាស់នឹងសង្គ្រោះគាត់ក៏ដូចជាសង្គ្រោះយើងរាល់គ្នាអោយឆ្លងផុតចេញពីសេចក្តីវេទនា ការរងទុក្ខលំបាកទាំងប៉ុន្មានអោយអស់។នៅពេលដែលរៀនព្រះបន្ទូលនៃព្រះជាម្ចាស់ តាមរយៈការសិក្សា និងការសញ្ជឹងគិតពិចារណា នោះទាំងគាត់ទាំងយើងបានរកឃើញប្រាជ្ញាពិត។គាត់នឹងមានប្រាជ្ញាជាងអ្នកដែលមានប្រាជ្ញានៅលើលោក ទោះបីជាគេធ្លាប់បានឆ្លងកាត់បទពិសោធន៍ជាច្រើនឆ្នាំហើយក៏ដោយ។ប្រាជ្ញាដែលបានមកពីព្រះបន្ទូល បានបង្កើតនូវភាពសុចរិត និងការជំនុំជម្រះដ៏ត្រឹមត្រូវ។ វាបានបង្ហាញអោយអ្នកនិពន្ធដឹងថា តើគាត់ត្រូវមានប្រតិកម្មបែបណា នៅពេលគាត់កំពុងតែត្រូវគេធ្វើបាប។ នៅពេលគាត់កំពុងថ្វាយបង្គំ ឬអធិស្ឋាននិងក្នុងពេលគាត់កំពុងតែមានគ្រោះថ្នាក់ផងដែរ។ ព្រះបន្ទូលបានផ្តល់អោយគាត់នៅអំណរដ៏ជ្រាលជ្រៅ នៅក្នុងចិត្តរបស់គាត់ទៀតផង។

សេចក្តីអធិស្ឋាន

ខែ12 ថ្ងៃសៅរ៍ 28

# ក្រឹត្យវិន័យរបស់ព្រះ

## ទំនុកដំកើង 119:113-136

ការអធិស្ឋាន

អានអត្ថបទ

១១៣ ទូលបង្គំស្អប់ចំពោះអស់អ្នកដែលមានចិត្ត២តែទូលបង្គំស្រឡាញ់ដល់ក្រឹត្យវិន័យទ្រង់វិញ
១១៤ ទ្រង់ជាទីពឹងជ្រកហើយជាខែលរបស់ទូលបង្គំទូលបង្គំសង្ឃឹមដល់ព្រះបន្ទូលនៃទ្រង់
១១៥ នៃអ្នករាល់គ្នាដែលប្រព្រឹត្តអាក្រក់អើយចូរថយពីអញចេញដើម្បីឲ្យអញបានរក្សាសេចក្តី
បង្គាប់របស់ព្រះនៃអញ ១១៦ សូមទប់ទល់ទូលបង្គំតាមព្រះបន្ទូលនៃទ្រង់ឲ្យទូលបង្គំបានរស់នៅ
សូមកុំឲ្យទូលបង្គំត្រូវខ្មាសដោយព្រោះសេចក្តីសង្ឃឹមរបស់ទូលបង្គំឡើយ ១១៧ សូមទ្រង់ធ្វើជា
បង្អែកនៃទូលបង្គំឲ្យទូលបង្គំបានសេចក្តីសុខនោះទូលបង្គំនឹងគោរពរាប់អានចំពោះបញ្ញត្តទ្រង់ជា
និច្ច ១១៨ ទ្រង់បានលើកថ្លឹងនូវអស់អ្នកដែលវង្វេងចេញពីបញ្ញត្តទ្រង់ដ្បិតសេចក្តីឆបោករបស់គេជា
សេចក្តីកំភូតទទេ ១១៩ ទ្រង់ធ្វើឲ្យពួកមនុស្សអាក្រក់បាត់ចេញពីផែនដីដូចជាគេជួសពពុះចេញពី
ឆ្នាំងហេតុនោះបានជាទូលបង្គំស្រឡាញ់ដល់សេចក្តីបន្ទាល់របស់ទ្រង់ ១២០ រូបសាច់ទូលបង្គំញ័រញាក់
ដោយភ័យខ្លាចដល់ទ្រង់ទូលបង្គំក៏ខ្លាចចំពោះសេចក្តីវិនិច្ឆ័យរបស់ទ្រង់ដែរ។១២១ ទូលបង្គំបានសំរេចតាមសេ
ចក្តីយុត្តិធម៌និងសេចក្តីសុចរិតសូមកុំបោះបង់ចោលទូលបង្គំទៅក្នុងអំណាចនៃពួកអ្នកដែលសង្កត់សង្កិន
ឡើយ ១២២ សូមទ្រង់ធានាឲ្យអ្នកបំរើទ្រង់បានសេចក្តីល្អសូមកុំឲ្យពួកមនុស្សឆ្មើងឆ្មៃសង្កត់សង្កិនទូលបង្គំ
ឡើយ១២៣ ភ្នែកទូលបង្គំស្រវាំងទៅ ដោយទន្ទឹងចាំឲ្យបានសេចក្តីសង្គ្រោះនឹងព្រះបន្ទូលដ៏សុចរិតរបស់ទ្រង់
១២៤ សូមប្រព្រឹត្តនឹងអ្នកបំរើទ្រង់តាមសេចក្តីសប្បុរសរបស់ទ្រង់ហើយបង្រៀនអស់ទាំងបញ្ញត្តរបស់ទ្រង់ដល់
ទូលបង្គំ ១២៥ ទូលបង្គំជាអ្នកបំរើទ្រង់ហើយសូមប្រទានឲ្យទូលបង្គំមានយោបល់ដើម្បីឲ្យបានស្គាល់សេចក្តី
បន្ទាល់របស់ទ្រង់ ១២៦ នេះជាវេលាដែលគួរឲ្យព្រះយេហូវ៉ាសំរេចការហើយដ្បិតគេបានរំលងល្មើសចំពោះ
ក្រឹត្យវិន័យរបស់ទ្រង់១២៧ ហេតុនោះបានជាទូលបង្គំស្រឡាញ់ដល់សេចក្តីបង្គាប់របស់ទ្រង់ច្រើនជាងមាសអើ
ក៏ស្រឡាញ់ច្រើនជាងមាសសុទ្ធផង ១២៨ ដូច្នេះទូលបង្គំរាប់អស់ទាំងបញ្ញត្តទ្រង់ថាជាត្រឹមត្រូវគ្រប់ប្រការតែ
ទូលបង្គំស្អប់ដល់គ្រប់ទាំងផ្លូវកំភូតវិញ។ ១២៩សេចក្តីបន្ទាល់របស់ទ្រង់សុទ្ធតែអស្ចារ្យហេតុនោះបានជា
ព្រលឹងនៃទូលបង្គំគោរពកាន់តាម ១៣០ ការបើកសំដែងព្រះបន្ទូលទ្រង់នោះផ្សាយពន្លឺចេញក៏ធ្វើឲ្យមនុស្ស
ឆោតល្ងង់មានយោបល់ ១៣១ ទូលបង្គំបានហាមាត់ដកដង្ហើមធំដោយនឹករឭកដល់សេចក្តីបង្គាប់របស់ទ្រង់
១៣២ សូមទ្រង់បែរមកមានសេចក្តីអាណិតមេត្តាដល់ទូលបង្គំដូចជាទ្រង់តែងធ្លាប់ធ្វើដល់អស់អ្នកដែល
ស្រឡាញ់ព្រះនាមទ្រង់ ១៣៣ សូមតាំងជំហាននៃទូលបង្គំឲ្យដើរតាមព្រះបន្ទូលទ្រង់សូមកុំឲ្យសេចក្តីទុច្ចរិត
ណាមានអំណាចលើទូលបង្គំឡើយ ១៣៤ សូមលោះទូលបង្គំឲ្យរួចពីការសង្កត់សង្កិនរបស់មនុស្សនោះទូល
បង្គំនឹងកាន់តាមបញ្ញត្តទ្រង់១៣៥ សូមឲ្យព្រះភក្ត្រទ្រង់ភ្លឺមកលើអ្នកបំរើទ្រង់ហើយបង្រៀនអស់ទាំងបញ្ញត្តទ្រង់
ដល់ទូលបង្គំផង១៣៦ ទឹកភ្នែកទូលបង្គំហូររហាមពីព្រោះគេមិនកាន់តាមក្រឹត្យវិន័យរបស់ទ្រង់។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

.........................................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

.........................................................................................................

## ការយល់ដឹងអំពីអត្ថបទ

***ក្រឹត្យវិន័យរបស់ព្រះ***

ផលផ្លែមួយដែលបានមកពីការស្រលាញ់នោះគឺ ការស្អប់គ្រប់ទាំងអំពើទុច្ចរិត និងការបៀតបៀនអំពើល្អ។ ព្រះនឹងដាក់ទណ្ឌកម្មដល់មនុស្សទាំងអស់ដែលជំទាស់នឹងព្រះបន្ទូល។ នេះជាមូលហេតុធំបំផុតដែលប្រជារាស្ត្រទាំងអស់ត្រូវតែកោតខ្លាចព្រះជាម្ចាស់ ហើយស្តាប់បង្គាប់ព្រះអង្គ។តាមរូបភាពនៃការស្តាប់បង្គាប់របស់គាត់ផ្ទាល់ និងព្រះបន្ទូលសន្យា អ្នកនិពន្ធសុំអោយព្រះសង្គ្រោះគាត់ អោយរួចផុតពីពួកដែលតែងតែយាយី និងពួកអ្នកដែលធ្វើខុសក្រិត្យវិន័យរបស់ព្រះ។ ពួកសត្រូវស្អប់បញ្ញត្តិច្បាប់របស់ព្រះ ប៉ុន្តែគាត់ក៏ដូចជាខ្ញុំបានពេញចិត្តនឹងច្បាប់ទាំងនេះវិញ។

ព្រះបន្ទូលរបស់ព្រះមានអត្ថន័យជ្រាលជ្រៅ ធ្វើអោយអ្នកបម្រើស្មោះត្រង់របស់ទ្រង់មានចិត្តចង់ស្វែងយល់ថែមទៀត។គាត់ដឹងថា ពេលដែលគាត់ធ្វើតាមព្រះបន្ទូលរបស់ព្រះ គាត់នឹងឈ្នះលើគ្រប់អំពើបាប និងសេចក្តីល្បួងទាំងឡាយ។គាត់យំសោកស្តាយនៅពេលគាត់ដឹងថា មនុស្សទាំងឡាយជាន់ឈ្លីសេចក្តីបង្រៀនដ៏មានប្រយោជន៍នេះ។

សេចក្តីអធិស្ឋាន

ខែ12
ថ្ងៃអាទិត្យ 29

# ការអធិប្បាយថ្ងៃអាទិត្យ

- ចំណងជើង :
- អត្ថបទ :
- អ្នកអធិប្បាយ :



ការប្រកបរបស់យើងជាមួយនិងព្រះ

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ



ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

## សេចក្ដីអធិស្ឋាន

ខែ12 ថ្ងៃច័ន្ទ 30

# ក្រឹត្យវិន័យរបស់ព្រះ

## ទំនុកដំកើង 119:137-152

ការអធិស្ឋាន

អានអត្ថបទ

[១៣៧] ឱព្រះយេហូវ៉ាអើយ ទ្រង់សុចរិតហើយសេចក្តីវិនិច្ឆ័យរបស់ទ្រង់ក៏សុទ្ធតែទៀងត្រង់[១៣៨] ទ្រង់
បានតាំងសេចក្តីបន្ទាល់របស់ទ្រង់នៅលើសេចក្តីយុត្តិធម៌ហើយលើសេចក្តីស្មោះត្រង់ដ៏ពិតផង
[១៣៩] សេចក្តីឧស្សាហ៍របស់ទូលបង្គំបានស៊ីបង្ហិនទូលបង្គំពីព្រោះអ្នកតតាំងនឹងទូលបង្គំគេបានភ្លេ
ព្រះបន្ទូលទ្រង់ [១៤០] ព្រះបន្ទូលទ្រង់បានត្រូវសំរង់យ៉ាងបរិសុទ្ធជាទីបំផុតហើយហេតុនោះអ្នកបំរើ
របស់ទ្រង់ក៏ស្រឡាញ់ណាស់[១៤១] ឯទូលបង្គំជាអ្នកតូច ហើយត្រូវគេមើលងាយប៉ុន្តែទូលបង្គំមិន
ភ្លេចបញ្ញត្តរបស់ទ្រង់ឡើយ [១៤២] សេចក្តីសុចរិតរបស់ទ្រង់ជាសេចក្តីសុចរិតដ៏នៅអស់កល្បជានិច្ច
ហើយក្រឹត្យវិន័យទ្រង់ជាសេចក្តីពិត[១៤៣] សេចក្តីទុក្ខ និងសេចក្តីលំបាក បានមកគ្របសង្កត់លើ
ទូលបង្គំហើយទោះបើយ៉ាងនោះ គង់តែសេចក្តីបង្គាប់របស់ទ្រង់ជាទីរីករាយដល់ទូលបង្គំដែរ
[១៤៤] សេចក្តីបន្ទាល់របស់ទ្រង់ សុទ្ធតែសុចរិតនៅជាដរាបសូមប្រោសឲ្យទូលបង្គំមានយោបល់នោះ
ទូលបង្គំនឹងបានរស់នៅ។[១៤៥] ទូលបង្គំបានអំពាវនាវដល់ទ្រង់អស់ពីចិត្តឱព្រះយេហូវ៉ាអើយ សូម
ឆ្លើយមកទូលបង្គំផងទូលបង្គំនឹងរក្សាអស់ទាំងបញ្ញត្តរបស់ទ្រង់ [១៤៦] ទូលបង្គំបានអំពាវនាវដល់
ទ្រង់ហើយសូមជួយសង្គ្រោះទូលបង្គំផងនោះទូលបង្គំនឹងកាន់តាមសេចក្តីបន្ទាល់របស់ទ្រង់
[១៤៧] ទូលបង្គំបានភ្ញាក់មុនពេលព្រលឹមស្រាងហើយបានបន្លឺឡើងថាទូលបង្គំបានសង្ឃឹមដល់ព្រះ
បន្ទូលទ្រង់[១៤៨] ទូលបង្គំភ្ញាក់មុនអស់ទាំងយាមយប់ ហើយបើកភ្នែកដើម្បីរំពឹងគិតពីព្រះបន្ទូលទ្រង់
[១៤៩] សូមស្តាប់សំឡេងទូលបង្គំ តាមសេចក្តីសប្បុរសរបស់ទ្រង់ឱព្រះយេហូវ៉ាអើយ សូមប្រោសឲ្យ
ទូលបង្គំមានកំឡាំងឡើង តាមច្បាប់របស់ទ្រង់[១៥០] ពួកអ្នកដែលរត់តាមសេចក្តីអាក្រក់ គេមកកាន់
តែជិតគេនៅឆ្ងាយពីក្រឹត្យវិន័យទ្រង់ទេ[១៥១] ឯទ្រង់ ឱព្រះយេហូវ៉ាអើយ ទ្រង់គង់នៅជិតដែរហើយ
គ្រប់ទាំងសេចក្តីបង្គាប់របស់ទ្រង់ សុទ្ធតែពិតត្រង់[១៥២] តាំងពីយូរមកហើយ ទូលបង្គំបានដឹង
ដោយសារសេចក្តីបន្ទាល់របស់ទ្រង់ថាទ្រង់បានតាំងសេចក្តីទាំងនោះឲ្យនៅអស់កល្បជានិច្ច។

[137] You are righteous, Lord,
and your laws are right.
[138] The statutes you have laid down are righteous;
they are fully trustworthy.
[139] My zeal wears me out,
for my enemies ignore your words.
[140] Your promises have been thoroughly tested,
and your servant loves them.
[141] Though I am lowly and despised,
I do not forget your precepts.
[142] Your righteousness is everlasting
and your law is true.
[143] Trouble and distress have come upon me,
but your commands give me delight.
[144] Your statutes are always righteous; give me understanding that I may live.

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

ការអនុវត្តន៍ក្នុងការរស់នៅ

## ការយល់ដឹងអំពីអត្ថបទ

### *ក្រឹត្យវិន័យរបស់ព្រះ*

អ្នកនិពន្ធរឹតតែមានកាឈឺចាប់ទៅទៀត នៅពេលដឹងថា ការដែលពួកគេមិនគោរពព្រះបន្ទូល នោះធ្វើអោយពួកគេត្រូវកាត់ផ្តាច់ចេញពីការយល់ដឹងរបស់ព្រះជាម្ចាស់។មានតែការសិក្សាស្វែងយល់ពីព្រះបន្ទូលទេដែលធ្វើអោយមនុស្សទាំងអស់ បានបង្កើតចំណេះដឹងពីភាពយុត្តិធម៌ និងស្មោះត្រង់របស់ព្រះអម្ចាស់។ចំពោះអ្នកនិពន្ធទំនុកដំកើងវិញគាត់បានយល់ថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់អាចទុកចិត្តបាន ហើយជាព្រះបន្ទូលពិត ជាប្រភពនៃការកម្សាន្តចិត្តនិងការប្រដៅណែនាំ។ការស្តាប់បង្គាប់ព្រះបន្ទូល ធ្វើអោយគេមានទំនុកចិត្តក្នុងការអធិស្ឋាន ប៉ុន្តែនេះមិនមែនមានន័យថា ជាការកាត់បន្ថយតម្រូវការ ក្នុងការអប់រំខ្លួនឯងនោះទេ ទោះបីជានៅក្នុងការសិក្សាព្រះបន្ទូលក៏ដូចជាការអធិស្ឋានដែរ។ ទោះបីជាមានគ្រោះថ្នាក់យ៉ាងណា ក៏ព្រះជាម្ចាស់តែងតែនៅជិតមនុស្សដែលស្មោះត្រង់ចំពោះព្រះអង្គជានិច្ច។

សេចក្តីអធិស្ឋាន

ខែ12
ថ្ងៃអង្គារ 31

# ក្រឹត្យវិន័យរបស់ព្រះ

## ទំនុកដំកើង 119:153-176

ការអធិស្ឋាន

អានអត្ថបទ

១៥៣ សូមទតមើលសេចក្ដីទុក្ខព្រួយរបស់ទូលបង្គំហើយជួយឲ្យរួចផងទូលបង្គំមិនភ្លេចក្រឹត្យវិន័យរបស់ទ្រង់
ឡើយ១៥៤ សូមការពាររឿងក្ដីរបស់ទូលបង្គំហើយលោះទូលបង្គំផងសូមប្រោសឲ្យទូលបង្គំមានកំឡាំង តាម
ព្រះបន្ទូលទ្រង់១៥៥ សេចក្ដីសង្គ្រោះរមែងនៅឆ្ងាយពីពួកមនុស្សអាក្រក់ពីព្រោះគេមិនស្វែងរកបញ្ញត្តរបស់
ទ្រង់១៥៦ ឱព្រះយេហូវ៉ាអើយ សេចក្ដីមេត្តាករុណាដ៏ទន់សន្ដោសរបស់ទ្រង់ នោះលើសលុបសូមប្រោសឲ្យ
ទូលបង្គំមានកំឡាំង តាមច្បាប់របស់ទ្រង់១៥៧ ឯពួកអ្នកដែលបៀតបៀន ហើយតតាំងនឹងទូលបង្គំគេមានគ្នា
ច្រើនប៉ុន្តែទូលបង្គំមិនបានបែរចេញពីសេចក្ដីបន្ទាល់របស់ទ្រង់ឡើយ១៥៨ ទូលបង្គំបានពិចារណាមើលមនុស្ស
ក្បត់ហើយក៏ស្អប់ខ្ពើមគេដោយព្រោះមិនកាន់តាមព្រះបន្ទូលទ្រង់សោះ១៥៩ សូមទ្រង់ពិចារណាដែលទូលបង្គំ
ស្រឡាញ់ដល់អស់ទាំងបញ្ញត្តរបស់ទ្រង់ជាយ៉ាងណាឱព្រះយេហូវ៉ាអើយ សូមប្រោសឲ្យទូលបង្គំមានកំឡាំង
ឡើង តាមសេចក្ដីសប្បុរសរបស់ទ្រង់១៦០ បូករួមទាំងអស់ព្រះបន្ទូលនៃទ្រង់ទៅឃើញថាពិតត្រង់ទាំងអស់
ហើយគ្រប់ទាំងច្បាប់ដ៏សុចរិតរបស់ទ្រង់ក៏ស្ថិតស្ថេរនៅអស់កល្បជានិច្ចដែរ។ ១៦១ ពួកអ្នកធំបានបៀតបៀន
ទូលបង្គំដោយឥតហេតុប៉ុន្តែចិត្តទូលបង្គំនៅតែភ័យញ័រចំពោះព្រះបន្ទូលទ្រង់១៦២ ទូលបង្គំមានសេចក្ដីរីករាយ
ចំពោះព្រះបន្ទូលទ្រង់ប្រៀបដូចជាមនុស្សណាដែលប្រទះនឹងរបឹបជាច្រើន១៦៣ ទូលបង្គំជិនណាយ ហើយក៏
ស្អប់ខ្ពើមសេចក្ដីកំភូតតែស្រឡាញ់ដល់ក្រឹត្យវិន័យទ្រង់វិញ ១៦៤ ទូលបង្គំសរសើរដល់ទ្រង់ក្នុង១ថ្ងៃដងដោយ
ព្រោះច្បាប់ដ៏សុចរិតរបស់ទ្រង់១៦៥ ពួកអ្នកដែលស្រឡាញ់ក្រឹត្យវិន័យទ្រង់នោះមានសេចក្ដីសុខដ៏លើសលុប
ហើយគ្មានហេតុនឹងចំពប់ដួលឡើយ១៦៦ ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានសង្ឃឹមដល់សេចក្ដីសង្គ្រោះរបស់
ទ្រង់ក៏បានប្រព្រឹត្តតាមបង្គាប់របស់ទ្រង់ដែរ ១៦៧ ព្រលឹងទូលបង្គំបានកាន់តាមសេចក្ដីបន្ទាល់របស់ទ្រង់ទូល
បង្គំក៏ស្រឡាញ់សេចក្ដីបន្ទាល់នោះយ៉ាងក្រៃលែង ១៦៨ ទូលបង្គំបានកាន់តាមអស់ទាំងបញ្ញត្តនិងសេចក្ដី
បន្ទាល់របស់ទ្រង់ពីព្រោះអស់ទាំងផ្លូវដែលទូលបង្គំប្រព្រឹត្តនោះសុទ្ធតែនៅចំពោះទ្រង់ហើយ។១៦៩ ឱព្រះយេ
ហូវ៉ាអើយ សូមឲ្យសំរែករបស់ទូលបង្គំបានចូលមកជិតនៅចំពោះទ្រង់សូមប្រទានឲ្យទូលបង្គំមានយោបល់
តាមព្រះបន្ទូលទ្រង់ ១៧០ សូមឲ្យពាក្យអង្វររបស់ទូលបង្គំបានមកនៅចំពោះទ្រង់សូមប្រោសទូលបង្គំឲ្យបាន
រួច តាមព្រះបន្ទូលទ្រង់ផង១៧១ សូមអនុញ្ញាតឲ្យបបូរមាត់ទូលបង្គំ បានពោលពាក្យសរសើរដ្បិតទ្រង់បង្រៀន
អស់ទាំងបញ្ញត្តរបស់ទ្រង់ដល់ទូលបង្គំ១៧២ សូមឲ្យអណ្ដាតទូលបង្គំបានច្រៀងពីព្រះបន្ទូលទ្រង់ពីព្រោះគ្រប់
ទាំងសេចក្ដីបង្គាប់របស់ទ្រង់សុទ្ធតែសុចរិតទាំងអស់ ១៧៣ សូមឲ្យព្រះហស្តទ្រង់បានប្រុងប្រៀបនឹងជួយទូល
បង្គំព្រោះទូលបង្គំបានរើសយកបញ្ញត្តរបស់ទ្រង់ ១៧៤ ឱព្រះយេហូវ៉ាអើយ ទូលបង្គំបាននឹករឭកដល់សេចក្ដី
សង្គ្រោះរបស់ទ្រង់ហើយក្រឹត្យវិន័យរបស់ទ្រង់ជាទីរីករាយដល់ទូលបង្គំ ១៧៥ សូមអនុញ្ញាតឲ្យព្រលឹងទូលបង្គំ
រស់នៅ នោះនឹងបានសរសើរដល់ទ្រង់ហើយសូមឲ្យច្បាប់របស់ទ្រង់ជួយទូលបង្គំផង១៧៦ ទូលបង្គំបានវង្វេង
ទៅ ដូចជាចៀមបាត់បង់សូមដេញរកអ្នកបំរើទ្រង់ផងដ្បិតទូលបង្គំមិនភ្លេចសេចក្ដីបង្គាប់របស់ទ្រង់ឡើយ។

ព្រះបន្ទូលដែលប្រទានថ្ងៃនេះ

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

ការអនុវត្តន៍ក្នុងការរស់នៅ

....................................................................................................

....................................................................................................

....................................................................................................

## ការយល់ដឹងអំពីអត្ថបទ

### *ក្រឹត្យវិន័យរបស់ព្រះ*

នៅពេលអ្នកនិពន្ធមានបញ្ហាធ្ងន់ធ្ងរ គាត់កាន់តែទូលអង្វរព្រះខ្លាំងឡើង គាត់រំលឹកព្រះថា គាត់មានចិត្តស្មោះត្រង់ចំពោះព្រះបន្ទូលជារៀងរហូតមក ហើយសុំអោយព្រះជួយសង្គ្រោះគាត់ផង។ គាត់យកសេចក្ដីស្រលាញ់ សច្ចធម៌ និងយុត្តិធម៌របស់ព្រះជាគោល ក្នុងការទូលអង្វរព្រះអោយជួយគាត់។អ្នកនិពន្ធមានអំណរខ្លាំងចំពោះព្រះបន្ទូលរបស់ព្រះ ហេតុដូច្នេះហើយ បានជាគាត់មានជំហររឹងប៉ឹង ក្នុងពេលដែលគាត់ប្រទះនឹងការបៀតបៀន ព្រមទាំងនៅតែអធិស្ឋានជាប់ជានិច្ច។ ជីវិតរបស់គាត់ ជាជីវិតដែលមានភាពសុខសាន្តនឹងលំនឹងខាងផ្នែកព្រលឹងវិញ្ញាណ។ គាត់មានចិត្តស្ងប់ស្ងាត់ ដោយមានទំនុកចិត្តលើព្រះជាម្ចាស់ហើយរង់ចាំព្រះអង្គសង្គ្រោះគាត់។អ្នកនិពន្ធ បញ្ចប់ការសញ្ជឹងគិតថា ខ្លាំងរបស់គាត់ ដោយសង្ខេបសំណើររបស់គាត់ចំពោះព្រះជាម្ចាស់ថា សូមព្រះអង្គប្រទានប្រាជ្ញាអោយគាត់យល់ព្រះបន្ទូលច្បាស់ ដោះគាត់អោយរួចពីទុក្ខសោក អោយមានចិត្តក្លាហានក្នុងការប្រកាសពីភាពគ្រប់លក្ខនៃព្រះបន្ទូល សុំជំនួយជាប្រចាំពីព្រះជាម្ចាស់ ព្រោះគាត់បានស្ដាប់ព្រះបន្ទូលជានិច្ច គាត់សុំព្រះជាម្ចាស់ជួយកែតម្រូវគាត់ ពេលគាត់ដើរខុសផ្លូវរបស់ព្រះជាម្ចាស់។

សេចក្ដីអធិស្ឋាន

ការចែកចាយស្ងៀមស្ងាត់
ក្នុងបន្ទប់ប្រជុំ
ខែ វិច្ឆិកា សប្ដាហ៍ទី ១

# ជំនឿដែលរីកឡើងក្នុងគ្រាលំបាក

## ពង្សាវតារក្សត្រទី១ ១៥:១-២៤

ពាក្យសម្ដី

Ice breaking ▶ ការចែកចាយក្នុងអាទិត្យមុន

ការចែកចាយដោយព្រះបន្ទូល

១.អ័ប៊ីយ៉ា ដែលបានឡើងសោយរាជ្យនៅស្រុកយូដា បន្ទាប់ពីយេរ៉ូបោម បានប្រព្រឹត្តអំពើបាបទាំងប៉ុន្មានដែលឪពុកខ្លួនធ្លាប់បានប្រព្រឹត្តរួចទៅហើយ តើចិត្តរបស់គាត់បែបណាដែរ? (ខ៣)

២.អេសាបានប្រព្រឹត្តយ៉ាងទៀងត្រង់នៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ដូចព្រះបាទដាវីឌដែរ ដោយបណ្ដេញពួកសុដុមចេញ ហើយដករូបព្រះទាំងប៉ុន្មានដែលបុព្វបុរសរបស់ទ្រង់បានធ្វើនោះចេញ។ (ខ១៣)

ការចែកចាយសៀមស្ងាត់
ក្នុងបន្ទប់ប្រជុំ
ខែ វិច្ឆិកា សប្តាហ៍ទី ២

# ព្រះកំពុងចិញ្ចឹមអេលីយ៉ា

## ពង្សាវតារក្សត្រទី១ ១៧:១-៧

ពាក្យសម្តី

ការចែកចាយក្នុងអាទិត្យមុន Ice breaking

ការចែកចាយដោយព្រះបន្ទូល

១. តើព្រះដាក់វិន័យបែបណាទៅលើអ៊ីស្រាអែលខាងជើងតាមរយៈអេលីយ៉ា ? (ខ១)

២.ព្រះដឹកនាំអេលីយ៉ាទៅជ្រលងកេរីត។ តើព្រះបានបង្គាប់អ្វីនៅទីនោះឲ្យចិញ្ចឹមអេលីយ៉ា ? (ខ៤)

ការចែកចាយសៀមស្វាត់
ក្នុងបន្ទប់ប្រជុំ
ខែ វិច្ឆិកា សប្តាហ៍ទី ៣

# ពួកគេបានមកដល់ភ្នំហោរែបជាភ្នំរបស់ព្រះ

## ពង្សាវតារក្សត្រទី១ ១៩:១-៨

ពាក្យសម្តី

Ice breaking ▶ ការចែកចាយក្នុងអាទិត្យមុន

ការចែកចាយដោយព្រះបន្ទូល

១. តើអេលីយ៉ាបានធ្វើអ្វី ពេលគាត់ទទួលរងការគំរាមកំហែងពីយេសិបិល ? ( ៣, ៤ )

២. តើព្រះបានធ្វើអ្វីដល់អេលីយ៉ា ដែលហត់នឿយ ហើយដេកនៅក្រោមដើមដង្កោ ? ( ៥,៧ )

# គេរដំណែលជូនតា

## ពង្សាវតារក្សត្រទី១ ២១:១-១៦

ការចែកចាយសៀមស្ងាត់
ក្នុងបន្ទប់ប្រជុំ
ខែ វិច្ឆិកា សប្តាហ៍ទី ៤

ការចែកចាយក្នុងអាទិត្យមុន ◀ Ice breaking ពាក្យសម្ដី

ការចែកចាយដោយព្រះបន្ទូល

១. តើណាបោតបាននិយាយអ្វីទៅស្ដេចអ័ហាប់ ពេលគាត់សុំលក់ចំការរបស់គាត់ ? (៦៣)

២. តើយេសិបិលមានផែនការអាក្រក់អ្វីសម្រាប់អ័ហាប់ ពេលណាបោតបដិសេធការទាមទាររបស់អ័ហាប់ ដោយព្រោះអ័ហាប់មិនអាចមានចំការនោះ ? (១០)

ការចែកចាយសៀមស្វាត់
ក្នុងបន្ទប់ប្រជុំ
ខែ ធ្នូ សប្ដាហ៍ទី ១

# ការបំពេញនិងការថែនាំ

## ពង្សាវតារក្សត្រទី២ ៤:១-៧

ពាក្យសម្ដី

Ice breaking ▶ ការចែកចាយក្នុងអាទិត្យមុន

ការចែកចាយដោយព្រះបន្ទូល

១. តើស្ត្រីរកឃើញនរណា ហើយនាងធ្វើអ្វីក្នុងស្ថានភាពលំបាកផ្សេងៗ? ម្យ៉ាងទៀត តើអេលីសេសំដៅទៅលើមនុស្សបែបណាតាមរយៈរឿងនេះ? (ខ១, ៧)

២. តើអេលីសេប្រាប់ប្រពន្ធសិស្សរបស់ព្យាការី ដែលគ្មានអ្វីក្រៅពីប្រេងមួយថាននេះឲ្យធ្វើអ្វី? (ខ៣)

# ពូថៅអណ្ដែតលើទឹក

## ពង្សាវតារក្សត្រទី២ ៦:១-៧

ការចែកចាយសៀមស្ងាត់
ក្នុងបន្ទប់ប្រជុំ
ខែ ធ្នូ សប្ដាហ៍ទី ២

ពាក្យសម្ដី

ការចែកចាយក្នុងអាទិត្យមុន ◀ce breaking

ការចែកចាយដោយព្រះបន្ទូល

១. តើពួកសិស្សបានផ្ដល់យោបល់អ្វីខ្លះដល់ព្យាការីអេលីសេ ពេលពួកគេនិយាយថាពួកគេមានកន្លែងកំណត់ដើម្បីរស់នៅជាមួយគ្នា ? (១-២)

២. ពេលពូថៅដែកធ្លាក់ចូលទឹក តើសិស្សស្រែកអ្វី? (៥)

ការចែកចាយសៀមស្វាត់
ក្នុងបន្ទប់ប្រជុំ
ខែ ធ្នូ សប្តាហ៍ទី ៣

# ដូចព្រះអម្ចាស់មានបន្ទូល

## ពង្សាវតារក្សត្រទី២ ៧:១១-២០

ពាក្យសម្តី

**Ice breaking** ▶ការចែកចាយក្នុងអាទិត្យមុន

ការចែកចាយដោយព្រះបន្ទូល

១. ពេលស្តេចមិនជឿនូវអ្វីដែលព្រះបានធ្វើ តើអ្នកណាបានជួយដើម្បីបញ្ជាក់ការពិតនេះ? (១៣)

២. តើមានអ្វីកើតឡើងបន្ទាប់ពីប្រជាជនបានបញ្ជាក់ពីអ្វីដែលព្រះបានធ្វើ និងចាប់យកជំរុំ? (១៦)

# រសជាតិនៃបន្ទូលរបស់ព្រះជាម្ចាស់

## ទំនុកដំកើង ១១៩:៩៧-១០៤

ការចែកចាយសៀមស្ងាត់
ក្នុងបន្ទប់ប្រជុំ
ខែ ធ្នូ សប្ដាហ៍ទី ៤

ពាក្យសម្ដី

ការចែកចាយក្នុងអាទិត្យមុន Ice breaking

ការចែកចាយដោយព្រះបន្ទូល

១. ពេលដែលអ្នកតែងទំនុកតម្កើងចាប់ផ្ដើមសរសេរអត្ថបទរបស់គាត់ គាត់សារភាពថា៖ «ខ្ញុំស្រឡាញ់ច្បាប់របស់ព្រះយ៉ាងណា»។ ហេតុផលដំបូងសម្រាប់ការស្រឡាញ់ព្រះបន្ទូលគឺថា អ្នកតែងទំនុកតម្កើងនិយាយថាព្រះបន្ទូលទ្រង់មានប្រាជ្ញាជាងអ្វីផ្សេងទាំងអស់ទៅទៀត? (៩៨, ៩៩, ១០០)

២. មូលហេតុទីពីរដែលអ្នកតែងទំនុកតម្កើងនិយាយថាគាត់ស្រឡាញ់ព្រះបន្ទូលខ្លាំងណាស់ គឺដោយសារព្រះបន្ទូលរបស់ព្រះអម្ចាស់មានលក្ខណៈដូចម្ដេច? (១០៣)

អាទិត្យទី ១
ខែ វិច្ឆិកា
បទចម្រៀង

# ការថ្វាយបង្គំគ្រួសារ

## យ៉ូហានទី១ ៥:១-១២

## ភស្តុតាងនៃសេចក្ដីស្រឡាញ់ចំពោះព្រះ

១. ខ្ញុំស្រឡាញ់បងប្អូនរបស់ខ្ញុំដែលកើតមកពីព្រះជាម្ចាស់ ដូចខ្ញុំស្រឡាញ់ព្រះជាម្ចាស់នៃខ្ញុំដែរ។

២. សូមចែករំលែកជាពិសេសអំពីរបៀបស្រឡាញ់បងប្អូនរបស់យើងដែលកើតមកពីព្រះ។

=>សូមសរសេរពីអ្វីដែលគ្រួសាររបស់អ្នក និងការអនុវត្តរួមគ្នា

អាទិត្យទី ២
ខែ វិច្ឆិកា
បទចម្រៀង

# ការថ្វាយបង្គំគ្រួសារ

ពង្សាវតារក្សត្រទី១ ១៨:៣០-៤០

## ចូរស្គាល់ព្រះជាម្ចាស់

១. តើអ្នកកំពុងរស់នៅក្នុងជីវិតរបស់អ្នកដែលធ្វើឱ្យគេស្គាល់ថាអ្នកជានរណានៅក្នុងលោកីយ៍នេះ ?

២. សូមចែករំលែកជាពិសេសអំពីរបៀបដែលអ្នកនឹងរស់នៅដើម្បីឱ្យព្រះស្គាល់។

=>សូមសរសេរពីអ្វីដែលគ្រួសាររបស់អ្នក និងការអនុវត្តរួមគ្នា

.......................................................................................................
.......................................................................................................
.......................................................................................................
.......................................................................................................
.......................................................................................................
.......................................................................................................

អាទិត្យទី ៣
ខែ វិច្ឆិកា
បទចម្រៀង

# ការថ្វាយបង្គំគ្រួសារ

## ពង្សាវតារក្សត្រទី១ ១៩:១-៩

## ព្រះដែលស្តារឡើងវិញ

១. តើអ្នកធ្លាប់មានអារម្មណ៍អស់កម្លាំងខាងផ្លូវកាយ ផ្លូវចិត្ត ឬខាងវិញ្ញាណទេ ?

២. ខ្ញុំចងចាំព្រះដែលបានធ្វើការ ពេញមួយជីវិតសម្រាប់ខ្ញុំ ហើយទ្រង់បានធ្វើរហូតមកដល់ពេលនេះ សូមចែករំលែកនូវគម្រោងដែលព្រះមានសម្រាប់យើងម្នាក់ៗ។

=>សូមសរសេរពីអ្វីដែលគ្រួសាររបស់អ្នក និងការអនុវត្តរួមគ្នា

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

អាទិត្យទី ៤
ខែ វិច្ឆិកា
បទចម្រៀង

# ការថ្វាយបង្គំគ្រួសារ

ពង្សាវតារក្សត្រទី១ ២២:២៤-៤០

## ផែនការដែលមិនអាចបញ្ឈប់ផែនការរបស់ព្រះបាន

១. តើអ្នកមានអារម្មណ៍យ៉ាងណា ពេលអ្នកឃើញព្រះសម្រេចផែនការរបស់ទ្រង់ដោយគ្មានទីបញ្ចប់?

២. ខ្ញុំចងចាំព្រះដែលបានធ្វើការ ពេញមួយជីវិតសម្រាប់ខ្ញុំ ហើយទ្រង់បានធ្វើរហូតមកដល់ពេលនេះ សូមចែករំលែកនូវគម្រោងដែលព្រះមានសម្រាប់យើងម្នាក់ៗ។

=>សូមសរសេរពីអ្វីដែលគ្រួសាររបស់អ្នក និងការអនុវត្តរួមគ្នា

.........................................................................................................................

.........................................................................................................................

.........................................................................................................................

.........................................................................................................................

.........................................................................................................................

.........................................................................................................................

អាទិត្យទី ១
ខែ ធ្នូ
បទចម្រៀង

# ការថ្វាយបង្គំគ្រួសារ

## ពង្សាវតារក្សត្រទី២ ៤:១-៧

## ជីវិតដែលមើលឃើញកិច្ចការរបស់ព្រះ

១. តើយើងគួររស់នៅបែបណា ដើម្បីទទួលបានបទពិសោធន៍កិច្ចការរបស់ព្រះ ?

២. តើថ្មីៗនេះអ្នកអាចស្តាប់បង្គាប់ ឬអាចធ្វើតាមកិច្ចការដែលក្នុងស្ថានភាពមួយដែលអ្នកមិនអាចយល់បាន ?ចូរចែករំលែកទាំងអស់គ្នា។

=>សូមសរសេរពីអ្វីដែលគ្រួសាររបស់អ្នក និងការអនុវត្តរួមគ្នា

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

អាទិត្យទី ២

ខែ ធ្នូ

បទចម្រៀង

# ការថ្វាយបង្គំគ្រួសារ

## ពង្សាវតារក្សត្រទី២ ៥:១-១៤

## ជីវិតដែលពឹងផ្អែកលើព្រះចេស្ដារបស់ព្រះ

១. ប្រសិនបើអ្នកទើបតែជួបបញ្ហាលំបាកដូចណាម៉ាន់ តើអ្នកដោះស្រាយវាដោយរបៀបណា ? ចូរចែករំលែកអ្វីដែលយើងបានធ្វើ។

២. តើអ្នកកំពុងទុកចិត្តលើឫទ្ធានុភាពរបស់ព្រះ ជាជាងវិធីសាស្ត្ររបស់លោកីយ៍នេះ ឬតើអ្នកគួរធ្វើយ៉ាងណា ? សូមចែករំលែកថាតើយើងគួរតែពឹងផ្អែក លើអំណាចរបស់ព្រះដោយរបៀបណា។

=>សូមសរសេរពីអ្វីដែលគ្រួសាររបស់អ្នក និងការអនុវត្តរួមគ្នា

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

អាទិត្យទី ៣

ខែ ធ្នូ

បទចម្រៀង

# ការថ្វាយបង្គំគ្រួសារ

ពង្សាវតារក្សត្រទី២ ៧:១១-២០

## ជីវិតនៃការជឿទុកចិត្តលើព្រះបន្ទូលរបស់ព្រះ

១. ប្រសិនបើអ្នកធ្លាប់មាន បញ្ហាក្នុងការជឿទុកចិត្តលើព្រះបន្ទូលរបស់ព្រះ សូមចែករំលែកវា។

២. តើយើងគួរធ្វើការបណ្តុះបណ្តាលខាងវិញ្ញាណអ្វីខ្លះ ដើម្បីអាចទុកចិត្តលើព្រះបន្ទូលរបស់ព្រះ ?

=>សូមសរសេរពីអ្វីដែលគ្រួសាររបស់អ្នក និងការអនុវត្តរួមគ្នា

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

អាទិត្យទី ៤
ខែ ធ្នូ
បទចម្រៀង

# ការថ្វាយបង្គំគ្រួសារ

ទំនុកតម្កើង ១១៩:៨៩-១១២

## ជីវិតដែលមិនភ្លេចច្បាប់របស់ព្រះអម្ចាស់

១.នៅក្នុងពេលអ្វីៗមិនបានល្អ តើអ្នកធ្លាប់សរសើរដំកើងដល់ព្រះដែរឬទេ ?

២. តើអ្នកធ្លាប់ជួបប្រទះនឹងព្រះបន្ទូលរបស់ព្រះដែលដឹកនាំជីវិតអ្នកដែរឬទេ ?

=>សូមសរសេរពីអ្វីដែលគ្រួសាររបស់អ្នក និងការអនុវត្តរួមគ្នា

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

ការចំណាំ

## ចូរលមើលគ្រប់ទាំងអស់
## ហើយកាន់ខ្ជាប់តាមសេចក្ដីដែលត្រឹមត្រូវ

ថែស្សាឡូនីចទី១ ៥:២១


ការចំណាំ
បើគាត់ធ្វើបាបនឹងអ្នក៧ដងក្នុង១ថ្ងៃ
ហើយត្រឡប់មកនិយាយនឹងអ្នក៧ដងថា
ខ្ញុំប្រែចិត្តហើយ នោះត្រូវឲ្យអ្នកអត់ទោសដល់គាត់
ជាកុំខាន
លូកា ១៧:៤

ការចំណាំ

**ឱពួកកំផិតទាំងប្រុសទាំងស្រីអើយ**
**តើមិនដឹងទេឬអីថាដែលស្រឡាញ់លោកីយ៍**
**នោះគឺជាស្អប់ដល់ព្រះហើយ ដូច្នេះ**
**អ្នកណាដែលចូលចិត្តចង់ធ្វើជាមិត្រសំឡាញ់នឹង**
**លោកីយ៍ នោះឈ្មោះថា**
**បានតាំងខ្លួនជាខ្មាំងសត្រូវនឹងព្រះវិញ**

យ៉ាកុប ៤:៤

# THE SUFFERING OF JOB













































# សៀវភៅដែល CDLD បានបោះពុម្ពហើយ

**ជាមួយនិងព្រះបន្ទូល ៖** លោកអ្នកអាចស្វែងរកពីបំណងនិងសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់បាន។សូមនឹកចាំពីព្រះបន្ទូលរបស់ព្រះអម្ចាស់និងចងចាំទុកនៅក្នុងជម្រៅចិត្តនោះអ្នកនឹងមើលពីព្រះគុណដ៏អស្ចារ្យរបស់ព្រះអម្ចាស់ដែលទ្រង់បានធ្វើការនៅក្នុងជីវិតរបស់អ្នក។សូមរស់នៅដោយព្រះបន្ទូលនោះអ្នកនឹងអាចយកឈ្នះនូវមារសាតាំងព្រមទាំងការល្បួងលនៅក្នុងលោកីយ៍នេះ។

**និងព្រះអម្ចាស់ ៖** លោកអ្នកនិងបានឃើញពីក្តីមេត្តារបស់ព្រះអង្គនៅក្នុងជីវិតរបស់អ្នក មិនថាអ្នកស្ថិតនៅក្នុងកាលៈទេសៈណាទេព្រះតែងនៅជាមួយនឹងអ្នកជីវិតអ្នកនឹងទទួលបានព្រះពរយ៉ាងពេញបរិបូរ







ដូច្នេះចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យដោយនូវព្រះនាមព្រះវរបិតាព្រះរាជបុត្រានិងព្រះវិញ្ញាណបរិសុទ្ធចុះហើយបង្រៀនឲ្យគេកាន់តាមគ្រប់ទាំងសេចក្តីដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផងហើយមើលខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរដរាបដល់បំផុតកល្ប។

(ម៉ាថាយ ២៨៖១៩-២០)

ដូច្នេះ កូនអើយ ចូរមានកំឡាំងឡើងដោយសារព្រះគុណដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវឯអស់ទាំងសេចក្តីដែលអ្នកបានឮអំពីខ្ញុំ នៅមុខស្មរបន្ទាល់ជាច្រើននោះក៏ត្រូវផ្ញើទុកនឹងមនុស្សស្មោះត្រង់ ដែលអាចនឹងបង្ហឹកបង្រៀនតទៅអ្នកឯទៀតដែរ។

( ២ធីម៉ូថេ ២៖១-២)

# សិក្ខាសាលាស្ដីអំពីការធ្វើការសៀមស្ងាត់ ជាមួយនឹងព្រះបន្ទូល និងព្រះអម្ចាស់

# QT SEMINAR

# ថ្ងៃទី14,22,31 ខែមីនា ២០២៣








1





*ការបង្រៀនដោយអ្នកគ្រូ ទិញ ចរិយា*

## ក្រុមជំនុំEMA

## ទីបន្ទាល់ អ៊ុច យីម

មុនពេលដែលនាងខ្ញុំមិនទាន់មានជំនឿលើព្រះយេស៊ូវ នាងខ្ញុំមានភាពវិលវល់ចំពោះការរស់នៅ នាងខ្ញុំមានជំនឿលើសាសនាផ្សេងៗ ដូចជាជំនឿលើការបន់ស្រន់ ជំនឿលើអារក្សអ្នកតា ហើយជឿថាដូនតាជាអ្នកជួយខ្ញុំ។ ប៉ុន្តែក្រោយមកនាងខ្ញុំបានលឺដំណឹងល្អតាមរយៈវិទ្យុផ្សព្វផ្សាយសម្លេង និងការផ្សព្វផ្សាយរបស់លោកគ្រូអ្នកគ្រូដែលជាអ្នកបម្រើព្រះ ធ្វើអោយនាងខ្ញុំយល់ឃើញថា ពួកអ្នកជឿលើព្រះល្អណាស់ ឃើញដូចជាសុភាពរាបសា ញញឹមរាក់ទាក់ចំពោះគ្នាទៅវិញទៅមក។ ធ្វើអោយនាងខ្ញុំទទួលយកព្រះយេស៊ូវធ្វើជាព្រះអង្គសង្គ្រោះសម្រាប់ជីវិតនាងខ្ញុំ។

ថ្ងៃនេះនាងខ្ញុំឃើញមេរៀនQT ដែលបង្ហាញពីភាពជាក់លាក់នៃព្រះបន្ទូលរបស់ព្រះពិតនិងជាការអស្ចារ្យចំពោះជីវិតរបស់ខ្ញុំ ព្រមទាំងបង្ហាញសេចក្តីមេត្តា ករុណារបស់ព្រះខ្លាំងណាស់។ យ៉ូហាន 3:16 បានថែងថា ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាតែ១ ដើម្បីអោយអស់អ្នកណាដែលជឿលើព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ គឺអោយមានជីវិតអស់កល្បជានិច្ចវិញ។ អាមែន!

# ទីបន្ទាល់ ហោ សុនឿន

ខ្ញុំបាទឈ្មោះ ហោ សុនឿន មានទីបន្ទាល់មួយមុននិងក្រោយពេលជឿលើព្រះយេស៊ូវគ្រីស្ទ។ មុនពេលមិនទាន់ជឿលើព្រះយេស៊ូវខ្ញុំមានរឿងមិនល្អជាច្រើន ខ្ញុំបានទៅដេកលេងនៅវត្តប្រាសាទអណ្តែតនឹងបានកោរសក់ហើយបានផ្សងសច្ចាថាសូមអោយកូនបានជួបព្រះពិតហើយខ្ញុំក៏បានដេកលក់ទៅ ។ បន្តិចក្រោយមកមានបុរសជាក្មេងពេញវ័យម្នាក់បានមកប្រាប់ខ្ញុំថា២អាទិត្យទៀតអ្នកនឹងបានទទួលដំណឹងល្អ។

ខ្ញុំក៏ចាំមើលពេលនោះបានគ្រប់ចំនួន២អាទិត្យក៏បានទទួលដំណឹងល្អពិតមែន ខ្ញុំក៏បានចូលព្រះវិហារលោកគ្រូទន ក្នុងពេលដែលគេធ្វើខួបកំណើតព្រះយេស៊ូវគ្រីស្ទឬហៅថាបុណ្យណូអែល ចាប់ពីពេលនោះមកខ្ញុំក៏បានទទួលជឿលើព្រះយេស៊ូវគ្រីស្ទរហូតដល់សព្វថ្ងៃ។

កូនសូមអរគុណដល់ព្រះយេស៊ូវដែលបានជ្រើសរើសកូនអោយបានស្គាល់ទ្រង់និងបានសង្រ្គោះព្រលឹងវិញ្ញាញកូនអោយរួចពីសេចក្តីស្លាប់ អាម៉ែន។

# អនុស្សាវរីយ៍ការបណ្តុះបណ្តាល បង្កើតកូនសិស្សម្នាក់ទល់ម្នាក់

## One To One Disciples





























# សិក្ខាសាលាស្តីអំពីការធ្វើការស្ងៀមស្ងាត់
# ជាមួយនឹងព្រះបន្ទូល និងព្រះអម្ចាស់
# QT SEMINAR
# ថ្ងៃទី14,22,31 ខែមីនា ២០២៣












*ការបង្រៀនដោយអ្នកគ្រូ ទិញ ចរិយា*

# សាលានិម្មិតឡូហ្គោសអន្តរជាតិ

## Logos Vision International School

*******



### អត្ថប្រយោជន៍

- កុមារជាច្រើនបានទទួលការអប់រំ ការយកចិត្តទុកដាក់ ពីសំណាក់លោកគ្រូ និងអ្នកគ្រូនៅក្នុងសាលារបស់យើងយ៉ាងល្អប្រសើរ។
- ដែលធ្វើអោយអាណាព្យាបាលជាច្រើនមានទំនុកចិត្តមកលើសាលារបស់យើង។
- សាលាជាប្រភពនៃចំណេះដឹងដែលកុមារជាច្រើនត្រូវការដើម្បីអនាគតរបស់ពួកគេ។
- សាលានិម្មិតឡូហ្គោសយើងចង់ឃើញកុមារជាច្រើនទទួលបានការអប់រំយ៉ាងល្អប្រសើរ និងចង់ឃើញកុមារជាច្រើនទទួលបាននូវសុខភាពល្អទាំងផ្លូវចិត្តនិងផ្លូវកាយ។
- ទទួលបានអាហារ២ពេលសម្រាប់កុមារ(ព្រឹក&ថ្ងៃត្រង់) ។
- មានដំណើរកំសាន្តរៀងរាល់ឆ្នាំ ។
- ទទួលបានអាហារូបករណ៍ជាច្រើនសម្រាប់កុមារដែលរៀនពូកែ មានចំណាត់ថ្នាក់ល្អ។

# សកម្មភាពសិស្សសាលានិម្មិតឡូហ្គោសអន្តរជាតិ
















#BeyondTheGames













# ជាមួយនឹងព្រះបន្ទូល និងព្រះអម្ចាស់ 2024•11/12

## គណៈកម្មការនិពន្ធ

កាលបរិច្ឆេទបោះពុម្ពផ្សាយលើកទី១ ថ្ងៃទី២០ ខែកុម្ភៈ ២០២២

អ្នកនិពន្ធ ៖ **លោកគ្រូគង្វាល គីម ចុងរ្យុង ( PASTOR KIM JEONG ROONG )**

អ្នករៀបរៀង ៖ **លោក គាត ឌឿន ( KEAT DOEUN )**

អ្នកសម្របសម្រួល ៖ **លោកគ្រូ ប្រាក់ ភក្តី ( PRAK PHEAKDEY )**

អ្នកបកប្រែ ៖ **កញ្ញា ទិញ ចរិយា ( TENH CHARIYA )**

ទីកន្លែងនិពន្ធ ៖ **ព្រះវិហារពួកជំនុំបល្ល័ង្កនៃព្រះគុណ ( CDLD )**

អាស័យដ្ឋាន៖ ផ្ទះ.9B ផ្លូវ.103P ភូមិរោងចក្រ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ ៖ 081 406 456 , 070 911 004 , 092 338 966

Email ៖ Sydoeun019@gmail.com

រោងពុម្ព ៖ Hosanna church

### អារម្ភកថាក្រោយនិពន្ធ

លោកីយ៍នេះនាំយើងអោយមានការហត់នឿយនិងលំបាកជាច្រើនណាស់។សូមបន្ទរអារម្មណ៍របស់អ្នកដោយស្រង់យកក្លិនផ្កាដ៏ក្រអូបនិងសំរាកចុះ។ព្រះយេស៊ូវជាទីសំរាកដ៏ពិតទ្រង់ជាផ្កាដ៏ក្រអូបនៃព្រលឹងរបស់អ្នក។

ដ្បិតទ្រង់បានធ្វើជាជំនួយដល់ទូលបង្គំ
ទូលបង្គំនិងមានចិត្តរីករាយ
នៅក្រោមម្លប់ស្លាបទ្រង់
( ទំនុកដំកើង ៦៣ ៖ ៧ )

# សមាគមព្រះគម្ពីរប៊ីបកម្ពុជា
# CAMBODIAN BIBLE SOCIETY

## ចលនា១០ម៉ឺននាក់ប្រើប្រាស់
## សៀវភៅQTទូទាំងប្រទេសកម្ពុជា





#90B St.103P Rongchak Village
Songkat Kok Kleang Khan Sen Sok,
Phnom Penh, Cambodia.

Tel ៖ (855) 081 406 456
070 911 004
092 338 966

Email ៖ Sydoeun019@gmail.com







ព្រះយេស៊ូវមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំហ្នឹងហើយជាផ្លូវ
ជាសេចក្ដីពិតនិងជាជីវិត។ គ្មាននរណាម្នាក់អាចទៅកាន់
ព្រះវរបិតាបានឡើយ លើកលែងតែទៅតាមរយៈខ្ញុំ។
(យ៉ូហាន១៤: ៦)

**មជ្ឈមណ្ឌល**

**CDLD**

**មជ្ឈមណ្ឌលអភិវឌ្ឍន៍សិស្ស និង អ្នកដឹកនាំ** (CDLD)

Center for Discipleship & Leadership Development